# ទាចារអ្នកនិពន្ធ

រឿងខ្មោច...រឿងទេវតា...រឿងវិញ្ញាណទី៦... អ្វីទាំងអស់នេះគ្រាន់តែជាព័ត៌មានមួយ ដែលនាងខ្ញុំជាអ្នកនិពន្ធធ្លាប់បានឮចាស់ៗនិទានតគ្នា ហើយរឿងទាំងអស់នេះមានមែន ឬ មិនមាន នាងខ្ញុំក៏មិនប្រាកដដែរ ។ ប៉ុន្តែប្រការដែលនាងខ្ញុំនិពន្ធរឿង " **ម្ចាស់វិមានមាស** " នេះ នោះគឺដើម្បីជូនជាចំណីចក្ខុថ្មី បង្កើតភាពចម្លែកក្នុងអារម្មណ៍ ជូនដល់អស់លោកអ្នក អ្នកនាងកញ្ញានិងក្មួយៗជាសិស្ស និស្សិតជាប្រិយមិត្តអ្នកអានតែប៉ុណ្ណោះ ។

" **ម្ចាស់វិមានមាស** "ក៏មានចេតនាសំខាន់មួយទៀត ដែលនាងខ្ញុំចង់បង្ហាញដែរថា អំពើអាក្រក់ដាច់ខាតត្រូវទទួលលទ្ធផលអាក្រក់ដល់អ្នកប្រព្រឹត្ត អំពើល្អជាចំណុចដែលនាំដល់អ្នកប្រព្រឹត្តទទួលនូវផលល្អ ។ រីឯគំនុំ ការសងសឹក ការព្យាបាទ ក៏មិនមែនជាទង្វើដែលអ្នកណាៗ គួរនឹងប្រព្រឹត្តនោះដែរទេ ។

សូមជូន " **ម្ចាស់វិមានមាស** " ដើម្បីកំដរអារម្មណ៍អស់លោកអ្នកនាងកញ្ញានិងបណ្ដាក្មួយៗជាសិស្សនិស្សិត ជាប្រិយមិត្តអ្នកអាន ដោយក្ដីគោរព រាប់អាននិងស្រឡាញ់បំផុត ។

រង់ចាំជានិច្ចដើម្បីទទួលនូវរាល់ការរិះគន់ ដែលជាការផ្ដល់នូវកិច្ចអភិវឌ្ឍដ៏ប្រសើរបំផុតសម្រាប់នាងខ្ញុំ ។

ភ្នំពេញថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៥

អ្នកនិពន្ធ

# ទគ្គទី ១

ពេលរាត្រីនេះ ក្នុងសណ្ឋាគារអាណ្ណាអូតែលតូក្យូនៃទីក្រុងតូក្យូ ប្រទេសជប៉ុន ជាសណ្ឋាគារលំដាប់ផ្កាយប្រាំដែលមានកម្ពស់ជាងសែសិបជាន់ យើងឃើញយុវជនម្នាក់សម្បុរសជ្រះ ទឹកមុខមានមន្តស្នេហ៍ មាត់ច្រមុះសមនឹងទម្រង់មុខ កម្ពស់ប្រហែលជា ១.៧៥ម៉ែត្រ ឋិតក្នុងវ័យប្រហែល៣០ឆ្នាំ កំពុងនិទ្រាលង់លក់យ៉ាងស្កប់ស្កល់លើគ្រែ ក្នុងបន្ទប់ដ៏ប្រណិតនៃសណ្ឋាគារខាងលើ។ នរៈរូបសង្ហាមាននាម ពិសិដ្ឋ។ គេធ្វើដំណើរមកកាន់ប្រទេសជប៉ុន ដើម្បីមកទាក់ទងការងារមុខជំនួញជាមួយជនជាតិជប៉ុនម្នាក់ ជាដៃគូរកស៊ី។ មាណពកំពុងតែលង់លក់ក្នុងដំណេក ព្រលឹងអ្នកប្រុសអណ្តែតចេញពីរូបកាយ បង្កើតជាសុបិនមួយ ដែលមានន័យ ដូចខាងក្រោម :

ក្នុងសួនច្បារដ៏ធំមួយ ប្រកបដោយវាលស្មៅយ៉ាងល្វឹងល្វើយ ដេរដាសទៅដោយដើមផ្កាជាច្រើនប្រភេទដូចជា ផ្កាម្លិះ ផ្កាមាលតី ផ្ការំយោល ផ្កាយិតថូផ្កាចេកទេស ផ្កាយីហ៊ុប ក្រវាន់ កំពុងរីករបាង់ បង្ហូតសម្រស់ផូរផង់ប្រណាំងគ្នាគួរពិចពិលរមិលមើល។ នៅក្បែរគុម្ពផ្កាចេកទេស ដែលមានផ្ការីកពណ៌លឿងលាយក្រហម កញ្ញាស្រស់សោភាប្រកបដោយកេសាខ្មៅក្រិបធ្លាក់រសាយដល់ពាក់កណ្តាលខ្នង អង្គុយប្របគុម្ពផ្កា ភក្ត្រានាងញញឹមពព្រាយ លេចចេញលើថ្ពាល់ស្រី នូវស្នាមខួចជិតយ៉ាងក្រឡៅ អមលម្អដោយធ្មេញសដូចចាន ជាមួយបបូរមាត់ពណ៌ស៊ីជម្ពូព្រឿងៗ ច្រមុះសមមាត់ ភ្នែកធំសមនឹងចិញ្ចើម ប្រកបដោយរោមនេត្រាងរខ្មៅ។ តរុណីមានវ័យប្រហែលជា២៤ឆ្នាំ។ ស្រមោលកំលោះរូបសង្ហាពិសិដ្ឋ សសៀរដើរ

លបៗវកិលទៅកៀកកាយស្រី។ ជូនជានារីឆោមយង់ងាកមកក្រោយ ក្រសែចក្ខុរបស់ស្រី ក្រឡេកមកឃើញអាកប្បកិរិយារបស់កំលោះ នាងដឹងថា គេបម្រុងនឹងដើរមកពញ្ញាក់ស្រី ទងវង់ក៏ញញឹម របៀបដឹងល្បិចរបស់អ្នកប្រុស។ ពិសិដ្ឋដែលមានបំណងដូចការគិតរបស់ស្រីស្រស់មែន លុះត្រូវឆោមល្អងាកមកដឹងពីសកម្មភាពរបស់គេបែបនេះ បុរសញញឹមរបៀបអៀនលាយឡំដោយការហួសចិត្ត ពីទង្វើខ្លួនដែលត្រូវនួនល្អងចាប់ថ្នាក់បាន។ មន្ទាប់មក ធីតាមានអាការៈហាក់ដូចជាប្រុងងើបពីទីអង្គុយ ក្នុងបំណងដើរមករកកំលោះ។ យល់បែបនេះ ពិសិដ្ឋក៏បង្កើនជំហានទៅកៀកកាយនាង ហើយនរៈលូកដៃរបៀបទទួលជួយចាប់ដៃស្រី ដើម្បីឱ្យនាងងើបពីទីបង្គុយ។ ប៉ុន្តែប្រាមទងវង់មិនទាន់បានប៉ះចុងហត្ថាអ្នកប្រុសផង ស្រាប់តែកញ្ចុំផ្សៀងសស្កុះផុសធ្លោចេញមកឃាំងចំកណ្ដាលរវាងដៃបុរសនិងដៃនារី។ រូបភាពស្ត្រីវ័យប្រមាណ២៥ឆ្នាំម្នាក់ក្នុងសម្លៀកបំពាក់ស្បៃវែងសស្កុងពីលើដល់ចុងជើង រង្វង់មុខស្លេកស្លាំងសដូចក្រដាស ភ្នែកក្រឡោតលៀនក្រហមថ្លៃ មុខស្រីចម្លែកគ្របដណ្ដប់ដោយសក់រតេរតាយ គ្របពីលើក្បាលរហូតដល់ចុងជើងអូសដី គឺជាព្រលឹងខ្មោចស្រីយ៉ាងកំណោច ដែលផុសមកជាមួយកញ្ចុំផ្សៀងសស្កុងនេះ។ បិសាចស្រីស្ទុះវឹងកញ្ឆក់ទាញកាយស្រីល្អ អូសនាំយកនាងទៅជាមួយ ហើយសំណើចគំរាមលាន់ពីបំពង់កខ្មោចកំណាច កងរំពងខ្ទរវេហា :

-ហាស់ ហាស់ នាងឯងត្រូវទៅជាមួយយើង ហាស់ ហ្វាស់ ! ទៅជាមួយយើង ! ទៅជាមួយយើង ហាស់ ហាស់ ។

នារីរងគ្រោះញ័ររន្ធត់អស់ផងកាយ ទឹកមុខស្រីផិតជាមដោយការភ័យខ្លាច ដៃញ័ររន្ធត់ ស្រីរើបម្រះ កញ្ជ្រោលដោយចង់ស្ទុះចេញពីកណ្ដាប់ដៃខ្មោចស្រី ទាំងនួន នាងស្រែកដោយការតក់ស្លុត :

-ទេ ! ទេ ខ្ញុំមិនទៅទេ...លែងខ្ញុំទៅ...ជួយខ្ញុំផង ជួយខ្ញុំផង ។

បិសាចស្រីត្រវីត្រវាត់ខ្លួនស្រីល្អក្នុងលំហមេឃ កល្យាណស្រែកគ្រលួច ដោយក្ដីរន្ធត់ តែសំឡេងគំរាមរបស់បិសាចស្រីលាន់ខ្ទរជី លប់បាត់សម្រែករបស់និមលកម្សត់ ។ កាលដែលយល់ឃើញសភាពដែលស្រីល្អទទួលការលងបន្លាចយីយាពីខ្មោចស្រី បណ្ដាលឱ្យពិសិដ្ឋរន្ធត់ភ័យខ្លាច លាយដោយការព្រួយបារម្ភពីឆោមឆាយ ។ នៅលើដី បុរសស្ទុះរត់ទៅតាមស្រីស្រស់ ដែលត្រូវព្រលឹងខ្មោចអូសកញ្ឆក់ហោះនាំទៅក្នុងលំហមេឃ ទាំងគេស្រែកភ្ញាត់សំឡេង :

-លោកយាយតូចលែងនាង ! លោកយាយតូចកុំធ្វើបាបនាង .

ខ្មោចស្រីដែលកាលនៅរស់ នាងឈ្មោះមាសត្រូវជាប្អូនបង្កើតរបស់ជីដូនកំលោះ ។ ពេលនេះ នាងខ្មោចបានចាប់អូសទាញដៃនាងល្អ ត្រវីត្រវាត់ត្រវែងខ្លួននាងយ៉ាងខ្លាំងទៅក្នុងលំហអាកាស តែបិសាចស្រីមិនបានលែងដៃចេញពីដៃធីតាឡើយ ។ ប្រាណនួននាងត្រូវវិលខ្វាល់ដូចគេបង្វិលអាប៉ោង ដៃនាងដែលឋិតនៅក្នុងកណ្ដាប់ដៃបិសាច បានទទួលការច្របាច់សង្កត់ សឹងតែបាក់ឆ្អឹង នាងមានការឈឺចាប់ឥតឧបមា ។ ណាឈឺដៃចុកចាប់ពាសពេញខ្លួន ដូចមានម្ជុលរាប់ពាន់ចាក់ដោតសព្វប្រាណ ណាវិលមុខវង្វេងទិសដោយវិលខ្វាល់ក្នុងលំហមេឃ ដែលជាប្រការពិបាកទ្រាំសឹងតែផុតដង្ហើមម្ដងៗ ណាភ័យខ្លាចត្រូវបិសាចបោកសម្លាប់ ណាខ្លាចធ្លាក់មកដី...កល្យាណបម្រះផង ញាប់ញ័ររន្ធត់ផង នាងស្រែកដោយអស់សំឡេង :

-កុំធ្វើបាបខ្ញុំលោកអើយ ! លែងខ្ញុំទៅ ! លែងខ្ញុំទៅ ! ខ្ញុំខ្លាចណាស់ ។

-លោកយាយតូចលែងនាង ! កុំធ្វើបាបនាង លែងនាងមក លោកយាយតូច។ "ពិសិដ្ឋស្រែកដោយអាការៈតក់ស្លុត ជាមួយជើងរត់ត្របាញ់ពីលើដីដេញតាមព្រលឹងខ្មោចយាយមាសនិងនរលក្ខណ៍ដែលកំពុងហោះលើមេឃ"

-ហាស់ ហាស់ ហាស់ ។

នាងបិសាចសើចរំពងអាកាស ហោះអូសនាំយកកាយឆោមឆើតលឿនស្លេវទៅមុខ បន្សល់តែសំណើចខ្ទរមេឃ ជាមួយនិងសំឡេងរន្ធត់ញាប់ញ័ររបស់ស្រីរងគ្រោះយ៉ាងគួរលូច ដោយការតក់ស្លុត ។ ពិសិដ្ឋបារម្ភពីរូបកាយនារីរងគ្រោះ គេរត់ដេញតាមនាងផង គេស្រែកមិនដាច់ពីមាត់ផង ដើម្បីឱ្យខ្មោចលោកយាយមាសបញ្ឈប់នូវការលងធ្វើបាប ហើយព្រមព្រលែងកាយស្រីល្អមកវិញ។ តែបិសាចស្រីនៅតែអូសនាំយកកល្យាណទៅជាមួយ ព្រមដោយបោះបង្វិលកាយនរនាថទៅក្នុងលំហ រួចខ្មោចកំណាចក៏ហោះទទួលទ្រខ្លួននាង។ ការដែលបិសាចធ្វើបែបនេះ គឺបិសាចមានចេតនានឹងធ្វើបាបស្រីល្អតែម្ដង ។ ពិសិដ្ឋស្រែកមិនឈប់ ស្រែករឹតតែខ្លាំង រូបកាយស្រីល្អកាន់តែរសាត់ឆ្ងាយទៅ តាមការអូសកញ្ឆក់របស់ខ្មោចយាយមាសទៅវិញ...

ពិសិដ្ឋភ័យរន្ធត់ លាយឡំការបារម្ភ ការអាណិត ដល់នារីឆោមយង់ នរៈរត់ដេញខ្មោចនិងមនុស្សស្រីដែលបេះដូងគេតែងប្រាថ្នា ពិសិដ្ឋប្រឹងរត់ ប្រឹងស្រែកទាល់តែភ្ញាក់ទាំងខ្លួន។នរៈបើកភ្នែកគេហាក់ដូចជាស្រពិចស្រពិលក្នុងចិត្ត បន្ទាប់មកគេក៏ញីភ្នែក ដោយបុរសដូចជានឹកឃើញអ្វីមួយ រួចគេលាន់មាត់ម្នាក់ឯង ល្មមឮតែខ្លួនឯង :

-ឃើ ! ខ្ញុំយល់សប្តិឃើញនាងទៀតហើយ ។ ហេតុអីខ្ញុំចេះតែយល់សប្តិឃើញនាងយ៉ាងនេះ ? នាងជានរណា ? នាងនៅទីណាហ្ន៎ ? ហើយ ហេតុអីពេលដែលខ្ញុំយល់សប្តិឃើញនាង ខ្ញុំក៏តែងតែឃើញលោកយាយមាសដែរអីចឹង ?

មុខពិសិដ្ឋជិតដាមដោយសញ្ញាវិះគិត ស្នូរដង្ហើមធំលាន់ឃ្លូរពីទ្រូងកំលោះអ្នកប្រុសងើបដើរមកជិតបង្អួច នរៈចោលភ្នែកមើលទៅមេឃ តាមបង្អួចកញ្ចក់នៃសណ្ឋាគារ ។ រាត្រីនៅអូសបន្លាយនៅឡើយ ស្បៃខ្មៅកំពុងគ្របដណ្តប់ សភាពខាងក្នុងបន្ទប់ឱ្យឋិតក្នុងភាពងងឹតស្លុប ភ្នែកពិសិដ្ឋមិនអាចមើលអ្វីឃើញទេ តែគេនៅតែឈរមើលសភាពងងឹត ដែលយើងមិនដឹងថា ពិសិដ្ឋមើលអ្វីសោះឡើយ ។ សភាពលើផ្ទៃមុខរបស់នរៈ ជោកជាំដោយគំនិតស្មុគ្រស្មាញ ដែលគ្មាននរណាស្មានបាន ។

យុវជនពិសិដ្ឋជាមនុស្សម្នាក់ដែលមានវិញ្ញាណទីប្រាំមួយ ខុសប្លែកពីមនុស្សធម្មតា គេអាចមើលឃើញព្រលឹងខ្មោច ឬ អាចមើលឃើញទេវតា ប្រសិនណាជាខ្មោច ឬ ទេវតាអង្គណាប្រាថ្នាចង់ឱ្យគេមើលឃើញ ។ ជារឿយៗ គេតែងតែយល់សប្តិឃើញនារីរូបស្រស់ម្នាក់ ។ ប៉ុន្តែរាល់ពេលដែលគេសុបិនឃើញនាង គេក៏តែងតែឃើញខ្មោចលោកយាយតួចរបស់គេ ចេញមកលងនិងធ្វើបាបនាងម្នាក់នោះជានិច្ច ។ ជាការចម្លែកមែនទែន តាមរយៈការយល់សប្តិ ពិសិដ្ឋមិនដែលស្គាល់ឈ្មោះនាង មិនដែលដឹងថា នាងជាកូនចៅនរណា ? នាងរស់នៅទីណា ? នាងមានរូបពិតប្រាកដនៅលើផែនដីយើងឬអត់ ? ប៉ុន្តែពិសិដ្ឋឧស្សាហ៍យល់សប្តិ ឃើញនាងជាញឹកញាប់ ។ កាលដែលគេតែងតែសុបិនឃើញស្រី បេះដូងពិសិដ្ឋបានត្រូវជាប់ព្រួញស្នេហ៍នារីក្នុងសុបិនដោយមិនដឹងខ្លួន ទាំងគេមិនដឹងថា ត្រូវទៅរកនាងនៅទីណាផង ។ ប៉ុន្តែភាពគួរឱ្យងឿងឆ្ងល់មួយ បានបង្កើតសំណួរនៅក្នុងខួរក្បាលពិសិដ្ឋឱ្យពិចារណាមិនអស់

មិនហើយ តើហេតុអ្វីបានជាលោកយាយតូចឈ្មោះ " មាស " តែងតែចេញមកលេងធ្វើបាបនារីក្នុងសុបិនម្នាក់នេះ ? ពិសិដ្ឋចង់បានចម្លើយពីរឿងនេះ តែគ្មាននរណាអាចឆ្លើយប្រាប់គេបានឡើយ ។

# វគ្គទី ២

ម៉ោង៨យប់ ក្នុងបរិវេណអាកាសយានដ្ឋានភ្នំពេញ ត្រង់កន្លែងយកវ៉ាលីស មានអ្នកដំណើរជាច្រើននាក់កំពុងឈរចាំយកវ៉ាលីស ដែលកំពុងបិតក្នុងកន្លែងដែលមានចលនាវិល ដើម្បីបញ្ជូននាំយករបស់របរទាំងឡាយមកដល់មុខពួកគេ។ ក្នុងចំណោមមនុស្សទាំងនោះ យើងឃើញមានកញ្ញាម្នាក់ បើយើងពិនិត្យឱ្យច្បាស់ នាងមានមុខមាត់ដូចបេះបិទទៅនឹងនារីក្នុងសុបិនរបស់ពិសិដ្ឋ ស្រីល្អមាននាម " សិទ្ធា នរលក្ខណ៍ "។ ធីតាឈរឡូកឡំជាមួយមនុស្សទាំងនោះក្នុងអាការៈរង់ចាំទទួលវ៉ាលីសរបស់ស្រី។ ពេលវ៉ាលីសមួយពណ៌ខ្មៅវិលមកដល់មុខនាង នួននាងលូកដៃយកវ៉ាលីសនោះ រួចស្រីលើកវាដាក់រទេះរុញ។ កល្យាណរុញរទេះមានវ៉ាលីស តម្រង់ទៅរកទ្វារ សម្រាប់ចេញមកផ្នែកខាងក្រៅនៃចំណតអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ នៅឯក្រោយខ្នងឆ្វេងឆោមឆើត យុវជនពិសិដ្ឋដើរមកពីខាងផ្នែកខាងក្នុងព្រលានយន្តហោះ សំដៅមករកត្រង់ទីដែលមានវ៉ាលីសវិល។ វ៉ាលីសមួយមានសភាពដូចវ៉ាលីសរបស់នរលក្ខណ៍ក៏វិលមកដល់មុខគេ ពិសិដ្ឋលូកដៃយកវ៉ាលីសនោះ ហើយគេដាក់វាទៅលើរទេះរុញជាចុងក្រោយ គេដើរចេញទៅមុខ ទៅរកទ្វារចេញដូចជានរលក្ខណ៍ដែរ ។

រថយន្ត C R V ពណ៌ទឹកប្រាក់មួយគ្រឿង កំពុងដឹកកំលោះរូបសង្ហារ៉ាកិលកង់ចូលមកក្នុងបរិវេណដីឡូត៍ដ៏ធំមួយ ដែលមានភូមិគ្រឹះសង់បែបម៉ូតអឺរ៉ុប ជាមួយនឹងទ្វារបង្អួចធ្វើអំពីឈើនាងនួន ពោរពេញដោយក្បាច់រចនាបែបចម្លាក់ខ្មែរយ៉ាងរស់រវើក ក្នុងកម្ពស់បីជាន់យ៉ាងប្រណិត។ ពិសិដ្ឋចុះពីរថយន្ត បោះជំហានសំដៅភូមិ

គ្រឹះ។ អ្នកបើកបររថយន្តយួរវ៉ាលីសដើរតាមក្រោយនរៈ។ មកដល់មាត់ទ្វារផ្ទះ ពិសិដ្ឋជួបនឹងស្រីបម្រើម្នាក់ កំលោះបន្លឺវាចា :

-បងអយ ! ជួយជម្រាបអ្នកម៉ាក់ផង បន្តិចទៀតខ្ញុំនឹងទៅជួបគាត់ ។

-ចាស អ្នកប្រុស ។

បន្ទាប់ពីប្រាប់ស្រីបម្រើរួចរាល់ បុរសរូបសង្ហាយាត្រាសំដៅទៅរកបន្ទប់ផ្ទាល់ខ្លួនរបស់គេ។ ពេលដែលគេមកដល់ក្នុងបន្ទប់ គេឃើញវ៉ាលីសនៅក្បែរគ្រែ ព្រោះមុននេះបន្តិច គ្រាដែលមាណពកំពុងនិយាយជាមួយស្រីបម្រើ អ្នកបើកបររថយន្តបានយកវ៉ាលីសមកទុកក្នុងបន្ទប់នេះរួចជាស្រេច ។ ភ្នែកពិសិដ្ឋចោលក្រឡេកទៅកន្លែងចាក់សោរបស់វ៉ាលីស គេឃើញថា មេសោបានរបូតដាច់ពីវ៉ាលីសមិនដឹងពីអង្កាល់ណាផង ។ មុខពិសិដ្ឋភ្ញាក់បន្តិចលាន់មាត់ម្នាក់ឯង :

-យី ! ដាច់មេសោបាត់ទៅហើយ ?

ពិសិដ្ឋស្រាយចំណងរឹតវ៉ាលីស រួចគេបើកវ៉ាលីស អ្វីដែលកន្ត្រាក់អារម្មណ៍គេ នោះគឺសភាពក្នុងវ៉ាលីស មិនមែនជាទ្រព្យរបស់គេឡើយ រួចគេកាន់តែភ្ញាក់ គ្រាដែលនេត្រារបស់កំលោះឃើញរូបថតនារីលក្ខណ៍ជាច្រើនសន្លឹក ដាក់ពីលើខោអាវដែលនៅក្នុងវ៉ាលីស ។ ជាមួយមុខភ្ញាក់ ពិសិដ្ឋលូកដៃទៅលើករូបថតចេញមកកាន់មើល លាន់មាត់តិចៗ :

-ហ្អាក ! រូបថតនាងតើ ។ ម៉េចក៏មកនៅក្នុងវ៉ាលីសនេះទៅវិញ ?

ពិសិដ្ឋត្រេកអរដូចកូនក្មេងបានស្ករគ្រាប់ ស្រីដែលគេតែងតែយល់សុបិនបានមកប្រាកដក្រោមក្រសែភ្នែករបស់អ្នកប្រុស ។ នេត្រាប្រុសល្អសម្លឹងមើលរូបថតស្រី ។ រូបថតនោះបង្ហាញពីសម្រស់ម្ចាស់រូបយ៉ាងត្រចង់ ជាមួយភក្ត្រញញឹម

ពព្រោយ។ មុខកំលោះញញឹមស្រស់ សម្លឹងរូបថតជាមួយបេះដូងលោតក្តុកក្តាក់ គេលាន់រាំចាតែឯកឯង :

-រូបនាងពិតជាស្អាតជាងក្នុងយល់សប្តិខ្ញុំទៅទៀត ។ នាងស្អាតមែន ។

បន្ទាប់មក ពិសិដ្ឋចាប់រូបថតបង្វិលមកផ្នែកខាងខ្នង ដើម្បីគេមើលក្រែងលោនាងមានសរសេរអ្វី ដែលជាព័ត៌មានល្អសម្រាប់គេ ឥឡូវភ្នែករបស់បុរសបានប្រទះឃើញមានអក្សរថា " នរលក្ខណ៍ ថតថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៣ " ។ ពិសិដ្ឋលាន់មាត់ទាំងញញឹម :

-នាងឈ្មោះ នរលក្ខណ៍ ។ ឈ្មោះពិរោះមែន ។

ការពិតវ៉ាលីសរបស់ពិសិដ្ឋត្រូវបាននាងនរលក្ខណ៍ច្រឡំយកទៅ ជូនជាពិសិដ្ឋចុះពីយន្តហោះក្រោយគេ ហើយវ៉ាលីសរបស់អ្នកដំណើរមានសល់តែវ៉ាលីសរបស់នរលក្ខណ៍តែមួយគត់ ថែមទាំងជាវ៉ាលីសនេះមានសភាពដូចវ៉ាលីសរបស់គេទើបពិសិដ្ឋច្រឡំយកវាមកតែម្តង ដោយមិនបានមើលឈ្មោះដែលចងភ្ជាប់នឹងវ៉ាលីស ។

.....................................................................................................

.....................................................................................................

ឥឡូវយើងបែរទៅមើលនាងនរលក្ខណ៍ម្តង តើពេលនេះនាងកំពុងតែធ្វើអ្វី? អូ! ស្រីស្រស់កំពុងឋិតនៅក្នុងបន្ទប់មួយ ជាមួយក្រុមគ្រួសារ ដែលមានលោកឪពុករបស់នាង ឈ្មោះលោកកិត្យា អ្នកម្តាយគឺអ្នកស្រីមាណេរី លោកជំនោរជាឪពុកមា និងភរិយារបស់លោកជំនោរឈ្មោះ អ្នកស្រីតារា អ្នកស្រីសួគ៌ាជាម្តាយមីងរបស់នរលក្ខណ៍ ។កញ្ញាទារិកានិងកំលោះវេហាជាបុត្រាបុត្រីរបស់លោកជំនោរនិង

អ្នកស្រីតារា ឯកញ្ញាឃីហ៊ុបជាកូនស្រីរបស់អ្នកស្រីសូតា ដោយយុវជនយុវតីទាំងបីរូបក៏មានវត្តមាននៅក្នុងបន្ទប់នោះដែរ ។ពួកគេទាំងអស់គ្នាពោរពេញទៅដោយទឹកមុខក្រៀមក្រំ ក្នុងអាការៈព្រួយបារម្ភពីសភាពជំងឺរបស់ប្រមុខគ្រួសារ គឺលោកឧកញ៉ាសិទ្ធា ដែលលោកជាឪពុករបស់លោកកិត្យា លោកជំនោរនិងអ្នកស្រីសូតា ។ ចំពោះនរលក្ខណ៍ នាងទើបតែបញ្ចប់ការសិក្សានៅឯបរទេស ហើយនាងទទួលដំណឹងថា ជំងឺលោកតារបស់នាងមានសភាពធ្ងន់ធ្ងរ ដែលលោកតារងការវាតត្បាតដោយសារជំងឺបេះដូង ។ ជាមួយភក្ត្រស្លេកស្លាំង លោកតាសិទ្ធាសម្រាន្តនៅលើគ្រែពោលវាចាខ្សាវៗ មកកាន់កូនចៅ :

-ម៉ាបារម្ភ ក្រែងប៉ាមិនរស់បានយូរ ទើបប៉ាបានចែកទ្រព្យឱ្យកូនគ្រប់ៗគ្នាយ៉ាងនេះ ។ ប៉ុន្តែនៅសល់តែផ្ទះសិទ្ធា ដែលឋិតនៅឯភ្នំពេញ គឺជាទ្រព្យចុងក្រោយដែលប៉ាត្រូវប្រគល់ឱ្យចៅលក្ខណ៍ ។

ប្រយោគរបស់ជីតា បណ្តាលឱ្យនរលក្ខណ៍សម្លឹងមើលមកលោកតាជាមួយភក្ត្រភាំរាំង ដោយស្រដី :

-លោកតា ! ចៅមិនចង់ទទួលផ្ទះសិទ្ធាទេ...ចៅ...

លោកតាមើលមកនរលក្ខណ៍ លោកបន្លឺទៅកាន់នាង :

-តាដឹងពីអ្វីដែលចៅចង់និយាយបន្ត តែចៅលក្ខណ៍កុំប្រកែកជាមួយបំណងតាអីណា ។

កាលបើព្ទបិតាប្រគល់ផ្ទះសិទ្ធា ដល់កញ្ញានរលក្ខណ៍ មុខលោកស្រីសូតាមានភាពក្រញូវដោយការច្រណែន ប៉ុន្តែអ្នកស្រីពុំហ៊ានស្តីអ្វីនោះទេ គាត់លាក់ស្មៀម

ផ្ទុយការគ្រេវគ្រោធតែក្នុងចិន្តា សោតឯត្រចៀករបស់លោកស្រីបានផ្ទៀងស្ដាប់វាចារបស់ឪពុក ដែលលោកឧកញ៉ាកំពុងពោលប្រាប់នរលក្ខណ៍ :

-ការដែលតាប្រគល់ផ្ទះសិទ្ធាឱ្យចៅ ជាភាពយុត្តិធម៌សម្រាប់រូបចៅហើយ ចៅត្រូវទទួលចុះណាំលក្ខណ៍ ។

ស្ទើរតែមិនទាន់ប្រយោគលោកតាផង កញ្ញាឃីហ៊ុបស្រែកដោយអាការៈច្រឡោត ជាមួយប្រយោគញ្ញ១ទៅកាន់ជីតា :

-ហេតុអីក៏លោកតាមានប្រសាសន៍ថា មានយុត្តិធម៌ បើខ្ញុំវិញ លោកតាមិនមានចែកអ្វីផ្សេង ក្រៅតែពីភាគហ៊ុនក្នុងសណ្ឋាគារ ដែលបងលក្ខណ៍ក៏បានទទួលដែរ ។

បន្ទាប់មក វេហាមានមុខពោរពេញដោយកំហឹង តែស្រដីខ្លាំង១ :

-ចំណែកខ្ញុំ ក៏លោកតាអត់មានចែកស្អីឱ្យទៀតដែរ គឺមានតែភាគហ៊ុនក្នុងសណ្ឋាគារ ខ្ញុំ...

កញ្ញាទារិកាចាប់ដៃវេហាជាបងប្រុស ជាសញ្ញាឃាត់មិនឱ្យវេហានិយាយបន្ត ។ កំហោះចិត្តខ្លាំងងាកមកទារិកា គេនិយាយញ្ញ១ទៅកាន់ប្អូនស្រី :

-ហើយវាកើតអី បានជាឯងមកឃាត់បង ក្រែងឯងក៏មិនបានស្អី ជាកេរពីលោកតាដែរតើហ្អាទារិកា ?

ទារិកាមុខហួសចិត្ត នាងនិយាយតិច១ប្រាប់វេហា :

-តែខ្ញុំមិនត្រូវការអ្វីទៀតទេ ព្រោះអ្វីដែលលោកតាបានចែកជាទ្រព្យសម្បត្តិយ៉ាងច្រើនដល់យើង ដល់ប៉ាម៉ាក់យើងហើយតើបងវេហា ។

-តែយ៉ាងណាលោកតាចែកឱ្យនាងនរលក្ខណ៍លើសពួកយើង គឺលើសផ្ទះសិទ្ធា ។ " វេហា "

-ខ្ញុំក៏យល់ដូចបងវេហាដែរ គឺលោកតាលំអៀង ។ " យីហ៊ុបនិយាយដោយសំឡេងខ្លាំងៗ "

លោកតាមុខស្លូត និយាយទៅកាន់សូគ៌ា និងលោកជំនោរ :

-ជំនោរ ! សូគ៌ា ! ពួកឯងចិញ្ចឹមកូនរបៀបណា បានជាចៅយីហ៊ុប និងចៅវេហាហ៊ានព្រហើនជាមួយយើងយ៉ាងនេះ ។

លោកស្រីសូគ៌ាព្យាយាមលាក់លៀមនូវការខឹងសម្បារ ដែលកប់ក្នុងចិត្ត គាត់សំដែងកាយវិការឱនក្បាលគោរពលោកតា ស្រដី :

-ខ្ញុំសុំទោសលោកពុក ។

រួចមកសូគ៌ាងាកមកមើលមុខយីហ៊ុប គាត់ពោល :

-កូនសុំទោសលោកតាភ្លាម យីហ៊ុប ។

-លោកតាខ្ញុំសុំទោស ។ " យីហ៊ុបស្រដីទាំងមុខក្រញូវ "

-លោកពុក ខ្ញុំសុំទោស ។ " លោកជំនោរ "

-លោកពុក ខ្ញុំសុំទោស ដែលប្រដៅកូនមិនបានល្អ " ជាប្រយោគរបស់អ្នកស្រីពារាដែលវាចាទៅកាន់បិតាក្មេក រួចអ្នកស្រីងាកមកវេហា បន្តវាចា "...វេហា ! សុំទោសលោកតាណ៎ាកូន ។

-បាទ ម៉ាក់ ។

បន្ទាប់មកវេហាងាកទៅមើលលោកតា ពេនិយាយ :

-ចៅសុំទោសដែលចៅមានសម្ដីមិនសមរម្យទៅលើលោកតា ។

លោកតាមើលមុខវេហាម្តង មើលមុខយីហ៊ុបម្តង ចុងក្រោយគាត់សម្លឹងទៅចំមុខទារិកា ទើបគាត់និយាយមុខមាំ :

-វេហា ទារិកា យីហ៊ុប ! ពួកឯងទាំងអស់គ្នាត្រូវស្តាប់យើង ការដែលយើងថា វាមានភាពយុត្តិធម៌ ចំពោះការដែលយើងប្រគល់ផ្ទះសិទ្ធា ដល់ចៅលក្ខណ៍ គឺព្រោះពួកឯងទាំងបីនាក់ សុទ្ធតែយើងបានចំណាយលុយឱ្យទៅរៀននៅបរទេស តែចំពោះចៅលក្ខណ៍វិញ គេទៅរៀនបរទេសដោយទទួលបានអាហាររូបករណ៍ពីរដ្ឋណោះ ។

និយាយបានត្រឹមនេះ លោកតាងាកមកសម្លឹងមើលយីហ៊ុប ទាំងមុខមាំពោលដោយម៉ឺងម៉ាត់ :

-ហើយឯងវិញណាំចៅយីហ៊ុប កាលទៅបរទេស ឯងនេះចោលម្សៀតមែនទែន ឯងមិនទៅរៀនទេ ឯងគិតតែយកលុយយើងទៅបំផ្លាញ ដោយការដើរលេងជាមួយមិត្តបរទេសរបស់ឯង ។

និយាយដល់ត្រង់នេះ លោកតាងាកមកមើលលោកជំនោរ លោកស្រីសូគ៌ា និងលោកស្រីតារា ទើបលោកតាស្រដី :

-ឥឡូវនេះឯងទាំងបីនាក់ជាម៉ែឪរបស់វេហា ទារិកា និងយីហ៊ុប តើឯងយល់ស្របតាមយើងទេ ក្នុងការដែលយើងចែកទ្រព្យបែបនេះ គឺព្រោះតែហេតុផលបែបហ្នឹងណា ។

-បាទ កូនយល់ហើយលោកពុក ។ " លោកជំនោរឆ្លើយទាំងមុខស្ងួត "

-ចាស លោកពុក ។ " លោកស្រីតារា "

-ចាស លោកពុក ។ " លោកស្រីសូគ៌ា "

លោកតាងាកមកលោកកិត្យា និងលោកស្រីមាណរី គាត់និយាយ :

-កិត្យា ! មាណរី ! នៅអាទិត្យក្រោយ ពួកកូនរើទៅនៅផ្ទះសិទ្ធាណា ។

-បាទ លោកពុក ។ " លោកកិត្យា "

-ចាស លោកពុក ។ " លោកស្រីមាណរី "

.....................................................................................................................

.....................................................................................................................

យើងបែរមកមើលពិសិដ្ឋម្តង គ្រាដែលគេកំពុងស្ពងអារម្មណ៍ជាមួយការគយគន់រូបថតនរលក្ខណ៍ ព្រលឹងខ្មោចលោកយាយមាសផុសឡើងក្នុងសម្លៀកបំពាក់ស្បៃសវែងអូសដី មុខស្លេកស្លាំង នៅពីមុខរបស់គេ ។ ពិសិដ្ឋភ្ញាក់ស្រឡាំងកាំងមើលទៅយាយមាស គេឃើញយាយមាសឈរសម្លក់សម្លឹងរបៀបពោរពេញដោយគំនុំ កែវភ្នែកបិសាចសម្លឹងរូបថតនរលក្ខណ៍ដែលនៅក្នុងដៃកំលោះ ។ ជាធម្មតាពិសិដ្ឋតែងតែបានឃើញព្រលឹងខ្មោចយាយមាស ជាញឹកញាប់ តែគេមិនដែលឃើញអាការៈខ្មោចលោកយាយមាស មានសភាពគួរឱ្យព្រឺខ្លាចដូចជាពេលនេះឡើយ ។ យល់អាការៈចម្លែករបស់បិសាចស្រី ពិសិដ្ឋមានភាពអន្ទះសារ គេសួរទៅកាន់ខ្មោចស្រី :

-លោកយាយ ម៉េចធ្វើមុខដូចជាខឹង តើខ្ញុំខុសអី ?

ព្រលឹងយាយមាសមុខកាន់តែមាំ តែសម្លក់រូបថតហាក់ដូចជាចង់កម្ទេចរូបថតស្រីដែលពិសិដ្ឋលួចប៉ងប្រាថ្នា ឱ្យរលាយបាត់សូន្យឈឹងពីដៃកំលោះ ។ នរះហាក់ដូចជាមិនយល់ពីបំណងខ្មោចលោកយាយមាស គាត់ខឹងនឹងនរណា ខឹងនឹងគេ ឬ ខឹងនឹងរូបថត ? មួយដង្ហើមធំកន្លងផុត ខ្មោចស្រីក៏រលាយរូបបាត់ពីក្រសែចក្ខុមាណព ។

ពិសិដ្ឋងឿងឆ្ងល់ គេវេភ្នែកតាមមើលត្រង់កន្លែងយាយមាសរលាយរូប ដូចជាមានបំណងសួរបិសាចឱ្យឆ្លើយបំភ្លឺចម្ងល់របស់យុវជន ។ កន្លងមក ប្រសិនបើគេនៅតែឯង ហើយខ្មោចយាយមាសផុសមករកគេ ព្រលឹងខ្មោចស្រីតែងតែទ្រហោយំ ក្នុងសភាពទឹកមុខដែលឈឺចាប់ហាក់ដូចជាមិនបិសាចកំពុងទទួលនូវភាពអយុត្តិធម៌អ្វីមួយ ប៉ុន្តែលើកនេះខ្មោចស្រីដែលឋិតក្នុងអាការៈហាក់ដូចជាមានកំហឹងចំពោះរូបថតដែលនៅក្នុងដៃពិសិដ្ឋទៅវិញ ។ អ្នកប្រុសពោរពេញទៅដោយការសង្ស័យ ប៉ុន្តែគេមិនអាចរកចម្លើយបានឡើយ ។ ក្នុងពេលបុរសឋិតនៅក្នុងការរិះគិត សំឡេងគោះទ្វារបានបន្លឺឡើង :

-តុក ! តុក !

ពិសិដ្ឋងាកទៅទ្វារ និយាយ :

-អ្នកណា ?

សំឡេងនាងអែម ជាស្រីបម្រើលាន់ពីក្រៅបន្ទប់ :

-ខ្ញុំអែមណាំលោកប្រុស ។

-ចូលមកបងអែម ខ្ញុំអត់ខ្ទាស់គន្លឹះទ្វារទេ ។ " ពិសិដ្ឋ "

ទ្វារបន្ទប់របើក នាងអែមដើរចូលមករកពិសិដ្ឋ ទាំងពោល :

-លោកប្រុស ! លោកយាយ និងលោកស្រីសុំអញ្ជើញលោកប្រុសទៅបន្ទប់លោកយាយ ។

-បងអែមទៅមុនចុះ ខ្ញុំទៅតាមក្រោយ ។

នាងអែមដើរចេញទៅ ពិសិដ្ឋទុករូបថតនរលក្ខណ៍នៅពីក្រោមខ្នើយ ។ ភ្លាមនោះ ស្រាប់តែផ្កាឈូកជាច្រើន បានផុសអណ្តែតមកនៅពីមុខពិសិដ្ឋ លេចចេញ

ជារូបរាងទេវតាស្រីមួយអង្គ ។ ពិសិដ្ឋងាកមកឃើញទេវតាស្រី ពិសិដ្ឋភ្ញាក់ព្រើត តែម្ដីម្ដាលុតជង្គង់ ថ្វាយបង្គំទេវតា :

-ទូលបង្គំថ្វាយបង្គំព្រះនាងទេវតា ។

ទេវតាត្រវីក្បាល មានបន្ទូលទាំងរាដៃ :

-ពិសិដ្ឋ ! យើងធ្លាប់ប្រាប់អ្នកហើយថា រាល់ពេលជួបយើង អ្នកមិនបាច់ថ្វាយបង្គំយើងទេ ព្រោះយើងមានទិស្ស៊ុយជាមួយអ្នក ដែលជាមនុស្សមានញាណពិសេស អាចទាក់ទងជាមួយយើងបាន ។

-តែទូលបង្គំចេះតែភ្លេច បើព្រះនាងជាទេវតា ឯទូលបង្គំ...

-អ្នកឈប់និយាយបញ្ហានេះចុះ យើងមកជួបអ្នកនៅពេលនេះ ព្រោះយើងដឹងថា អ្នកមានអ្វីដែលកំពុងកប់ក្នុងចិត្ត ហើយអ្នកចង់សួរយើង ។

-ហេតុអីបានជាព្រះនាងទេវតាដឹងថា ទូលបង្គំមានសំណួរចង់ទូលសួរព្រះនាងទេវតា ?

-យើងដឹង ព្រោះយើងជាទេវតាហ្នឹងណា៎ តែពេលនេះ អ្នកត្រូវទៅជួបលោកយាយនិងម្ដាយអ្នកសិនទៅ យើងនឹងនៅចាំអ្នកនៅទីនេះ ។

-បើទូលបង្គំទៅជួបលោកយាយនិងម៉ាក់ទូលបង្គំ នោះជាការមិនគប្បីដែលព្រះនាងទេវតាត្រូវចាំទូលបង្គំ...

-យើងមកពេលនេះ គឺមកដោយខ្លួនយើង ទើបយើងត្រូវចាំអ្នកអីចឹងហើយណា៎ ។

-ទូលបង្គំថ្វាយ...

-ចូរអ្នកនិយាយពាក្យមនុស្សលោក ជាមួយយើងណា៎ ។

-បាទ ខ្ញុំជម្រាបលាព្រះនាងទេវតាសិនហើយ ។

បន្ទាប់ពីពិសិដ្ឋថ្វាយបង្គំលាព្រះនាងទេវតាហើយ នរៈក៏ដើរចេញទៅក្រៅបន្ទប់ដើម្បីទៅជួបម្ដាយនិងជីដូនដែលរង់ចាំគេនៅក្នុងបន្ទប់ទទួលភ្ញៀវ ។ ទេវតាស្រីតាមទតមើលពិសិដ្ឋរហូតដល់ចេញផុតពីបន្ទប់ ព្រះភក្ត្រព្រះនាងញញឹម រួចព្រះនាងលើកព្រះហស្តចង្អុលទៅចំខ្មៅដៃ ដែលមុននេះពិសិដ្ឋបានសិករូបថតរបស់នរលក្ខណ៍ចូលទៅពីខាងក្រោម អំណាចបារមីរបស់ទេវតាបានបញ្ចេញជាកម្មវត្ថុភ្លឺចិញ្ចាចផុះលើខ្មៅដៃរមៀលចេញ ពីទីកន្លែងដើម ហើយរូបថតនរលក្ខណ៍ក៏បានបង្ហាញវត្តមានចំពោះព្រះនេត្ររបស់ទេវតា ។ ព្រះនាងទេវតាញញឹមមើលរូបនរលក្ខណ៍ជាមួយទឹកមុខបែបច្រលើម...យើងមិនដឹងថាព្រះនាងទេវតា បញ្ចេញកាយវិការបែបនេះ ក្នុងបំណងអ្វីទេ ប៉ុន្តែបើសង្កេតតាមទឹកព្រះភក្ត្ររបស់នាង អាចបញ្ជាក់បានថាព្រះនាងមិនបានស្អប់ម្ចាស់រូបថត ដូចជាព្រលឹងខ្មោចយាយមាសនោះឡើយ ។

នាពេលជាមួយគ្នានេះ ប្រសិនយើងបែរមកមើលក្រុមគ្រួសាររបស់ម្ចាស់រូបថតវិញ តើពួកគេទាំងអស់គ្នានោះមានអារម្មណ៍បែបណា ? កាលបើគ្រាមុននេះបន្តិច លោកឧកញ៉ាសិទ្ធាដែលជាប្រមុខគ្រួសារដ៏ធំនេះ បានប្រគល់នូវផ្ទះសិទ្ធាដ៏ស្កឹមស្កៃទៅឱ្យនរលក្ខណ៍ ដែលជាចៅស្រីរបស់កូនប្រុសនៃភរិយាទីមួយរបស់គាត់ ហើយតាមរយៈទឹកមុខនឹងសម្ដីរបស់សមាជិកគ្រួសារមួយចំនួន ពិតជាបង្ហាញពីភាពមិនពេញចិត្ត ចំពោះការបែងចែកមរតកនេះទេ ។ ឥឡូវដើម្បីចង់ដឹងការពិត យើងលបស្ដាប់ការសន្ទនារវាងអ្នកស្រីសួគ៌ាដែលជាកូនទីពីរ របស់ភរិយាទីពីររបស់លោកតា និងកូនស្រីរបស់អ្នកស្រីសួគ៌ា គឺកញ្ញាយីហ៊ុប នោះយើងនឹងបានឮប្រយោគដំបូងរបស់យីហ៊ុបបន្លឺ :

-កូនខឹងលោកតាដែលឱ្យវិមានសិទ្ធាទៅបងលក្ខណ៍ លោកតាស្រឡាញ់តែបងនរលក្ខណ៍ ជាងចៅទាំងអស់គ្នា ។

-ម៉ាក់ដឹងតើ តែយ៉ាងណាការដែលម្ដាយកូនយើងសុំលោកតា ក្នុងការបានទៅរស់នៅក្នុងវិមានសិទ្ធា ជាមួយគ្រួសារបងកិត្យា ធ្វើឱ្យម៉ាក់សប្បាយចិត្តណាស់កូន ។

-ហេតុអីក៏ម៉ាក់សប្បាយចិត្ត ។

-ព្រោះនោះជាឱកាសល្អសម្រាប់ឱ្យយើងមានពេលឆ្កើះកកាយ ពីកំហុសនាងលក្ខណ៍ សម្រាប់ជម្រាបដល់លោកតា ដែលជាលេសអាចនឹងឱ្យលោកតាដកហូតវិមានសិទ្ធាពីនាងលក្ខណ៍ មកវិញបានណាកូន ។

-ម៉ាក់ពូកែមែន តែប៉ុណ្ណេះ បងលក្ខណ៍អើយ កុំសង្ឃឹមថាវិមានសិទ្ធានឹងបានទៅលើដៃបងនោះ ។

ទន្ទឹមគ្នានេះ បើយើងមើលមកបន្ទប់លោកជំនោរដែលជាកូនច្បងរបស់ភរិយាទីពីរនៃលោកឧកញ៉ាសិទ្ធា យើងឃើញលោកជំនោរអង្គុយលើកៅអីក្នុងទឹកមុខមូម៉ៅ ឯអ្នកស្រីតារាជាភរិយារបស់គាត់ ដែលមានមុខជិតដាម ទៅដោយកំហឹងអ្នកស្រីអង្គុយលើពូកជិតវេហាជាកូនប្រុសច្បង ដែលនរ:ឈរផ្អែកជញ្ជាំងក្នុងទឹកមុខពោរពេញទៅដោយការក្រេវក្រោធ ទឹកមុខមនុស្សទាំងបីនាក់មានសភាពខុសពីកញ្ញាទារិកា ដែលនាងឈរក្នុងអាការ:រំបែបហី ហាក់ដូចមិនចាប់អារម្មណ៍ពីអាកប្បកិរិយារបស់ម្ដាយឪពុកនិងបងប្រុស ដែលកំពុងឋិតក្នុងសភាពមួហ្មងនោះឡើយ ។ ស្រីទារិកាកំពុងឈរចោលភ្នែកមើលតាមចន្លោះបង្អួច ទៅក្នុងលំហមេឃ

ដែលមានដួងចន្ទរះក្រឡង់កណ្តាលវេហា ។ មុខទារិកាញញឹម រួចនាងបែរសឡឹមៗ មកសម្លឹងម្តាយ នាងស្រដី :

-ម៉ាក់ ! លោកប៉ា! កូនសុំទៅក្រៅហើយ ។

-ហេតុអីក៏កូនត្រូវចេញទៅក្រៅនៅពេលនេះ បើទាំងម៉ាក់ ទាំងប៉ា ទាំងបងប្រុសឯងកំពុងតែឈឺក្បាលពីរឿងវិមានសិទ្ធាណ៎ា ។

-ហេតុអីម៉ាក់ឈឺក្បាលពីរឿងវិមានសិទ្ធា ? បើគ្រួសារយើងបានទៅរស់នៅក្នុងផ្ទះនោះហើយហ្នឹង ។

-តែប៉ានិងម៉ាក់ព្រមទាំងបងប្រុសឯង មិនមែនត្រឹមតែចង់ទៅរស់ក្នុងផ្ទះនោះទេ គឺយើងត្រូវការចង់បានផ្ទះនោះណ៎ា ។ " លោកជំនោរ "

ទារិកានិយាយទាំងមុខបែបហី :

-តែផ្ទះនោះ លោកតាបានប្រគល់ឱ្យនរលក្ខណ៍ហើយតើលោកប៉ា ។

វេហាងាកមើលទារិកា ស្រែកគំហកដាក់នាង :

-ទារិកាចង់ទៅណា ក៏ទៅភ្លាមទៅ យើងធុញស្តាប់ឯងណាស់ ។

វេហាងាកមកលោកជំនោរ តេស្រដី :

-លោកប៉ា នាងល្អិតនេះដែលខ្វល់អ្វី ក្រៅពីការគូររូបរបស់គេហ្នឹង ។

លោកជំនោរបែរមកទារិកា ស្រដី :

-ឯងទៅណាក៏ទៅចុះ ព្រោះឯងមិនដែលស្របយោបល់ជាមួយពួកយើងម្តងណាទេ ។

ទារិកាសំពះឪពុក រួចងាកមកសំពះម្តាយ :

-លោកប៉ា! ម៉ាក់! កូនសុំទៅគូររូបហើយអីចឹង ។

ទារិកាដើរចេញទៅ លោកស្រីតារានិយាយ :

-ចាំវា ! យើងគិតយ៉ាងណា ដើម្បីឱ្យវិមានសិទ្ធាក្លាយមកជាសម្បត្តិយើង ។

-កុំអាលគិតច្រើន ចាំពេលទៅរស់ក្នុងផ្ទះសិទ្ធាជាមួយនាងលក្ខណ៍សិន សឹម យើងនឹងរកល្បិចធ្វើឱ្យលោកពុកដកការស្រឡាញ់ពីក្មួយលក្ខណ៍ ហើយដកផ្ទះនោះ ពីនាងលក្ខណ៍ ដូចកាលពី៣០ឆ្នាំមុន ដែលលោកពុកដកហូតផ្ទះនេះ ពីអ្នកមីង មាសវិញដែលនោះអី ។

..............................................................................................................

..............................................................................................................

នៅក្នុងបន្ទប់ទទួលភ្ញៀវនាភូមិគ្រឹះរបស់អ្នកកំលោះពិសិដ្ឋ លោកយាយ រំដួលអង្គុយលើសាឡុង វាចាទៅកាន់ពិសិដ្ឋជាចៅសំណព្វដែលអង្គុយបត់ជើង លើឥដ្ឋជិតជីដូន :

-មែនហើយកាលពី៣០ឆ្នាំមុន ឧកញ៉ាសិទ្ធាបានប្រគល់ផ្ទះសិទ្ធា ឱ្យមក លោកយាយមាស ដែលជាលោកយាយតូចរបស់ចៅ និងបានទាំងដូរឈ្មោះវិមាន សិទ្ធាថា ជាវិមានមាស ដែលជាឈ្មោះលោកយាយតូចរបស់ចៅ ។

-ប្រហែលជាលោកឧកញ៉ាស្រឡាញ់លោកយាយតូចណាស់ ទើបគាត់ដាក់ ឈ្មោះផ្ទះ ដោយយកឈ្មោះលោកយាយតូចបែបហ្នឹង មែនទេលោកយាយធំ ?

យាយរំដួលមុខស្លូត សម្លឹងទៅឆ្ងាយ និយាយរាងអួលៗ :

-ដំបូងគឺដូចការគិតរបស់ចៅមែន តែមិនយូរប៉ុន្មាន ក្រោយពីការប្រគល់ វិមានមាសដល់ប្អូនមាស អ្វីៗវាបែរជាក្លាយការអាម៉ាស់សម្រាប់ប្អូនមាសទៅវិញ ណាចៅសិដ្ឋ...

លោកយាយរំដួលអាក់វាចា ទឹកភ្នែកហូរមកលើផែនថ្ពាល់ បបូរមាត់គាត់ញ័រទទ្រើត អណ្តាតមិនអាចរលាស់ចេញជាពាក្យសម្តី ។ ពិសិដ្ឋក្តុកក្តួលក្នុងចិត្ត គេយល់ថា លោកយាយតូចប្រហែលជាជួបបញ្ហាឈឺចាប់មិនខាន ទើបបេះដូងលោកយាយធំពោរពេញទៅដោយទុក្ខសោក គ្រាដែលរំលឹកដល់ប្អូនស្រីយ៉ាងនេះ ពិសិដ្ឋសម្លឹងមើលយាយរំដួល ជាមួយសំណួរ :

-អ្វីជាការអាម៉ាស់នោះលោកយាយធំ? លោកយាយអាចប្រាប់ចៅបានទេ ។

-ពីមុនលោកយាយលាក់ការអាម៉ាស់របស់ប្អូនមាស តែឥឡូវយាយមិនលាក់អ្វីទៀតទេ ព្រោះពេលវេលាវាក៏មកដល់ដែរហើយ ចៅចាំស្តាប់ណ៎ា ។

# វគ្គទី ៣

ក្នុងផ្ទះឈើដ៏ធំមួយ ដែលសាងសង់អំពីឈើមានតម្លៃនៅក្នុងដីឡូតិ៍
ប្រហែលជាសាមសិបម៉ែត្រ គុណនឹងមួយរយម៉ែត្រ ដោយក្នុងបរិវេណដី មាន
សួនច្បារប្រកបដោយផ្កាក្លាំងឃា ក្រវ៉ាន់ រំដួល ចំប៉ា ចំប៉ី ដាំក្នុងសភាពរៀបចំយ៉ាង
ប្រណិតគួរឱ្យទាក់ភ្នែក ។ បើគេដើរចូលទៅក្នុងផ្ទះឈើដ៏ធំនេះ គេនឹងឃើញ
សង្ហារឹមដែលតុបតែងក្នុងគេហដ្ឋាន គឺសុទ្ធសឹងរបស់របរបូរាណ ធ្វើអំពីឈើនាងនួន
និងមៃសាក់ ។ ការរៀបចំតុបតែងលម្អក្នុងផ្ទះដ៏ស្កឹមស្កៃនេះ មានលក្ខណៈគួរឱ្យចង់
គយគន់ ដែលបង្ហាញអំពីភាពប៉ិនប្រសប់និងពោរពេញទៅដោយទេពកោសល្យ
របស់ម្ចាស់ផ្ទះ ។ លើគ្រែជើងគ្រុឌពោរពេញដោយក្បាច់រចនាយ៉ាងរស់រវើក
យាយរំដួលក្នុងអាយុ[illegible]០ឆ្នាំកំពុងអង្គុយលើក្ការឿ ដៃគាត់លើកចិញ្ចៀនពេជ្រ
ផ្ទៀងផ្ទងមើល ក្នុងក្រសែភ្នែកពេញចិត្តចំពោះគ្រាប់ពេជ្រ ដែលមានចរណៃ
ដល់ទៅបីជាន់យ៉ាងស្អាតប្រណិត ជាមួយនឹងទឹកពេជ្រដែលគេហៅថា ទឹកសំណរ
កាត់ ក្នុងទំហំប្រាំមួយលី ។ កំពុងតែលង់នៅក្នុងពេញចិត្តទៅលើក្បាច់ក្បូររចនា
របស់ចិញ្ចៀនពេជ្រដ៏ធំនេះ ស្រាប់តែសំឡេងស្រួយស្រេះរបស់ស្ត្រីម្នាក់បានលាន់
មកប៉ះសោតាស្រីម្ចាស់ចិញ្ចៀន :

-បងស្រី !

លោកជំទាវរំដួលងាកមករកប្រភពសំឡេង ភ្លាមនោះ អាការៈភន្តភាំង
ដែលមកកន្ត្រាក់អារម្មណ៍បណ្តាលមកពីភ្នែកគាត់បានឃើញ គឺជាជំទាវមាសកំពុង
ដើរចូលមករកគាត់ ។ ក្នុងសម្រស់ស្រស់ចិញ្ចាចដែលឋិតនៅវង្វង់ភក្ត្ររបស់ជំទាវ

មាស ដាក់បង្អប់នូវភាពឈឺចាប់ក្នុងអាការៈស្លូតស្រៀមស្រគំ បានប្រាកដលើក្រសែភ្នែកជំទាវរំដួល ជាពិសេសជំទាវម្ចាស់ផ្ទះ ក៏បានឃើញនាងព្រីងជាស្រីបម្រើយួរហឹបមួយ ដើរក្នុងកាយវិការឱនលំទោនតាមពីក្រោយជំទាវមាស ។ យល់សភាពចម្លែករបស់ប្អូនស្រីក្នុងការធ្វើដំណើរមកកាន់ផ្ទះរបស់គាត់ ជំទាវរំដួលបន្លឺ :

-ប្អូនមាស ហេតុអីមកលេងផ្ទះបង ដោយស្ងាត់ៗយ៉ាងនេះ ?

មុននឹងឆ្លើយតបទៅកាន់បងស្រី ជំទាវមាសស្រដីទៅកាន់នាងព្រីង ជាស្រីបម្រើ :

-ឯងយកហឹបយើងទៅទុកបន្ទប់ចាស់ ដែលយើងធ្លាប់នៅពីមុននោះទៅនាងព្រីង ។

-ចាស លោកជំទាវតូច ។

នាងព្រីងយួរហឹបដើរសំដៅទៅរកបន្ទប់មួយ ។ ជំទាវមាសដើរមករកជំទាវរំដួល ។ គ្រាដែលមកក្បែរកាយបងស្រី ជំទាវមាសជាប្អូនលុតជង្គង់សំពះជំទាវរំដួល ជាមួយទឹកភ្នែកហូរសស្រាក់ បង្ហូរវាចាអាក់រអួលលាន់ពីបបូរមាត់ :

-បងស្រី...ខ្ញុំមានទុក្ខធំណាស់ ហ៊ឹក ហ៊ឹក ហ៊ឹក ។

ជំទាវរំដួលឈោងដៃមកចាប់លើកប្អូនស្រីឱ្យអង្គុយ លើគ្រែក្បែរខ្លួនគាត់ ទឹកមុខរបស់ជំទាវរំដួលស្រពាប់ស្រពោន បន្លឺ :

-ប្អូនស្រី! នេះមានរឿងអីអ្ហេះ បានជាធ្វើមុខបែបនេះ ?

ជំទាវមាសស្រវាឱបជំទាវរំដួល ស្រដីទាំងយំសសឹក :

-បងស្រី ! ពេលនេះប្អូនត្រូវលះលែង...ជាមួយបងឧកញ៉ាសិទ្ធាហើយ ហ៊ឹក...ហ៊ឹក...

ជំទាវរំដួលមុខភ្ញាក់ ទាញជំទាវមាសឱ្យខិតឆ្ងាយពីទ្រូងគាត់ គាត់មើលមុខប្អូនស្រី ស្រដី :

-ប្អូនស្រី ! ឯងនិយាយថាម៉េច បងស្តាប់ច្រឡំទេដឹង ?

-ចាស...មិនច្រឡំទេបងស្រី ហ៊ឹក ហ៊ឹក ខ្ញុំលែងគ្នាជាមួយបងឧកញ៉ាហើយ ហ៊ឹក ហ៊ឹក មិនតែប៉ុណ្ណេះវិមានមាសដែលគាត់សន្យាឱ្យខ្ញុំ ក៏ត្រូវបងឧកញ៉ាដកយកវិញដែរ ហ៊ឹក ហ៊ឹក ខ្ញុំរងអំពើអយុត្តិធម៌ ខ្ញុំឈឺចិត្តណាស់បង ។

ជំទាវរំដួលមុខខឹង និយាយដោយម៉ឺងម៉ាត់ :

-មិនបាន ! គេមិនអាចធ្វើបែបនេះជាមួយប្អូនបានទេ ទោះជាប្អូនជាភរិយាទីបីរបស់គេក៏ដោយ តែប្អូនជាភរិយាម្នាក់របស់គេដែរតើ បងនឹងប្តឹងទាមទារ យកអ្វីដែលជាចំណែកប្អូនមកវិញ ។

-កុំប្តឹងអីបងស្រី ហ៊ឹក ហ៊ឹក ខ្ញុំមិនចង់ឱ្យរឿងអាម៉ាស់នេះ ត្រូវខ្ចរខ្ចាយទេ ហ៊ឹកហ៊ឹក ព្រោះវានឹងធ្វើឱ្យប៉ះពាល់ដល់កិត្តិយសត្រកូលសារយើង ហ៊ឹកហ៊ឹក គ្រាន់តែខ្ញុំស្តាយវិមានមាស ហ៊ឹកហ៊ឹក ប្អូនខឹងណាស់បងស្រី ខឹងដែលគេមិនគោរពសម្តី ហ៊ឹកហ៊ឹក ។

នៅពេលដែលលោកជំទាវរំដួលនិយាយដល់ចំណុចនេះ យុវជនពិសិដ្ឋក៏ពោលវាចាកាត់សម្តីជីដូន :

-មិនត្រឹមត្រូវទេ លោកឧកញ៉ាធ្វើផ្តេសផ្តាស វិមានមាសត្រូវតែជារបស់លោកយាយតូច ទោះជាលោកយាយតូចមានការលះលែងជាមួយលោកតាឧកញ៉ាក្តី ...” និយាយដល់ត្រឹមនេះ ពិសិដ្ឋងាកមកម្តាយ ស្រដីបន្ត “ ...មែនហើយម៉ាក់

កូននឹកឃើញហើយ កាលដែលកូនបានឃើញព្រលឹងលោកយាយតូច កាលពីដំបូង នោះ គឺកាលណោះ ព្រលឹងលោកយាយតូចយំខ្លាំងណាស់ ។

បន្ទាប់មកពិសិដ្ឋក៏និយាយរៀបរាប់ពីហេតុការណ៍ ដែលគេតែងតែបានជួប ព្រលឹងខ្មោចលោកយាយមាស ដែលគេហៅថាលោកយាយតូចនោះ ដែលតែងតែ ចេញមកជួបគេ ។ ជារៀងរាល់ដង ដែលព្រលឹងរបស់លោកយាយតូចចេញមកជួប នរៈ ទឹកមុខរបស់ខ្មោចស្រីពោរពេញទៅដោយការឈឺចាប់ ស្រែកដង្ហោយឱ្យពិសិដ្ឋ ជួយរកយុត្តិធម៌ក្នុងប្រការអ្វីមួយ ។ សម្រាប់យុវជននេះ គេមិនត្រឹមតែអាចមើល ឃើញខ្មោចទេ គេធ្លាប់ថែមមើលឃើញព្រះនាងទេវតា ដូចអ្នកអានដឹងពីខាងដើម ស្រាប់ ។ អ្វីដែលពិសិដ្ឋនិយាយជម្រាបលោកយាយរំដួលនិងម្តាយរបស់គេ គឺគេចាប់ ផ្តើមចាប់តាំងពីពេលដំបូងនាថ្ងៃទីមួយ ដែលគេបានជួបនឹងអព្ភូតហេតុដ៏ចម្លែក ក្នុងជីវិតរបស់គេ ។

កាលណោះពិសិដ្ឋកំពុងអង្គុយរៀន ដោយនេត្រាក្មួងអានសៀវភៅ ស្រាប់ តែមានផ្កាឈូកជាច្រើនផុសចេញជារូបទេវតាស្រី នៅមុខពិសិដ្ឋ ។ គ្រាកាលណោះ ពិសិដ្ឋភ្ញាក់ស្ទើរតែដួលរលំលើកៅអី កំលោះបន្លឺទៅទេវតាស្រីដោយការងឿងឆ្ងល់ :

-នាងជានរណា ? មកពីទីណា នាងស្លៀកពាក់ចម្លែកម្ល៉េះ ?

ទេវតាស្រីញញឹម មានព្រះសុរណ្ណេទីយមក់កាន់មាណោព :

-យើងជាទេវតា !

-ទេវតា ! " ពិសិដ្ឋសួរដោយការភ្ញាក់ផ្អើល "

-ពិតហើយ យើងនឹងអ្នកមាននិស្ស័យជាមួយគ្នា ទើបយើងនឹងមកជួយ ថែរក្សាអ្នក ។

-ហេតុអីខ្ញុំមានទិស្សរ៍យជាមួយទេវតា ? ខ្ញុំមិនយល់ ។

-ព្រោះអ្នកជាមនុស្សមានវិញ្ញាណពិសេស គឺវិញ្ញាណទី៦ ដែលរូបអ្នកខុសពីមនុស្សធម្មតានេះហើយ អ្នកមិនត្រឹមតែអាចមើលយើងឃើញទេ អ្នកអាចមើលឃើញអ្នកស្លាប់ណាម្នាក់ ដែលចង់ឱ្យអ្នកឃើញបានទៀតផង ។

ពិសិដ្ឋមានទឹកមុខភ្ញាក់ ដោយអាការៈព្រឺស្ញើប :

-ទេវតាមានសុវណ្ណទីយថាម៉េច ខ្ញុំអាចឃើញខ្មោចទៀត ទេ! ខ្ញុំខ្លាច... ខ្ញុំមិនចង់ឃើញ...

-ពេលនេះយើងមកប្រាប់អ្នកបានតែប៉ុណ្ណោះទេ យើងលាអ្នកទៅវិញសិនហើយ ។

ព្រះកាយទេវតារលាយបាត់ ពិសិដ្ឋដែលមិនទាន់យល់ច្បាស់ពីអ្វី ជាអត្ថន័យរបស់សុវណ្ណនីយរបស់ទេវតា គេមានភាពមិងមាំង ទើបគេស្រែកសួរទៅទេវតាដែលកំពុងរលាយព្រះកាយបន្តិចម្តងនោះ :

-ឈប់ៗ កុំអាលយាងទៅអីទេវតា ខ្ញុំចង់សួរព្រះនាង...

គ្មានចម្លើយនិងគ្មានរូបភាពអ្វី ជិតក្រោមក្រសែនេត្រាពិសិដ្ឋទៀតឡើយ បុរសញ៉ីភ្ញែកជាមួយទឹកមុខរិះគិត ពោលតែឯងតិចៗ :

-ម៉ិញនេះ ខ្ញុំយល់សប្តិទេដឹង !

ដុំភ្លើងពណ៌លឿងឆ្អៅផុសផ្តោល លេចចេញជាខ្មោចយាយមាស ដែលមានអាយុ២៥ឆ្នាំ គ្រងដោយស្បៃស មុខស្លេកស្លាំង សក់រតេរតាយ ស្ថិតចំពីមុខយុវជន។ ដូចគេជាន់ក្បាលពស់ ពិសិដ្ឋលោតថយក្រោយ ស្រែកដោយការភ័ន្តភាំង :

[library stamp]

-លោកយាយតូច ! គឺលោកយាយតូច តែ...តែលោកយាយអនិច្ចកម្ម ហើយតើ ។មែនហើយ! មុននេះបន្តិច ខ្ញុំពិតជាឃើញទេវតា ហើយពេលនេះខ្ញុំឃើញព្រលឹងលោកយាយតូចទៀត ។

ខ្មោចយាយមាសឈរយំ និយាយអណ្ដើតអណ្ដក ក្នុងសភាពហាក់ដូចជាទទួលការធ្វើទុក្ខបុកម្នេញពីនរណាម្នាក់ អាការៈបិសាចបង្ហាញពីភាពឈឺចាប់ ជាមួយប្រយោគ :

-ហ៊ឹក ហ៊ឹក យាយឈឺចិត្ត ហ៊ឹក ហ៊ឹក ឈឺចិត្តណាស់ ហ៊ឹក ហ៊ឹក យាយចង់បានយុត្តិធម៌ ហ៊ឹក ហ៊ឹក ។

ជាមួយការងឿងឆ្ងល់ ពិសិដ្ឋសួរខ្មោចយាយមាស :

-ហេតុអីលោកយាយឈឺចិត្ត ? ហេតុអីលោកយាយចង់បានយុត្តិធម៌ ? តើនរណាធ្វើអ្វីមិនគប្បីទៅលើលោកយាយ ?

-ហ៊ឹក ហ៊ឹក ឈឺចិត្ត ហ៊ឹក ឈឺចិត្ត ហ៊ឹក ហ៊ឹក អយុត្តិធម៌ ។

បន្ទាប់ពីស្រែកយំទាររកយុត្តិធម៌មួយខណៈ ខ្មោចយាយមាសក៏រលាយបាត់សូន្យឈឹង ។ ឥឡូវចម្ងល់បានបង្កើតក្នុងខួរក្បាលអ្នកប្រុសជាបន្ថែម ។ ភាពមិនអស់ចិត្តបានបង្ខំឱ្យពិសិដ្ឋស្រែកហៅខ្មោចយាយមាស :

-លោកយាយ! លោកយាយ! ចៅមិនយល់ទេ ?

នេះជារឿងរ៉ាវដែលពិសិដ្ឋបានជួបប្រទះគ្រាដំបូង ដែលក្មេងប្រាប់មាតា ។ លុះត្រូវកូនប្រុសរំលឹករឿងនេះឡើងវិញ លោកស្រីវិចង់ជាមាតារបស់អ្នកប្រុសបានបន្ថែ :

-មែនហើយពិសិដ្ឋ ព្រោះកូនតែងនិយាយប្រាប់ម៉ាក់ថា កូនបានជួបព្រលឹងអ្នកមីងមាស ដែលតែងតែចេញមកឈរយំស្រែករកយុត្តិធម៌ នៅចំពោះមុខកូនជាញឹកញាប់ ។

-បាទ គឺកូនឃើញលោកយាយតូចច្រើនដងណាស់ ឃើញក្នុងសភាពដូចដែលម៉ាក់មានប្រសាសន៍មែន ។

រំចង់ងាកមើលយាយរំដួល អ្នកស្រីស្រដីទាំងមុខស្លូត :

-ម៉ាក់ ! អ្នកមីងមាសមុនពេលអនិច្ចកម្ម ប្រាកដជាជួបរឿងអយុត្តិធម៌ចុកចាប់ ពីសំណាក់អ្នកណាម្នាក់ហើយ ទើបព្រលឹងគាត់មិនអាចទៅរកទីស្ងប់បាន ។ បើបែបនោះមែន ខ្ញុំអាណិតអ្នកមីងណាស់ម៉ាក់ ។

-លោកយាយធំ ! តើមូលហេតុអីបានជាលោកយាយតូចនិងលោកតាឧកញ៉ាសិទ្ធាលះលែងគ្នា ។

យាយរំដួលហូរទឹកភ្នែករហាម វាចា :

-យាយមិនត្រូវការឱ្យចៅហៅគេម្នាក់នោះថា ជាលោកតាទេ ព្រោះទោះជាយាយមិនដឹងពីមូលហេតុច្បាស់លាស់ ដែលប្អូនមាសត្រូវលះលែងជាមួយគេនោះក្តី តែយ៉ាងណាការលះលែងនោះ...មិនមែនជារឿងល្អ ឬ មានយុត្តិធម៌សម្រាប់ប្អូនមាសឡើយ...ព្រោះថា បើរាល់ពេលយាយសួរប្អូនមាស ពីការលះលែងនោះ ប្អូនមាសមិននិយាយប្រាប់យាយទេ...គេតែងតែយំ...យំដោយគ្មានចម្លើយ ហ៊ឹកហ៊ឹក ។

-គាត់អាចនឹងជួបការឈឺចាប់ខ្លាំងពេក គឺឈឺចាប់ទាល់តែគាត់និយាយមិនចេញណាលោកយាយ ។

-ខ្ញុំយល់ដូចកូនសិដ្ឋដែរម៉ាក់ ។

-ម៉ាក់ក៏យល់អ៊ីចឹងដែរ បើលោកឧកញ៉ាសិទ្ធាមានភរិយាដល់ទៅបីនាក់ តើសុភមង្គល វាបានមកដោយរបៀបណា សម្រាប់លោកយាយតូចរបស់ចៅ ដែលជាភរិយាទីបីនោះ ?

-ចុះហេតុអីលោកយាយតូចទទួលអន្តិកម្ម លោកយាយធំ ?

-គឺបន្ទាប់មកពីប្អូនមាសរស់ជាមួយយាយ គេតែងតែដើរចេញបាត់ៗពីផ្ទះ លុះពេលមកវិញ គេក៏ចូលសម្ងំក្នុងបន្ទប់ មិនរវល់ជាមួយនរណាទេ...យាយគិតថា ការដែលគេចេញបាត់ពីផ្ទះ និងការដែលគេចូលទៅពួនក្នុងបន្ទប់...ដើម្បី...គេចពីសំណួរយាយ...គេចពីការអាម៉ាស់ គេចមិនចង់ឱ្យនរណាឃើញទុក្ខសោករបស់គេ ...ហើយមិនបានប៉ុន្មានថ្ងៃផង... ប្អូនមាសស្រាប់តែត្រូវស្លាប់ដោយភ្លូករថយន្ត នាំយកទាំងការឈឺចាប់ទៅជាមួយសពគេ... យាយអាណិតគេណាស់ ហ៊ឹក ហ៊ឹក ។

រំចង់មើលមុខម្តាយ និយាយទាំងហូរទឹកភ្នែក :

-ពុទ្ធោ ! អ្នកមីងមាស នេះម៉ាក់មិនដែលនិយាយរឿងគាត់ប្រាប់ខ្ញុំទេ... គាត់គួរឱ្យអាណិតណាស់ ។

ពិសិដ្ឋសម្លឹងមើលទៅឆ្វាយ មុខគេជិតដាមដោយកំហឹង គេពោល :

-ខ្ញុំត្រូវយកយុត្តិធម៌ជូនលោកយាយតូច ។

ជាមួយការហូរទឹកភ្នែក យាយរំជួលស្រដី :

-គឺពេលនេះហើយដែលល្អបំផុតសម្រាប់ចៅត្រូវរកយុត្តិធម៌ ឱ្យប្អូនមាស ព្រោះពីអាទិត្យមុន ពេលចៅនៅបរទេសទាក់ទងការងារនោះ យាយបានឃើញតាមកាសែតចុះផ្សាយថា គ្រួសារសិទ្ធានឹងប្រគល់វិមានសិទ្ធា ឬ វិមានមាសនោះ ដល់ចៅស្រីរបស់ភរិយាទីមួយរបស់គេនៅអាទិត្យក្រោយ ទើបធ្វើឱ្យយាយនៅមិនសុខ ហើយ

យាយក៏មកពីផ្ទះយាយឯខេត្ត ដើម្បីមកចាំជួបចៅនេះណា៎ គឺដើម្បីចៅធ្វើយ៉ាងយក
វិមានមាសមកវិញ ក្នុងបំណងស្តារកេរ្តិ៍ឈ្មោះលោកយាយតួចរបស់ចៅ ។

-លោកយាយធំ!ហេតុអីផ្ទះនោះបែរជាមានឈ្មោះជាវិមានសិទ្ធាទៅវិញ ?

-នេះក៏ជារឿងឈឺចាប់សម្រាប់មាសដែរ ព្រោះមិនដឹងហេតុអី នៅពេលបួនមាសចាកចេញពីគ្រួសារគេ គេក៏ប្តូរឈ្មោះផ្ទះដែរ ។

-ហ៊ឹ! អាក្រក់ណាស់ សូម្បីតែឈ្មោះផ្ទះ ក៏មិនរក្សាតាមឈ្មោះម្ចាស់វាដែរ គ្រួសារនោះគួរឱ្យស្អប់មែន ចៅត្រូវតែយកផ្ទះនោះមកវិញនិងធ្វើឱ្យមនុស្សទាំងឡាយដែលស្គាល់ផ្ទះនោះ ត្រូវហៅផ្ទះនោះថា វិមានមាស មិនមែនជាវិមានសិទ្ធាឡើយ ។

..............................................................................................................................................

..............................................................................................................................................

ក្នុងពេលជាមួយគ្នានេះ នៅក្នុងបន្ទប់គេងរបស់កញ្ញានរលក្ខណ៍ដែលជាម្ចាស់វិមានសិទ្ធា ឬ វិមានមាស យើងឃើញថាពីតាកំពុងស្រាយខ្សែរឹតវ៉ាលិសបណ្តើរទាំងស្រដីទៅកាន់លោកកិត្យាជាបិតាផង :

-វិមានសិទ្ធានោះអ្វេះលោកប៉ា ? កូនពិតមិនចង់បានមែន ។

-ប៉ាដឹងចិត្តកូន ហើយចិត្តប៉ាក៏ដូចចិត្តកូនដែរ មិនចង់បានវិមានសិទ្ធាអីទេ បើមាសពេជ្រនិងភាគហ៊ុនក្នុងសណ្ឋាគារទាំងបីដែលលោកតាប្រគល់ឱ្យប៉ា ជាទ្រព្យច្រើនណាស់ ហើយតែអ្វីដែលនាំឱ្យប៉ាមិនបដិសេធនោះ គឺលោកតារបស់កូនបានប្រកាសផ្សព្វផ្សាយតាមកាសែតជាចំហថា លោកនឹងប្រគល់ផ្ទះនោះឱ្យកូនណា៎ ។

-ម៉ាក់វិញ ក៏គិតមិនខុសពីកូននិងលោកប៉ាទេ ម៉ាក់មិនចង់បានទ្រព្យអ្វី ដែលធ្វើឱ្យមានបញ្ហាដែរ ព្រោះម៉ាក់ដឹងថា ទាំងគ្រួសារប្អូនជំនោរ ក៏ដូចជាគ្រួសារប្អូនសូតិ សុទ្ធតែចង់បានផ្ទះនោះ ដើម្បីឱ្យកូនៗរបស់ពួកគេ។ តែយ៉ាងណា គឺគ្មាននរណាអាចជំទាស់ការគិតរបស់លោកតាបានទេកូន ទើបម៉ាក់មិនមានយោបល់អ្វី ក្នុងពេលលោកតាប្រកាសប្រគល់វិមានសិទ្ធាដល់កូន ។

-កូនយល់ចិត្តប៉ាម៉ាក់ហើយ ។

កិត្យាញញឹម មើលនរលក្ខណ៍ លោកនិយាយ :

-ណ្ហើយ! ឈប់និយាយពីរឿងវិមានសិទ្ធាចុះ កូនបើកវ៉ាលីសទៅមើល តើកូនមានអ្វីខ្លះមកផ្ញើម៉ាក់និងប៉ា ?

នរលក្ខណ៍ញញឹម រួចស្រឹយកកូនសោចាក់ចូលមេសោ ដែលនៅជាប់វ៉ាលីសទាំងនាងវាចា :

-ចាស កូនមានបញ្ញើសម្រាប់ទាំងអស់គ្នាក្នុងផ្ទះយើង តែវាពិសេសបំផុតសម្រាប់ម៉ាក់ប៉ានិងលោកតា ។

នរលក្ខណ៍ចាក់សោមិនត្រូវ នាងចាក់សោច្រើនដង ក៏កូនសោមិនអាចចាក់បាន ជាមួយចម្ងល់ ធីតាក៏ចោលនេត្រាមកមើលសោ ស្រាប់តែនាងភ្ញាក់ព្រើតលាន់ប្រយោគ :

-ហ្អាក! មិនមែនវ៉ាលីសកូនទេ ។

-កូនថាម៉េច ? មិនមែនវ៉ាលីសកូនទេ ?

នរលក្ខណ៍លើកក្រដាសជាប់វ៉ាលីស មកមើលឈ្មោះ ឃើញអក្សរសរសេរ " ពិសិដ្ឋ : ធនាគាររំចង់ " នាងងាកមកម្ដាយ និយាយ :

-ទេ មិនមែនជារបស់កូនទេ គឺជារបស់ចៅហ្វាយរបស់ឈ្មោះពិសិដ្ឋ ហើយឈ្មោះពិសិដ្ឋនេះ ក៏ជាអ្នកធ្វើការនៅធនាគារវ៉ែងប៉េះយ៉ាត់ ។

-ធនាគារវ៉ែង ! អាធនាគារដែលបើកទានគណនីសរសៃប្រាក់ប្រាប់ឲ្យកូន អីចឹងផ្ញើកក្រុងរៀនយកទៅផ្ញើរនៅក្រៅស្រុកជាប្រាក់សម្រាប់កូន ។

-បាទ លោកតា ។

............................................................................................................................................

............................................................................................................................................

ចំណែកពិសិដ្ឋវិញ ក្រោយពេលបានជួបសន្ទនាមួយរយៈពេលនៅគេហដ្ឋានលោកជាការ ហើយ គេក៏រីករាយត្រឡប់មកកាន់បន្ទប់ដេកវិញ ។ គ្រាន់តែឡើងដល់បន្ទប់ ពិសិដ្ឋក្រឡេកក្រឡាប់ឃើញទេវតាកំពុងអង្គុយនៅលើគ្រែ ក៏ភ្ញាក់ព្រើត មានអារម្មណ៍ឆ្ងល់អៀនចំពោះទេវតា ដែលទេវតាគ្រាន់តែញញឹម រួចឆ្លើយដោយស្រទន់ទៅក្រោយខ្មាស ហើយតាមពាក្យសួរថា :

-ព្រះនាងទេវតា ហេតុព្រះនាងឆ្លើយមើលផ្ទៃរបស់ខ្ញុំ ?

ទេវតាទ្រង់ព្រះសម្រួល ទាំងមើលមុខពិសិដ្ឋ ដោយបន្ទូលសួរថា :

-យ៉ាងណាទេវតាជាញាតិស្នេហ៍របស់អ្នកដែរ តាមរឿងរ៉ាវដែលនៅ ជាមួយគ្នា ហើយបើអ្នកមិនចង់ ចំពោះខ្ញុំ ?

-អុះ ខ្ញុំសុំទោស ខ្ញុំមិនដែលភ្លេចស្រលាញ់ ខ្ញុំ...

-ស្នេហាជាអ្វីទៅ ធ្វើឲ្យមនុស្សវង្វេងយ៉ាងនេះ ។ ពិសិដ្ឋពេញចិត្តជាមនុស្សមានកេរ្តិ៍ឈ្មោះ ក្នុងពេលវេលាត្រឹមតែនេះ ។ ហេតុនេះហើយ ។

មានព្រះសុវណ្ណនីយចប់ ព្រះកាយព្រះនាងទេវតាក៏រលាយបាត់ ពិសិដ្ឋមិនយល់ពីអ្វីដែលជាអត្ថន័យរបស់សុវណ្ណនីទេវតា គេហាក់មានបំណងចង់សួរជាបន្តទើបគេស្រែកក្នុងគំនិតចង់បង្អាក់ការយាងទៅរបស់ព្រះនាងទេវតា :

-ឈប់សិនព្រះនាងទេវតា ខ្ញុំមិនទាន់បានទូលសួរអីផង ។

ប៉ុន្តែព្រះនាងមិនបានយាងវិលមកជួបគេដូចបំណងទេ ព្រះនាងយាងទៅបាត់ទៅហើយ ពិសិដ្ឋមុខស្លុយ គេអង្គុយចុះលើពូក គេលើករូបថតនរលក្ខណ៍មកមើល ផ្ទៃភក្ត្រដ៏ស្រស់របស់នារីជាទីគួចប្រាថ្នា បានជួយមកបន្ធូរ ជម្រុះកង្វល់ពីក្នុងទ្រូងរបស់យុវជនរូបសង្ហា ហើយស្នាមញញឹមក៏អណ្តែតមកលើវង្ងង់មុខរបស់គេ ។

# វគ្គទី ៤

ម៉ោងប្រាំបី កំលោះពិសិដ្ឋកំពុងតែឈរនៅកន្លែងដូរវ៉ាលីស នាចំណត អាកាសយានអន្តរជាតិភ្នំពេញ ។ នារីអ្នកធ្វើការនៅព្រលានយន្តហោះមួយរូបបាន ហុចវ៉ាលីសរបស់ពិសិដ្ឋ ជាមួយប្រយោគ :

-នេះជាវ៉ាលីសរបស់លោក ។

-ហេតុអីវ៉ាលីសខ្ញុំមកនៅទីនេះ ។

-ចាស មានមនុស្សប្រុសម្នាក់យកវ៉ាលីសលោក មកឱ្យពួកយើង ដើម្បី ទុកដូរយកវ៉ាលីសគេវិញ តាំងពីដប់នាទីមុនពេលដែលលោកអញ្ជើញមក ។

-អូ៎! បាទគឺបែបហ្នឹងទេអ្ហេះ ? អ៊ីចឹងខ្ញុំលាអ្នកនាងហើយ ។

-ចាស អញ្ជើញលោក ។

ពិសិដ្ឋយួរវ៉ាលីសដើរចេញមក ទាំងនឹកគិតក្នុងចិត្ត :

-ខ្ញុំខំមកទីនេះយ៉ាងលឿន ព្រោះសង្ឃឹមក្រែងបានឃើញមុខនាង ដោយ ផ្ទាល់ភ្នែក តែនាងមិនមកសោះ ។

រថយន្តបានជូនពិសិដ្ឋចាកចេញ ពីកន្លែងដូរវ៉ាលីសឆ្ពោះទៅកាន់គោលដៅ។ ប្រហែលជាដប់ប្រាំនាទីក្រោយ មករថយន្តបានមកឈប់នៅមុខធនាគាររំចង់ ។ អ្នក បើកបររថយន្តស្ទុះមកបើកទ្វារយាន ជូនកំលោះម្ចាស់ធនាគារ ។ មាណពដើរ ដោយជំហានយ៉ាងញាប់សំដៅទៅរកផ្នែកខាងក្នុងនៃធនាគាររំចង់ ដើម្បីតម្រង់ ទៅបន្ទប់ធ្វើការរបស់ខ្លួន ។ នៅខាងក្រោយខ្នងបុរសសង្ហា ស្រីស្រស់សោភាម្នាក់ ក្នុងវ័យ២៥ឆ្នាំនិងកំលោះសង្ហាមួយរូបដែលមានវ័យប្រហែលជា២៧ឆ្នាំ កំពុងដើរ

យ៉ាងលឿនតម្រង់មករកពិសិដ្ឋ ។ នារីរូបស្អាតមានឈ្មោះថាម៉ានីន នាងគឺជាប្អូនជីទូតមួយខាងឪពុករបស់ពិសិដ្ឋ កល្យាណរំកិលជំហានកាន់តែមកកៀកមាណពទាំងនួននាងបន្លឺវាចាហៅគេ ដោយសំឡេងតិចៗ :

-បងសិដ្ឋចាំខ្ញុំផង ។

សំឡេងម៉ានីន ទាញកាយបុរសយើងឱ្យងាកបែរមកមើលនាង ។ ស្នាមញញឹមអណ្តែតលើផ្ទៃមុខអ្នកប្រុស ជាមួយនឹងការឈររង់ចាំស្រស់ស្រី ។ ម៉ានីននិងម៉ានុតដើរមកទន្ទឹមពិសិដ្ឋ ទើបស្រីម៉ានីនស្រដី :

-សួស្តីបងសិដ្ឋ តើការងារនៅឯបរទេសបានជោគជ័យយ៉ាងណាដែរបង ?

-បានជោគជ័យដូចដែលពួកយើងបានរៀបផែនការអីចឹងណាអូននីន ។

-អូ៎! ខ្ញុំសប្បាយចិត្តណាស់បងសិដ្ឋ តែពីយប់មិញនេះ ម៉ាក់បងបានទូរស័ព្ទមកប្រាប់ខ្ញុំថា បងមានធុរៈត្រូវទៅធ្វើកិច្ចការមួយ ដែលមិនមែនជាកិច្ចការរបស់ធនាគាររំចង់យើង ។ " ម៉ានុត "

ម៉ានុតនិងម៉ានីន មានភាគហ៊ុនរួមគ្នាជាមួយនឹងគ្រួសារពិសិដ្ឋ ក្នុងការបើកធនាគាររំចង់នេះ ។ ឪពុករបស់គេទាំងពីរជាបងប្អូនជីដូនមួយរបស់ឪពុកពិសិដ្ឋ ។ លោកម៉ាណោជាឪពុករបស់អ្នកទាំងពីរមិនបានរវីរវល់ ក្នុងកិច្ចការរកស៊ីក្នុងធនាគារទេ ដោយគាត់សម្រាកនៅផ្ទះ ដើម្បីទុកនាទីឱ្យកូនប្រុសនិងកូនស្រីធ្វើការងារ ដើម្បីជាការដកពិសោធ ប៉ុន្តែលោកម៉ាណោគឺជាទីប្រឹក្សារបស់កូនៗរបស់គាត់ ។ ចំពោះពិសិដ្ឋវិញ អ្នកកំលោះនិងម្តាយ គឺជាមនុស្សដែលត្រូវរួមការងារជាមួយម៉ានីននិងម៉ានុត ។ ដោយសារភាគហ៊ុនរបស់ពិសិដ្ឋនិងម្តាយមានចំណែកដល់ទៅពីរភាគរយ ហើយភាគហ៊ុនរបស់លោកម៉ាណោមានតែមួយភាគ ទើបពួកគេសម្រេចដាក់ឈ្មោះ

ធនាគារនេះថា ជាធនាគាររំចង់ដែលឈ្មោះម្តាយពិសិដ្ឋ ។ ទាំងពិសិដ្ឋនិងបងប្អូនរបស់ម៉ានីន សុទ្ធសឹងតែបានបញ្ចប់ការសិក្សាពីបរទេស ។ ម៉ានីទនិងម៉ានុតជាយុវជនយុវនារីដែលមានសន្តានចិត្តល្អ មិនចេះឆ្មើងឆ្មៃដូចជាពិសិដ្ឋដែរ ។ ប៉ុន្តែសម្រាប់ម៉ានុត កំលោះជាមនុស្សមាត់ដាចបន្តិច ប្រសិនបើមានអ្នកណាធ្វើអ្វីខុសនៅចំពោះមុខរបស់គេ គេប្រាកដជាមិនទុកមុខឱ្យអ្នកនោះឡើយ គេមុខជានិយាយបន្ទោសអ្នកនោះដោយចំហតែម្តង ។ ស្រីម៉ានីនមានចរិតស្លូតបូតនិងរួសរាយ នាងបានលួចស្រឡាញ់បងជីទូតមួយពិសិដ្ឋដោយសម្ងាត់ តែពិសិដ្ឋមិនបានដឹងខ្លួនទេ អ្នកប្រុសទុកនាងត្រឹមតែប្អូនស្រីមួយរូប ។

កាលបើត្រូវម៉ានុតសួរនូវសំណួរដែលពាក់ពន្ធ័នឹងការងារ ដែលពិសិដ្ឋត្រូវធ្វើដើម្បីរកភាពយុត្តិធម៌ជូនលោកយាយមាសនោះ យុវជនញញឹមបន្តិចឆ្លើយតបទៅម៉ានុត :

-ពិតមែនហើយប្អូនម៉ានុត បងនឹងទៅធ្វើកិច្ចការមួយ ហើយការងារនៅធនាគារនេះ បងនឹងប្រគល់ដល់ប្អូនម៉ានុតឱ្យទទួលខុសត្រូវជាមួយអ្នកម៉ាក់បង គឺចាប់ពីថ្ងៃស្អែកនេះតែម្តងនិងបន្ទាប់ពីបងរៀបរយការងារនៅថ្ងៃនេះទុកឱ្យប្អូនសិន។

-បងសិដ្ឋទៅធ្វើការអី ? ហើយទៅធ្វើនៅទីណា ? " ម៉ានីន "

ពិសិដ្ឋញញឹមស្រដី ទាំងមើលមុខម៉ានីន :

-បងសុំលាក់ការសិនណ៎ាអូននីន ។

ម៉ានីទធ្វើមុខងរង៉ក់ សួរពិសិដ្ឋបន្ត :

-ជាការងារអីហ្នឹង ទើបបងសិដ្ឋត្រូវលាក់ការនោះ ?

ម៉ានុតយកដៃអង្អែលក្បាលប្អូនស្រី ពោល :

-អូនទីន មនុស្សយើងម្នាក់ៗតែងតែមានរឿងផ្ទាល់ខ្លួនមិនខាន កុំរំខានបងសិដ្ឋ ។

ម៉ានីងញុញឹម បែរមកមើលមុខពិសិដ្ឋ នាងស្រដី :

-ឱ្យខ្ញុំសុំទោសណាំបងសិដ្ឋ ។

-មិនអីទេ បងអត់មានទោសឱ្យអូនទីនផង ។ ម៉ោះ! នាំគ្នាចូលបន្ទប់បងមក ព្រោះបងមានកាដូ មកពីបរទេសសម្រាប់ពួកយើងទាំងពីរនាក់ ។

ពោលចប់ ពិសិដ្ឋក៏រុញទ្វារបន្ទប់ធ្វើការរបស់គេ ហើយនរៈដើរចូលទៅខាងក្នុង ម៉ានុតនិងម៉ានីនដើរតាមក្រោយកំលោះយើង ។

ក្នុងបន្ទប់កំលោះម្ចាស់ធនាគាររំចង់ យើងឃើញដៃពិសិដ្ឋលូកហុចប្រអប់កាដូទៅឱ្យម៉ានីន ។ ម៉ានីនទទួលកាដូ នាងញញឹមយ៉ាងស្រស់ និយាយទៅកាន់ពិសិដ្ឋ :

-ខ្ញុំអាចបើកមើលវានៅទីនេះណាំបង ។

ពិសិដ្ឋងក់ក្បាល ។ ម៉ានីនបើកកាដូ ឃើញខ្សែកតូចឆ្មាមួយខ្សែ នាងលើកខ្សែកមកមើល ស្រដីទាំងភ្លង់នេត្រាទៅចំមុខពិសិដ្ឋ :

-អរគុណបងសិដ្ឋ ខ្ញុំស្រឡាញ់វាណាស់ ។

-បងឃើញវាស្អាត បងក៏នឹកដល់អូនទីន ហើយក៏ទិញមកផ្ញើអូនទីនណ៎ា ។

បន្ទាប់មក នរៈក៏ដកយកប្រអប់កាដូមួយ ហុចទៅម៉ានុត។ ម៉ានុតញញឹមទទួលរបស់មកកាន់ ពិសិដ្ឋបន្ថែវាចាទៅបងប្រុសម៉ានីន :

-បងឃើញកាបូបដាក់លុយនេះស្អាត ទើបបងទើបមកផ្ញើឯង ។ មិនដឹងជាប្អូនម៉ានុតពេញចិត្តដែរទេ ?

ម៉ានុតបើកប្រអប់កាដូ គេសម្លឹងកាបូបដាក់ប្រាក់ រួចគេបែរមុខមកពិសិដ្ឋ ញញឹម ស្រដី :

-ស្អាតតើបង ។ខ្ញុំពេញចិត្ត បងសិដ្ឋពូកែរើសរបស់មែន ។ អរគុណណាំបង ។

........................................................................................................................

........................................................................................................................

ឥឡូវយើងបែរមកមើលផ្ទះលោកតាសិទ្ធា ដែលនៅឯក្រុងកំពង់សោមវិញ យើងឃើញកញ្ញាសិទ្ធា នរលក្ខណ៍ កំពុងដកយកកញ្ចប់កាដូតូចមួយហុចឱ្យទារិកា ។ កញ្ញាទារិកាកំពុងមូរផ្ទាំងរូបគំនូរ នាងក៏ងាកមកទទួលកាដូពីនរលក្ខណ៍ ។ នរលក្ខណ៍ពោលវាចាទៅកាន់ទារិកា :

-នេះជាកាដូសម្រាប់ឯងណាំទារិកា ។

ទារិកាញញឹម ទទួលកាដូពីនរលក្ខណ៍ ទាំងនាងស្រដី :

-គ្នាអរគុណកាដូនេះ ហើយគ្នាសុំទោសជំនួសបងវេហាពីរឿងវិមានសិទ្ធាណាំលក្ខណ៍ ។

-មិនមានអ្វីជាបញ្ហាសម្រាប់ខ្ញុំទេ ពួកយើងជាបងប្អូនជីដូនមួយ មានអីទាស់ឆ្គងមិនត្រូវប្រកាន់ចំពោះគ្នានោះឡើយ ហើយម្យ៉ាងគ្នាចូលចិត្តអ្នកដែលនិយាយត្រង់ៗដូចបងវេហានិងយីហ៊ុប ។ គឺបើពួកគេមិនពេញចិត្តនឹងអ្វី ពួកគេក៏និយាយមកភ្លាម ។

-ដោយសារតែលក្ខណ៍ជាមនុស្សចិត្តទូលាយ ទើបខ្ញុំមិនសូវបារម្ភពីទង្វើបងវេហា ។ ឥឡូវខ្ញុំលាសិនហើយ ព្រោះខ្ញុំប្រញាប់ទៅតូរទេសភាពមាត់សមុទ្រនាពេលព្រឹកព្រលឹម ។

នរលក្ខណ៍ងក់ក្បាល ។ ទារិកាឱបផ្ទាំងគំនូរ ដើរចេញពីបន្ទប់នាង ដើម្បីយាត្រាទៅកាន់មាត់សមុទ្រ ក្នុងបំណងគូររូបទេសភាពនាព្រឹកព្រលឹម ដែលជាចំណូលចិត្តរបស់ស្រី ។ ទារិកាចាកចេញទៅ តែនរលក្ខណ៍នៅអង្គុយមើលឯកសារឯលើតុធ្វើការ ក្នុងបន្ទប់ធ្វើការរបស់ស្រី នៅក្នុងគេហដ្ឋាន ។ មួយខណៈកន្លងទៅ នាងសយជាស្រីបម្រើដើរមករកនរលក្ខណ៍ ទាំងសយនិយាយ :

-សុំទោសអ្នកនាងលក្ខណ៍ លោកប្រុសសេរីមកសុំជួបអ្នកនាងទារិកា តែខ្ញុំរកអ្នកនាងទារិកាមិនឃើញ ទើបមកជម្រាបសួរដល់អ្នកនាង ព្រោះលោកប្រុសទីពីរ លោកស្រីតារានិងអ្នកប្រុសវេហាមិនបាននៅផ្ទះទេ ។

-ចាំខ្ញុំទៅជួបសេរី ។ តើឥឡូវគាត់នៅទីណាបងសយ ?

-ចាស គាត់អញ្ជើញចាំក្នុងបន្ទប់ទទួលភ្ញៀវជាន់ទីមួយ ។

នរលក្ខណ៍បិទសៀវភៅបញ្ជី ទាំងឆ្លើយ :

-អរគុណ! បងសយទៅចុះ ចាំខ្ញុំទៅជួបសេរី ។

សេរីគឺជាយុវជនកំព្រាឪពុកម្ដាយ គេរស់នៅជាមួយឪពុកមាម្នាក់ ដែលជាអ្នកជំនួញធំមួយរូប ប៉ុន្តែកំលោះសេរីមិនចូលចិត្តកិច្ចការជំនួញរបស់ឪពុកមាទេ គេបានចូលបម្រើការងាររដ្ឋ ដោយធ្វើជានគរបាលនៅទីក្រុងព្រះសីហនុ ។ ជីវភាពរបស់សេរីមានភាពសមគួរដែរ គេមានរថយន្តមួយគ្រឿងជិះ ដែលឪពុកមាជាអ្នកទិញឱ្យ ។ ចំណែកប្រាក់កាសក្នុងការចាយវាយមួយចំនួន ក៏នរៈត្រូវបានការឧបត្ថម្ភពីឪពុកមាផងដែរ ព្រោះឪពុកមារបស់គេមិនមានកូនឡើយ គាត់ស្រឡាញ់បុរសទុកដូចជាកូនបង្កើត ។ កំលោះជាមនុស្សស្អប់អំពើពុករលួយ មានចរិតស្រឡាញ់ការងារ ហ៊ានពុះពារគ្រប់ឧបសគ្គក្នុងមុខនាទី គេជាមនុស្សដែលមាន

អាធ្យាស្រ័យល្អ ក្នុងការរាប់អានជាមួយអ្នកដទៃ ។ សេរី នរលក្ខណ៍និងទារិកាធ្លាប់ជាមិត្តរួមថ្នាក់ កាលពីរៀននៅវិទ្យាល័យ ។

នរលក្ខណ៍យាត្រានាំកាយសំដៅមកបន្ទប់ទទួលភ្ញៀវនាជាន់ទីមួយ ។ នៅពេលស្រស់ស្រីមកដល់ទីកន្លែងដែលសេរីអង្គុយ នាងក្រឡេកទៅឃើញយុវជនសេរីអង្គុយទល់មុខលោកស្រីតារា ។ ពេលនរលក្ខណ៍ដើរចូលមតរកសេរី នាងបានឮប្រយោគរបស់អ្នកស្រីតារានិយាយទៅកាន់អ្នកប្រុស :

-ក្មួយសេរីមករកកូនទារិកាមែនទេ ?

-បាទ ខ្ញុំមករកអ្នកនាងទារិកា ។ ចុះអ្នកមីងទើបតែអញ្ជើញមកពីទីណាព្រោះពេលមុននេះ បងសយប្រាប់ខ្ញុំថា អ្នកមីងមិននៅផ្ទះទេ ។

-គឺមុននេះ មីងនិងកូនវេហា ចេញទៅសណ្ឋាគារជាមួយប៉ារបស់កូនទារិកា តែជួនជាភ្លេចឯកសារ មីងក៏វិលមកយកវិញ តែនាងមឿនប្រាប់មីងថា ក្មួយមករកកូនទារិកា ទើបមីងចូលមករកក្មួយសិននេះ ។

នរលក្ខណ៍ដើរចូលមកដល់ នាងសំពះសេរី :

-ជម្រាបសួរសេរី ។

សេរីងាកមកឃើញនរលក្ខណ៍ គេសំពះតបនាង :

-បាទ ជម្រាបសួរលក្ខណ៍ នេះមកពីបរទេសពីអង្កាល់ហ្នឹង ទើបខ្ញុំមិនដឹងសោះ ។

-ចាស ខ្ញុំមកដល់ពីម្សិល ។

នរលក្ខណ៍បែរមកតារា នាងនិយាយទៅកាន់អ្នកស្រី :

-អំបាញ់មិញ ខ្ញុំស្មានតែមិនមាននរណាទៅជាមួយសេរី ទើបខ្ញុំមកទទួលគេ តែពេលនេះមានអ្នកមីងហើយ ខ្ញុំសុំដកខ្លួនសិន ។

តារាមុខក្រញូវ និយាយមិនមើលមុខនរលក្ខណ៍ :

-តែក្មួយមានដឹងថា កូនទារិកាទៅណាទេ ?

-ចាស ទារិកាទៅគូររូបនៅមាត់សមុទ្រ ។

-លក្ខណ៍អាចជូនខ្ញុំទៅរកទារិកាបានដែរទេ ?

កាលបើឮសេរីនិយាយរាក់ទាក់ទៅកាន់នរលក្ខណ៍ អ្នកស្រីតារាដែលមានអារម្មណ៍មួហ្មង ដោយក្នុងគំនិតគាត់គិតថា នរលក្ខណ៍មានចំណង់ចង់ទាក់ទងសេរីជាតួគាប់ ដ្បិតថាចិត្តអ្នកស្រីតារាចង់ភ្ជាប់និស្ស័យសេរីទៅនឹងកូនស្រីរបស់គាត់ គឺកញ្ញាទារិកា ។ ដូចនេះអ្នកស្រីតារាបានភ្ញង់នេត្រា សម្លឹងឥតព្រិចទៅកាន់ស្រីនរលក្ខណ៍ ស្រីល្អយល់ពីអារម្មណ៍របស់ម្ដាយមីងយ៉ាងច្បាស់ ហើយបេះដូងរបស់នាងក៏មិនដែលមានបំណងនឹងគិតដណ្ដើមកំលោះសេរី ពីទារិកាម្ដងណាដែរ ចិត្តនរលក្ខណ៍កំណត់សេរី គឺជាមិត្តល្អរបស់នាងតែប៉ុណ្ណោះ ។ កាលបើដឹងថា ម្ដាយមីងកំពុងតែមានភាពសង្ស័យមកលើនាង ពីទំនាក់ទំនងនាងនិងសេរី នរលក្ខណ៍ធ្វើជាមិនបានឃើញពីទឹកចិត្តម្ដាយមីង ដោយស្រីគេចពីក្រសែភ្នែកអ្នកស្រីតារា ហើយនាងបែរមកអ្នកប្រុសអធិការប៉ូលីស ដោយបន្ទី :

-ខ្ញុំសុំទោស ខ្ញុំមិនទំនេរទេសេរី ខ្ញុំជាប់ពិនិត្យបញ្ជីសណ្ឋាគារ ព្រោះមិនប៉ុន្មានថ្ងៃទៀតទេ ខ្ញុំត្រូវចូលធ្វើការនៅទីនោះហើយ ។ ខ្ញុំជម្រាបលាសេរីហើយ ។

នាងបែរមកសំពះតារា ស្រដីទៅកាន់អ្នកស្រី :

-អ្នកមីង! ខ្ញុំជម្រាបលា ។

-បាទ លក្ខណ៍ ។

តារាងក់ក្បាល នរលក្ខណ៍ដើរចេញទៅ ។ សេរីបែរមកសំពះតារា គេវាចាៈ

-ខ្ញុំជម្រាបលាអ្នកមីង ទៅតាមរកទារិកាហើយ ។

-អញ្ជើញចុះក្មួយ ។

សេរីបោះជំហានសំដៅទៅរកឡានរបស់គេ ហើយគេបញ្ជាយានតម្រង់ទៅរកមាត់សមុទ្រ ដែលជាទីកន្លែងមិនឆ្ងាយប៉ុន្មានពីផ្ទះស្រីល្អ ហើយក៏ជាទីកន្លែងដែលនាងចំណាំគូររូបនៅទីនោះដែរ ។ គ្រាដែលនរៈយាត្រាមកកាន់តែជិតទារិកា ភ្នែករបស់មាណពក្រឡេកទៅឃើញស្រីស្រស់កំពុងស្ងួងអារម្មណ៍ជាមួយរូបគំនូរ សេរីបានសម្រួលឥរិយាបទដើរយ៉ាងស្ងៀមស្ងាត់ជាមួយជំហានស្រាលៗ ដើម្បីចៀសវាងការរំខានឆោមស្រី ។ សេរីឈរនៅពីក្រោយទារិកា ក្នុងចម្ងាយប្រហែលមួយម៉ែត្រ ភ្នែកអ្នកប្រុសផ្ដោតទៅលើរូបគំនូរ ដែលកល្យាណកំពុងគូរ ។ គឺជារូបទេសភាពមាត់សមុទ្រនាពេលព្រឹកព្រលឹម ។ មួយសន្ទុះ ទារិកាងាកមកសម្លឹងសេរី ភ្ញាប់ដោយស្នាមញញឹម ស្រីវាចាសួរ :

-សេរីអផ្សុកទេ មកកំដរអ្នកគំនូរអាត្មានិយមដូចខ្ញុំ ។

សេរីសើច មើលមុខនាង :

-អផ្សុកតិចៗដែរ បើឈរចាំនាងគូរម្ដងណា ក៏យូរយ៉ាងនេះ ជួនកាលខ្ញុំរឹតែនិយាយរកនាង តែនឹកឃើញថា ខ្ញុំមករកនាងខុសពេលដោយខ្លួនឯង ទើបខ្ញុំខំទ្រាំចាំនាងជាបន្ត ដោយមិនហ៊ានមាត់ មិនហ៊ានស្ដីណា ។

ទារិកាសើច ទាំងរើផ្ទាំងគំនូរផង និយាយមកកាន់សេរីផង :

-សុំទោសណាំសេរី ខ្ញុំនេះព្រហើនដោយទុកឱ្យសេរីឈរចាំយ៉ាងនេះ តែខ្ញុំព្រហើនដោយសារតែជាមួយសេរីជាមិត្តល្អរបស់ខ្ញុំដែរ បើជាមួយមនុស្សដទៃ ខ្ញុំមិនហ៊ានធ្វើបែបនេះទេ ។

មាណវីរីប្រដាប់គូររូប សេរីជួយកាន់ផ្ទាំងគំនូរនាង ឯធីតាកាន់ជក់និងប្រដាប់ដាក់ជក់ ទាំងនាងនិយាយ :

-តោះ! យើងទៅញ៉ាំអាហារពេលព្រឹក នៅកន្លែងដដែលជាមួយគ្នាណា ។

-បាទ ល្អណាស់ ខ្ញុំមកនេះប្រុងអញ្ជើញនាងទៅញ៉ាំអាហារពេលព្រឹកហ្នឹងហើយ ។

-ខ្ញុំដឹងតើ ទើបខ្ញុំនិយាយមុន ដើម្បីឱ្យមានប្រៀបជាងសេរីនោះណា ។

នាងសើច សេរីក៏សើច...ជាសំណើចដែលហាក់ដូចជាមានការយល់ចិត្តគ្នា។ គេទាំងពីរដើរទៅរកឡានរបស់សេរី ដែលចតនៅមិនឆ្ងាយប៉ុន្មានពីទីនេះ ។ មិនដល់ដប់ប្រាំនាទីផង រថយន្តបាននាំគេទាំងពីរ មកដល់ភោជនីយដ្ឋាន ដែលពួកគេតែងតែណាត់ជួបគ្នា ។ បន្ទាប់ពីសម្រួលឥរិយាបទអង្គុយលើកៅអីមក ប្រយោគដំបូងបានលាន់ចេញពីបបូរមាត់ប្រុសកំលោះ :

-ខ្ញុំឃើញកាសែតសរសេរពីការប្រកាសរបស់លោកតានាង ដែលគាត់ប្រគល់ផ្ទះសិទ្ធាឱ្យនរលក្ខណ៍ ខ្ញុំមិនដឹងថា គ្រួសារទារិកានឹងត្រូវផ្លាស់ទៅរស់នៅជាមួយគ្រួសារលក្ខណ៍ឯភ្នំពេញក្នុងវិមានសិទ្ធា ឬ អត់ ?

-គ្រួសារខ្ញុំក៏ទៅរស់នៅឯភ្នំពេញជាមួយគ្រួសារលក្ខណ៍ដែរ ។

-អ៊ីចឹងខ្ញុំប្រហែលជាត្រូវរត់ការទៅធ្វើការនៅភ្នំពេញដែរហើយ ។

ទារិកាមានភក្ត្រជិតដាមដោយការងឿងឆ្ងល់ នាងសួរកំលោះ :

-ហេតុអីទៅសេរី ?

-គឺខ្ញុំទៅតាមការពារទារិកាហ្នឹងណា៎ ។ " សេរីនិយាយទាំងសើចរបៀបលេងបន្តិច របៀបមែនបន្តិច "

-តែខ្ញុំធំហើយណា៎ មិនចាំបាច់មាននរណាតាមការពារខ្ញុំទេ ។ " ទារិកានិយាយទាំងសើច បែបលលេង តបទៅសេរីវិញ "

-យើងជាមិត្តរួមថ្នាក់កាលពីមធ្យមសិក្សាមែន ? ហើយកន្លងមក យើងត្រូវតែរាប់អាននិងការពារគ្នានោះអី ។

-តាមចិត្តសេរីចុះ អូ! សេរីមានដឹងថា លក្ខណ៍មកពីបរទេសទេ ?

-ខ្ញុំបានជួបគេហើយ លក្ខណ៍នៅតែដដែល ដូចកាលពីប្រាំឆ្នាំមុនដែលគេរៀនជាមួយពួកយើង គឺគេជាមនុស្សនិយាយត្រង់ៗនោះឯង ។

-លក្ខណ៍តែអ៊ីចឹង នាងនិងខ្ញុំមានអាយុស្រករគ្នា តែកាលពួកយើងទៅរៀននៅបរទេស ខ្ញុំរៀនជំនាញខុសពីនាង ទើបខ្ញុំត្រូវត្រឡប់មកស្រុកខ្មែរមុននាង។ អូ! ខ្ញុំភ្លេចប្រាប់សេរី ខ្ញុំសុំលោកតាបើកហាងលក់គំនូរនៅភ្នំពេញបានហើយ ។

-អ៊ីចឹងទារិកាសប្បាយចិត្តខ្លាំងហើយ ដែលនាងបានដូចបំណង តែខ្ញុំឯណោះវិញ ខ្ញុំមិនទាន់បានដូចបំណងទាល់តែសោះ ។ " មុខសេរីស្ងួត "

ទារិកាមានទឹកមុខឆ្ងល់ នាងបន្លឺសួរសេរី :

-សេរីនៅខ្វះអីទៀតដែលមិនដូចបំណង ក្រែងធ្វើជាប៉ូលីសនេះ ជាបំណងប្រាថ្នាតាំងពីតូចរបស់សេរីអេះ ?

មុខសេរីលេចនូវសញ្ញាវិះគិត គេបន្លឺហាក់ដូចជាមិនចំពោះថា តើគេនិយាយទៅកាន់ទារិកា ឬ និយាយម្នាក់ឯង :

-មែន ! ខ្ញុំបានធ្វើប៉ូលីសហើយ ។

ការពិត អ្វីដែលកំលោះនិយាយក្នុងន័យថា គេមិនបានសម្រេចដូចបំណងនោះគឺជាបញ្ហាផ្លូវចិត្តដែលគេលួចប៉ងប្រាថ្នាទៅលើទារិកាសោះ ។ លុះត្រូវស្រីឆ្មើមបង្វែរបញ្ហាមកកាន់រឿងការងារទៅវិញ ធ្វើឱ្យនរៈស្រងល់ក្នុងចិត្តលែងហ៊ានហាស្តីពីអ្វីដែលកប់ក្នុងបេះដូងជាបន្តទៀត ។ យល់ថា ទារិកាហាក់ដូចជាមិនដឹង មិនយល់ពីចិត្តខ្លួន សេរីចាំបាច់បន្ទប់បេះដូងពុះកញ្ជ្រោល ដោយបង្វិលសភាពការណ៍ទៅរករឿងផ្សេងទៅវិញ ។ បុរសយើងបានបន្លឺជាបន្តទៀត :

-ទារិកាត្រូវទុកនាទីឱ្យខ្ញុំជាអ្នកបាវនាង នៅថ្ងៃនេះណ៎ា ។

-ចាស យល់ព្រម ។

ជួនជាអ្នកបម្រើក៏លើកគុយទាវមកដល់ល្មម គេទាំងពីរក៏នាំគ្នាបរិភោគជាមួយការកសាងសង ក្នុងលក្ខណៈជាមិត្តភាព ។

# វគ្គទី ៥

យប់នេះ ជារាត្រីទីមួយដែលមនុស្សក្នុងគ្រួសារលោកឧកញ៉ាសិទ្ធា បានចូលមករស់នៅក្នុងភូមិគ្រឹះសិទ្ធា ដែលទើបនឹងជួសជុលរួច ។ អធាត្រម៉ោងដប់ពីរយប់ ស្នូរនាឡិកាទើបតែនឹងបន្លឺដប់ពីរអន្លូងចប់ ភាពស្ងាត់ជ្រងំគ្របដណ្ដប់ភូមិគ្រឹះដ៏ធំជង្រ្គាងនេះ ឱ្យកាន់តែស្ងប់ស្ងាត់ក្នុងភាពខ្មៅងងឹតនៃរាត្រីកាល ។ ដើមជម្ពូដើមស្វាយ ដែលមុននេះបន្តិច ឈរស្ងៀមគ្មានកម្រើកសូម្បីស្លឹកមួយណានោះ ស្រាប់តែពេលនេះ សន្ធឹកខ្យល់បក់មកយ៉ាងខ្លាំង បណ្ដាលឱ្យរំជួយញ័រអស់ទាំងតួដើមរុក្ខជាតិទាំងពីរ ឱ្យរេទៅរេមក ប្រៀបដូចជាមាននរណាមកចាប់អង្រួនយ៉ាងខ្លាំង ស្លឹកស្វាយនិងស្លឹកជម្ពូទង្គិចគ្នា លាន់ស្នូរគ្រលួចដូចសំឡេងស្រីស្រែកយំកណ្ដាលយប់ស្ងាត់ ស្ដាប់ទៅគួរឱ្យព្រឺក្បាលសំពោង ។ ដុំភ្លើងមួយដុំហោះចេញពីមែកស្វាយកាត់ពីលើដើមជម្ពូ បោះពួយតម្រង់ឆ្ពោះទៅកាន់បន្ទប់របស់អ្នកស្រីសូគាអមដោយស្នូរសំឡេងយ៉ាងគ្រលួចដូចមនុស្សស្រីស្រែកយំអណ្ដឺតអណ្ដក ទៅជាមួយផង ។ ដុំភ្លើងហោះមកដល់ចុងជើងអ្នកស្រីសូគានិងកញ្ញាយីហ៊ុប ស្នូរស្រែកយំក៏រលត់បាត់ ហើយដុំភ្លើងនោះ ក៏ប្រែក្លាយទៅជារូបលោកយាយមាស ដល់ទៅពីរនាក់ដែលមានសភាពដូចជាស្រីក្រមុំមានវ័យ២៧ឆ្នាំ ។ ខ្មោចយាយមាសទាំងពីរនេះរំកិលយ៉ាងលឿនស្លេវ តម្រង់ទៅរកសូគានិងយីហ៊ុប ។ ដៃយាយមាសទីមួយលូកទាញជើងសូគាអូសពីគ្រែទម្លាក់មកលើឥដ្ឋ ដៃខ្មោចយាយមាសទីពីរលូកអូសទាញកញ្ញាយីហ៊ុបទម្លាក់មកលើឥដ្ឋដែរ ។ បិសាចស្រីទាំងទ្វេបំពងសំឡេងលាន់គ្រលួចជាសំណើចអង្រួនដាស់ម្ចាស់បន្ទប់ទាំងពីរនាក់ ឱ្យស្វាងពីដំណេក ។ សូគាបើកភ្នែក

មើលមកឃើញខ្មោចយាយមាសទីមួយកំពុងចាប់អូសគាត់ទម្លាក់គ្រែ ជាមួយនឹងសំណើចលាន់គួរឱ្យព្រឺក្បាល អ្នកស្រីសួគ៌ាមួម៉ៅជាខ្លាំង ដោយគិតថា ខ្មោចយាយមាសជាមនុស្សធម្មតា ដែលមករំខានដំណេកគាត់ ទើបអ្នកស្រីស្រែកគំហក :

-នែ! នាងនេះមកពីណា មកទាញយើង ។

ខ្មោចយាយមាសទីមួយសើចកាន់តែខ្លាំងជាងមុន ទាំងកន្ត្រាក់ទាញអូសសួគ៌ាទាល់តែធ្លាក់ផុតពីលើគ្រែ ហើយស្រែកខ្លាំងៗថា :

-ហាស់ហាស់ កុំចង់បានផ្ទះយើង ហាស់ហាស់ កុំចង់បានផ្ទះយើង ហាស់ហាស់ ។

សួគ៌ាណាមួយខឹងដោយសារឈឺខ្លួនដែលត្រូវបោកទៅលើឥដ្ឋ ណាមួយម៉ៅដែលស្រីចម្លែកម្នាក់មកស្រែកថ្ងូរស្រែកយំដោយមិនដឹងរឿង ដែលនាំឱ្យរំខានដល់ត្រចៀកគាត់ សួគ៌ាហាមាត់ប្រុងស្រែកជេរទៅកាន់ខ្មោចយាយមាស តែមាត់អ្នកស្រីធ្លាស់ឆ្អើមនេះ បែរជាត្រូវបិតនៅក្នុងសភាពហាជម្រូងដោយការភ័យខ្លាច ព្រោះភាពរូបកាយរបស់ខ្មោចលោកយាយមាស ក្នុងភាពជាមនុស្សបានក្លាយទៅជាបិសាចស្រីដែលមានសក់រតេរតាយ មុខស្លេកស្លាំង ជាមួយនឹងខោអាវសសំពោង តាំងពីលើដល់ក្រោម វែងអូសដី ព្រមដោយសំឡេងខ្លាំងៗ ឡើងរង្គើអស់ផ្ទៃបន្ទប់ទាំងមូល :

-ហាស់ ហាស់ កុំចង់បានផ្ទះយើង ហាស់ហាស់ ។

ឯគ្រែម្ខាងឯណោះ ខ្មោចយាយមាសទីពីរក៏បញ្ចេញរឹទ្ធិ លងបន្លាចកញ្ញាយីហ៊ុប ដែលកំពុងដេកញ័ររន្ធត់នៅលើឥដ្ឋ ព្រោះត្រូវបិសាចទាញទម្លាក់ស្របពេលខ្មោចទីមួយអូសម្តាយនាងមកលើឥដ្ឋដែរ ។ បិសាចស្រីទីពីរក៏បំពងសំឡេងសម្ដីញដាក់យីហ៊ុប ក្នុងអាការៈគំរាមបន្លាចនាង :

-ហាស់ ហាស់ កុំចង់ផ្ទះយើង ហាស់ហាស់ ។

កាលបើឃើញច្បាស់ថា រូបភាពដែលឋិតនៅខាងមុខ គឺជាព្រលឹងខ្មោច យីហ៊ុបក៏ដូចជាអ្នកស្រីសូតិា មានភាពភ័យរន្ធត់ ស្លុត ដោយពួកគេស្គុះរត់គេចពីបិសាច ។ យីហ៊ុបរត់ទៅរកម្ដាយ ម្ដាយរត់មករកនាង។ ចំណែកបិសាចទាំងពីររត់ដេញប្រកិត តាមស្រីទាំងពីរដែរ ។ យីហ៊ុបរត់ផងស្រែកផង ដោយការស្ទោស្ទន់ :

-ខ្មោច! ខ្មោច! ជួយខ្ញុំផង ខ្ញុំខ្លាចណាស់! ម៉ាក់ជួយខ្ញុំផង!

អ្នកស្រីសូតិាភ័យទាល់តែលេចនោម រត់មករកកូនស្រី ទាំងស្រែកដោយរន្ធត់ :

-ខ្មោច! អូយ! ខ្ញុំខ្លាចណាស់ កុំធ្វើបាបខ្ញុំ ។

ម្ដាយរត់មកជិតកូន កូនរត់ទៅកៀកម្ដាយ រួចទាំងពីរនាក់ស្រវាឱបគ្នា ។ ខ្មោចយាយមាសទាំងពីរឈរមើលទៅសូតិាទិងយីហ៊ុបឱបគ្នា ខ្មោចទាំងពីរស្រែកលាយសំណើចគួរឱ្យព្រឺក្បាល :

-ហាស់ ហាស់ កុំយកផ្ទះយើង ។

បន្ទាប់មក ដៃខ្មោចទីមួយលូកទាញយីហ៊ុប ។ដៃខ្មោចទីពីរលូកទាញសូតិា។ សូតិាភ័យស្ទើរបាត់ព្រលឹងពីប្រាណ អ្នកស្រីស្រែកឡើងភ្លាត់សំឡេង ទាំងកាយញ័រទទ្រើត ធ្មេញរណ្ដំលាន់ក្រឹកៗ :

-អូយ! កុំធ្វើបាបខ្ញុំ ។

រន្ធត់ តក់ស្លុត ញាប់ញ័រ...សូតិាដួលសន្លប់ ។ យីហ៊ុបតក់ស្លុត នាងខ្លាច នាងញ័រញាក់ លុះមកឃើញម្ដាយសន្លប់ នាងកាន់តែភិតភ័យ នាងស្រែកយ៉ាងខ្លាំង :

-អូយ! ខ្ញុំខ្លាចណាស់ ។

ស្រែកតែប៉ុណ្ណឹង យីហ៊ុបដួលសន្លប់ក្បែរម្ដាយ ។ បង្ហាញពីមហិទ្ធិឫទ្ធិកំញើញតំរាមស្មារតីអ្នកចង់បានផ្ទះសិទ្ធារួចហើយ ខ្មោចយាយមាសទាំងទ្វេក៏រលាយរូបចូលគ្នា ជារូបខ្មោចតែមួយបង្កើតសំនៀងយ៉ាងគ្រលួច ហោះវូចេញទៅ បាត់ស្រមោល។ ផ្ទៃបន្ទប់ទាំងមូលបែរជាឋិតក្នុងសភាពស្ងាត់ជ្រងំ បន្សល់តែម្ដាយនិងកូនស្រី ដេកសន្លប់ស្ដូកស្ដឹង ។

ក្នុងពេលជាមួយគ្នានេះ ពិសិដ្ឋកំពុងតែអង្គុយថ្វាយបង្គំព្រះពុទ្ធរូប ដែលតម្កល់លើក្បាលដំណេក ។ ស្រាប់តែនៅក្នុងអារម្មណ៍របស់អ្នកប្រុស បង្កើតជារូបភាពដែលលោកយាយតូចកំពុងតែលងធ្វើបាបយីហ៊ុបនិងអ្នកស្រីសូត៌ា មកយ៉ាងច្បាស់ ។ ពិសិដ្ឋរន្ធត់ ចំពោះរូបភាពលងបន្លាចដែលខ្មោចលោកយាយមាស បានធ្វើបាបយីហ៊ុបនិងម្ដាយនាង នរៈស្រែកខ្លាំងៗហាក់ដូចជាមានបំណងឃាត់លោកយាយតូចកុំឱ្យបញ្ចេញរិទ្ធិបារមីធ្វើបាបមនុស្ស :

-លោកយាយតូចកុំធ្វើបាបមនុស្សអី ចៅសូមអង្វរ កុំធ្វើបាបគេ ។

សំឡេងយាយមាសសើចលាន់ខ្ទាំងពេញក្នុងបន្ទប់ពិសិដ្ឋ ហាក់ដូចជាឆ្លើយតបមកកាន់ពិសិដ្ឋ :

-ហាស់ ហាស់ ហាស់ យើងធ្វើបាបវា យើងធ្វើបាបវា ហាស់ ហាស់ ។

ពិសិដ្ឋនៅតែអង្គុយបិទភ្នែក ដៃសំពះប្រណម្យថ្វាយបង្គំព្រះពុទ្ធរូបជាដដែល ។ សំឡេងខ្មោចយាយមាសលាន់តិចទៅៗ រហូតបាត់ឈឹង ។ ក្រោយពីព្រលឹងបិសាចបានរលាយបាត់ ពិសិដ្ឋបើកភ្នែក មុខស្លូត និយាយតែឯង :

-ខ្ញុំមិនយល់ ហេតុអីលោកយាយតូចលងធ្វើបាបមនុស្ស ។

បិសាចស្រីដែលពោរពេញដោយគំនុំនិងកំហឹង ហោះយ៉ាងលឿនស្លេវតម្រង់មកផ្ទះសិទ្ធាម្តងទៀត ។ សំឡេងគួរឱ្យភ័យខ្លាច បំពងលាន់ពេញអាកាស ។ ដុំភ្លើងបិសាចស្រីហោះសំដៅចូលទៅកាន់បន្ទប់របស់លោកជំនោរ និងអ្នកស្រីតារាម្តង ។ ដុំភ្លើងនេះក៏ក្លាយទៅជារូបយាយមាសក្នុងសភាពជាមនុស្ស ដូចគ្រាដែលគាត់លងបន្លាចអ្នកស្រីសូគានិងកញ្ញាយីហ៊ុបដែរ ។ ម្ចាស់បន្ទប់ទាំងពីរនាក់កំពុងលង់លក់នៅក្នុងដំណេក ។ បិសាចស្រីលើកដៃបង្កើតជាដុំភ្លើងសិល្ប៍ បាញ់វូ សំដៅទៅរកលោកជំនោរនិងអ្នកស្រីតារា ។ អនុភាពភ្លើងសិល្ប៍ដុតកំដៅគេទាំងពីរ ឱ្យភ្ញាក់ពីដំណេកយ៉ាងស្លោស្លន់ ។ អ្នកស្រីតារាស្រែកឡើងដោយការក្តៅរោលរាល :

-អូយ ស្អីហ្នឹង ក្តៅណាស់ ?

-អូយ ! ម៉េចក្តៅម្ល៉េះ ? " ជំនោរ "

-ហាស់ ហាស់ កុំយកផ្ទះយើង ហាស់ ហាស់ ។

សម្រែកបិសាច កន្ទ្រាក់ស្មារតីម្ចាស់បន្ទប់ទាំងពីរនាក់ ឱ្យងាកដោយស្វ័យប្រវត្តិសម្លឹងប្រភពសូរ ស្របពេលដែលដុំភ្លើងសិល្ប៍ក៏រលាយបាត់ល្មម ។ អ្វីដែលលោកជំនោរនិងអ្នកស្រីតារាបានឃើញ គឺជាមុខរបស់ខ្មោចយាយមាស ដែលលៀនអណ្តាតក្រហមឆ្អៅ វែងអូសដី ។ អណ្តាតបិសាចរំកិលយឺតៗមកជិតពួកគាត់ លោកជំនោរនិងអ្នកស្រីតារាតក់ស្លុតឧបមា គាត់ស្រឡាំងកាំង ស្រែកដោយការខ្លបខ្លាច :

-អូយ! ខ្មោច !

-យី! ខ្មោចលង !

ខ្មោចយាយមាសលូកដៃវែងអន្លាយ ដែលមានឈាមកក្លាក់ មករកអ្នកទាំងពីរ ហើយសំឡេងគ្រលួចញ៉ៀវៗដូចគេយំស្រែក លាន់ឡើងខ្ទរបន្ទប់ :

-ហាស់ ហាស់ កុំយកផ្ទះយើង ហាស់ ហាស់ ។

តារានិងជំនោរភ័យរបូតដួលសន្លប់ ។ ខ្មោចយាយមាសឈរសម្លឹងមើលឪពុកម្ដាយរបស់ទារិកាដែលដេកស្តូកស្តឹងនៅលើឥដ្ឋ បិសាចបន្ទរសំណើចរងឹក លាន់ដូចសំឡេងមច្ចុរាជ រួចរូបកាយបិសាចស្រីក៏រលាយបាត់សូន្យឈឹង ។

ដុំភ្លើងបិសាចហោះមកផុសឡើងនៅចំកណ្ដាលបន្ទប់របស់វេហា លេចចេញជាយាយមាសដែលមានសភាពដូចជាស្ត្រីក្រមុំរូបស្អាត ។ ខ្មោចស្រីក្នុងស្រោមជាមនុស្សស្រីរូបស្អាតសសៀវកាយទៅរកកំលោះម្ចាស់បន្ទប់ ទាំងលូកដៃមានម្រាមក្រចកស្រួចៗ ទៅអង្រួនដាស់វេហា ជាមួយសម្ដីស្រទន់ពិរោះ :

-ក្រោកឡើងបងសម្លាញ់ ។

វេហាភ្ញាក់ បើកភ្នែក គេឃើញស្រីក្រមុំរូបស្អាតនៅអង្គុយក្បែរកិតកាយគេ ជាមួយស្នាមញញឹមជាប់បបូរបបូរមាត់នាង បណ្ដាលឱ្យសម្រស់បិសាចលេចត្រដែតអង្រួនកាមារម្មណ៍កំលោះ។ ដោយទិស្ស័យជាប្រុសព្រានទារី វេហាញញឹមរាយសម្ដីមានអន្ទាក់ស្នេហ៍ មកកាន់ខ្មោចយាយមាស :

-អូនស្រីមកពីណា បានជាមករកបង ដល់បន្ទប់ ។

ខ្មោចយាយមាសបញ្ចេញឫកពាបែបរឹមអៀន ញញឹមរាយសំណាញ់ស្នេហ៍ វាចាផ្អែមល្ហែមមកកាន់បុរសព្រានតណ្ហា :

-ខ្ញុំមកយកផ្ទះ ។

វេហាឆ្លល់នឹងវាចានាង តែទោះជាគេមិនយល់ពីអត្ថន័យសម្ដីស្រីក្ដី ក៏ចរិតជាព្រានកំពូលតណ្ហា ធ្វើឱ្យគេខ្ជិលសួរនាំអ្វីច្រើនដល់នាង គេក៏ងើបអង្គុយខិតកាយ

ទៅកៀកកិតជិតខ្មោចយាយមាសក្នុងស្រោមក្រមុំរូបស្អាត ដោយវេហាបញ្ចេញឫកបែបព្រានទារី គេពោល :

-មករកបងហើយ មិនបាច់ទៅផ្ទះអូនទៀងណាទេ អូនស្អាតណាស់ ។

វេហាទាញយាយមាសមកឱប វេហាឱនទៅរកថើបមុខយាយមាស ដែលញញឹមស្រស់ជាមួយភាពក្អឹកក្អក់ ស្រាប់តែមុខយាយមាសស្លេកស្លាំង មានឈាមស្រក់កក្លាក់ លេចចេញអណ្តាតវែងអូសដី ភ្នែកលៀនវ័ត្តប៉ុនពងមាន់សម្លឹងខមដាក់គេ។ ភ្ញាក់សោយភ័យ វេហាស្រែកអស់សំឡេង :

-ខ្មោច! នាងជាខ្មោច !

វេហាច្រានខ្មោចយាយមាសចេញពីខ្លួនយ៉ាងប្រញាប់ប្រញាល់ តែខ្លួនខ្មោចបិសាចមិនកម្រើកសូម្បីបន្តិច ។ ប្រាណបិសាចនិងប្រាណវេហាជាប់ស្អិត ដូចគេបិទជ័រកាវ ។ វេហាស្ទើរបាត់ព្រលឹង ដៃតែដែលស្រវាឱបខ្មោច ក៏ជាប់ខ្លួនអសុរកាយ ។ ឈាមស្រក់ពីមុខបិសាច មកលើទ្រូងវេហា...ខ្លាច...ខ្ពើម...ភ័យ... ស្លុត...វេហាខំប្រឹងដកដៃ ប្រឹងកម្រើកកាយ តែឥតប្រយោជន៍ ដកមិនបាន ប្រាណមិនអាចឃ្លាតពីបិសាច ។ ខ្មោចយាយមាសសើចខ្លាំងៗ :

-ហាស់ ហាស់ យើងមកយកផ្ទះយើង ហាស់ ហាស់ កុំយកផ្ទះយើង ។

វេហាស្រែកទាំងញ័រញាក់ផងកាយទាំងមូល ដោយការភ័យ :

-លែង ! លែងដៃយើង ។ យើងខ្លាច លែងទៅ ។ លោកអើយមកជួយខ្ញុំផង ។

ខ្មោចយាយមាសបញ្ចេញសិល្ប៍ ធ្វើឱ្យដៃវេហារបូតពីខ្លួនបិសាច គ្រាន់តែដឹងថា ដៃនិងខ្លួនគេ បានរបូតពីស្រីអសុរកាយហើយ វេហាស្ទុះជើងពីរជើងបីបោល

សម្រុករត់ទៅរកទ្វារបន្ទប់ តែដៃខ្មោចយាយមាសមិនបានទុកឱកាសឱ្យគេ អាចគេចផុតកណ្តាប់ដៃឡើយ បិសាចលើកដៃបញ្ចេញភ្លើងហោះដូចផ្លេកបន្ទោរលោន់ឆ្វាច តម្រង់វេហា ។ ព្រាននារីងាកមកឃើញភ្លើងឆ្ពោះមករក គេស្លុតដូចឃើញសេចក្តីស្លាប់មកដល់ គេស្រែកភ្លាត់សំឡេង :

-អូយ! កុំធ្វើបាបយើង យើងខ្លាចណាស់ អូយ ។

វេហាដួលព្រួស សន្លប់បាត់មាត់ ។ បិសាចសើចរំពងបន្ទប់ ហោះលឿនស្លេវទៅបាត់ បន្សល់តែសំណើចយ៉ាងគួរព្រឺព្រួចក់សាច់ ។ ផ្ទៃបន្ទប់ក៏វិលមកក្នុងសភាពងងឹតស្ងួនស្ងប់ដូចពេលមុន ។

..............................................................................................................

..............................................................................................................

ព្រលឹមម៉ោងប្រាំមួយកន្លះ យើងឃើញនរលក្ខណ៍ដឹកដៃលោកតាសិទ្ធាដើរមើលផ្កាក្នុងសួន ។ ស្រស់ស្រីស្រដីទាំងញញឹម :

-លោកតា! យប់មិញសម្រាន្តស្រួលទេ ?

-យប់មិញជំងឺតាមិនធ្វើទុក្ខ តាលក់ស្រួលណាស់ចៅលក្ខណ៍ ។ នែ ! តាសួរចៅ តើចៅស្រឡាញ់ផ្ទះសិទ្ធាដែលតាបានជួលជុលថ្មីហើយនេះដែរទេ?

នរលក្ខណ៍លបគិតក្នុងចិត្ត : " ខ្ញុំមិនចង់បានផ្ទះនេះសោះ តែខ្ញុំមិនត្រូវនិយាយជំទាស់ចិត្តលោកតាទេ។ " គិតរួចនរលក្ខណ៍ញញឹម នាងមើលមកលោកតាដោយស្រីស្រដី :

-ចាស វិមានសិទ្ធាដែលជួសជុលរួចអ៊ីចឹង គឺស្អាតណាស់លោកតា ។ ចៅស្រឡាញ់ផ្ទះនេះ ហើយចៅអរគុណលោកតាដែលប្រគល់ផ្ទះនេះដល់ចៅ ។

-ព្រោះចៅជាក្មេងពូកែគួរឱ្យស្រឡាញ់ ទើបចៅត្រូវទទួលរង្វាន់ពីតា។ តាសប្បាយចិត្តដែលតាមានចៅរៀនពូកែ រូបស្អាតនិងចិត្តល្អយ៉ាងនេះ។ ចុះចៅមានដឹងដែរទេ តើចៅទារិកាទៅហាងតំនួររបស់គេហើយឬនៅចៅ ?

-ពេលចៅចេញមកកំដរលោកតា ទារិកាមិនទាន់ចេញទៅហាងទេ គេកំពុងរៀបចំផ្ទាំងគំនូរដើម្បីយកទៅហាងណាំលោកតា ។

-ចៅទារិកាក៏ជាក្មេងគួរឱ្យស្រឡាញ់ម្នាក់ដែរ មានតែចៅវេហានិងចៅយីហ៊ុប ដែលធ្វើឱ្យតាបារម្ភ ។ ថ្ងៃនេះចៅលក្ខណ៍មិនទៅសណ្ឋាគារទីបីទេអី ?

-ចាស ចៅទៅធ្វើការនៅម៉ោងប្រាំបីលោកតា តែពេលនេះទើបតែម៉ោងជិតប្រាំពីរណាំលោកតា ទើបចៅនៅកំដរលោកតាសិន ។

នរលក្ខណ៍កំដរលោកតាដើរទៅយកខ្យល់អាកាស នាពេលព្រលឹម ក្នុងសួនឧទ្យាន ។ ជីតានិងចៅសំណាញ់ដើរផង ជជែកគ្នាដោយភក្ត្រស្រស់ស្រាយទាំងទ្វេ ។ ជាក្តីសុខក្នុងចិត្តរបស់លោកឧកញ៉ាដែលមានចៅល្អ ដូចជាកញ្ញាទារិកានិងកញ្ញានរលក្ខណ៍ ហើយជាក្តីបារម្ភដែលលោកមានចៅប្រកបដោយទង្វើមិនគាប្បីដូចកញ្ញាយីហ៊ុបនិងវេហា។ នេះជាទឹកចិត្តរបស់អ្នកជាអាណាព្យាបាលទាំងឡាយក្នុងលោក។

នៅឯក្នុងវិមានសិទ្ធាឯណោះវិញ លោកស្រីតាវានិងលោកជំនោរ ស្លៀកពាក់របៀបចេញទៅធ្វើការ ដោយពួកគាត់ដើរចេញពីបន្ទប់ ក្នុងបំណងបម្រុងទៅធ្វើការ ។ លោកជំនោរបន្ទឺ :

-យប់មិញបងយល់សប្តិថា ខ្មោចស្រីម្នាក់មកលងបង ។

មុខតាវាភ្ញាក់ ងាកមកសួរបញ្ជាក់ប្តី :

-បងថាម៉េច! យប់មិញបងយល់សប្តិត្រូវខ្មោចលង ?

ជំនោរងក់ក្បាល តារាមុខធ្ងល់ និយាយ :

-តែខ្ញុំនេះក៏ត្រូវយល់សប្តិឃើញខ្មោចលងដែរណាំបង ។

ជាមួយការជជែក តារានិងជំនោរមកដល់មុខបន្ទប់វេហា ជូនជាកំលោះជាកូនច្បងដើរចេញពីបន្ទប់មកដែរ ។ ក្រឡេកឃើញបិតានិងមាតា នរៈស្រដីទៅកាន់ម្តាយឪពុក :

-ម៉ាក់ប៉ា ! យប់មិញ ខ្ញុំយល់សប្តិត្រូវខ្មោចលង ។ ស័យមែន ទើបតែមកគេងក្នុងវិមានសិទ្ធានៅយប់ដំបូង ខ្ញុំក៏យល់សប្តិឆ្កួតៗទៅហើយ ។

តារាមុខភ្ញាក់ សួរវេហា :

-កូនយល់សប្តិឃើញខ្មោចលង គឺខ្មោចស្រីមែនទេ ?

-បាទ ជាខ្មោចស្រី ។ អូយ! ខ្ញុំនៅខ្លាចមិនទាន់បាត់ផងម៉ាក់អើយ ។

តារាងាកមុខមើលប្តី ស្របពេលលោកជំនោរងើបមើលមកភរិយា កែវភ្នែកអ្នកទាំងពីរបោក់បង្ហាញពីអាការៈងឿងឆ្ងល់ ក្នុងចិត្តគេទាំងពីរក៏មិនប្រាកដថា តើកាលពីយប់មិញកន្លងមកនេះ អ្វីដែលជារូបភាពខ្មោចលង តើជារូបភាពពិត ឬមួយជាសុបិន ព្រោះថា ហេតុអ្វីក៏កំលោះជាកូនមានអារម្មណ៍យល់សប្តិថា ឃើញខ្មោចលងដូចជាពួកខ្លួនដែរ ។ កំពុងស្មុងនៅក្នុងគំនិតបែបនេះ ប្រយោគរបស់កំលោះវេហាបន្លឺមកកាន់ម្តាយឪពុក :

-ម៉ាក់ប៉ា ! មានការអីដែរហ្នឹង ?

-ម៉ាក់កំពុងថម្លែកក្នុងចិត្ត ព្រោះយប់មិញប៉ានិងម៉ាក់យល់សប្តិឃើញខ្មោចលងដែរ ។

ក្នុងពេលជាមួយគ្នា ទារិកាដើរមកដល់កៀកពួកគេទាំងបីនាក់ ដោយដៃស្រីកាន់ក្រដាសផ្ទាំងគំនូរនៅក្នុងដៃ ចំនួនពីរផ្ទាំង ។ ធីតាវាចាទាំងមុខញញឹម :

-តែខ្ញុំសំណាងល្អជាងគេ ព្រោះខ្ញុំអត់មានយល់សប្តិឃើញខ្មោចលងទេ ហើយខ្ញុំគេងលក់ស្រួលណាស់ គឺលក់ទល់ភ្លឺណា៎ម៉ាក់ប៉ា ។

តាវាងាកមើលទារិកា ទឹកមុខអ្នកស្រីបង្ហាញនូវអាការៈមិនសប្បាយចិត្ត ភ្ជាប់ប្រយោគទៅកាន់បុត្រី :

-កូនទៅបាងលក់គំនូរអ្ហេះ? នេះកូនមិនគិតទៅជួយធ្វើការនៅសណ្ឋាគារទីបីរបស់យើងមែនអ្ហេះ ?

-កូនសុំទោសម៉ាក់ កូនបានសុំលោកតាបើកបាងគំនូរតូចមួយហើយ កូនត្រូវទៅមើលបាងរបស់កូន កូនមិនទៅសណ្ឋាគារយើងទេ ព្រោះនៅទីនោះ មានអ្នកមីងសុធា បងវេហា នរលក្ខណ៍និងប្អូនឃីហ៊ុបជាអ្នកគ្រប់គ្រងហើយតើ ។ កូនជម្រាបលាហើយម៉ាក់ប៉ា ។

ទារិកាងាកខ្លួនដើរទៅម្ខាង លោកជំនោរមើលទៅនាង គាត់ពោល :

-ឈប់សិនទារិកា !

ទារិកាទុចជំហាន នាងងាកមកឪពុក ស្រីវាចាសួរបិតា :

-លោកប៉ាមានធុរៈអីជាមួយកូន ?

អាការៈគិតជិតដាមនៅលើផ្ទៃភក្ត្រលោកជំនោរ រួចលោកស្រាយទឹកមុខវិញ ទើបនិយាយទៅកាន់កូនស្រី :

-ល្អើយ! កូនទៅបាងគំនូររបស់កូនចុះ ។

ទារិកាញញឹម ផ្ដុំហត្ថាសំពះឪពុក រួចស្រីនិយាយ :

-កូនអរគុណលោកប៉ាដែលអនុញ្ញាតដល់កូន ដោយមិនឃាត់កូន មិនឱ្យទៅហាងតំនូរ ។

ទារិកាងាកមកសំពះម្ដាយ រួចនាងដើរតម្រង់ទៅរកទ្វារ ដើម្បីយាត្រាចេញទៅរកហាងតំនូររបស់នាង ដែលត្រូវបើកលក់នៅថ្ងៃនេះ ។ កាលបើបុត្រីចាកចេញទៅ អ្នកស្រីតារាបែរភក្ត្រមករកស្វាមី គាត់និយាយ :

-ហេតុអីបងមិនជួយរាំងកូន ព្រោះកូនគួរតែទៅជួយធ្វើការជាមួយកូនវេហា នៅក្នុងសណ្ឋាគារណ៎ាបង ដើម្បីកុំឱ្យពួកគេអាចមានប្រៀប លើកូនយើងទាំងពីរដែលមានភាគហ៊ុនក្នុងសណ្ឋាគារនោះអីបង ។

-តែបងស្គាល់កូនទារិកា គេមិនចង់ធ្វើអីហើយ យើងមិនគួរបង្ខំគេទេព្រោះយ៉ាងណាគេមិនសប្បាយចិត្តនឹងតាមយើងជាដដែល ហើយវេហាមិនល្ងង់ឱ្យពួកគេខ្សែលើបានដែរ មែនទេកូន ?

-បាទ លោកប៉ា ។

-ប៉ាទៅសណ្ឋាគារទីពីរហើយណ៎ា ឯងទៅសណ្ឋាគារទីបីចុះ ។

បើយើងបែរមកមើលក្នុងបន្ទប់កញ្ញាឃីហ៊ុបម្ដង ទុំហ្នំ កល្យាណកំពុងសិតសក់នៅមុខកញ្ចក់ ក្នុងសម្លៀកបំពាក់ស៊ិចស៊ី ។ ភ្នែកឃីហ៊ុបសម្លឹងទៅក្នុងភក្ត្រនាងដែលជិតនៅក្នុងកញ្ចក់ បបូរមាត់ស្រើកម្រើកវាចា ជាបទចម្រៀងរង់តិចៗ។ កៀកកាយស្រីល្អ គឺអ្នកស្រីសូគីសម្លឹងមកបុត្រី គាត់ស្រដីទាំងមុខស្ងួត :

-យប់មិញកូនពិតជាយល់សប្តិឃើញខ្មោចស្រីលង ដូចម៉ាក់មែនអេ្ហះ?

ឃីហ៊ុបត្រញ្ចៀងខ្លួនរបៀបខ្លាច និយាយ :

-ចាស មែនហើយម៉ាក់ ពេលកូនទឹកដល់យល់សប្តិកាលពីយប់មិញ កូននៅព្រឹសម្បុរមិនទាន់បាត់ផង ។

-តែយប់មិញនេះ ដូចជាមិនមែនយល់សប្តិទេ ដូចជាខ្មោចលងមែនៗ។

យីហ៊ុបលោបក្រែម ដោយនាងនិយាយមកកាន់ម្តាយផង :

-ម៉ាក់ហ្អា! យល់សប្តិ ឬ មែនទែន ម៉ាក់កុំរំលឹកពីរឿងខ្មោចហ្នឹងទៀតអី កូនមិនចង់រំខានអារម្មណ៍ទេ ព្រោះថ្ងៃនេះកូនមានណាត់ជាមួយមិត្តភក្តិផង ។

-ណាត់មិត្តស្រី ឬ មិត្តប្រុសកូនយីហ៊ុប ?

-មិត្តស្រី ឬ ប្រុស តើមានអីប្លែកនោះ បើមិត្តគឺជាមិត្តហ្នឹងហើយម៉ាក់។

-យីហ៊ុប ! លោកតាមិនចូលចិត្តឱ្យកូនធ្វើអីបែបបរទេសទេណ៎ា ម៉ាក់ចង់ឱ្យកូន...

យីហ៊ុបនិយាយកាត់វាចាម្តាយ :

-ម៉ាក់ចង់ឱ្យលោកតាស្រឡាញ់កូនអ្ហេះ ? គ្មានប្រយោជន៍ទេម៉ាក់ លោកតាមានចៅសំណព្វហើយ គឺបងលក្ខណ៍និងបងទារិកា ។ ឯខ្ញុំជាចៅកៀនជញ្ជាំងទេម៉ាក់អើយ ។

-ឯងអគតិនឹងលោកតាពេកទេដឹង ព្រោះលោកតាបានឱ្យឯងទៅធ្វើការនៅសណ្ឋាគារទីបី ជាមួយនាងលក្ខណ៍ រហែានិងម៉ាក់ដែរតើ ម៉េចក៏ឯងថា លោកតាមិនរវល់នឹងឯង ?

-គឺលោកតាមិនស្រឡាញ់ខ្ញុំ ព្រោះលោកតាក៏ដឹងថា ខ្ញុំរៀនមិនចប់ តែលោកតាបែរជារុញខ្ញុំឱ្យទៅទទួលការងារដែលខ្ញុំមិនអាចធ្វើបាន ឯបងទារិកាវិញ

គាត់មិនចូលចិត្តធ្វើការងារនៅសណ្ឋាគារ គាត់សុំលោកតាបើកហាងលក់រូបគំនូរ ហើយលោកតាក៏ព្រមតាមគាត់ភ្លែត ។

-ចុះកូនមានបំណងចង់ធ្វើអ្វី ? ម៉េចកូនមិនសាកសុំលោកតា ?

-កូនមិនសាកសុំលោកតាទេ ព្រោះយ៉ាងណាវាមិនបានឡើយ ។

-តែម៉ាក់មិនដែលដឹងទេ តើកូនចង់សុំអ្វីពីលោកតានោះ ?

-មនុស្សណាម៉ាក់ សុទ្ធតែមានបំណងផ្ទាល់ខ្លួន ហើយបំណងកូននោះ គឺជាសេរីភាពក្នុងការដើរលេង ដោយមិនចង់ធ្វើការងារអីទេ ។

-កូនចង់មានសេរីភាពដោយដើរលេង ហើយមិនធ្វើការងារអ្ហេះ ? កូនគិតឆ្កួតទេដឹង ?

-គិតឆ្កួតយ៉ាងម៉េចម៉ាក់ ? ទ្រព្យឧកញ៉ាដូចលោកតា មានជាសណ្ឋាគារធំៗដល់ទៅបី មានដីឡូតិ៍រាប់រយហិចតា មានលុយផ្ញើធនាគារក្នុងស្រុកផង ក្រៅស្រុកផង គ្រាន់តែចៅម្នាក់សុំដើរលេង មិនធ្វើការងារ ឱ្យវាស្រួលខួរក្បាល មិនអាចបានអ្ហេះម៉ាក់ ? ខ្ញុំជម្រាបលាហើយម៉ាក់ ព្រោះដល់ម៉ោងត្រូវណាត់ជាមួយមិត្តភក្តិ ។

ពេលវាចាចប់ យីហ៊ុបលូកដៃទាញយកកូនកាបូបដាក់ប្រាក់តូចមួយ រួចនាងលើកដៃគ្រវីលាម្តាយ ចាកចេញទៅបែបហ៊ី ។ សុគិតាមុខហួសចិត្ត អង្គុយស្មៀមតាមសម្លឹងរាងកាយបុត្រីពីក្រោយ ។

បើយើងបែរមកមើលកញ្ញាសិទ្ធា នរលក្ខណ៍ម្តង យើងឃើញនាងដឹកដៃលោកតាដើរដល់គុម្ពផ្កាណាគ្រី ។ មកដល់ទីនេះ អ្នកទាំងពីរបានជួបតាចាន់ជាអ្នកបម្រើចាស់មួយរូប ដែលមានអាយុ៧៣ឆ្នាំ តែគាត់មានរាងកាយរឹងប៉ឹងស្វាហាប់

មិនសមនឹងអាយុក្នុងវ័យជរារបស់គាត់សោះ ។ លោកឧកញ៉ាក្រឡេកឃើញអ្នកបម្រើចាស់ពីក្រោយ លោកក៏ស្រដី :

-ចាន់មែនទេ កំពុងបោចស្មៅ ?

តាចាន់ងើបឈរឱនគោរពលោកតា ទាំងគាត់និយាយ :

-បាទ ខ្ញុំបាទចាន់ ទានប្រោសលោកឧកញ៉ា ។

-នរណាប្រើចាន់ឱ្យមកបោចស្មៅហ្នា ?

-ទានប្រោស អត់មាននរណាប្រើខ្ញុំបាទទេ ។

-ពីថ្ងៃនេះទៅ ចាន់ឈប់ធ្វើការងារណា៎ ព្រោះឯងចាស់ហើយ ។

ស្រដីរួចលោកតាងាកមកនរលក្ខណ៍ និយាយទៅកាន់នាង :

-ចៅជាម្ចាស់ផ្ទះ ត្រូវឱ្យចាន់សម្រាកណា៎ ។

-ចៅបានឃាត់គាត់ដែរតើលោកតា តែតាចាន់មិនព្រមសោះ ។

-បាទអ្នកនាងតូចលក្ខណ៍ឃាត់ខ្ញុំបាទមែន តែខ្ញុំបាទអផ្សុក ទើបបោចស្មៅតិច១ តាមកម្លាំងទាន ។

-បើធ្វើដើម្បីកុំឱ្យអផ្សុក ឯងក៏ធ្វើចុះណា៎ចាន់ ។

នាងសយដែលជាស្រីបំរើដើរឱន១ដោយកាយវិការគោរព ចូលមករកលោកតានិងនរលក្ខណ៍ ។ ពេលមកក្បែរម្ចាស់ផ្ទះ អ្នកបម្រើនិយាយទាំងលុតជង្គង់ពីមុខលោកតា :

-ជម្រាបលោកឧកញ៉ានិងអ្នកនាងលក្ខណ៍ មានប្រុសម្នាក់មកសុំការងារធ្វើ ក្នុងផ្ទះយើង ។

នរលក្ខណ៍មុខឆ្ងល់ សួរទៅនាងសយ :

-តែផ្ទះយើងអត់មានត្រូវការមនុស្សធ្វើការទេបងសយ បងឱ្យគេទៅវិញចុះ ។

-ឈប់សយ ឯងទៅនាំគេចូលមក យើងមានការងារឱ្យគេធ្វើ ។ " លោកតាស្រដី "

-ចាស លោកឧកញ៉ា ។

នៅពេលនាងសយដើរចេញទៅ លោកតាងាកមកនរលក្ខណ៍ លោកវាចា :

-តាគិតថា ទឹងរកអ្នកបើកឡានជូនចៅនិងចៅឃីហ៊ុបទៅធ្វើការនៅឯធនាគារ ហើយតាក៏ត្រូវរកអ្នកបើកឡានសម្រាប់ចៅមារិកាដែរ ។

នៅក្បែរមាត់ទ្វាររបង សយនិងពិសិដ្ឋកំពុងបោះជំហានមករកលោកតានិងចៅស្រី ជូនជាភ្នែកពិសិដ្ឋងាកទៅឃើញនរលក្ខណ៍ កំលោះមានអារម្មណ៍ភ្ញាក់យ៉ាងខ្លាំង ព្រោះស្រីដែលគេតែងតែយល់សុបិនឃើញ កំពុងប្រាកដនៅចំពោះមុខគេ ។សម្រស់នារីក្នុងសុបិនដែលឋិតនៅចំពោះមុខអ្នកប្រុស មានភាពស្អាតស្រស់ជាជាងនៅក្នុងការយល់សប្តិរបស់គេទៅទៀត ។ គំនិតពិសិដ្ឋពោរពេញទៅដោយភាពរំភើបត្រេកអរ ដោយរកឃើញនារីដែលខ្លួនលួចប្រាថ្នា ដែលកន្លងមក គេមិននឹកស្មានថា ស្រីដែលថ្កក់បេះដូងរបស់គេ មានរូបពិតនៅលើលោកនេះសោះ ។ ប៉ុន្តែកាលបើគេដឹងថា នារីម្ចាស់ចិត្ត គឺជាចៅស្រីរបស់ត្រកូលជាសត្រូវរបស់លោកយាយតូច ដែលប្រមុខគ្រួសារនេះ ជាអ្នកបានធ្វើនូវអំពើអយុត្តិធម៌មកលើលោកយាយមាស កំហឹងក៏ផុសមកពេញបេះដូងជាមួយឈាមតំនុំដ៏ច្រាលមកលើផ្ទៃមុខនរៈ ។ ជំហាននាំកាយអ្នកកំលោះយាត្រាតាមស្រីបម្រើ ដោយដក់ជាប់នូវការក្រេវក្រោធ

យកទៅជាមួយ ។ នៅពេលដែលពិសិដ្ឋនិងនាងសយមកដល់ជិតម្ចាស់ផ្ទះសិទ្ធា នាងសយនិងអ្នកប្រុសក៏លុតជង្គង់នៅពីមុខលោកតា ហើយសយស្រដី :

-លោកឧកញ៉ា គឺអ្នកកំលោះនេះហើយទានប្រោស ដែលមកសុំការងារធ្វើទានប្រោស ។

លោកតាឧកញ៉ាធ្វើដៃជាសញ្ញាឱ្យនាងសយទៅក្នុងផ្ទះវិញ រួចលោកតាមើលមកពិសិដ្ឋ ដោយលោកសួរទៅកាន់គេ :

-អ្នកឈ្មោះអី ?

ពិសិដ្ឋឱនមុខ ធ្វើអាការៈបាក់ដូចជាខ្លាចអំណាចរបស់លោកឧកញ៉ា បុរសពោល :

-បាទទាន ខ្ញុំបាទឈ្មោះក្លាម ។

នរលក្ខណ៍មើលមុខពិសិដ្ឋ នាងយល់ថា យុវជនម្នាក់នេះមានសាច់ឈាមស្រស់បស់ មិនសមជាមនុស្សដែលរស់នៅក្នុងត្រកូលខ្សត់ខ្សោយនោះឡើយ សូម្បីតែមុខមាត់របស់នរៈក៏មានភាពស្រស់សង្ហាដែរ ដូច្នេះកាលបើឮមាណពបន្លឺឈ្មោះរបស់គេ អារម្មណ៍របស់ធីតាលេចជាសំណួរក្នុងចិត្តឡើងថា : "ឈ្មោះក្លាម ! ឈ្មោះនេះមិនសមនឹងរូបរាងទេ។"

-ឈ្មោះមិនសមរូបមនុស្សសោះ ? "លោកតាពោលទាំងញញឹម"

-បាទ តែជាឈ្មោះដែលពុកម៉ែខ្ញុំបាទដាក់ឱ្យមកទាន ។

-ពីមុនអ្នកធ្លាប់បើកឡានដែរទេ ?

-បាទ ធ្លាប់បើកឱ្យជនបរទេសទៀតផងទាន ។

-អ្នកមានបណ្ណបើកបរដែរទេ ?

-ពីមុនខ្ញុំបាទមានបណ្ណបើកបរដែរទាន តែជាអកុសល កាលពីខែមុន ភ្លើងឆេះខ្ទមខ្ញុំបាទ ហើយក៏ឆេះដោយទាំងបណ្ណបើកបររបស់ខ្ញុំបាទផង ។

-អូ! ក្រហើយជួបរឿងកម្សត់ទៀតហ្ន៎។ ល្អើយ! យើងឱ្យក្ដាមឯងបើកឡានផ្ទាល់ខ្លួនរបស់ចៅស្រីយើងពីរនាក់ណា ។

ពិសិដ្ឋមុខញញឹមទាំងផ្តុំហត្ថាសំពះលោកតា ទើបនរៈស្រដី :

-ខ្ញុំបាទសុំអរគុណ ។

លោកតាងក់ក្បាលទទួលការអរគុណពីពិសិដ្ឋ ។ រួចលោកឧកញ៉ាងាកមកនរលក្ខណ៍ ទាំងលោកពោលទៅកាន់នាង :

-ចៅលក្ខណ៍ឱ្យក្ដាមសាកល្បងថ្ងៃនេះចុះ ហើយចៅដល់ពេលទៅធ្វើការហើយនឹង ? រួចសឹមចៅឱ្យគេទៅប្រឡងយកបណ្ណបើកបរ

នរលក្ខណ៍មើលនាឡិកានៅដៃ នាងញញឹមភ្ជាប់វាចា :

-ចាស ម៉ោងជិតប្រាំបីល្មមលោកតា ចៅជូនលោកតាចូលបន្ទប់វិញ ។

នាងងាកមកពិសិដ្ឋ និយាយទៅកាន់គេ :

-នែ! នាយក្ដាមទៅយកឡានពីរោងឡាន ចេញមកចាំខ្ញុំណា ។

ពិសិដ្ឋសួរនរលក្ខណ៍ទាំងមុខឆ្ងល់ :

-អ្នកនាង! តើរោងឡាននៅទីណា ?

តាចាន់ដែលនៅក្បែរនោះក៏ងាកមកពិសិដ្ឋហើយនិយាយទៅកាន់កំលោះ:

-ក្ដាមមកតាមតាមក៍ ។ តានឹងនាំឯងទៅរោងឡាន ។

នរលក្ខណ៍ញញឹមមើលតាចាន់ ទាំងនាងវាចា :

-អរគុណតាចាន់ ដែលតាជួយនាំនាយក្ដាមទៅកាន់រោងឡាន ។

ស្នាមញញឹមដែលជិតដាមលើផ្ទៃភក្ត្រាស្រស់ស្រីនរលក្ខណ៍ ប្រៀបដូចជាមេដែកដែលឆក់ស្រូបទាញខ្សែនេត្រារបស់កំលោះម្ចាស់ធនាគារឱ្យភ្លង់ឥតដក ពីផ្ទៃមុខដ៏ស្រស់ចិញ្ចាចរបស់ធីតា ចរន្តគំនិតរបស់គេលបកើតនៅក្នុងខួរក្បាល ជាប្រយោគដែលមានន័យ :

-នាងញញឹមស្រស់ណាស់ តែនាងជាចៅសត្រូវរបស់លោកយាយតូច ។

ពិសិដ្ឋត្រូវដាច់គំនិតស្រមើស្រមៃ ដែលលង់ដោយសម្រស់ស្រស់ស្រីដោយសារតែសម្ដីតាចាន់ដែលឆ្លើយទៅកាន់នរលក្ខណ៍ :

-បាទ អ្នកនាងលក្ខណ៍ ។

សម្រាប់ធីតាវិញ ក្រោយពីអរគុណដល់អ្នកបម្រើចាស់រួចហើយ ស្រីនរលក្ខណ៍ទប់គ្រាហ៍លោកតាដើរសំដៅទៅភូមិគ្រឹះសិទ្ធា ។ ដំណើរញ៉ៀងញ៉ាង ផ្សំដោយរូបរាងស្រឡូន ជាមួយនឹងសរសៃសក់ដែលធ្លាក់រំសាយពាក់កណ្ដាលខ្នងរបស់នួនល្អង កំពុងស្រូបកែវភ្នែកពិសិដ្ឋឱ្យគយគន់ឥតព្រិច ។ តាចាន់បានឃើញពីអាកប្បកិរិយាបុរសលង់នឹងសម្រស់ម្ចាស់វិមាន គាត់ធ្វើជាគ្រហែម ដើម្បីជាសញ្ញាដាស់សតិឱ្យពិសិដ្ឋចាកចេញពីអារម្មណ៍អណ្ដែតអណ្ដូង ។ ដូចការគិតទុករបស់តាចាន់មែនស្នូរគ្រហែមរបស់គាត់មានឥទ្ធិពលធ្វើឱ្យអ្នកប្រុសមកកាន់សភាពនឹងនវិញ ។ កាលបើដឹងថា បុរសចាស់ម្នាក់បានដឹងថា ខ្លួនលង់ស្នេហ៍នឹងក្រមុំម្ចាស់ផ្ទះ អាការៈខ្មាសអៀនក្នុងសភាពជាមនុស្សលួចស្នេហ៍គេ បានចូលមកគ្របដណ្ដប់ដួងចិត្តបុរស ហើយភាពញញឹមស្ទើរ លាយដោយការអៀនខ្មាសបានលេចអណ្ដែតមកលើផ្ទៃភក្ត្រអ្នកប្រុសយើង ។ តាចាន់ធ្វើជាមិនដឹងរឿងអ្វី គាត់ដើរទៅមុខទាំងនិយាយ :

-មក៏ក្មួយ ទៅតាមតា ។

-បាទ តា ។

ឯកៀនតុម្គផ្កា ភ្នែកពិសិដ្ឋក្រឡេកទៅឃើញកញ្ញាយីហ៊ុបក្នុងសភាពតុប តែងកាយឆើតឆាយ ជាមួយនឹងគ្រឿងអលង្ការមានតម្លៃ ដែលធីតាដើរលប១ ទៅរករថយន្តមួយគ្រឿងដែលចតមុខផ្ទះ ។ យីហ៊ុបមានអាការៈហាក់ដូចជាមាន ការកោតក្រែងនរណាម្នាក់ ជាពិសេសពិសិដ្ឋឃើញនាងលួចចោលភ្នែកមើលទៅ លោកតានិងនរលក្ខណ៍ដែលដើរដល់ជិតមាត់ទ្វារផ្ទះ ។ កាលបើយល់អាការៈចម្លែក របស់ក្រមុំរូបឆើតយីហ៊ុប កំលោះពិសិដ្ឋមានអាការៈងឿងឆ្ងល់ ព្រោះគេគិតថា កញ្ញាដែលត្រងដោយសម្លៀកបំពាក់និងគ្រឿងអលង្ការដ៏មានតម្លៃ ប្រាកដជាមាន ជាប់សាច់ឈាមជាមួយម្ចាស់វិមានដ៏ស្កឹមស្កៃនេះមិនខាន ប៉ុន្តែគេមិនយល់ថា តើ ហេតុអ្វីបានជានាងមានសភាពលីបលដូចជាខ្លាចអ្វីមួយ ដែលមិនទំនងជារូបនាង ដែលមានឈាមជ័ររបស់ត្រកូលនេះទេ ។ ចម្ងល់ជាមួយនឹងការចង់ដឹង ជាមួយ មនុស្សដែលពាក់ពន្ធ័នឹងវិមានមាស ឬ វិមានសិទ្ធា ទាមទារចាំបាច់ឱ្យនរៈត្រូវតែបន្លឺ សួរតាចាន់ :

-តា! នាងជាអ្នកណា ?

តាចាន់និយាយតិច១ប្រាប់ពិសិដ្ឋ :

-គឺអ្នកនាងយីហ៊ុប ជាចៅពៅរបស់លោកឧកញ៉ា ។ អ្នកនាងយីហ៊ុបចូល ចិត្តដើរលេង តែលោកឧកញ៉ាមិនពេញចិត្តអំពើអ្នកនាង ទើបអ្នកនាងត្រូវលបលាក់ ជាមួយនឹងលោកឧកញ៉ាយ៉ាងហ្នឹង ។

-លោកឧកញ៉ាមានចៅប៉ុន្មាននាក់ដែរតា ?

-លោកមានចៅបួននាក់ គឺអ្នកប្រុសវេហា អ្នកនាងនរលក្ខណ៍ អ្នកនាងទារិកានិងអ្នកនាងយីហ៊ុប ។

-ពួកចៅៗរបស់លោកឧកញ៉ាកាចៗទេតា ?

មុននឹងឆ្លើយ តាចាន់សើចញឹមៗទាំងមើលមុខពិសិដ្ឋ ។ អ្នកប្រុសសម្លឹងតាចាន់ តេបន្លឺសំណួរបន្ថែម :

-ខ្ញុំសួរព្រោះបើពួកគាត់កាច នោះខ្ញុំខ្លាចណាស់តា ។

-គឺមានកាចខ្លះ ស្លូតខ្លះ តែបើក្មាមឯងមិនធ្វើផ្តេសផ្តាស នោះប្រហែលមិនមានអីឱ្យខ្លាចទេដឹង ។

ប្រយោគរបស់តាចាន់ ធ្វើឱ្យពិសិដ្ឋលេចនូវសញ្ញាកិរិះគិតជាច្រើន ។ មុននេះបន្តិច គេជួបចៅម្នាក់របស់លោកឧកញ៉ាដែលមានអាកប្បកិរិយា ឫកពាសុភាពរាបសាជាមួយនឹងការគ្រងនូវសម្លៀកបំពាក់សមសួន ក្នុងលក្ខណៈជានារីថ្លៃថ្នូរនៃត្រកូលអភិជន តែពេលនេះសភាពរបស់កញ្ញាយីហ៊ុបដែលជាចៅស្រីម្នាក់ទៀតបង្ហាញក្រោមក្រសែភ្នែកមាណព នូវសភាពដែលផ្ទុយដូចមេឃនិងដី ពីចៅស្រីដែលពិសិដ្ឋបានឃើញនាគ្រាដំបូង ព្រោះចៅស្រីម្នាក់នេះតុបតែងខ្លួនឆើតឆាយហាក់បីដូចជានារីមិនបានទទួលការអប់រំពីគ្រួសារ ដែលមានរបៀបរៀបរយពោរពេញដោយបែបផែនថ្លៃថ្នូរទាល់តែសោះ។ ហេតុអ្វីក៏មានសភាពបែបនេះកើតមានឡើងចំពោះមនុស្សនៅក្នុងដំបូលផ្ទះតែមួយដូចនេះ ?

# វគ្គទី ៦

ថ្ងៃដដែល នៅលើឡាន C R V ដ៏ទំនើបដែលបញ្ជាដោយកំលោះពិសិដ្ឋ កំពុងដឹកចៅហ្វាយក្រមុំរូបស្អាត ដែលជិះនៅចំាងខាងក្រោយ តម្រង់ទៅសណ្ឋាគារ ទីបីរបស់គ្រួសារលោកឧកញ៉ាសិទ្ធា ។ តាមកញ្ចក់ខាងក្នុងរថយន្ត ពិសិដ្ឋលបមើល នាង អ្វីដែលភ្នែកនរៈបានឃើញ គឺនរលក្ខណ៍កំពុងពិនិត្យមើលបញ្ជីការងារក្នុងដៃ ទាំងនាងហើបវាចាពោលមកកាន់គេ :

-ក្ដាម! ជូនខ្ញុំទៅធនាគាររំចង់ ។

សម្ដីបញ្ជារបស់ចៅហ្វាយក្រមុំកន្ត្រាក់អារម្មណ៍ក្ដាម ឬ ពិសិដ្ឋ ដែលកំពុង លង់អារម្មណ៍ក្នុងការគយគន់សម្រស់នាងតាមកញ្ចក់ឡាន ឱ្យភ្ញាក់ព្រើត ព្រោះ ពាក្យថា " ធនាគាររំចង់ " វាមកសំពងអារម្មណ៍គេឱ្យភ័ន្តភាំង បើរូបគេជាម្ចាស់ ធនាគារនេះ ស្រាប់តែនួននាងឱ្យគេធ្វើជាអ្នកបើកបររថយន្តជូនស្រីទៅទីកន្លែង ដែលគេត្រូវលាក់ការពីការងារក្លែងកាយរបស់ខ្លួនយ៉ាងនេះ តើមិនឱ្យគេភ្ញាក់ផ្អើល យ៉ាងម៉េច ? ដូចនេះ ភ្លាមៗមាណពទប់ចិត្តមិនទាន់ គេក៏ភ្លាត់មាត់ស្រដី :

-ធនាគាររំចង់ !

នរលក្ខណ៍ឆ្ងល់នឹងប្រយោគរបស់អ្នកបើកបរ ធីតាងើបមុខពីមើលបញ្ជី បែរមកមើលក្ដាម នាងបន្លឺសួរ :

-អ្នកមិនស្គាល់ធនាគាររំចង់អ្ហេះ ?

ក្ដាមខំសម្រួលទឹកមុខ និយាយឱ្យមានសភាពធម្មតា :

-បាទទាន ខ្ញុំបាទមិនស្គាល់ទេទាន ។

-ខ្ញុំសុំហាមអ្នកណាំ កុំនិយាយ " បាទទាន " ជាមួយខ្ញុំអី ។

-តើអ្នកនាងឱ្យខ្ញុំបាទនិយាយពាក្យអ្វីទាន ?

-ក្រែងអ្នកធ្លាប់នៅបើកឡានឱ្យជនបរទេសអ្ហេះ ? និយាយដូចបែបកាល ណោះណាំក្តាម ។

-តែខ្មែរនិងបរទេសគឺមានទម្លាប់រស់នៅមានការខុសគ្នា ជាពិសេសមនុស្ស ដែលមានត្រកូលជាអ្នកមានជាន់ចាស់ដូចអ្នកនាង ពាក្យសម្តីរបស់អ្នកបម្រើដូចខ្ញុំ បាទក្នុងការនិយាយ ត្រូវតែពោរពេញដោយការគោរពណាំអ្នកនាង ។

នរលក្ខណ៍ញញឹម ស្រដី :

-ចេះដឹងគ្រាន់បើតើក្តាម តែអ្នកធ្វើតាមខ្ញុំប្រាប់ចុះ ព្រោះខ្ញុំមិនមែនជាអ្នក មានអីទេ ។ ខ្ញុំនេះទើបតែចេញទៅធ្វើការនៅថ្ងៃនេះហ្នឹង តើខ្ញុំមានទ្រព្យពីអង្កាល់?

ក្តាមលួចមើលមុខនរលក្ខណ៍តាមកញ្ចក់ គេស្ញើចសរសើរនាងតែក្នុងពោះ ពីចរិតមិនប្រកាន់វណ្ណៈនិងមិនមានអំណួត ក្នុងនាមជាចៅរបស់ជនមានទ្រព្យ ស្តុកស្តម្ភ ដោយក្តាមឆ្លើយតបទៅនាង :

-តែលោកឧកញ៉ាមានទ្រព្យច្រើនណាស់អ្នកនាង ។

-អ្នកម៉េចក៏ដឹងថា លោកតាខ្ញុំមានទ្រព្យច្រើន ។

-ខ្ញុំបាទឃើញផ្ទះធំ ឃើញឡាន ខ្ញុំបាទគិតថា លោកឧកញ៉ាពិតជាអ្នកមាន ទ្រព្យច្រើនហើយ ។

-ក្តាម! អ្នកជាមនុស្សឆ្លាតតើ ។ អុំះ! បត់ខាងឆ្វេងដៃ ។

-បាទអរគុណ ដែលអ្នកនាងសរសើរខ្ញុំ ។

ពិសិដ្ឋបើករថយន្តជូនចៅហ្វាយស្រីមកដល់ធនាគារវិចង់ល្អម ដែលនាំដល់ការបញ្ចប់នូវបទសន្ទនារវាងគេនិងចៅហ្វាយក្រមុំរូបស្រស់ ។

ក្នុងការិយាល័យម៉ានុត យើងឃើញនរលក្ខណ៍កំពុងអង្គុយទល់មុខម៉ានុត ហើយប្រយោគដំបូង គឺជាវាចារបស់ម៉ានុតដែលពោលមកកាន់ចៅស្រីសំណព្វរបស់លោកតាសិទ្ធា :

-ខ្ញុំនឹកដល់ថ្ងៃចូលឆ្នាំខ្មែរកាលយើងនៅតូក្យូនោះណា៎ កាលណោះជាថ្ងៃដំបូងដែលខ្ញុំបានស្គាល់នរលក្ខណ៍ ហើយបើគិតមកដល់ពេលនេះ យើងបែកគ្នាបានជាងបីឆ្នាំហើយមែនទេលក្ខណ៍ ?

-មែនហើយលោកម៉ានុត ហើយកាលណោះខ្ញុំរៀនឆ្នាំទីមួយ ឯលោកម៉ានុតរៀនឆ្នាំបញ្ចប់ណា៎ ។

-កាលណោះ គឺមិនប៉ុន្មានខែផង ខ្ញុំក៏ត្រូវវិលមកស្រុកខ្មែរមុនលក្ខណ៍តែម្តង ។ រួចតាំងពីពេលនោះរហូតមកដល់ពេលនេះ ខ្ញុំក៏មិនដែលដឹងសោះ ដែលគ្រួសារលក្ខណ៍មានគណនីក្នុងធនាគារខ្ញុំ តែបំណាច់យើងជួបគ្នាជាថ្មី ខ្ញុំអាចអញ្ជើញនាងទៅញ៉ាំអាហារមួយពេលណា៎ ។

-ញ៉ាំអាហារពេលព្រឹក ឬ ថ្ងៃត្រង់លោកម៉ានុត ?

ម៉ានុតលើកដៃមើលនាឡិកា គេធ្វើមុខជូរ រួចនិយាយ :

-អី ! ម៉ោងជាងដប់ទៅហើយ ។

-ចាស ម៉ោងជាងដប់ហើយ ខ្ញុំក៏ញ៉ាំអាហារពេលព្រឹករួចដែរ ឯអាហារថ្ងៃត្រង់ ខ្ញុំមិនទាន់ឃ្លានទេលោកម៉ានុត ។ សុំទោសណា៎ យើងអាចញ៉ាំអាហារជាមួយគ្នានៅថ្ងៃក្រោយចុះ ។

-បាទ ថ្ងៃក្រោយក៏ថ្ងៃក្រោយ ។

យើងទុកឱ្យពួកគេបន្តការសាសងសិនចុះ ហើយបែរមកមើលពីសកម្មភាព របស់ចៅផ្សេងទៀតរបស់លោកឧកញ៉ាម្តងវិញ គឺចំពោះក្រមុំទារិកាកំពុងអង្គុយក្នុង ហាងលក់គំនូររបស់ធីតា ដោយកល្យាណលើកទូរសព្ទមកនិយាយតបទៅកាន់ចុង ខ្សែម្ខាង ក្នុងសភាពភក្ត្រញញឹម :

-ចាស ខ្ញុំសុខសប្បាយទេសេរី ចុះសេរីវិញ តើយ៉ាងណាដែរ ?

-បាទ ខ្ញុំសុខកាយតែមិនសប្បាយចិត្តទេ ។

-ហេតុអីមិនសប្បាយចិត្ត ឬមួយការងាររបស់សេរីមានភាពស្មុគស្មាញ មែនទេ ?

-មិនមែនការងារទេ គឺបេះដូងមានបញ្ហា ។

-អីចឹងប្រញាប់ទៅរកពេទ្យព្យាបាលណាសេរី ។ អុំះ! សុំទោស មានភ្ញៀវ មករកទិញគំនូរខ្ញុំ ខ្ញុំសុំបិទទូរសព្ទសិនហើយ យើងនឹងជួបគ្នាលើកក្រោយ ។

ទារិកាម្ចាស់ម្នាយត្រាទៅរាក់ទាក់ជាមួយអតិថិជនរបស់នាង តាមទម្លាប់នាង ជាស្រីមានភាពរួសរាយ ។

ចំណែកក្នុងចំណតអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ យើងឃើញយីហ៊ុប ដើរជិតនាងណារី នាយវណ្ណានិងនាយសីហា ដោយស្រីយីហ៊ុបនិយាយទូរសព្ទ បណ្តើរ :

-អាឡូម៉ាក់ ខ្ញុំសុំទៅលេងបាងកកជាមួយមិត្តភក្តិចំនួនមួយអាទិត្យណា ។

បន្ទាប់ពីយីហ៊ុបស្តាប់ទូរសព្ទដែលមានចម្លើយឆ្លើយតបពីមាតា ក្នុងការ ដែលនាងសុំម្តាយទៅលេងទីក្រុងបាងកក ។ មិនដឹងជាអ្នកស្រីសូគានិយាយអ្វីខ្លះទេ

តែយើងឃើញឃីហ៊ុបញាក់មុខដាក់វណ្ណា ទាំងនាងឆ្លើយទៅកាន់ម្ដាយដែលកំពុងស្ដាប់នាម្ខាងខ្សែទូរសព្ទ :

-សុទ្ធតែមិត្តស្រី១ទេម៉ាក់ ។ បាយ!បាយ! ម៉ាក់ ។

ឃីហ៊ុបបិទទូរសព្ទ នាងងាកមកពួកវណ្ណា ស្រដីទាំងសើចស្រស់ :

-ជាមួយម៉ាក់គ្នា ទាល់តែស្ដាយក្បួនភរ ទើបបានដើរលេងណាំពួកយើង ។

-គ្នាក៏ភរម៉ាក់គ្នាដែរ ។ " នាងណារី "

-ពួកគ្នាក៏ភរប៉ាម៉ាក់ដែរ ។ " វណ្ណានិងសីហា "

ចប់ប្រយោគរបស់ម្នាក់១ គេទាំងបួនសើចរអឹក បោះជំហានសំដៅទៅកាន់ទ្វារអាកាសយានដ្ឋាន ។

មុខធនាគារវំចង់ ពិសិដ្ឋកំពុងអានកាសែត ស្រាប់គេក្រឡេកទៅឃើញចៅហ្វាយស្រីដើរទន្ទឹមនឹងម៉ានុតចេញពីមាត់ទ្វារធនាគារ ពិសិដ្ឋភ្ញាក់ព្រើត តែចាំបាច់ត្រូវតែគេចមុខពីម៉ានុត ទើបគេដាក់កាសែតចុះ ហើយបញ្ឆាចង្កូតឡានឱ្យចាកចេញពីទីចំណតយ៉ាងលឿន ។

ក្រោយពីនិយាយលាម៉ានុតរួចរាល់ ចៅស្រីរបស់លោកឧកញ៉ាសិទ្ធាក៏បោះជំហានតម្រង់ទៅកាន់ទីដែលនាងគិតថា រថយន្តរបស់នាងមុខជាចតនៅម្ដុំទីនោះ ប៉ុន្តែមិនមែនដូច្នេះទេ ភ្នែកនរលក្ខណ៍មិនបានឃើញអ្វីទាំងអស់ ។ កញ្ញាទៅជាមីងមាំង និមលងាកឆ្វេងស្ដាំក្នុងបំណងរកមើលរថយន្ត ។ បន្ទាប់ពីមិនបានឃើញរថយន្តនរលក្ខណ៍ក៏ហៅស៊ីក្លូ ដើម្បីជិះទៅកាន់សណ្ឋាគារទីបីរបស់គ្រួសារនាង ។ សំឡេងទូរសព្ទដៃស្រីល្អបានរោទិ៍ឡើង :

-អាឡូ!ខ្ញុំបាទក្ដាម សុំជម្រាបសួរអ្នកនាង ។

-ក្ដាម! អ្នកនៅទីណា ?

-បាទ ខ្ញុំបាទសុំទោសអ្នកនាង មុននេះខ្ញុំបាទឈឺបត់ជើងធំពេកទើបបើកឡានមករកកន្លែងបត់ជើងនៅម្ដុំផ្សារថ្មី ពេលនេះ តើអ្នកនាងអញ្ជើញចេញពីធនាគារហើយឬនៅ ?

-ខ្ញុំបានចេញពីទីនោះហើយ ហើយខ្ញុំកំពុងជិះស៊ីក្លូទៅកាន់សណ្ឋាគារ ។

-តើពេលនេះអ្នកនាងនៅកន្លែងណា ដើម្បីខ្ញុំបាទនឹងទៅទទួល ។

ក្រោយពីបានស្ដាប់ការរៀបរាប់ពីទីកន្លែងដែលចៅហ្វាយស្រី បាននិយាយតាមទូរសព្ទប្រាប់មក ពិសិដ្ឋបត់ក្បាលឡានត្រឡប់មកក្រោយ ដើម្បីបកទៅទទួលចៅហ្វាយស្រីនៅទីកន្លែងដែលនាងកំពុងឋិតនៅលើស៊ីក្លូ ។មកដល់ទីកំណត់ ភ្នែករបស់ពិសិដ្ឋបានឃើញកញ្ញារូបល្អកំពុងចុះពីស៊ីក្លូ ដើម្បីនាងមកឈររង់ចាំរូបគេ ។ នរៈបានបើករថយន្ដទៅអែបជិតចៅហ្វាយស្រី ហើយគេរត់ទៅបើកទ្វារឡានជូននាង ក្នុងកាយវិការគោរពស្រីល្អ ទាំងពោលវាចាផង :

-ខ្ញុំបាទសុំទោសអ្នកនាង ។

នរលក្ខណ៍ចូលក្នុងរថយន្ដបណ្ដើរ នាងនិយាយទាំងញញឹមទៅកាន់ក្ដាម :

-ហេតុអីក៏សុំទោសច្រើនម្ល៉េះ អ្នកបានសុំទោសខ្ញុំតាមទូរសព្ទហើយតើ ម្យ៉ាងខ្ញុំយកទោសអ្នកយ៉ាងម៉េច បើអ្នកមានធុរៈដែលចាំបាច់បែបនេះ ។ ណ្ហើយ ! អ្នកជូនខ្ញុំទៅសណ្ឋាគារ ។

ពិសិដ្ឋចូលកាន់ទីកន្លែងរបស់គេត្រូវបញ្ជាចង្កូតវិញ ។ មុននឹងចាកចេញ គេលបមើលមុខនាង ក្នុងសភាពលួចស្ទាបស្ទង់ចិត្តស្រី តើនាងមានបង្ហាញនូវភាពខឹងសម្បារពីទង្វើគេ ដែលបើករថយន្ដមកចោលរូបធីតាដែរទេ?បុរសឃើញនាងពិនិត្យ

បញ្ជីការងារ ក្នុងទឹកមុខធម្មតា ។ ពិសិដ្ឋទទួលអារម្មណ៍ថា ស្រីម្នាក់នេះមានអធ្យាស្រ័យល្អចំពោះអ្នកដទៃ ហើយនាងជាមនុស្សមិនខ្វះខ្វាយពេលវេលាទៀតផង ព្រោះសូម្បីតែនាងកំពុងជិះនៅក្នុងរថយន្ត ក៏នាងនៅតែឆ្លៀតបំពេញការងារដែរ ។

ចំណែកវេហា ជាចៅប្រុសរបស់លោកឧកញ៉ាវិញ កំលោះព្រាននារីជាមនុស្សដែលចូលចិត្តការសប្បាយជាមួយស្រីស្រា គេមានចរិតជាប្រុសដែលទុកស្រីជាការកម្សាន្តហើយពេលនេះគេកំពុងស្នំបេះដូងជាមួយនារីម្នាក់ ដែលជាបុគ្គលិកនៃសណ្ឋាគារទីបីរបស់គ្រួសារគេ នៅក្នុងបន្ទប់មួយនៃសណ្ឋាគារ ។ ក្រោយពីក្រេបរសស្នេហារួច ស្រីទីជានារីកំដរទ្រូងរបស់បុរស ក៏ប្រញាប់ប្រញាល់រៀបចំខ្លួន ដើម្បីចាកចេញទៅធ្វើការវិញ ។ តែវេហាហាក់មិនទាន់ឆ្អែតឆ្អន់ជាមួយការក្រេបរសស្នេហ៍លួចលាក់ ព្រានតណ្ហាទាញនាងទីមកកៀកកាយ ទាំងប្រើនាសាបបោសអង្អែលថ្ពាល់ស្រី គេស្រដី :

-អូនស្រីប្រញាប់ទៅណាចោលបង ?

-អ្នកប្រុសលែងខ្ញុំទៅ ខ្ញុំប្រញាប់ទៅធ្វើការ ។

-ធ្វើការអីទៀត បើកំពុងធ្វើការឱ្យចៅកែនៅលើគ្រែហើយនោះ ។

និយាយចប់ វេហាទាញនាងទីផ្ដួលទៅលើពូក គេចាប់នាងឱបថើបញ៉ីញ៉ក់បំពក់ចិត្តស្រើបស្រាលតាមចំណង់រោលរាល ។ លុះត្រាតែអស់ចិត្ត ទើបគេប្រលែងកាយ ឱ្យនាងទីអាចងើបចេញពីទ្រូងគេ។ ស្រីបុគ្គលិកស្លៀកពាក់បណ្ដើរ នាងឆ្លៀតងាកមកចោលសម្រស់ញញឹមដាក់ចៅហ្វាយកំលោះ របៀបក្និកក្នក់ ម្និកម៉ូក់ ជាស្នាមញញឹមរាយអន្ទាក់ស្នេហ៍ទាក់ចៅប្រុសឧកញ៉ា ដើម្បីស្រវាទៅកាន់ទីខ្ពស់ ដែលនាងលួចសង្ឃឹមថា បានដូចប្រាថ្នា ។ ប៉ុន្តែអ្វីដែលកប់លាក់ក្នុងចិត្តវេហា នាងទីដំកម្សត់មិនបានដឹងសោះ ។ ប្រាណនារីគិតខ្លី ត្រូវបុរសមានល្បិចបោះដៃមកទទួល

រាងកាយស្រីដែលស្លៀកពាក់រួចរាល់ មកក្រសោបឱបផ្អប់ឱរា រួចច្រមុះប្រុសព្រានក៏ស្រូបក្លិនថ្ពាល់នាងនីភ្លែត ។

នរលក្ខណ៍កំពុងដើរតាមចន្លោះមុខបន្ទប់ទាំងឡាយនៃសណ្ឋាគារ នេត្រាឆោមឆើតបានចោលទៅប៉ះចំនាងនី ដែលចេញពីបន្ទប់មួយ ។ ចៅស្រីរបស់លោកឧកញ៉ាសិទ្ធាបានសង្កេតថា បុគ្គលិកស្រីម្នាក់នេះមានអាកប្បកិរិយាហាក់ដូចជាជាប់ពិរុទ្ធនូវរឿងអ្វីមួយ ។ នរលក្ខណ៍បោះជំហានតម្រង់ជិតនាងនី ដែលនាងនីកំពុងតែងាកទៅក្រោយ របៀបមើលទៅកាន់បន្ទប់ដែលនាងទើបតែចេញ ក្នុងគំនិតគិតថា តើវេហានឹងចេញពីបន្ទប់មកដែរឬអត់ ? យល់ភាពចម្លែករបស់បុគ្គលិកស្រី នរលក្ខណ៍ដែលមកជិតនាង ក៏បន្លឺវាចាទៅកាន់នាងនី :

-នាងឈប់សិន ។

សំឡេងរបស់នរលក្ខណ៍ពញ្ញាក់អារម្មណ៍នាងនីឱ្យភ្ញាក់ព្រើត បេះដូងរបស់នាងលោតក្តុកក្តាក់ មុខឡើងស្លេក បបូរមាត់ញ័រទទ្រើត តាំងសម្តីមិនអាចហានិយាយអ្វី ក្រៅពីការឈរសម្លឹងមុខនរលក្ខណ៍ដោយការភ័ន្តភាំង ។ ម្ចាស់សណ្ឋាគារក្រមុំរូបស្រស់ជិតដោយសញ្ញាវិះគិតលើផ្ទៃមុខ នាងពោល :

-នាងធ្វើការនៅផ្នែកណា ?

នាងនីឆ្លើយទាំងរដាក់រដុប :

-ចាស អ្នកនាងជានរណា? ជាអ្នកនាងឃីហ៊ុប ឬ អ្នកនាងនរលក្ខណ៍ ? ខ្ញុំ...ខ្ញុំ ...ជាបុគ្គលិកនៅផ្នែកចុងភៅ តែខ្ញុំ...ខ្ញុំ មានធុរៈមកជួបនាងធឿនជាអ្នកសំអាតតាមបន្ទប់ ។

-យើងជានរលក្ខណ៍ ! នាងទៅធ្វើការចុះ តែថ្ងៃក្រោយកុំដើរចោលការងារទៀតណា ។

-ចាស អ្នកនាង ។

ក្រោយពីទទួលការអនុញ្ញាតិពីចៅហ្វាយស្រីហើយ នាងនីហាក់ដូចជាធូរទ្រូងខ្សាក ។ បុគ្គលិកស្រីដើរឱនៗដោយកាយវិការគោរព ឆ្ពោះទៅកាន់ទីកន្លែងដែលនាងត្រូវធ្វើការ ។ នរលក្ខណ៍ទើបតែបោះជំហានទៅមុខបានបន្តិច ជួនជាកំលោះវេហាក៏បានចេញមកពីបន្ទប់ដែលនាងនីទើបតែចេញមុននេះ ។ ឥឡូវនរលក្ខណ៍បានរកឃើញចម្លើយ ដែលបង្ហាញពីការភិតភ័យដ៏ចម្លែករបស់នាងនីហើយ ។ កំលោះវេហាវិញ គេជាមនុស្សដែលមានមន្ទិល ដូច្នេះគ្រាដែលគេងាកទៅឃើញនរលក្ខណ៍ ដូច្នេះដើម្បីជាលេសការពារនូវអ្វីដែលជាការខុសឆ្គងរបស់ខ្លួនវេហាចាំបាច់ត្រូវតែព្យាយាមរាវរកកំហុសរបស់នរលក្ខណ៍ មកចោទប្រកាន់ជាមុនដល់នរលក្ខណ៍ ចៀសវាងនាងហាមាត់មកឈ្លេចសួរនូវទង្វើមិនឥប្បីរបស់គេប្រព្រឹត្តជាមួយនាងនី ។ គិតឃើញយ៉ាងដូច្នោះ ចៅប្រុសលោកតាសិទ្ធាក៏បោះជំហានយ៉ាងលឿនទៅជិតនរលក្ខណ៍ ទាំងនរៈបើកភ្នែកធំៗ ស្រដីទាំងពេបមាត់ទៅកាន់ស្រីល្អ :

-អាងខ្លួនជាម្ចាស់ផ្ទះសិទ្ធា ដែលជាចៅសំណព្វលោកតា ថ្មើរនេះទើបតែអញ្ជើញមកធ្វើការអ្ហេះ ?

-ក្រែងបងដឹងថា ខ្ញុំមានធុរៈយកលុយទៅដាក់ធនាគារដែរមែនទេ ? ហើយបងក៏មិនពូកែបង្វែរសភាពការណ៍ទេណា ព្រោះយ៉ាងណាបងមិនអាចសម្រួលទឹកមុខ ឱ្យគេចផុតពីភាពមានពិរុទ្ធបានទេបងវេហា ។

វេហាមុខភ្ញាក់ តែគេនៅតែប្រឹងរៀបចំទឹកមុខឱ្យមកកាន់ភាពធម្មតា ដោយតបទៅសួរនាង :

-ចុះបងមានពិរុទ្ធអី ?

-បងសាកសួរខ្លួនបងទៅ ធ្វើអាចារ្យលួចស៊ីមាត់វត្ត តើវាសមទេ ?

-នាងនិយាយអីហ្នឹង យើងស្ដាប់មិនចូលទេ ?

-បងស្ដាប់ចូល ឬ មិនចូល ក៏បងត្រូវចាំណាំ បើមានរឿងដូចដែលបងប្រព្រឹត្តនៅថ្ងៃនេះទៀត ខ្ញុំនឹងជម្រាបអ្នកមីងសូគាំជាអ្នកគ្រប់គ្រងទីនេះជាមិនខាន។

និយាយចប់ នរលក្ខណ៍ដើរទៅមុខធ្វើជាហី ។ វេហាខឹងណាស់ គេតាមសម្លឹងនាងពីក្រោយ ទាំងមុខក្រហមច្រាលដោយកំហឹង ។ ភ្លាមនោះ កំលោះព្រាននារីបានបោះជំហានយ៉ាងលឿនចាកចេញទៅ ក្នុងគំនិតដើម្បីទៅរកកូនចៅ ក្នុងបំណងរៀបចំផែនការធ្វើបាបនរលក្ខណ៍ ឱ្យសមនឹងអ្វីដែលជាទឹកចិត្តគុំគួនចំពោះស្រីល្អ ដែលនាងត្រូវទទួលបានផ្ទះសិទ្ធានិងនាងបានបន្ទោសគេពីប្រការដែលគេបានពាក់ពន្ធ័ស្នេហាជាមួយនាងនី ។

មកដល់ក្នុងបន្ទប់ធ្វើការ វេហាជាកំលោះព្រាននារីកំពុងបញ្ជាទៅកាន់នាយគ្រាក់ជាកូនចៅ ដោយសម្ដីខ្លាំង១យ៉ាងមុតមាំ :

-ហ្អែងមើលទៅចាត់ការនាងលក្ខណ៍ ឱ្យអញធូរកំហឹងផងវ៉ឺ ។

-បាទទាន អ្នកប្រុស ខ្ញុំនឹងធ្វើឱ្យលោកប្រុសបានពេញចិត្ត ។

ក្នុងពេលដែលនាយគ្រាក់កំពុងរៀបចំផែនការជាមួយនឹងវេហា ស្រាប់តែរូបភាពរបស់ជនពាលទាំងពីរនាក់នេះ បានប្រាកដលើផ្ទៃកាសែតដែលពិសិដ្ឋកំពុងតែ

អាន ។ ចៅប្រុសរបស់ខ្មោចលោកយាយមាសបានដឹងភ្លាមតាមរយៈអារម្មណ៍ទីប្រាំមួយរបស់គេ ដោយអារម្មណ៍នេះបានប្រាប់គេ ពីហេតុការណ៍ទាំងឡាយរបស់មនុស្សដែលមានការពាក់ពន្ធ័ជិតស្និទ្ធជាមួយនឹងទរៈ ។ គ្រោះអាក្រក់ដែលនឹងត្រូវកើតឡើងចំពោះនារីដែលបេះដូងបុរសធ្លាប់ជាប់ជំពាក់ តែនាងជានារីមានសាច់ឈាមក្នុងត្រកូលដែលគេត្រូវសងសឹកជូនលោកយាយមាស ធ្វើឱ្យពិសិដ្ឋមានការរារែកជាខ្លាំង ដោយមិនដឹងថា គេគួរជួយ ឬ មិនគួរជួយដល់នរលក្ខណ៍ ឱ្យរួចផុតពីកណ្ដាប់ដៃនាយគ្រាក់និងវេហា ។ កំលោះម្ចាស់ធនាគាររំចង់ត្រូវប្រឈមមុខជាមួយគំនុំនិងមនសិការជាកូនប្រុស គេប្រាកដជាពិតមិនដាច់ស្រេច...តែមិនដឹងធ្វើការជ្រើសរើសដើរផ្លូវណា...កំពុងស្លុងក្នុងគំនិតពីរដែលច្បាំងប្រឆាំងគ្នា សំឡេងស្រួយស្រិបបានលាន់ឮប៉ះសោតា :

-ក្ដាមជូនខ្ញុំទៅផ្ទះសិទ្ធា ។

ការឈឺចាប់ចំពោះភាពអយុត្តិធម៌ដែលលោកឧកញ៉ាសិទ្ធាបានដកហូតយកវិមានមាស ពីលោកយាយតូចរបស់ពិសិដ្ឋ ដុតរោលចិត្តកំលោះ ឱ្យមានកំហឹងជានិច្ចកាលបើនរណាម្នាក់និយាយថា វិមានមាស ជាវិមានសិទ្ធា ហើយពេលនេះ ពាក្យថ "វិមានសិទ្ធា" បានធ្វើឱ្យពិសិដ្ឋមានការក្រេវក្រោធជាខ្លាំង តែស្រដីទាំងកំហឹង :

-វិមានមាសម្ដេះអ្នកនាង ?

នរលក្ខណ៍ឆ្ងល់ចំពោះការខឹងសម្បាររបស់អ្នកបើកបរ ស្រីសួរពិសិដ្ឋ :

-អ្នកថាម៉េច វិមានមាសនៅឯណា ?

-គឺផ្ទះដែលអ្នកនាងរស់នៅហ្នឹងហើយ ជាវិមានមាស ។

-អ្នកធ្លាប់នៅវត្តអ្ហេះ ទើបប្រសព្វរើសឈ្មោះពីរោះយ៉ាងនេះ មកដាក់ឱ្យផ្ទះសិទ្ធាខ្ញុំ តែខ្ញុំមិនយកទេណា៎ ព្រោះផ្ទះខ្ញុំមានឈ្មោះហើយ ។

ក្តាមខាំមាត់ដោយកំហឹង ខ្នាក់វាចាខ្លាំងជាងមុនបន្តិច :

-ខ្ញុំមិនបានដាក់ឈ្មោះឱ្យផ្ទះអ្នកណាទេ តែវិមានមាស គឺវិមានមាស ។

នរលក្ខណ៍មើលមុខពិសិដ្ឋ នាងកាន់តែមិនយល់ពីអាកប្បកិរិយារបស់អ្នកបើកបររថយន្តរូបនេះ តែភាពជាមនុស្សមានអធ្យាស្រ័យអ្នកដទៃ ធីតាស្រដីដោយពាក្យធម្មតាសួរទៅគេ :

-អ្នកកំពុងយ៉ាងម៉េចហ្នឹង ? គ្រាន់តែខ្ញុំមិនទទួលឈ្មោះដែលអ្នកដាក់ឱ្យផ្ទះខ្ញុំ អ្នកខឹងខ្ញុំអ្ហេះ ?

ប្រយោគចៅហ្វាយស្រី ពញ្ញាក់ស្មារតីពិសិដ្ឋឱ្យវិលមកកាន់ភាពនឹងនរ គេឱនមុខ និយាយរបៀបដឹងពីកំហុសដែលភ្លេចខ្លួន ហ៊ានពោលនូវពាក្យមិនគាប្បីជាច្រើនទៅកាន់នរលក្ខណ៍ ទើបគេវាចាដោយសម្តីមួយៗ :

-ខ្ញុំបាទសុំទោសអ្នកនាង ។

នរលក្ខណ៍ញញឹម :

-មិនអីទេ ខ្ញុំយល់ពីបំណងល្អរបស់អ្នក ព្រោះឈ្មោះវិមានមាសពិតជាពីរោះណាស់ តែពាក្យ " សិទ្ធា " ជាឈ្មោះលោកតាខ្ញុំណា៎ ទើបខ្ញុំមិនអាចដូរឈ្មោះនេះបាន ។ តោះ យើងទៅ ។

-បាទ ។

ក្នុងផ្ទះសិទ្ធាឯណោះ ទារិកាគ្រាហ៍លោកតាឱ្យងើបអង្គុយ បន្ទាប់មកនាងបញ្ចុកថ្នាំលោកតា ស្រដី :

-កាលពីព្រឹក ចៅឃើញលោកតាស្រស់បស់ណាស់ ស្រាប់តែឥឡូវលោកតាមិនស្រួលទៀតហើយ ចៅនឹងអញ្ជើញពេទ្យមកព្យាបាលលោកតាណា៎ ។

-កុំអីចៅទារិកា តាម៉្ងៃកាត់ ម៉្ងៃកោរ ទៅតាមសភាពជាមនុស្សចាស់ហ្នឹងណា៎ ។ យ៉ាងម៉េចទៅហើយហាងរបស់ចៅ តើលក់ដាច់ដែរ ?

-ចាស ថ្ងៃនេះ លក់ដាច់ណាស់លោកតា ចៅចំណេញដល់ទៅ៥០ដុល្លា ។

លោកតាសើច មើលមុខទារិកា និយាយ :

-ចំណេញ៥០ដុល្លា ចៅសប្បាយដល់ម្លឹងទៅហើយ តែសណ្ឋាគារយើងណា៎ មិនមែនចំណេញប៉ុណ្ណឹងទេ ចៅមកជួយខាងសណ្ឋាគារវិញទៅ ចៅនឹងបានលុយច្រើនជាង ។

-លោកតា! កុំបង្ខំចៅឱ្យធ្វើអីដែលចៅមិនស្រឡាញ់ណា៎លោកតា ។

-បានតើចៅទារិកា តាគ្រាន់តែលេងតើ ។

កាលបើយល់ថា លោកតាល្មមដល់ពេលត្រូវសម្រាន្ត ទារិកាក៏ជួយទប់គ្រាហ៍លោកតា ដើម្បីផ្ដេកគាត់ឱ្យប្រាសកាយលើពូក ។ ទារិកានៅកំដរជជែកលេងជាមួយជីតា រហូតទាល់តែលោកឧកញ៉ាបិទភ្នែកសម្រាន្តលង់លក់ ទើបឆោមឆើតចាកចេញពីបន្ទប់របស់លោកតា ។

# វគ្គទី ៧

ពេលល្ងាច លើផ្លូវវិថីមួយ រថយន្តរបស់កញ្ញាសិទ្ធា នរលក្ខណ៍ កំពុងរំកិលកង់ក្នុងល្បឿនមធ្យម ដោយមានក្លាមជាអ្នកកាច់ចង្កូត ហើយម្ចាស់ស្រីក្រមុំរូបស្រស់អង្គុយនៅបាំងខាងក្រោយ ។ ប្រយោគមួយឃ្លាដំបូង ផ្ដើមឡើងដោយបបូរមាត់របស់នាយក្លាម :

-អ្នកនាងមានធុរៈអីនៅសណ្ឋាគារ ទើបអញ្ជើញទៅទាំងល្ងាចអីចឹង ?

-មានបុគ្គលិកម្នាក់មានធុរៈ ហើយនាងសរសេរសំបុត្រអង្វរឱ្យខ្ញុំ ទៅជួយនាង ។

-អូ៎! អ្នកនាងចិត្តល្អណាស់ ។

នៅពេលដែលរថយន្តមកដល់ម្ដុំជិតវត្តភ្នំ ភ្នែកស្រីស្រស់បានក្រឡេកទៅឃើញឡានមួយឈប់អែបទៅគៀនចិញ្ចើមផ្លូវ ដោយនាយគ្រាក់ឈរបក់ដៃជាសញ្ញាសុំឱ្យរថយន្តរបស់នរលក្ខណ៍ឈប់ ដើម្បីគេសុំជំនួយ ។ ស្រីល្អវាចា :

-ក្លាមឈប់ឡាន ប្រហែលគេមានការពឹងពាក់យើង ។

ក្លាមមើលស្គាល់ជាមនុស្សដែលគេឃើញតាមវិញ្ញាណទិប្រាំមួយ ដែលគេដឹងថា ជាមនុស្សរបស់វេហាដែលប៉ងមកធ្វើបាបចៅសំណព្វរបស់លោកតា ដោយក្លាមនឹកក្នុងចិត្ត : "ហ៊ី ! ជាបក្សពួកលោកវេហាតើ។ " គិតរួច នរៈងាកមកកល្យាណ អ្នកប្រុសពោល :

-អ្នកនាងក្រែងប្រញាប់អញ្ជើញទៅសណ្ឋាគារអេះ ?

-មិនអីទេ ការងារនៅទីនោះ ខ្ញុំមិនប្រញាប់ពេកទេ យើងជួយគេនៅទីនេះសិនណាក្លាម ។

ដោយមិនអាចជំទាស់នឹងបញ្ហាចៅហ្វាយស្រីបាន ពិសិដ្ឋ ឬ ក្លាមចាំបាច់ត្រូវតែបញ្ឈប់រថយន្តនៅពីក្រោយរថយន្តរបស់នាយគ្រាក់ ។ នរលក្ខណ៍ចេញពីយានបោះជំហានទៅរកជនពាល ស្របពេលនាយគ្រាក់ក៏បោះជំហានមករកនាងដែរ ។ ភ្លាមនោះនាយគ្រោងដែលឈរនៅលើផ្លូវ កៀកនរលក្ខណ៍ វាក៏ស្ទុះមកចាប់ឱបនាងពីក្រោយ ដោយយកកន្សែងមានថ្នាំមកខ្ទប់ច្រមុះនាង ។ ក្លាមដែលបានប្រុងជើងការរួចជាស្រេច គេក៏ស្ទុះទៅធាក់នាយគ្រោងពីក្រោយមួយជើង បណ្ដាលឱ្យនាយនេះភ្លាត់ជំហារ របូតដៃពីដងខ្លួនរបស់នរលក្ខណ៍ ។ ស្រីល្អស្ទុះរត់គេចពីក្រញាំដៃជនពាលទាំងភ័យឥតឧបមា ។ ឆាកប្រយុទ្ធក៏កើតឡើងរវាងនាយគ្រាក់ នាយគ្រោងនិងពិសិដ្ឋ ។ អ្នកដែលមានប្រៀបក្នុងការប្រយុទ្ធគឺកំលោះក្លាម ។ នួនល្អងមើលការប្រកួតដោយអារម្មណ៍ច្រាស់ច្រាល នាងហាក់ដូចជាស្ទោស្ទន់ រកធ្វើអ្វីមិនត្រូវ គិតមិនលេច ក្រៅតែពីក្នុងចិត្ត បន់ស្រន់សុំឱ្យពិសិដ្ឋមានប្រៀបជាងគូប្រយុទ្ធ ។ នៅទីបំផុតការបែរបន់របស់ធីតាបានដូចបំណង ដោយអ្នកបើកបររថយន្តរបស់ចៅស្រីឱកញ៉ាបានផ្ដួលគូសត្រូវទាំងពីរឱ្យរត់ផាស់ក្រញ៉ាំតម្រង់ទៅរករថយន្តរបស់វា ។ ពិសិដ្ឋគ្មានចេតនានឹងដេញសង្គ្រប់ចាប់ជនពាលទាំងពីរនាក់នោះទេ គេបារម្ភពីសុវត្ថិភាពរបស់ចៅហ្វាយស្រីទៅវិញ ទើបនរៈបែរកាយដើរមករកនួននាង ស្របពេលនាងល្អស្ទុះតម្រង់មករកគេដែរ ។បបូរមាត់ស្រីស្រស់កម្រើកទាំងញ័រទទ្រើតសួរមកកាន់ក្លាមៈ

-អ្នកមានត្រូវរបួសទេ ?

-បាទ មិនមានអ្វីធ្ងន់ធ្ងរទេ គ្រាន់តែត្រូវបន្តិចបន្តួច។ ចុះអ្នកនាងមានត្រូវត្រង់ណាទេ ?

-ខ្ញុំអត់មានត្រូវអីទេ។

ឆ្លើយបានតែត្រឹមនេះ សម្លេងទូរសព្ទរបស់នរលក្ខណ៍ក៏រោទិ៍ឡើង កល្យាណលើកទូរសព្ទមកស្តាប់ ។ មិនដឹងជានាងបានឮអ្វីខ្លះ ពីចុងខ្សែម្ខាងនៃទូរសព្ទ ប៉ុន្តែបន្ទាប់ពីធីតាបិទទូរសព្ទ ស្រីបែរមកសម្លឹងមុខក្លាម បន្លឺវាចា :

-បើអ្នកមិនមានអីធ្ងន់ទេ ហើយមិញនេះមានទូរស័ព្ទមកប្រាប់ខ្ញុំថា បុគ្គលិកដែលមានធុរៈនោះ ត្រូវបានដោះស្រាយរួចហើយដែរ អីចឹងយើងទៅផ្ទះវិញ

-បាទ អ្នកនាង ។

ការពិតហេតុការណ៍ដែលនាយគ្រោងនិងនាយគ្រាក់ ព្រមទាំងមនុស្សដែលនិយាយពីខ្សែម្ខាងនៃទូរសព្ទ គឺជាក្រុមកូនចៅរបស់វេហា ដែលជាគម្រោងការរៀបចំឡើងដោយវេហា ដើម្បីចាប់នរលក្ខណ៍យកទៅវាយធ្វើបាបឱ្យសមនឹងចិត្តដែលវេហាមានកំហឹងចំពោះនិមល ដែលនាងបានរករឿងបន្ទោសកំលោះព្រាននារីដែលប្រព្រឹត្តផ្តេសផ្តាសទៅលើនាងនី និងជាប្រការដែលវេហាត្រូវការផ្តល់មេរៀនព្រៃផ្សៃមួយ ជាការតម្រាមស្មារតីនរលក្ខណ៍ ដែលទើបតែក្លាយជាម្ចាស់ផ្ទះសិទ្ធផងដែរ ព្រោះគេនិងម្តាយឪពុកគេក៏ត្រូវការផ្ទះនោះដែរ ។ ប៉ុន្តែអ្វីទាំងអស់ដែលជាគោលបំណងដ៏ខ្មៅកខ្វក់របស់វេហា បែរជាត្រូវបរាជ័យដោយស្នាដៃនាយក្លាម។

បើយើងក្រលេកមើលទៅកញ្ញាម៉ានីន នាងនាថគេងសន្ទឹងសន្ធៃលើពូកទន់ល្មើយតែកាយវិការរបស់ស្រី ហាក់ដូចជាពូកដែលនៅពីក្រោមប្រាណនាង ពោរពេញទៅដោយភាពក្តៅគគុក។ នាងប្រែកាយចុះឡើង នៅមិនសាប់មិនសុខ រសាប់

រសល់ ខ្ទល់ពេញឱរា ភក្រ្តាស្រពាប់ស្រពោន ។ និមលលូកដៃទៅយកខ្សែកមួយខ្សែ ដែលដាក់នៅក្នុងប្រអប់ដ៏ប្រណិតនៅក្បែរក្បាំងគ្រែ ។ ដៃកាន់ខ្សែក ភ្នែកសម្លឹងឥតព្រិច ម៉ានីនបន្លឺតិចៗតែឯង :

-បងសិដ្ឋ តើថ្ងៃនេះ បងនៅទីណា ហើយកំពុងធ្វើអ្វី ? ខ្ញុំនឹកបងណាស់ ចុះបងមាននឹកខ្ញុំទេ ?

ម៉ានីនលើកខ្សែកមកឱបថ្នប់នឹងទ្រូង ស្រើលស្រមៃឃើញថ្ងៃដែលពិសិដ្ឋបានប្រគល់ខ្សែកនេះដល់នាង ។ កាលណោះ នៅក្នុងការិយាល័យពិសិដ្ឋ ស្រីអង្គុយទល់មុខបងប្រុសជីដូនមួយ ម្រាមហត្ថាស្រីផ្ដុំសំពះប្រុសកំលោះ វាចា :

-អរគុណបងសិដ្ឋចំពោះខ្សែកនេះ ។

-បងមិនត្រូវការពាក្យអរគុណទេ បងត្រូវការឃើញប្អូនទីនញញឹមស្រស់បែបនេះ ។

-បងសិដ្ឋពូកែបញ្ចោរអូនណាស់ អូនមិនបានស្អាតស្រស់ ដូចដែលបងនិយាយឡើយ ។ អូនលាបងទៅធ្វើការវិញហើយ ។

-អូនទៅចុះ ហើយទុកខ្សែកបងឱ្យល្អណាំ បើសិនជាអូនធ្វើឱ្យវាឱ្យបាត់នោះ បងនឹងមិនសប្បាយចិត្តទេ ។

-អ៊ូ! របស់ពិសេសយ៉ាងនេះ អូននឹងថែវាឱ្យបានល្អ ។

ការស្រមៃបានបញ្ចប់ ដោយម៉ានីនលើកខ្សែកយកទៅដាក់នៅក្នុងប្រអប់ដូចដើម ។ នាងញញឹមគ្រវីក្បាលតិចៗ ស្រដី :

-បងសិដ្ឋអើយ តើថ្ងៃណាទើបបងមកជួបអូនវិញ ។

រាត្រីស្ងប់ស្ងាត់ ក្រោមពន្លឺអំពូលភ្លើងអគ្គិសនីក្នុងសួនច្បារផ្ទះសិទ្ធា កំលោះពិសិដ្ឋអង្គុយលើស្មៅរាបស្មើផេង ដោយដៃនរៈកំពុងយកប្រេងកូឡា មករីតពីលើរបួសនៅដើមដៃរបស់គេ ។ អារម្មណ៍ពិសិដ្ឋច្របូកច្របល់ណាស់ គេមិនយល់ពីចិត្តខ្លួនឯង ដែលពេលមុន គេមានបំណងមកជានិវិមានសិទ្ធា ក្នុងគំនិតធ្វើយ៉ាងណាឱ្យមនុស្សទាំងអស់ដែលរស់នៅក្នុងផ្ទះនេះ ជួបតែការក្តៅក្រហាយជាមួយការគ្មានសេចក្តីសុខ ប៉ុន្តែពីរសៀលមិញនេះ សមអីដែលគេត្រូវយកខ្លួនទៅប្រយុទ្ធតតាំងជាមួយនាយគ្រាក់និងនាយគ្រោង រហូតបណ្តាលឱ្យមានការឈឺខ្លួនដោយជាំទាំងលើដៃនិងលើខ្លួនរបស់គេទៅវិញ ហើយអំពើដែលនាំដល់ការឈឺខ្លួននេះ គឺមាណពធ្វើដើម្បីការពារនិងផ្តល់ក្តីសុខដល់សមាជិកក្នុងផ្ទះនេះតែម្តង វាពិតជាផ្ទុយពីការតាំងចិត្តរបស់គេហើយ ។ កំលោះគិតមិនលេចដែលគេប្រឹងប្រែងប្រយុទ្ធ ដើម្បីជួយស្រីល្អជាកូនចៅសត្រូវរបស់លោកយាយតូចឱ្យផុតពីភ័យ ។ គិតដល់ត្រឹមនេះ មាណពហាក់ស្រមៃដល់សម្តីដ៏ទន់ភ្លន់និងមុខពោរពេញដោយភាពបារម្ភរបស់ចៅហ្វាយក្រមុំដែលមានន័យថា " អ្នកមានត្រូវរបួសដែរទេ ? " ។ ប៉ុន្តែភាពទន់ភ្លន់ស្រស់ស្អាតរបស់នរលក្ខណ៍ត្រូវរលុបពីអារម្មណ៍អ្នកប្រុសមួយរំពេច ដោយជំនួសមកនូវរូបភាពឈឺចាប់របស់ខ្មោចលោកយាយមាស បានអណ្តែតមកលងក្នុងខួរក្បាលរបស់គេ ។ កំហឹងចំពោះលោកឧកញ៉ាសិទ្ធាដែលផ្តល់ភាពអយុត្តិធម៌ចំពោះ លោកយាយមាសដែលស្តែងជាការគ្រេវគ្រោធដល់យុវជនយើង បណ្តាលឱ្យគេដកយករូបថតរបស់នរលក្ខណ៍ដែលគេតែងលាក់ទុកនៅក្នុងហោប៉ៅអាវ មកសម្លឹងដោយក្រសែភ្នែកដាលដោយកំហឹងមួយភ្លែត ហើយក៏គ្រវែងរូបថតនោះចោលទៅលើស្មៅ ។ ទេវតា

ស្រីផុសភ្លែតមកទ្រូបថតស្រីស្រស់ មិនឱ្យធ្លាក់ទៅលើស្មៅ ។ ទេពធីតាញញឹមស្រស់ កាន់រូបថតក្នុងព្រះហស្ត មានព្រះសុរិយ្ណនីយមកកាន់ពិសិដ្ឋ :

-ហេតុអីខឹងគោ មកវាយរទេះ ?

-ព្រះនាងទេវតាក៏ដឹងថា ម្ចាស់រូបពាក់ពន្ធ័យ៉ាងម៉េចជាមួយលោកយាយតូចរបស់ខ្ញុំដែរ ទើបខ្ញុំបោះរូបនេះចោល ។

-តើម្ចាស់រូបខុសអី ទើបអ្នកមិនប្រណី គប់រូបថតនេះចោលអីចឹង ? ហើយកុំប្រាប់ណាំថា ចោលរួចនឹងរើសវិញនោះ ។

-ព្រះនាងទេវតា ខ្ញុំខឹងមែនណ៎ា ។

-ខ្ញុំជាទេវតា ហេតុអីមិនដឹងចិត្តអ្នក ណោះ! យករូបថតទុកវិញទៅ ហើយអ្នកធ្វើអ្វី ត្រូវតែមានហេតុផលណ៎ា ។ តើអ្នកណាខុស អ្នកណាត្រូវ អ្នកត្រូវរកឱ្យឃើញ ។ ខ្ញុំលាហើយ ។

ជាមួយសុរិយ្ណនីយរបស់ទេវតាស្រី ព្រះកាយរបស់ព្រះនាង ក៏រលាយបាត់សូន្យទៅ បន្សល់ទុកនូវពិសិដ្ឋកម្សត់ ឱ្យអង្គុយរិះគិតតែឯងឯកាលើវាលស្មៅកណ្ដាលសួនឧទ្យាន ក្រោមសំណាញ់រះរោយនៃសន្សើមរាត្រី ។

ក្នុងបន្ទប់លោកឧកញ៉ា យើងឃើញលោកតាសម្រាន្តលើគ្រែ ចោលភ្នែកសម្លឹងមើលទៅកូនប្រុសកូនស្រីនិងចៅៗ ដែលមានសូគ៌ា វេហា ជំនោរ តារា និងនរលក្ខណ៍ ។ ម្នាក់ៗដែលនៅក្នុងបន្ទប់នេះ លើកលែងតែលោកតា គឺពួកគេសុទ្ធតែមានទឹកមុខស្ងួត ហាក់បង្កប់នូវការព្រួយបារម្ភអ្វីម្យ៉ាង ។ ប្រយោគលោកតាបន្លឺ សួរទៅកាន់អ្នកស្រីសូគ៌ា :

-ម្នាក់ៗរាយការណ៍ពីការងារដែលខ្លួនបានធ្វើក្នុងថ្ងៃនេះរួចហើយ ហើយសកម្មភាពកិត្យានិងមាណវីនៅសណ្ឋាគារទីមួយឯកំពង់សោម ក៏គេសរសេរអ៊ីម៉ែលផ្ញើមកយើងដែរ ។ ចុះឯណាចៅយីហ៊ុប ឱ្យគេមករាយការពីការងារនៅថ្ងៃនេះ ឱ្យយើងស្តាប់ផង ។

សួគ៌ាអេះអុញបន្តិច ទើបឆ្លើយ :

-លោកពុក! កូនយីហ៊ុបមិនបានទៅធ្វើការទេ តែទៅលេងបាងកកបាត់ហើយ ។

-ព្រហើនមែន យើងនឹងដកភាគហ៊ុនរបស់យីហ៊ុប ឮទេទាំងអស់គ្នា ។

សម្តីរបស់ឪពុកដែលមានន័យថា គាត់នឹកដកចំណែកភាគហ៊ុនរបស់កូនស្រីយីហ៊ុបនោះ ផុតរោលចិត្តអ្នកស្រីសួគ៌ាឱ្យពោរពេញដោយកំហឹង ។ ប៉ុន្តែជាមួយបិតាដែលពោរពេញដោយអំណាចនិងភាពម៉ត់ចត់ សួគ៌ាមិនហ៊ានហើបវាចាមួយម៉ាត់ ឬកម្រើកខ្លួនប្រាណអ្វីបន្តិច ។ អ្នកស្រីទ្រាំទ្រលាក់លៀមនូវការឈឺចាប់ដោយកំហឹងតែក្នុងទ្រូង ។ លោកជំទាវនិងអ្នកស្រីតារា ដែលតែងតែដឹងពីទង្វើមិនគប្បីរបស់កូនប្រុសវេហា ដែលកំលោះមិនសូវម៉ត់ចត់លើការងារក៏ដូចជាមានលក្ខណៈជាព្រានទារីដែលមិនមែនជាចំណូលចិត្តរបស់លោកឧកញ៉ា កំពុងបង្កអារម្មណ៍ភ័យព្រួយចំពោះម្តាយឪពុកពីររូបនេះ ។ លោកជំទាវនិងអ្នកស្រីតារាលបចោលក្រសែភ្នែកភ័យខ្លាចសម្លឹងទៅវេហាជាបុត្រា ក្នុងន័យប្រាប់កំលោះជើងល្អ ឱ្យប្រយ័ត្នខ្លួនលើទង្វើរបស់គេ ដើម្បីចៀសវាងបាននូវការចាប់ទោសអូសដំណើរពីជីតា ។ វេហាមានការភ័យមិនតិចដែរនៅក្នុងចិត្តគេ នរៈក្បាលខូចឱនមុខចុះ មិនស្តីអ្វី ប្រៀបដូចជាឆ្មា

លាក់ក្រចក ។ គឺមានតែនរលក្ខណ៍ដែលងើបមុខសម្លឹងមើលមកជីតា វាចាទាំងស្រងូតស្រងាត់ :

-លោកតាកុំដកភាគហ៊ុនប្អូនឃីហ៊ុបអី...គេប្រហែលទទួលណាត់ពីមិត្តភក្តិមុនពេលដែលលោកតាឱ្យគេទៅធ្វើការ ទើបគេ...

លោកតានិយាយកាត់សម្តីចៅសំណព្វភ្លាម :

-ចៅលក្ខណ៍កុំការពារគេ ។

រួចលោកតាបែរមើលសូគីា ជំនោរ តារា វេហា គាត់និយាយដោយសំឡេងធ្ងន់ៗ :

-ត្រឡប់ទៅវិញទាំងអស់គ្នាចុះ ទុកចៅលក្ខណ៍ម្នាក់ឱ្យនៅជាមួយយើង ។

វេហានិងម្តាយឪពុក ព្រមទាំងអ្នកស្រីសូគីាបានបោះជំហាន ដើម្បីចាកចេញទៅក្រៅបន្ទប់ តាមបញ្ជារបស់លោកឧកញ៉ា ។ ប៉ុន្តែមុននឹងឈានជើងចេញទៅ កំលោះព្រាននារីលបចោលភ្នែកសម្លឹងទៅកាន់ភគ្រ្គានរលក្ខណ៍ ទាំងគេលបគិតនៅក្នុងចិត្ត : "ហ៊ឺ នាងលក្ខណ៍ ! បើហ៊ានចាក់រុកលោកតាពីរឿងយើងនិងស្រីម្នាក់នោះ នាងមុខជាបានឈឺខ្លួនមិនខាន ។"

ឥឡូវក្នុងបន្ទប់ទាំងមូល នៅសល់តែលោកតានិងនរលក្ខណ៍ ។ លោកឧកញ៉ាសម្លឹងចៅសំណព្វចិត្ត លោកវាចា :

-ចៅបើកទូរដែក ហើយយកសែកនិងប្លង់សាងសង់ផ្ទះសំណាក់នៅកែបចេញមកឱ្យតា ។

-ចាស លោកតា ។

បន្ទាប់មក នរលក្ខណ៍ក៏បើកទូរដែក នាងយកសែកនិងក្រដាសដែលមានគូរប្លង់មួយផ្ទាំង ហុចមកជូនលោកតា តែលោកតាភ្ញៃដៃជាសញ្ញាមិនទទួលរបស់ទាំងនោះ ដោយគាត់ពោល :

-ស្តាប់ការរាយការណ៍ពីការងារចៅនៅថ្ងៃនេះ ធ្វើឱ្យតាមានជំនឿថា ចៅមុខជាអាចធ្វើឱ្យគម្រោងសាងសង់ផ្ទះសំណាក់ទាំងដប់ ដែលនៅក្នុងដៃចៅកាន់នេះនឹងបានសម្រេច ។ ណេះ! តាប្រគល់ផែនការនេះ ឱ្យចៅចាត់ចែង ។

-លោកតា!ចៅមិនហ៊ានទទួលគម្រោងធំនេះទេ ចៅនៅក្មេង មិនទាន់មានបទពិសោធន៍ការងារទេ ។ ចៅមិន...

-គ្មានឫស្សីណាដែលមិនក្លាយមកពីទំពាំងទេ កុំប្រកែក តាស្គាល់ចៅ ។

ជាមួយមុខបារម្ភ នរលក្ខណ៍តបវាចា :

-ចាសលោកតា ចៅនឹងប្រឹងប្រែងមិនឱ្យលោកតាអស់សង្ឃឹម ។

# វគ្គទី ៨

យប់ដដែល ក្នុងបន្ទប់សម្រាប់អ្នកបម្រើ ដែលជាកម្មសិទ្ធិរបស់តាចាន់និង ពិសិដ្ឋ យើងឃើញកំលោះម្ចាស់ធនាគារគេងទន្ទឹមតាចាន់ ដែលជាអ្នកបម្រើចាស់របស់លោកឧកញ៉ា ។ ពិសិដ្ឋបើកភ្នែកភ្លឺះៗសម្លឹងដំបូលមុង ពោលវាចាបន្ទឺ :

-លោកតាជាបម្រើចាស់នៅទីនេះ ចុះលោកតាមានដឹងដែរទេ តើហេតុអីអ្នកខ្លះហៅផ្ទះនេះថា វិមានមាស តែអ្នកខ្លះហៅថា វិមានសិទ្ធា ?

-ហេតុអីបានជាឯងដឹងថា ផ្ទះនេះធ្លាប់មានឈ្មោះថា វិមានមាស ?

-មានលោកយាយម្នាក់ដែលនៅផ្ទះជាប់របងផ្ទះនេះ ជាអ្នកប្រាប់ខ្ញុំ ។

-អូ! ប្រហែលជាយាយសុខហើយ ។ តែឯងកុំហៅផ្ទះនេះថា វិមានមាសទៀតណា ជាពិសេសនៅចំពោះមុខលោកឧកញ៉ា ឯងកុំច្រឡំហៅផ្ទះនេះថា វិមានមាសឱ្យសោះ ។

-ហេតុអីទៅលោកតា ?

-កុំចង់ដឹងអី ។ ឯងដេកទៅ យើងងងុយដេកហើយ ។

និយាយចប់ តាចាន់ក៏បិទភ្នែកសម្ងំតែម្តងទៅ ។ ពិសិដ្ឋសម្លឹងដំបូលមុងលែងស្តីអ្វីដែរ ។ ខួរក្បាលរបស់គេកំពុងធ្វើការជំនួសឱ្យមាត់ ដើម្បីរាវរកចម្លើយដែលពាក់ពន្ធ័វិមានមាសនិងលោកយាយមាសរបស់គេ ។ តើមានអ្វីជាអាថិកំបាំងដែលគេមិនទាន់បានដឹងឬទេ ? ព្រោះតាមមើលទៅអាការៈតាចាន់ ហាក់ដូចជាមានអ្វី ដែលគាត់មិនចង់និយាយប្រាប់គេ ។

ក្នុងពេលជាមួយគ្នានេះ ស្រស់ស្រីនរលក្ខណ៍មិនទាន់ចូលគេងដូចជានរៈយើងនៅឡើយ នាងនាថកំពុងអង្គុយនៅតុធ្វើការក្នុងបន្ទប់របស់ធីតា ។ នេត្រានាងភ្លង់ពិនិត្យមើលប្លង់ផ្ទះសំណាក់ ដែលលោកតាទើបតែប្រគល់ឱ្យស្រីទទួលខុសត្រូវក្នុងការអនុវត្តគម្រោងសាងសង់នេះ ។ស្រាប់តែភ្លាមនោះ នៅពីក្រោយខ្នងស្រស់ស្រី ខ្មោចយាយមាសផុសថ្កោលឡើងដោយគ្មានលាន់ស្នូរអ្វីបន្តិចដល់សោតានួនល្អង ។ ខ្មោចស្រីមានសភាពដូចជាមនុស្សស្រីដែលមានជីវិតពិតៗ គ្រាន់តែគ្រងកាយសម្លៀកបំពាក់ ជាសម្លៀកបំពាក់បែបផែនកាលពីសាមសិបឆ្នាំមុន ។ បិសាចស្រីមើលមកនរលក្ខណ៍ ដោយក្រសែភ្នែកហាក់ដូចជាចង់ស៊ីសាច់ចៅស្រីរបស់លោកឧកញ៉ា ទាំងខ្មោចបំពងសម្រែកគំហកមករកនាង :

-នាងនរលក្ខណ៍ ។

ភ្ញាក់ដូចជាទាញទម្លាក់ទីដ៏ខ្ពស់ ឱ្យដួលមកដី នរលក្ខណ៍ងាកមករកប្រភពសំឡេងដ៏ខ្ទ័រខ្ទារ ដែលបន្លឺហៅឈ្មោះនាង...អ្វីដែលភ្នែកនួនស្រីមើលឃើញ ហាក់ដូចជាមានភាពស្រពិចស្រពិលពីរូបរាងរបស់ខ្មោចយាយមាស ព្រោះពេលនោះអំណាចសិល្ប៍របស់ខ្មោចស្រីកំពុងអន្ទងព្រលឹងនរលក្ខណ៍ ឱ្យលង់នៅក្នុងការសណ្ដំ ។ ខ្មោចកំណាចស្រែកកំញើញស្មារតីនួនល្អង :

-មកតាមយើងភ្លាម ។

មហិទ្ធិឫទ្ធិសិល្ប៍អន្ទងនាំកាយនរលក្ខណ៍ ឱ្យដើរតាមខ្មោចយាយមាសទាំងមិនដឹងខ្លួន ។ ទាំងខ្មោចទាំងមនុស្សកំពុងដើរចេញពីបន្ទប់គេងរបស់នរលក្ខណ៍ដោយសន្សឹមៗ ដែលរូបកាយចៅស្រីរបស់លោកឧកញ៉ាមិនមានស្មារតីក្នុងប្រាណ

ឡើយ ។ បិសាចចេះតែបក់ដៃហៅនាង ស្រស់ស្រីចេះតែនាំកាយដើរតាមអនុភាពនៃការអន្ទងព្រលឹងរបស់ខ្មោចកំណាច ។

វិញ្ញាណទីប្រាំមួយរបស់ពិសិដ្ឋដាស់កន្ត្រាក់ឱ្យគេស្ទុះងើប ទាំងសើងមម៉ើងជាមួយទឹកមុខភិតភ័យ ដោយអ្នកប្រុសយើងភ្លាត់មាត់តិចៗ :

-អ្នកនាងនរលក្ខណ៍! លោកយាយតូច!

ស្ទើរមិនទាន់ចប់ប្រយោគផង ពិសិដ្ឋក្រោកចាកពីគ្រែដំណេក អង្គុយច្រង៉ុកគេងាកមកសម្លឹងមើលតាចាន់ ក្នុងគំនិតភ័យខ្លាចក្រែងតាចាន់មិនទាន់សម្រាន្ត គាត់អាចនឹងកើតការសង្ស័យពីអាកប្បកិរិយាចម្លែក ខុសពីមនុស្សធម្មតារបស់ពិសិដ្ឋ ។ លុះគេឃើញតាចាន់លង់លក់ក្នុងដំណេក អ្នកប្រុសម្ចាស់ផ្ទះស្ទុះស្ទាចាកចេញពីបន្ទប់ គេរត់លឿនស្លេវតម្រង់ទៅកាន់ផ្នែកខាងក្រៅផ្ទះ ។ នៅពេលកំលោះយើងរត់មកដល់សួនច្បារខាងមុខគេហដ្ឋាន ពិសិដ្ឋបានក្រលេកឃើញខ្មោចលោកយាយតូចកំពុងបក់ដៃអន្ទងហៅនរលក្ខណ៍ ឱ្យដើរទៅតាមអំណាចសិល្ប៍របស់បិសាច សំដៅទៅរកផ្លូវថ្នល់ ។ នៅឯឆ្ងាយបន្តិចពីខ្មោចនិងនរលក្ខណ៍កំពុងដើរ មាននរស្មីជះមកភ្លឺចិញ្ចាចគឺជាពន្លឺភ្លើងហ្វាររបស់រថយន្តដឹកទំនិញដ៏ធំមួយ កំពុងបើកមករកនាងនិងបិសាចដោយបញ្ចាំងពន្លឺមកចំរាងកាយខ្មោចស្រីនិងនរលក្ខណ៍ ។ ចៅសំណព្វរបស់លោកឧកញ៉ាសិទ្ធាដើរទាំងគ្មានព្រលឹងក្នុងខ្លួន ទៅរកទីដែលរថយន្តនឹងត្រូវបើកសំដៅមករកស្រី ។ ពិសិដ្ឋភ័យរន្ធត់ ចំពោះគ្រោះអាក្រក់ដែលបណ្តាលមកពីរថយន្តដ៏ធំបង្កមកលើកាយនួនល្អង ។ ព្រោះមិនយូរពេលទេ រថយន្តនឹងស៊ុះមកបុកនរលក្ខណ៍ជាមិនខាន បើនាងនៅតែដើរបែបមីងមាំងទៅក្នុងទ្រូងផ្លូវយ៉ាងនេះ។គ្រោះអាក្រក់

មុខជាធ្លាក់មកលើកាយធីតា នាពេលបន្តិចទៀត ។ ពិសិដ្ឋភ័យស្លោស្លន់ គេស្ទុះរត់ដូចគេបោះ ទាំងស្រែកពេញសំឡេង ដើម្បីឃាត់ខ្លួននាង :

-អ្នកនាងនរលក្ខណ៍កុំទៅមុខទៀត ។ អ្នកនាងសុំប្រយ័ត្ន ។ កុំទៅមុខ ។

ប៉ុន្តែនរលក្ខណ៍នៅតែដើរសំដៅទៅរកឡាន តាមការអន្ទងរបស់ខ្មោចយាយមាស ។ ពិសិដ្ឋភ័យណាស់ សេចក្តីស្លាប់កំពុងតែរំកិលមករកមនុស្សដែលគេស្រឡាញ់ហើយ ។ បើមើលទៅរថយន្តដឹកទំនិញ ហាក់ដូចជាបរមកមុខ ដោយអ្នកបើកបរដូចជាមិនបានឃើញនរលក្ខណ៍កំពុងដើរលើថ្នល់ថ្នល់ នៅពីមុខយានយន្តទេដឹង ។ ភ័យណាស់ កំលោះរត់លឿនគ្មានបង្អង់ ទាំងស្រែកផង :

-អ្នកនាងនរលក្ខណ៍ឈប់សិន ។ លោកយាយកុំធ្វើបាបនាង ។

ប៉ុន្តែគ្មានឥទ្ធិពលអីអាចបញ្ឈប់ដំណើរនរលក្ខណ៍បានទេ នាងបានដើរទៅដល់កណ្តាលថ្នល់ហើយ ។ យានយន្តធំក៏បើកមកកាន់តែជិតនរលក្ខណ៍ដែរ ។ អ្នកដែលភ័យមិនមែនជានរលក្ខណ៍សោះ គឺពិសិដ្ឋទៅវិញទេ ។ ការបារម្ភធ្វើឱ្យជំហានពិសិដ្ឋឈានលឿនស្លេវ មកក្បៀកកាយនារី រួចគេស្រវាឱបនាង ទាញស្រីមកខាងចិញ្ចើមថ្នល់យ៉ាងបន្ទាន់ ដូចផ្លេកបន្ទោរ ។ ខ្មោចលោកយាយមាសក៏រលាយបាត់ឈឹងកណ្តាលភពខ្មៅងងឹត ។ ចំណែករថយន្តដឹកទំនិញក៏បើកមកដល់ទីកន្លែងដែលពិសិដ្ឋទើបតែទាញនរលក្ខណ៍ចេញមុននេះបន្តិច ។ គ្រោះថ្នាក់បានរសាត់បាត់ទៅហើយ អំណាចសិល្បរបស់បិសាចក៏រលាយពីខ្លួននរលក្ខណ៍ដែរ ។ កញ្ញាស្វាងស្មារតី តែនាងត្រូវមកស្រឡាំងកាំង ដោយប្រាណកល្យាណឋិតនៅក្នុងរង្វង់ដៃរបស់អ្នកបើកបរកំលោះ ក្នុងសភាពដែលរាងកាយរបស់បុរសសង្កត់នៅពីលើរាងកាយនាងយ៉ាងក្បៀកកិត ។ នរលក្ខណ៍មឹងម៉ាំងឈាយឡំដោយការខ្មាសអៀន ។ នាងមិន

ទាន់ទាំងប្រមូលស្មារតីឱ្យវិលមកកាន់ភាពនឹងនរស្រួលបួលនៅឡើយ ស្រាប់តែសំឡេងរបស់ពិសិដ្ឋបានបន្លឺក្បែរត្រចៀកនាង :

-អ្នកនាងផុតគ្រោះថ្នាក់ហើយ ។

នរលក្ខណ៍មិនដឹង មិនយល់សោះថា ពិសិដ្ឋកំពុងនិយាយពីអ្វី ហើយក៏មិនយល់ដែរ ដែលនាងមកឋិតនៅក្នុងសភាពឱបក្រសោបរបស់បុរស នាពេលរាត្រីដែលឋិតនៅកណ្ដាលវាល លើផ្លូវខាងមុខគេបង្ហានទៅវិញ ។ ប៉ុន្តែទោះជាពោរពេញដោយចម្ងល់យ៉ាងណា ក៏ភាពអៀនខ្មាស ដែលរាងកាយនៅក្រោមភាពស្និទ្ធស្នាលជាមួយបុរស បានដណ្ដើមឥទ្ធិពលពាសពេញអារម្មណ៍នាង ជំនួសដោយចម្ងល់ទាំងឡាយ ។ មិនតែប៉ុណ្ណោះ ក្រសែភ្នែករបស់ពិសិដ្ឋបានសម្លឹងយ៉ាងស្រទន់មកលើវង់ភក្ត្រនាង...ខ្មាស...ភ័យ ព្រួយ មិនយល់ លាយឡំក្នុងទ្រូងនាង ។ ស្រីបម្រះពីដៃមាណព ធីតាស្រដី :

-លែងខ្ញុំ !

ពិសិដ្ឋបាក់ភ្ញាក់ពីសុបិនស្នេហ៍មួយរំពេច ដែលកើតឡើងដោយការក្រសោបរាងកាយស្រស់ស្រី ។ ទឹកមុខដែលពោរពេញដោយមន្តស្នេហ៍នាគ្រាមុនរបស់នរៈត្រូវជំនួសដោយភាពភិតភ័យ ជាមួយប្រយោគរបស់អ្នកប្រុសលាន់មក :

-អ្នកនាងអត់មានត្រូវអីត្រង់ណាទេអេះ ?

ចប់ប្រយោគ មាណពក៏ប្រលែងដៃពីកាយនាង ស្រីល្អដើបឈរបែរខ្នងមករកអ្នកប្រុស ស្រីវាចាស្ទើរតែមិនឮ :

-ខ្ញុំអត់មានត្រូវត្រង់ណាទេ ។

កល្យាណអៀនណាស់ ហេតុអីនាងធ្លាក់ក្នុងរង្វង់ដៃប្រុស ។ នាងរកនឹកមូលហេតុមិនឃើញទាល់តែសោះ តែការពិតគឺប្រាណនាងប្រាកដជាទើបនឹងចេញផុតពីការកៀកកិតកាយបុរស ។ ដើម្បីលាក់លៀមនូវភាពអៀនអន់ ឆោមឆើតងាកមុខមកម្ខាង ។នាងខ្លាចក្រសែភ្នែកយុវជន នាងញញើតនឹងការគយគន់របស់បុរស ។ ពិសិដ្ឋធ្វើមុខញឹម១ គេគិតថា " នាងអៀន នាងស្អាតមែន " ហើយគេក៏ព្រេកអរដែលចម្លើយនាពេលមុននេះ បញ្ជាក់ថា នាងមិនមានត្រូវរបួស ទើបយុវជនពោល :

-ខ្ញុំអរណាស់ដែលអ្នកនាងមិនអីយ៉ាងនេះ ។

ចម្ងល់ជិតពេញឱរ៉ាស្រី អ្វីជាហេតុការណ៍ដែលកើតមុននេះ ទួនល្អងប្រាកដជាមិនយល់ពីមូលហេតុឡើយ ធីតាបន្លឺ :

-ហេតុអីខ្ញុំមកទីនេះ ?

-បាទ ខ្ញុំបាទមិនដឹងដែរ តែមុននេះខ្ញុំបាទអង្គុយនៅសួនច្បារ ខ្ញុំបាទឃើញអ្នកនាងដើរចេញពីក្នុងផ្ទះ ដូចមមើ ហើយដើរទៅរកថ្នល់ ។ ជួនជាខ្ញុំឃើញមានឡានមួយបើកតម្រង់មករកអ្នកនាង តែអ្នកនាងបែរជានៅតែដើរទៅរកឡាន ទើបខ្ញុំភ័យពេក ខ្ញុំក៏រត់ទៅចាប់អូសទាញអ្នកនាង ទាល់តែយើងដួលទាំងពីរនាក់តែម្តង ។

មុខនវលក្ខណ៍របៀបដូចជានឹកឃើញអ្វីមួយ រួចនាងនិយាយ :

-ខ្ញុំមមើ! ទេ! ខ្ញុំដូចជាស្រពិចស្រពិលថា មានមនុស្សស្រីស្អាតម្នាក់មកហៅខ្ញុំ ឱ្យដើរតាមគេ ។

-តែខ្ញុំបាទមិនបានឃើញមាននរណាផ្សេង ក្រៅពីអ្នកនាងដើរតែឯងទៅរកឡាន...

ភ្លាមនោះពិសិដ្ឋមានអារម្មណ៍ដឹងថា ខ្មោចយាយមាសបម្រុងនឹងសម្លាប់មនុស្ស ទើបគេមិនបានបញ្ចប់ប្រយោគដែលនិយាយទៅកាន់នួនល្អង ដោយគេបែរជានិយាយនូវពាក្យសម្ដីម៉ឺងម៉ាត់ទៅកាន់កល្យាណ :

-អ្នកនាងកុំរំលឹកអ្វីដែលកើតឡើងនេះអី ព្រោះយ៉ាងណាវាក៏កន្លងទៅហើយ អ្នកនាងត្រូវប្រញាប់អញ្ជើញចូលផ្ទះវិញ ព្រោះនៅទីនេះពេលយប់អីចឹងជាប្រការមិនសមរម្យសម្រាប់ភ្ញៀវកញ្ញាតិទេ ។

-មែនហើយ ។ ខ្ញុំអរគុណដែលអ្នករំលឹកខ្ញុំ ។

ស្ទើរតែនាងនិយាយមិនទាន់ចប់ផង ស្រាប់តែពិសិដ្ឋបោះជំហានដើរយ៉ាងលឿនតម្រង់ទៅផ្ទះសិទ្ធា ក្នុងអាកប្បកិរិយាដូចជាមានការអ្វីប្រញាប់យ៉ាងខ្លាំង ។ ឋិតនៅក្នុងរាត្រីដ៏ងងឹត ខ្លួននាងជាស្ត្រីមានភាពភ័យខ្លាច រួមថែមទាំងត្រូវពិសិដ្ឋមានអាការៈដូចជាចង់រត់ចោលនាងទៀត ឆោមឆើតព្រឺសំបុរ ត្រជាក់អស់ដៃជើងស្ទុះយ៉ាងលឿនដើរតាមពិសិដ្ឋ ទាំងស្រែកហៅគេផង :

-ក្ដាមចាំខ្ញុំផង ។

ពិសិដ្ឋមិនបានងាកមុខមកមើលនាង ឬ ក៏បន្ថយល្បឿននៃដំណើររបស់គេទេ តែគេក៏ឆ្លៀតឆ្លើយមកស្រីល្អ :

-អ្នកនាងដើរឱ្យលឿនមក ។

ជំហានពិសិដ្ឋបោះទៅមុខកាន់តែលឿនឡើង១ គេមិនបានទាំងងាកមកមើលស្រស់ស្រីសូម្បីតែបន្តិច ។ នរលក្ខណ៍ខ្លាច ភ័យ លាយឡំដោយការវង្វេងវង្វាន់ចំពោះអាកប្បកិរិយារបស់បុរស ដែលហាក់ដូចជាមិនខ្វល់អំពីនាង ដែលជាស្ត្រីកំពុងឋិតនៅកន្លែងមួយដែលមិនមានអ្វីគួរកក់ក្ដៅកណ្ដាលយប់ស្ងាត់ តែចិត្តដែលភ័យ

ខ្លាចជំរុញឱ្យស្រស់ស្រីដែលលែងហ៊ានសួរនាំអ្វីទៅកាន់អ្នកប្រុស ក្រៅតែពីប្រឹងបន្តឹងជំហានរត់តាមគេ យ៉ាងត្របាញ់ជើង តម្រង់ឆ្ពោះទៅរកវិមានសិទ្ធា ។

ដូចអារម្មណ៍ពិសិដ្ឋដែលបានដឹងជាមុនថា ខ្មោចយាយមាសកំពុងតែប៉ុនប៉ងសម្លាប់មនុស្សមែន ព្រោះថា ពេលនេះបិសាចស្រីផុសយ៉ាងគួរឱ្យខ្លាចនៅចុងជើងលោកតាសិទ្ធាដែលកំពុងសម្រាន្តលង់លក់នៅលើគ្រែ ។ ខ្មោចស្រីឋិតនៅក្នុងសភាពពាក់កណ្តាលមនុស្ស ពាក់កណ្តាលខ្មោច ដោយបិសាចស្លៀកពាក់សម្លៀកបំពាក់ដូចជាមនុស្សនាទស្សវត្សរ៍ដែលលោកយាយមាសរស់នៅ គឺកាលពី១៩៧៥ បិសាចមានសភាពរូបរាងកាយបែបមនុស្សធម្មតា គ្រាន់តែទឹកមុខរបស់គេ មានភាពស្លេកស្លាំងសដូចក្រដាស ។ ស្រីខ្មោចឈរនៅចុងជើងលោកតាបន្លឺសំឡេងគ្រលួច គួរព្រឺខ្លាច :

-លោកបងឧកញ៉ាភ្ញាក់ឡើង ។

លោកតាបើកភ្នែក អ្វីដែលគាត់ឃើញគឺជារូបភាពភរិយាទីបីរបស់គាត់ដែលមានឈ្មោះថា ជំទាវមាស កំពុងឈរញញឹមនៅចុងជើងគាត់ ។ បេះដូងលោកតាលោតជាខ្លាំង ព្រោះគាត់ដឹងច្បាស់ថា ភរិយាទីបីនេះបានស្លាប់ទៅជាយូរឆ្នាំទៅហើយ ហើយបើនាងប្រាកដកាយនៅពីមុខគាត់បែបនេះ គឺប្រាកដជាព្រលឹងខ្មោចមិនខាន ។ អ្នកណាដែលមិនចេះខ្លាចខ្មោច នៅពេលដែលខ្មោចមកឈរយ៉ាងស្ងៀងនៅពីមុខខ្លួននោះ យ៉ាងណាមិញលោកឧកញ៉ាភ័យស្ទើរតែបាត់ព្រលឹងពីក្នុងខ្លួនគាត់បន្លឺទាំងបបូរមាត់ស្វាយល្អកញ័រទទ្រើត ធ្មេញរញ្ជុំគ្នាលាន់ក្រឹកក្រាក់ លោកតាប្រឹងវាចាស្ទើរតែស្តាប់មិនបាន :

-នាង...មាស! នាងមក...ធ្វើអី ?

ខ្មោចស្រីរំកិលកាយសសៀរទៅរកលោកតា ទាំងភ្នែកល្មៀនថ្លៃ តែបបូរមាត់ញញឹម ជាមួយអណ្តាតល្មៀនមកវែងអូសដី ហើយពោលដោយសំឡេងម្យ៉ាងស្តាប់ព្រឺគួរសង្វៀវត្រចៀក :

-លោកប្តីសម្លាញ់...អូនមករក...បងហើយ ។

សភាពទ្រុឌទ្រោមដោយជំងឺរាតត្បាត បណ្តាលឱ្យលោកតាខំប្រឹងងើបពីទីដំណេកទាំងពិបាក ផ្សំដោយការភិតភ័យ ហើយបបូរមាត់ញ័រញាក់របស់មនុស្សចាស់រូបនេះ ប្រឹងហាំស្រែកទាំងមិនចង់ចេញសំឡេង :

-ទេ ! ទេ នាងស្លាប់ហើយ...នាងមាសកុំមកធ្វើបាបយើង ។

ខ្មោចយាយមាសមិនទុកឱកាសឱ្យលោកតាអាចដកឃ្លា ដើម្បីគេចទៅទីណាបាន នាងកាន់តែខិតទៅជិតលោកឧកញ៉ា ខិតរបៀបសង្វើញ ដើម្បីគំរាមស្មារតីលោក អណ្តាតវែងរបស់ខ្មោចលូកទៅរកលោកតា ។ ប្រមុខគ្រួសាររន្ធត់ស្លុះស្មាប្រឹងទាំងត្រដាបត្រដួស គេចពីអណ្តាតរបស់បិសាចដែលបម្រុងមកយីយា ។ បិសាចសើចញ័រអស់ទាំងកាយ រង្កើគ្រប់សរសៃសក់របស់វា ឱ្យប៉ើងដូចមានខ្យល់បក់បោកមកប៉ះ ។ បិសាចក្លាយជារូបភាពកាន់តែសម្បើម បានគំរាមលោកឧកញ៉ាឱ្យតក់ស្លុត ។ សំឡេងលាន់គ្រលួចខ្ទរផ្ទះ ចេញពីមាត់មានឈាមកក្លាក់របស់ខ្មោចស្រី :

-ខ្ញុំមកយក...ហ៊ឺ ហ៊ឺ...មកយកផ្ទះខ្ញុំ ។ លោកបង...ហ៊ឺ ហ៊ឺ កុំយកផ្ទះខ្ញុំ ។

ភាពភ័យខ្លាចបង្ខំឱ្យលោកតាស្ទុះងើប ដើរថយក្រោយទាំងតតិះតតាស់ក្នុងបំណងចេញទៅក្រៅបន្ទប់ ដើម្បីរកជំនួយ ។ ប៉ុន្តែបិសាចស្រីបានស្ទុះមកពាំងពីមុខលោកតាជាប់ ធ្វើឱ្យលោកឧកញ៉ាបង្ខំចិត្តរត់តម្រង់ទៅរកទ្វារ ដែលត្រូវចេញទៅ

ខាងក្រៅបន្ទប់ផ្នែកម្ខាងទៀត ។ ទីនោះមិនមានផ្លូវអាចចេញទៅណារួចឡើយ វាគ្រាន់តែជាកន្លែងសម្រាប់ទុកឱ្យមនុស្សចេញមកយកខ្យល់អាកាស ឬ មកទស្សនាសួនច្បារដែលស្ថិតនៅខាងមុខផ្ទះតែប៉ុណ្ណោះ ។ ដោយសារបន្ទប់ដំណេករបស់លោកតាឋិតនៅជាន់ទីមួយនៃភូមិគ្រឹះ ដូចនេះពេលដែលលោកតារត់មកដល់ទីរបៀងស្រូបយកខ្យល់អាកាស លោកតាមិនអាចឆ្លងកាត់ដោយការរំលងបង្កាន់ដៃនៃទីរបៀងនេះ ដើម្បីគេចខ្លួន ទៅឱ្យឆ្ងាយបានឡើយ ។ ប្រមុខគ្រួសារមកដល់កន្លែងទាល់ហើយ លោកឡេឡា ឆ្លេឆ្លា ញាប់ញ័រដោយការភ័យខ្លាច ឈរផ្អែកតោងបង្កាន់ដៃរបៀង ជាទីពឹងពាក់ ។ ព្រលឹងខ្មោចហោះសសៀរតាមមកបន្ទាច់ កំញើញស្មារតីប្រមុខគេហដ្ឋាន ។ រន្ធត់ តក់ស្លុត ពេញទ្រូងលោកតា ព្រោះគាត់ហាក់ដូចជាទទួលឥទ្ធិពលពីអំណាចសិល្ប៍របស់បិសាច បានមករុញដងកាយរបស់គាត់ឱ្យរត់លឿនស្ទេវទៅបុកជញ្ជាំងដែលនៅពីមុខគាត់ក្នុងចម្ងាយប្រហែលពីរម៉ែត្រ រួចហាក់ដូចជាមានកំលាំងខ្យល់យ៉ាងខ្លាំង ទាញខ្លួនគាត់ត្រឡប់ក្រោយឱ្យបក មកបុកបង្កាន់ដៃវិញ ។ កាលដែលមិនអាចម្ចាស់ការលើខ្លួនឯងបាន និងត្រូវឈឺចុកចាប់ដោយការរត់បុកជញ្ជាំងនិងបុកបង្កាន់ដៃ លោកឧកញ៉ាភ័យណាស់ គាត់ស្រែកយ៉ាងខ្លាំង :

-នាងមាសកុំធ្វើបាបយើង យើងខ្លាចនាងហើយ ។

គ្មានអ្វីអាចទប់ទល់ជាមួយសកម្មភាព ដែលខ្មោចស្រីបានធ្វើបាបលោកតាទេ ។ បិសាចមិនស្តាប់ពាក្យអង្វររបស់លោកតានរលក្ខណ៍សោះ វានៅតែបញ្ចេញមហិទ្ធិឫទ្ធិលងបន្លាចលោកឧកញ៉ា ។ដោយម្ចាស់ផ្ទះសិទ្ធាត្រូវសិល្ប៍របស់បិសាច រុញច្រឡើតតើតឱ្យទៅបុកនឹងជញ្ជាំងម្តង ទៅបុកនឹងបង្កាន់ដៃម្តង បណ្តាលឱ្យក្បាលរបស់គាត់ទង្គិចនឹងចម្រឹងដែកបង្កាន់ដៃ ឬ ជញ្ជាំងបន្ទប់ របបូតបែកក្បាលរួចមាន

ឈាមហូរមករហាម ។ ឈើផង ខ្លាចផង លោកតាប្រឹងជំនះខំអង្គុយចុះ ទៅលើផ្ទៃប្របបង្កាន់ដៃ ដើម្បីមិនឱ្យអនុភាពដងកាយទាំងមូលរបស់គាត់នឹងត្រូវរងឥទ្ធិពលបិសាចទាញទៅបុកបង្កាន់ដៃ ឬ ជញ្ជាំងជាបន្តទៀត ។ ទីបំផុតបិសាចបានបញ្ឈប់រឹទ្ធិកំណាចក្នុងការលេងបន្លាច ។ លោកតារអាចអង្គុយក្រវៀន ញ័រទទ្រើត កៀកបង្កាន់ដៃ ។ ឈាមហូរពីក្បាលរបស់ម្ចាស់ផ្ទះសិទ្ធា អមដោយការឈឺចាប់ ជាមួយការភ័យខ្លាចកំពុងរុករានទន្ទ្រានពាសពេញរាងកាយនិងចិត្តលោកតា ។ រីឯបិសាចស្រីឈរជំទែងសើចចំអក ដោយសំឡេងខ្ទររមេយខ្ទរជី :

-ហាស់ ហាស់ លោកបង ហាស់ ហាស់ ។

ចប់សំណើច ដៃខ្មោចស្រីលូកទៅរកច្របាច់កម្ចាស់ផ្ទះសិទ្ធា ជាមួយសំឡេងសន្ធាប់ព្រលឹងលោកតា :

-ហាស់ ហាស់ កុំយកផ្ទះយើង ។

-អូយ! កុំចូលមករកយើង យើងខ្លាចហើយ ។

នៅឯសួនច្បារមុខភូមិគ្រឹះសិទ្ធា ពិសិដ្ឋកំពុងរត់នាំមុខកញ្ញានរលក្ខណ៍ស្រាប់តែសំឡេងដ៏គ្រលួចលាន់រំពងកណ្តាលយប់ងងឹត ឮដល់ត្រចៀកគេទាំងពីរ :

-អូយ! ជួយផង !

ពិសិដ្ឋមានអាការៈភិតភ័យ គេឈប់រត់ រួចងាកមកនរលក្ខណ៍ ទាំងវាចា :

-អ្នកនាង! បានឮលោកឧកញ៉ាស្រែកទេ ?

-មែនហើយ លោកតាស្រែកខ្លាំងណាស់ ។ លោកតាមានរឿងអី ?

ជាមួយនឹងការព្រួយបារម្ភចំពោះហេតុការណ៍ ដែលកើតមានទៅលើម្ចាស់ផ្ទះសិទ្ធា យុវជនប្រុសស្រីទាំងទ្វេបានបន្ថែងដំហានរត់កាន់តែលឿនជាងមុន ឆ្ពោះទៅ

កាន់វិមានដ៏ស្ងៀមស្ងាត់ ។ នៅពេលដែលអ្នកទាំងពីរចូលទៅដល់បន្ទប់លោកតា ពួកគេបានឃើញទិដ្ឋភាពគួរឱ្យសោកសង្រេង ដែលរាងកាយលោកឧកញ៉ាដេកស្លាប់នៅកៀកបង្កាន់ដៃខាងមុខបន្ទប់ដំណេករបស់គាត់ ។ វន្ធត់ណាស់ ស្រស់ស្រីនរលក្ខណ៍ស្ទុះរត់ទៅស្រវាឱបសពលោកតា ជាមួយសម្រែក :

-លោកតា!

-លោកឧកញ៉ា! " ពិសិដ្ឋស្រែកដោយការភ្ញាក់ផ្អើល "

សម្រែករបស់នរលក្ខណ៍និងពិសិដ្ឋ បានធ្វើឱ្យផ្អើលអស់មនុស្សម្នានៅក្នុងវិមានសិទ្ធាទាំងមូល ។ មើលចុះ! អ្នកស្រីសូត៌ា លោកជំនោរ អ្នកស្រីតារា អ្នកស្រីមាណវី កញ្ញាទារិកា វេហានិងអ្នកបម្រើទាំងអស់ស្ទុះចូលមកក្នុងបន្ទប់លោកតាដោយព្រមគ្នា ទាំងតក់ក្រហល់ ។ នរលក្ខណ៍យំតក្អួក នាងឱបនៀវលើសពជីតាវាចាអណ្ដឺតអណ្ដក :

-លោកតាកើតអី ? លោកតាកុំកើតអីណាំ ...ចៅភ័យណាស់ ។

-យី! លោកពុកមានរឿងអី ? "ជំនោរ "

-លោកពុកយ៉ាងម៉េចហ្នឹង ? " លោកស្រីតារា "

-លោកពុក! "លោកស្រីសូត៌ា "

-លោកតា! "ទារិកា "

-លោកតា! "វេហា "

មនុស្សក្នុងគ្រួសារទាំងអស់ គ្មាននរណាដឹងថា តើហេតុអ្វីបានជាលោកតាសិទ្ធាទទួលអនិច្ចកម្ម ដោយគ្មានមូលហេតុយ៉ាងនេះទេ គឺមានតែកំលោះពិសិដ្ឋដែលអាចដឹងថា នរណាបានសម្លាប់ប្រមុខគ្រួសារនេះ ។ ទោះជាយ៉ាងណា ពិសិដ្ឋមិនបាន

បង្អើបមាត់និយាយពីអាថិកំបាំងរវាងខ្មោចលោកយាយមាស ដែលមានការពាក់ពន្ធ័ជាមួយមនុស្សក្នុងវិមានសិទ្ធាទាំងអស់នោះឡើយ ។ ប៉ុន្តែកាលបើឃើញខ្មោចលោកយាយតូចបានប្រព្រឹត្តអំពើឃោរឃៅ ដោយការសម្លាប់មនុស្ស ដើម្បីជាការសងសឹក ពិសិដ្ឋមានអារម្មណ៍ថា លោកយាយតូចរបស់គេសាហាវពេកហើយ ។ វិញ្ញាណទីប្រាំមួយបានប្រាប់ពិសិដ្ឋឱ្យដឹងទៀតថា ខ្មោចលោកយាយមាសមុខជាតាមសម្លាប់មនុស្សនៅក្នុងផ្ទះនេះជាបន្តទៀត តែអ្នកនោះជានរណា ហើយខ្មោចលោកយាយតូចនឹងត្រូវសម្លាប់ប៉ុន្មានទាក់ទៀត ពិសិដ្ឋមិនអាចដឹងបានឡើយ ព្រោះអ្វីដែលពិសិដ្ឋអាចដឹង លុះត្រាតែហេតុការណ៍នោះបម្រុងនឹងកើត ។

# វគ្គទី ៩

បីថ្ងៃក្រោយពីពិធីបុណ្យសពប្រាំពីរថ្ងៃនៃសពលោកឧកញ៉ាសិទ្ធា មនុស្សទាំងអស់ក្នុងគ្រួសារសិទ្ធាទាំងមូល បានមកជួបជុំគ្នា នៅក្នុងបន្ទប់ទទួលភ្ញៀវ ។ លោកជំនោរសម្លឹងមុខនរលក្ខណ៍ក្នុងក្រសែភ្នែកមិនជឿជាក់ ដោយគាត់វាចា :

-ពូមិនជឿថា លោកពុកប្រគល់គម្រោងសាងសង់ដ៏ធំ ឱ្យក្មួយលក្ខណ៍តែម្នាក់ឯង ជាអ្នកទទួលខុសត្រូវនិងសម្រេចនោះទេ ។

-មីងក៏មិនជឿដូចបងជំនោរដែរ ។ " សូគា "

-មែនហើយ ប្រហែលជាឯងបង្ខំលោកតាទេដឹង ព្រោះក្នុងយប់ដែលលោកតាខូច ពួកយើងចូលមក គឺឃើញឯងនៅជាមួយលោកតាតែម្នាក់ ។ " វេហា "

នរលក្ខណ៍មុខស្លូត និយាយទៅកាន់លោកកិត្យានិងអ្នកស្រីមាណវីជាមាតាបិតារបស់នាង :

-លោកប៉ា! ម៉ាក់! តើកូនត្រូវនិយាយបែបណា ទើបលោកពូ អ្នកមីងនិងបងវេហា ព្រមជឿសម្ដីកូន ?

យីហ៊ុបនិយាយទាំងពេបមាត់ :

-បងលក្ខណ៍អាងតែលោកតាស្រឡាញ់ ហើយតែងនៅជិតលោកតាជាងគេ ទើបពេលលោកតាទទួលអនិច្ចកម្ម ក៏អាចទទួលយកគម្រោងនេះ មកអះអាងប្រាប់ពួកយើងថា លោកតាប្រគល់ឱ្យទេដឹង ។

ស្នូរគោះទ្វារបានលាន់ អ្នកស្រីតារាងាកមើលមកទ្វារ ស្រែកទាំងមុខពោរពេញដោយកំហឹង :

-អ្នកណាព្រហើនហ៊ានមករំខានហ្នា ?

សំឡេងមនុស្សប្រុសម្នាក់លាន់មកពីក្រៅបន្ទប់ ឮដល់ត្រចៀកអ្នកទាំងអស់ដែលនៅក្នុងបន្ទប់ :

-គឺខ្ញុំមេធាវីសុធី ។

ទារិកាបែរមកអ្នកស្រីតារាជាម្ដាយ នាងនិយាយ :

-ម៉ាក់ ! គឺលោកមេធាវី ។

តារាមើលមុខទារិកា ស្រែកគំហកតិចៗឱ្យទារិកា :

-ម៉ាក់មិនមែនថ្លង់ទេ ។

ទារិកាងើបដើរទៅបើកទ្វារ ដើម្បីឱ្យលោកមេធាវីសុធីចូលមកក្នុងបន្ទប់ ដើម្បីបំពេញនាទីជាអ្នកបង្ហាញនូវបណ្ដាំមរតក ដែលលោកឧកញ៉ាបានសរសេរទុក ។ ក្នុងពេលដែលលោកមេធាវីកំពុងតែនាំកាយ មកធ្វើការបើកអាននូវបណ្ដាំមរតក អ្នកស្រីសូតិាងាកមកមើលមុខនរលក្ខណ៍ ពោល :

-ល្អណាស់ ! លោកមេធាវីមកដល់ល្មម យើងនឹងដឹងថា តើក្មួយលក្ខណ៍មានសំអាងអី ដែលថាលោកតាប្រគល់គម្រោងនោះឱ្យឯង ។

នរលក្ខណ៍មានអាការៈបារម្ភនៅក្នុងចិត្ត នាងក៏មិនបានដឹងដែរថា តើលោកតាមានសរសេរពីគម្រោងសាងសង់ផ្ទះសំណាក់ទាំងដប់នៅទីក្រុងកែប ដើម្បីប្រគល់ឱ្យនាងកាន់កាប់មែនដែរឬទេ ? ថ្វីបើគម្រោងសាងសង់នេះ នាងបានឮ ដោយផ្ទាល់ត្រចៀកពីមាត់លោកតា ដែលលោកប្រគល់ឱ្យនាងធ្វើជាម្ចាស់ផែនការដ៏ធំនេះក៏ដោយ ។ អ្នកស្រីមាណវីជាម្ដាយស្រស់ស្រីហាក់ដូចជាយល់ពីអារម្មណ៍របស់បុត្រី ហើយមាតារូបនេះតែងតែមានការជឿជាក់ទៅលើឪពុកក្មេក ដែលជាលោកឧកញ៉ា

សិទ្ធានិងទឹកចិត្តទៀងត្រង់របស់កូនស្រី ដែលកល្យាណមិនមានការលោភលន់ លុះគិតឃើញយ៉ាងនេះ អ្នកស្រីក៏លូកដៃមកចាប់ម្រាមហត្ថារបស់នរលក្ខណ៍ មកច្របាច់ស្រាលៗ ក្នុងន័យជួយបន្ធូរបន្ថយក្តីសង្ស័យនៅក្នុងចិត្តនូនល្អង ។ មេធាវីសុធីបានចូលមកដល់ហើយ មនុស្សទាំងអស់នៅក្នុងបន្ទប់ទទួលភ្ញៀវ និងមេធាវីបានសំដែងការគួរសមចំពោះគ្នាទៅវិញទៅមក តាមបែបបទសុជីវធម៌ ។ អ្នកស្រីមាណវីចង្កុលកៅអី រួចស្រដីទៅកាន់លោកមេធាវី :

-អញ្ជើញអង្គុយលោកមេធាវី ។

-បាទ អរគុណ ។

-លោកមេធាវី សុំជួយបំភ្លឺពីគម្រោងសាងសង់ផ្ទះសំណាក់ទាំងដប់ នៅឯកែបផង តើលោកពុកប្រគល់ឱ្យនរណា ? "អ្នកស្រីសួគ៌ា"

លោកមេធាវីបើកសៀវភៅមួយ ហើយគាត់អានទូវអត្ថន័យតួអក្សរ ដែលសរសេរក្នុងសៀវភៅ រួចគាត់និយាយឮៗមកកាន់មនុស្សទាំងអស់គ្នា :

-លោក ! លោកស្រីទាំងអស់គ្នា ! ការពិតទ្រព្យសម្បត្តិរបស់លោកឧកញ៉ាសិទ្ធាគាត់បានបែងចែកតាមផ្លូវច្បាប់ ជូនដល់លោក លោកស្រីរួចរាល់ កាលពីប៉ុន្មានខែមុន ដោយគ្មានអ្វីជាការផ្លាស់ប្តូរទេ លើកលែងតែពីរករណី គឺ...

លោកជំនោរសួរកាត់សម្តីមេធាវី :

-លើកលែងតែអ្វីដែលលោកមានប្រសាសន៍ថា ពីរចំណុចនោះ ?

-មែនហើយលោកមេធាវី តើជាអ្វី ? "សួគ៌ា"

-បាទ ពីរចំណុចនោះ គឺចំណុចទីមួយ គម្រោងសាងសង់ផ្ទះសំណាក់ទាំងដប់នៅកែប ជាការទទួលខុសត្រូវនិងសម្រេចដោយកញ្ញាសិទ្ធា នរលក្ខណ៍ ដែល

គ្មានអ្នកណាអាចលូកលាន់បាន លើកលែងតែលោកកិត្យានិងអ្នកស្រីមាណរី ជា ម្តាយឪពុករបស់កញ្ញានរលក្ខណ៍តែប៉ុណ្ណោះ ។

-លោកពុកអយុត្តិធម៌ ។ " សូតា "

-ខ្ញុំខឹងលោកតាណាស់ ។ " វេហា "

-លោកពុកធ្វើបែបនេះមិនត្រឹមត្រូវទេ ។ " ជំនោរ "

-ខ្ញុំស្អប់លោកតា ។ លោកតាស្រឡាញ់ចៅមិនស្មើគ្នា ។ " យីហ៊ុប "

លោកស្រីតារាមុខស្មើ ងាកមកមេធាវី ដោយអ្នកស្រីសួរ :

-លោកមេធាវី ចុះចំណុចទីពីរ តើជាអ្វី ? សូមលោកអានមក ពួកយើងចង់ដឹង ។

-បាទ ចំណុចទីពីរ គឺកញ្ញាសិទ្ធា យីហ៊ុប ត្រូវដកហូតភាគហ៊ុនរបស់នាងទាំងស្រុង ដែលជាភាគហ៊ុនដែលមាននៅក្នុងសណ្ឋាគារ ហើយចំណែកដែលជាភាគហ៊ុនរបស់កញ្ញាយីហ៊ុប ត្រូវយកមកចែកជាទ្រព្យដល់កូននិងចៅទាំងអស់ ផ្សេងពីកញ្ញាយីហ៊ុប ដោយស្មើៗគ្នា លើកលែងតែកញ្ញាយីហ៊ុបដែលនាងមិនបានទទួលអ្វី ។

ស្ទើរតែលោកមេធាវីអានខ្លឹមសារបណ្តាំមរតករបស់លោកឧកញ៉ាមិនទាន់ចប់ផង កញ្ញាយីហ៊ុបច្រឡោតខឹងជាខ្លាំង ហើយស្រែកឡើង :

-លោកតាចិត្តអាក្រក់ !

ចប់ប្រយោគខាងលើ យីហ៊ុបខ្ទប់មុខយំ រត់ចេញទៅក្រៅបន្ទប់យ៉ាងលឿន នាងមិនអាចទ្រាំទ្របាននូវអ្វីដែលលោកតាបានផ្តល់ចំពោះនាង ដែលជាលទ្ធផលលោកតាទូរទាត់ជាមួយអំពើមិនស្តាប់បង្គាប់លោកតា ដោយយីហ៊ុបបានប្រើជីវិតរស់នៅ បណ្តោយឱ្យវង្វេងនៅក្នុងភាពសប្បាយហ៊ឺហា ហើយយីហ៊ុបមិនបានយល់

ស្របនូវគំនិតលោកតា ដែលឱ្យនាងប្រឹងប្រែងធ្វើការក្នុងសណ្ឋាគារ ទាល់តែសោះ។ អ្នកស្រីសូគាជាម្ដាយមានការរន្ធត់ចិត្តអាណិតបុត្រី ហើយគាត់គិតថា បុត្រីទទួលរង នូវភាពអយុត្តិធម៌ពីឪពុកក្នុងការបែងចែកទ្រព្យសម្បត្តិ ។ អ្នកស្រីបង្ខំចិត្តរត់តាម កូនស្រី ដើម្បីលួងលោមនាង ទាំងអ្នកស្រីដង្ហោយហៅយីហ៊ុបផង :

-កូនស្រី ! យីហ៊ុប !

សូគារត់តាមកូន រហូតមកដល់ក្រៅផ្ទះ តែអ្នកស្រីមិនអាចដេញតាមទាន់ នាងឡើយ ។ លុះពេលរត់មកក្បែររថយន្ត ដែលចតនៅមុខផ្ទះ យីហ៊ុបបានស្ទុះចូល ទៅក្នុងឡាន នាងដកយកកូនសោពីក្នុងកាបូប ដើម្បីបញ្ឆេះឡាន ក្នុងបំណងចាក ចេញពីគេហដ្ឋានដែលកំពុងដុតរោលចិត្តនាង ។ ក្នុងឱកាសនោះ ជាចន្លោះពេល ដែលធ្វើឱ្យអ្នកស្រីសូគាអាចបើកទ្វារឡានចូលមកអង្គុយទន្ទឹមបុត្រី គាត់ស្រដី :

-កូនកុំអាលច្រឡោត ស្ដាប់ម៉ាក់សិនណា ។

-បើកូនស្ដាប់ម៉ាក់ តើនឹងមានអី ឱ្យកូនសង្ឃឹមនោះ ?

សូគាខ្សឹបដាក់ត្រចៀកយីហ៊ុបអំពីផែនការ ដែលអ្នកស្រីនឹងរៀបចំក្នុងការ ធ្វើយ៉ាងណាឱ្យផ្ទះសិទ្ធាព្រមទាំងទ្រព្យសម្បត្តិរបស់ត្រកូលលោកឧកញ៉ា នឹងក្លាយ មកជាកម្មសិទ្ធរបស់ម្ដាយកូនរបស់គាត់ ។ យីហ៊ុបស្ដាប់ល្បិចកលរបស់មាតា ក្នុង ទឹកមុខទទួលស្គាល់នូវផែនការដ៏មានពិសពុល តែប្រកបដោយប្រសិទ្ធភាពរបស់ មាតា ទាំងញញឹម ហើយស្រដី :

-គំនិតម៉ាក់ធ្វើឱ្យកូនពេញចិត្ត ។ ហ៊ឺះ ! តែប៉ុណ្ណេះនាងលក្ខណ៍មិនរួចពី កណ្ដាប់ដៃម្ដាយកូនយើងទេ ។

អ្វីៗដែលកើតឡើងអំពីគំនិតអាក្រក់របស់ម្ដាយកូនទាំងពីរនាក់នេះ មិនដឹងថានឹងវិវត្តន៍យ៉ាងម៉េចទេ តែសម្រាប់ស្ត្រីពីរនាក់នេះ ពួកគេក៏ចេញពីរថយន្ត ដើរវិលទៅបន្ទប់ទទួលភ្ញៀវវិញ ដើម្បីមកចូលរួមជាមួយសមាជិកគ្រួសារទាំងមូល ក្នុងបំណងបន្តស្ដាប់សេចក្ដីបែងចែកបណ្ដាំមរតករបស់លោកឧកញ៉ា និងដើម្បីកុំឱ្យមនុស្សក្នុងក្រុមគ្រួសារមានការសង្ស័យថា ពួកគេនឹងមានការអាក់អន់ចិត្តខ្លាំងក្លា ព្រមទាំងមិនចង់ឱ្យនរណាម្នាក់មានការមន្ទិលគិតថា ពួកគេអាចនឹងមានគំនិតប៉ងធ្វើអ្វីដែលមិនល្អ ដោយប្រការណាមួយ ។ នេះជាគំនិតអូសទូកកុំឱ្យល្អាន ចាប់ត្រីបានកុំឱ្យល្អក់ទឹក ។

ច្រើនថ្ងៃកន្លងមក នារសៀលថ្ងៃមួយ នៅក្នុងសួនឧទ្យានមុខវិមានសិទ្ធាយើងឃើញទារិកាកំពុងគូររូបគំនូរ ។ មួយរយៈពេលក្រោយមក កញ្ញាតូចតន់ងាកមកម្ខាងដើម្បីប្ដូរជក់ ។ ក្នុងពេលនោះ លើផ្ទាំងគំនូរដែលទារិកាកំពុងគូរ ស្រាប់តែលេចចេញនូវមុខមាត់ខ្មោចយាយមាស ដែលមានភាពជាមនុស្សធម្មតា ។ វិចិត្រករនារីងាកមកសម្លឹងមើលផ្ទាំងគំនូរ ក្នុងបំណងនឹងគូរបន្ថែម ប៉ុន្តែភ្នែកនាងបានឃើញមុខខ្មោចយាយមាសជិតនៅលើផ្ទៃក្រដាសគំនូរ ទារិកាមានអាការៈងឿងឆ្ងល់នាងគិតថា ខ្លួនឯងព្រិលភ្នែក ទើបនាងយកដៃញីភ្នែក ហើយសម្លឹងមកក្រដាសគំនូរម្ដងទៀត រូបភាពយាយមាសក៏រលប់បាត់ទៅ រូបភាពលើផ្ទាំងគំនូរបានវិលមកដូចសភាពដើមវិញ ។ ទារិកាគ្រវីក្បាលតិចៗរអ៊ូ :

-ចេះព្រិលភ្នែកទៅកើត ។

នៅឯក្បែរគុម្ពផ្កាម្លិះ ដែលឋិតនៅឆ្ងាយបន្តិចពីកន្លែងទារិកាកំពុងគូររូប នាយក្ដាមកំពុងឈរកាន់ទុយយោបាញ់ទឹកស្រោចផ្កា គេពោលតិចៗតែឯង :

-សូមលោកយាយតូចកុំលងធ្វើបាបអ្នកនាងទារិកាអី ចៅកំពុងតែស្វែងរកយុត្តិធម៌ជូនលោកយាយហើយ ។

ក្នុងពេលជាមួយគ្នានេះដែរ នៅក្នុងបន្ទប់ធ្វើការរបស់នរលក្ខណ៍ យើងឃើញនរលក្ខណ៍ និងលោកកិត្យាកំពុងអង្គុយសិក្សាគម្រោងសាងសង់ផ្ទះសំណាក់ទាំងដប់ ។ កំពុងតែលង់អារម្មណ៍នៅក្នុងការពិនិត្យ ពីគម្រោងសាងសង់ផ្ទះសំណាក់ សំឡេងទូរសព្ទរបស់នរលក្ខណ៍បានរោទិ៍ ។ កល្យាណស្រវាចាប់ទូរសព្ទមកស្ដាប់ :

-អាឡូ ជម្រាបសួរ សុំទោស តើជាអ្នកណា ?

បន្ទាប់ពីនាងស្ដាប់សំឡេងឯចុងខ្សែម្ខាងរបស់ទូរសព្ទ ស្រីល្អនិយាយ :

-អូ៎ ! គឺជាលោកម៉ានុតឬ ? ចាសបាន យប់នេះ ខ្ញុំទំនេរតើ ខ្ញុំយល់ព្រម ។

នរលក្ខណ៍ដាក់ទូរសព្ទចុះ ស្រែងាកមករកលោកកិត្យាជាបិតា ធីតាស្រដី :

-លោកប៉ា ! អ្នកទូរសព្ទមករកកូន គឺជាលោកម៉ានុត ដែលកូនពឹងគាត់ឱ្យជួយទាក់ទងលោកវិស្វករដារ៉ុធ ដើម្បីមកទទួលគម្រោងសាងសង់ផ្ទះសំណាក់ទាំងដប់នៅកែបរបស់យើងណា៎លោកប៉ា ព្រោះលោកដារ៉ុធធ្លាប់សិក្សានៅជប៉ុនជាមួយលោកម៉ានុត ។

-តាមកូនចុះ បើលោកដារ៉ុធចំណាប់ ហើយកូនត្រូវធ្វើការតាមអ្វីដែលប៉ាបានណែនាំកូនណា៎ ហើយបើកូនមានបញ្ហា កូនត្រូវទូរសព្ទសួរប៉ា ព្រោះស្អែកនេះ ប៉ា និងម៉ាក់ទៅកំពង់សោមវិញហើយ ដ្បិតយើងមិនអាចចោលការងារសណ្ឋាគារទី១ ដែលនៅទីនោះយូរទេ ។

-ចាស លោកប៉ា ។

យើងទុកឱ្យអ្នកទាំងពីរនៅទីនេះ ដើម្បីធ្វើការរបស់គេចុះ យើងបែរមកមើលនាយក្លាមវិញ គឺពេលនេះក្លាមមិនទាន់បញ្ឈប់ការងារស្រោចផ្កាបស់គេទេ អ្នកបើកបររថយន្តក្លែងក្លាយនេះ កំពុងតែបាញ់ទៅលើគុម្ពផ្កាឃីហ៊ុប ។ ស្រាប់តែមានដៃមួយលូកមកចាប់ស្មាក្លាម ធ្វើឱ្យអ្នកកំលោះក្លែងកាយងាកដោយស្វ័យប្រវត្តិមកកាន់មនុស្សដែលរំខានគេ ។អ្វីដែលគេបានឃើញ គឺជារង្វង់ភក្រ្តសើញស្វាញរបស់កំលោះសេរី ។ ម្ចាស់ធនាគាររំចង់ភ្ញាក់ស្រឡាំងកាំង ភ្លាត់មាត់ :

-ហ្អាក សេរី !

-អើ គឹក្លា ! ហើយវាស្អីអីចេះ សេដ្ឋីកំលោះមកដើរតួកម្សត់អីនៅទីនេះ ? ក្លាច្រឡំមនុស្សទេដឹង ?

ពិសិដ្ឋញាក់មុខជាសញ្ញាឃាត់កុំឱ្យសេរីនិយាយឮ គេទាញសេរី មកបាំងគុម្ពផ្ការំយោល ដោយពិសិដ្ឋនិយាយតិចៗប្រាប់កំលោះនគរបាល :

-សេរី ! ឯងកុំប្រាប់នរណាក្នុងផ្ទះនេះថា ឯងស្គាល់ក្លា និងកុំនិយាយពីប្រវត្តិពិតរបស់ក្លាណា៎ ព្រោះក្លាក្លែងខ្លួននេះ ដោយសារមានធុរៈផ្ទាល់ខ្លួន ។

ឯមាត់បង្អួចនាជាន់ទីមួយរបស់ភូមិគ្រឹះសិទ្ធា រង្វង់ភក្រ្តរបស់នរលក្ខណ៍លេចតាមចន្លោះបង្អួចដែលចំហ នេត្រារបស់ស្រីចោលសម្លឹងមកកាន់សភាពឱបក្លារវាងកំលោះនគរបាលនិងនាយក្លាម ។ សំណួរកំពុងកើតមាននៅក្នុងខួរក្បាលថាតើហេតុអ្វីគេទាំងពីរមានអាការៈស្និទ្ធស្នាលនឹងគ្នា ? នាយក្លាមត្រូវជាអ្វីនឹងសេរី ? ឋានៈរបស់ពួកគេទាំងពីរ វាមិនគួរដែលពួកគេស្និទ្ធស្នាលនឹងគ្នាដល់ម្លឹងទេ ? ប៉ុន្តែភ្លាមនោះ នរលក្ខណ៍ក៏បានឃើញបុរសទាំងពីរលោះដៃពីការឱបគ្នា ហើយសេរីបាន

ពោះជំហានដើរទៅរកទារិកាដែលកំពុងគូររូប ។ កូនស្រីលោកកិត្យាក៏ឃើញនាយក្លាមទាញទុយយោមកស្រោចផ្កា ជាបន្ត ។ នរលក្ខណ៍ស្រដីតិចៗ :

-ហេតុអីសេរីស្គាល់នាយក្លាម ?

បើយើងមកតាមដានកញ្ញាទារិកាវិញ មែនហើយ ! នាងកំពុងបន្តគូររូបគំនូរយ៉ាងផ្ចិតផ្ចង់ ជក់របស់នាងកំពុងតែវាសលើក្រដាស បែរជាលេចនូវមុខយាយមាសលើផ្ទាំងគំនូរ ទារិកាស្រឡាំងកាំងសម្លឹងទាំងភន្តភាំងទៅកាន់មុខខ្មោចស្រីដែលមានភាពដូចមនុស្សធម្មតា ទារិកាមិនច្បាស់ថា តើនាងព្រិលភ្នែក ឬមួយជារូបភាពពិតដែលជិតនៅលើក្រដាស ។ កំពុងតែកើតការមិនស្រួលក្នុងចិត្ត សំឡេងមួយលាន់មកប៉ះសោតាររបស់នាង :

-សួស្តី ទារិកា !

ទារិកាងាកមកកាន់ប្រភពសួរសៀង ឯលើផ្ទៃក្រដាសក៏រលាយបាត់រូបខ្មោចយាយមាសដែរ ។ វិចិត្រករនារីបានឃើញមុខកំលោះសេរីដែលឈរនៅក្បែរខ្លួននាង និមលស្រដីសួរអ្នកប្រុស :

-សួស្តីសេរី ។

-ខ្ញុំមានដំណឹងល្អសម្រាប់យើងណា ។

-ជាដំណឹងអីសេរី ?

-បាទ គឺខ្ញុំបានផ្លាស់មកធ្វើការនៅភ្នំពេញហើយ ទារិកាត្រេកអរទេ ?

-ចាស បើសេរីអរ ខ្ញុំត្រូវតែអរដែរហើយ ។

ចម្លើយរបស់កញ្ញារូបល្អ បណ្តាលឱ្យខួរក្បាលសេរីធ្វើការរិះគិត តើពាក្យដែលនាងថាត្រេកអរក្នុងការដែលសេរីមកធ្វើការនៅភ្នំពេញ មានបង្កប់អត្ថន័យ

បែបណា ? នេត្រាសេរីសម្លឹងទូនល្អង បាក់ភាវរកអ្វីជាចម្លើយដែលគេចង់ដឹង រួចគេសួរនាង :

-ព្រោះអីទារិកា បានជាខ្ញុំអរ នាងត្រូវអរដែរនោះ ?

ទារិកាហាក់ដូចជាចុះចាញ់ នូវអានុភាពខ្សែនេត្រារបស់កំលោះនគរបាល អំណាចអ្វីមិនដឹង ដែលបង្ខំឱ្យនាងគេចចេញពីការសម្លឹងរបស់នរៈ ។ ទារិកាធ្វើជាបែរមកមើលរូបតំនួររបស់នាង ហើយស្រីតបវាចា ក្នុងអាការៈហាក់ដូចជាមិនមានរឿងអ្វីនៅក្នុងចិត្ត :

-ព្រោះយើងជាមិត្តនឹងគ្នាហ្នឹងអី ។

ប្រហែលជាចម្លើយរបស់ទូនល្អង មានសញ្ញាអវិជ្ជមានសម្រាប់បេះដូងត្រូវការរបស់សេរីទេដឹង ទើបមាណពមានភក្ត្រស្រងូតស្រងាត់ ដោយបង្វែរការសន្ទនាទៅកាន់រឿងភាវ ដែលមានលក្ខណៈទាក់ទងនឹងការគូររូបរបស់ស្រស់ស្រីទៅវិញ ។ ស្រីល្អឆ្លងឆ្លើយជាមួយបុរសក៏ពិតមែន ប៉ុន្តែនាងព្យាយាមមិនសូវមើលចំកែវភ្នែករបស់អ្នកប្រុសទេ ហើយអ្វីៗជាបទសន្ទនារវាងគេទាំងពីរ ក៏ប្រព្រឹត្តតាមបែបយ៉ាងនេះជារហូត ដែលយើងមិនដឹងថា ពេលណាដែលពួកគេបញ្ចប់ការសន្ទនានោះឡើយ...

រាត្រីនេះ ក្ដាមស្លៀកពាក់ស្អាតបាតខុសពីសព្វដង អ្នកបើកបររូបសង្ហាឈរក្នុងអាការៈរង់ចាំនរណាម្នាក់ នៅក្បែររថយន្តរបស់នរលក្ខណ៍ ដែលចតនៅពីមុខទ្វារចេញនៃវិមានសិទ្ធា ។ សន្ទឹកយានយន្តមួយបានលាន់ស្នូរពីក្រោយខ្នងនាយក្ដាម គឺជារថយន្តរបស់កំលោះម៉ានុតតែម្ដង ។ រថយន្តក្រោយនេះបានឈប់នៅមិនឆ្ងាយពីរថយន្តនរលក្ខណ៍ ម្ចាស់យានក៏ចេញពីរថវិទ្យាសាស្ត្រ ។ ក្ដាមបានងាកមករកទិស

ដែលមានស្នូររថយន្តឈប់ គេក៏ប្រទះឃើញប្អូនជីដូនមួយ ដើរមករកគេ ក្នុងអាការៈ ម៉ានុតឱនទាញតម្រង់អាវ ទើបម៉ានុតមិនបានឃើញមុខរបស់ពិសិដ្ឋ ឬ ក្លាម ។ ពិសិដ្ឋវិញ គេភ្ញាក់ដូចជាន់ក្បាលពស់ ជាមួយចរន្តគំនិតធ្វើការរិះគិតរកវិធីនិយាយ ជាមួយម៉ានុត ក្នុងហេតុផលមិនឱ្យនរណាដឹងអំពីសមាសភាពពិតរបស់ខ្លួនគេ ។ ពិតឃើញហើយ ក្លាម ឬ ពិសិដ្ឋបានដើរយ៉ាងលឿនទៅរកម៉ានុតស្របពេលម៉ានុត ងាកមកសម្លឹងមកគេដែរ ។ មិនបង្អង់យូរពិសិដ្ឋវាចា :

-ប្អូនម៉ានុត មកណេះ ។

ឥឡូវមិនមែនតែពិសិដ្ឋទេ ដែលភ្ញាក់ផ្អើល ម៉ានុតឯណោះក៏ស្រឡាំងកាំង មិនតិចដែរ សមអីដែលបងប្រុសជីដូនមួយជាម្ចាស់ភាគហ៊ុនដ៏ធំនៃធនាគាររំចង់ បែរជាឋិតនៅក្នុងសម្លៀកបំពាក់របៀបអ្នកបើកបររថយន្តឱ្យនរណាម្នាក់ ។ម៉ានុតបន្លឺ :

-បងសិដ្ឋ ! បងស្លៀកពាក់អីយ៉ាងនេះ ហើយបងមកធ្វើអីនៅទីនេះ ?

ពិសិដ្ឋបូញមាត់ធ្វើសញ្ញាកុំឱ្យម៉ានុតនិយាយឮ នាយបានទាំងអូសដៃបង ប្រុសរបស់ម៉ានីនដើរយ៉ាងលឿន តម្រង់ទៅគុម្ពផ្កាចេកទេសដែលស៊ុបទ្រុប ។ បន្ទាប់មក ពិសិដ្ឋព្យាយាមក្នុងហេតុផលមិនឱ្យម៉ានុតធ្វើជាស្គាល់រូបគេ ហើយនឹង មិនឱ្យម៉ានុតសួរអំពីហេតុផលអ្វីទាំងអស់ ដោយម៉ានុតមានតួនាទីតែម្យ៉ាង គឺចាំ ឆ្លើយស្របនូវអ្វីដែលពិសិដ្ឋនិយាយ ។ និយាយរៀបរាប់ប្រាប់ម៉ានុតបណ្ដើរ ភ្នែក ពិសិដ្ឋសម្លឹងទៅកាន់ទ្វារផ្ទះបណ្ដើរ ចិត្តគេច្រាស់ច្រាល ភ័យក្រែងម្ចាស់ស្រីនឹង ចេញមកទាន់គេកំពុងនិយាយជាមួយម៉ានុត ។ មិនខុសពីការបារម្ភរបស់អ្នកបើកបរ រថយន្តក្លែងក្លាយឡើយ ស្រីរូបស្អាតបាននាំកាយមកដល់មាត់ទ្វារផ្ទះល្មម ។ ពិសិដ្ឋមិនបានបង្អង់យូរទេ គេធ្វើជានិយាយឮៗ ទៅកាន់ម៉ានុត :

-ក្តាមសុំគោរព តើអ្នកប្រុសម៉ានុតសុខសប្បាយដែរទេទាន ?

មុខនរលក្ខណ៍ឆ្វល់ លាយមុខគិត នាងមើលទៅពិសិដ្ឋនិងម៉ានុត នាងឮម៉ានុតឆ្លើយឮៗ តបទៅក្តាម :

-យើងសុខទេនាយក្តាម ។

រួចម៉ានុតងាកមកក្រោយ ដោយម៉ានុតញញឹមដាក់នាង ទាំងនិយាយ :

-សួស្តីអ្នកនាងលក្ខណ៍ ។

នរលក្ខណ៍សម្រួលមុខ នាងញញឹម វាចា :

-ចាស សួស្តីលោកម៉ានុត ។ យើងអាចទៅបានទេ ?

-បាទ បានតើអ្នកនាង ។

ម៉ានុតដើររកយានជំនិះរបស់គេ ។ ពិសិដ្ឋបើកទ្វារយានជូននរលក្ខណ៍ នាងចូលអង្គុយក្នុងរថយន្ត ។ រថវិទ្យាសាស្ត្រទាំងពីរបោះពួយសំដៅទីដៅ ដែលម្ចាស់វាបានកំណត់ ។ ទីនោះគឺជាភោជនីយដ្ឋាន ។

នៅតុមួយ ក្នុងភោជនីយដ្ឋាន ពិសិដ្ឋអង្គុយមើលមកនរលក្ខណ៍ ដែលអង្គុយទល់មុខម៉ានុត ពិសិដ្ឋឃើញម៉ានុតចាប់ម្ហូបដាក់ចាននរលក្ខណ៍ ឃើញម៉ានុតញញឹមដាក់នាង ឃើញនរលក្ខណ៍ញញឹមមើលម៉ានុត ។ ពិសិដ្ឋគិតថា ពួកគេមានការស្និទ្ធស្នាលនឹងគ្នា ។ រួចមិនដឹងជាមូលហេតុអី ពិសិដ្ឋស្រាប់តែមានកំហឹងសម្ងាត់ លបកើតក្នុងទ្រូង ។ គេមិនចង់ឱ្យអ្នកទាំងពីរមានផ្អែមល្ហែមយ៉ាងនេះទាល់តែសោះ ។ គេដូចជាច្រណែនជាមួយម៉ានុត មុខបុរសមើលមកនរលក្ខណ៍ដោយមួហ្មង ។ ជួនជានួនល្អងលបចោលនេត្រាមើលពិសិដ្ឋ នាងឃើញមុខគេមើលមកនាង ជាមុខក្រញូវ ។ នាងភ្ញាក់ នាងមានរំញោចក្នុងចិត្ត ដៃនាងដូចជាត្រជាក់ស្រេក បេះដូងដូចជា

ប្រហោងធ្មុង ... មាណវីមិនដឹងតើអ្វីដែលកើតមានចំពោះនាយក្ដាមទេ បានជានរៈមានទឹកមុខអាក្រក់មើលម៉្លេះពេលគេចោលនេត្រាមករករូបស្រី តែអារម្មណ៍នាងដូចជាប្រាប់ថា កំលោះអ្នកបើកបររថយន្តមិនសប្បាយចិត្តដែលនាងស្និទ្ធស្នាល ជាមួយម៉ានុត ។ ចុះគេមានសិទ្ធិអ្វីដែលអាចមកបង្គាប់នាង ? តែស្រីហាក់ដូចជាចង់បំពេញចិត្តគេដែរ ។ នាងកំពុងគិតថា នាងមិនគួរធ្វើអ្វីដែលស្និទ្ធស្នាលជាមួយម៉ានុតឡើយ ។

កាលបើឃើញចៅហ្វាយស្រីងាកមកចំភក្ត្រ ពិសិដ្ឋក៏ងើបពីតុ ដើរទៅខាងក្រៅភោជនីយដ្ឋាន ធ្វើវាហឺ ។ មុខនរលក្ខណ៍ឆ្ងល់លាយគិត នាងរាវរកចម្លើយពីអាកប្បកិរិយារបស់នាយក្ដាម ។

ចំណែកម៉ានុតវិញ នរៈមិនបានចាប់អារម្មណ៍ពីនរលក្ខណ៍ ឬ ពិសិដ្ឋទេ នាយកំពុងតែដួសអាហារ មកបរិភោគ ដោយសភាពធម្មតា ។

នៅឯខាងក្រៅភោជនីយដ្ឋានឯណោះ ពិសិដ្ឋកំពុងយារដៃដាល់ដើមឈើមួយដើមដែលនៅជិតរថយន្តរបស់នរលក្ខណ៍ ដៃគេឡើងជាំខៀវ ក៏គេមិនខ្វីរវល់លើកដៃរបូសមកមើលឡើយ ។ គេខាំមាត់ ទប់ទល់ជាមួយក្ដីស្រឡាញ់រូបស្រស់ស្រី និងគំនុំដែលគេត្រូវសងសឹកជំនួសលោកយាយតូច ។ គំនិតពីរនេះកំពុងច្បាំងគ្នា ក្នុងការដណ្ដើមទីតាំងដួងចិត្តគេហើយ ។ ពិសិដ្ឋរាវរក មិនដឹងជ្រើសរើសយកមួយណា ។ ភ្លាមនោះស្រទាប់ផ្កាឈូកជាច្រើនបានផុសនៅពីមុខគេ អង្គកាយទេវតាស្រីផុសមកជាមួយគំនរផ្កាឈូកទាំងនោះ ។ ពិសិដ្ឋងាកឃើញព្រះនាងទេវតា ស្របពេលទេវតាទ្រង់ព្រះសម្រួលដាក់គេ ភ្ជាប់ព្រះសុរ័ណ្ណនីយ :

-នាយក្លាម ! ហេតុអីអ្នកប្រើអារម្មណ៍ ។ អ្វីទាំងអស់វាមានហេតុមានផលណា៎ ។

ពិសិដ្ឋមើលទេវតា គេនិយាយទាំងមុខមួម៉ៅ :

-ព្រះនាងទេវតាទ្រង់ជ្រាបទេថា ខ្ញុំនេះកំពុង...

-ហេតុអីខ្ញុំមិនដឹង អ្វីនៅក្នុងចិត្តអ្នក កំពុងដូចអំបោះជំពាក់ អ្នកត្រូវស្រាយវាដោយម្តងបន្តិច នោះអ្នកនឹងរកមុខអំបោះឃើញណា៎ ។ ខ្ញុំលាហើយ ។

ស្រទាប់ផ្កាឈូករលាយទៅភ្លាម ហើយរូបកាយទេវតារលាយបាត់ដែរ ។ ពិសិដ្ឋមីងមាំង មិនយល់ពីអ្វីជាអត្ថន័យរបស់ព្រះសុវណ្ណនីយនៃទេវតា ។ គេឈររិះគិតម្នាក់ឯង ដោយរកចម្លើយមិនឃើញឡើយ ។ តែយ៉ាងណា គេនឹងព្យាយាមរកឱ្យទាល់តែឃើញ នាពេលខាងមុខ ។

នៅខាងក្នុងភោជនីយដ្ឋាន ម៉ានុតចោលនេត្រាមើលនរលក្ខណ៍ គេឃើញស្រីមានមុខភាំង អង្គុយភ្លឹកដូចគ្មានវិញ្ញាណ ម៉ានុតក៏ស្រដី :

-អ្នកនាង ! តើអាហារមិនឆ្ងាញ់អ្ហេះ ?

នរលក្ខណ៍ភ្ញាក់ នាងសម្រួលទឹកមុខ រួចសួរម៉ានុត :

-អត់ទោស លោកសួរអ្វី ?

-បាទ ខ្ញុំសួរថា អាហារនៅទីនេះមិនឆ្ងាញ់មែនទេអ្នកនាង ?

នរលក្ខណ៍ញញឹម នាងគ្រវីក្បាល វាចា :

-ចាស អត់ទេ ទីនេះអាហារឆ្ងាញ់ណាស់ តែខ្ញុំមានរឿងមួយចង់ជម្រាបសួរលោក តែខ្ញុំមិនដឹងគួរ ឬ មិនគួរសួរលោក ក្នុងពេលនេះទេ ?

-អ្នកនាងអាចសួរខ្ញុំបានគ្រប់បញ្ហា ដែលអ្នកនាងចង់សួរ ។

-អ៊ីចឹង ខ្ញុំសុំទោសលោកម៉ានុតណាំ ដោយខ្ញុំចង់ដឹងពីអាសយដ្ឋានលោកដាវុធ ។ តើលោកម៉ានុតអាចប្រាប់ខ្ញុំផងបានទេ ?

-បាទ បានតើ ។

ម៉ានុតដកនាមបណ្ណមួយសន្លឹក ពីកូនកាបូបហុចមកឱ្យនាង ភ្ជាប់សម្តី :

-នេះជាអាសយដ្ឋានរបស់គេអ្នកនាង ។

នរលក្ខណ៍ទទួលនាមបណ្ណមួយសន្លឹកដៃពីអ្នកប្រុស ស្រដី :

-ខ្ញុំសុំអរគុណលោកម៉ានុត ។

ម៉ានុតសើច និយាយទាំងមើលមុខនាង :

-តែខ្ញុំមិនមែនត្រូវការតែពាក្យប៉ុណ្ណឹងទេណាំ ។

-តើលោកត្រូវការអ្វី ?

-ពេលនេះ ខ្ញុំនឹកមិនទាន់ឃើញទេ ចាំពេលណាខ្ញុំនឹកឃើញ ខ្ញុំនឹងទារពីអ្នកនាង ។

-ប្រសិនមិនមានបញ្ហាហួសពីសមត្ថភាពខ្ញុំទេ ខ្ញុំមិនបដិសេធឡើយ ។

.......................................................................................................

.......................................................................................................

យប់ដដែល ក្នុងបន្ទប់នរលក្ខណ៍ វេលារំលងអាធាត្រទៅហើយ យើងឃើញនាងនាថតេងលើពូក ពោរពេញទៅដោយភក្ត្រស្រងូតស្រងាត់ ។ ស្រីប្រែកាយចុះប្រែឡើង ហាក់ដូចជាស្ទុះស្ទាប់ក្នុងប្រាណ ។ ម៉ាស៊ីនត្រជាក់ក្នុងបន្ទប់ មិនបានជួយឱ្យចិន្តានិមលរហោយទូវការរោលរាលក្នុងចិត្តទេ វាគ្រាន់តែបង្កភាពត្រជាក់លើរាងកាយតែប៉ុណ្ណោះ ។ កល្យាណបង្កើរអារម្មណ៍ស្រមៃឃើញពីទឹកមុខ និង

អាកប្បកិរិយាអ្នកបើកបររបស់នាង នារាត្រីដែលពិសិដ្ឋឱបនាង ដែលគេបានជួយនាងឱ្យផុតពីរថយន្តបុក នាងទទួលអារម្មណ៍ថា គេព្រួយបារម្ភពីនាង គេយកចិត្តទុកដាក់មកលើនាងយ៉ាងចម្លែក ហើយនាងមានអារម្មណ៍កក់ក្ដៅ ដែលកាលណោះនាងនៅកៀកកិតកាយគេ ។បន្ទាប់មក នាងស្រមៃពីរង្វង់មុខហ្មងដែលបុរសសម្លឹងមើលមកនាង នាគ្រាស្រីកំពុងញ៉ាំអាហារជាមួយម៉ានុត ។ មុខពិសិដ្ឋពេលនោះមានអានុភាពសម្ងាត់មកបញ្ឆោចិត្តនាង ឱ្យក្រែងរអែងចិត្តគេ ធ្វើឱ្យនាងចង់ធ្វើអ្វីដែលជាប្រការយកចិត្តគេ ។ នាងមិនយល់ចិត្តខ្លួនឯង ។ នាងគ្មានចម្លើយច្បាស់លាស់ពីអ្វីទាំងនេះ ដែលកំពុងកប់ក្នុងទ្រូងស្រី ។

ឯក្នុងបន្ទប់ទឹកមួយ ដែលនៅក្នុងបន្ទប់គេងរបស់យីហ៊ុបឯណោះ កញ្ញាយីហ៊ុបកំពុងឈរមុខកញ្ចក់ ដើម្បីលាបម្សៅសម្រាប់មុនពេលចូលដំណេក ព្រោះមុននេះបន្តិច នាងទើបតែវិលមកវាំកម្សាន្តនៅឱស្ថតែតមួយ ។ ស្រីមើលមុខខ្លួននាងក្នុងកញ្ចក់ ស្រាប់តែមុខនាងប្រែក្លាយជាមុខខ្មោចយាយមាសទៅវិញ ។ យីហ៊ុបភ្ញាក់ព្រើតលាយឡំដោយចម្ងល់ នាងដូចជារអើលព្រឺសម្បុរយ៉ាងម៉េចមិនដឹងទេ ស្រីស្ទុះថយ ហើយងាកមកក្រោយរបៀបរកមើលយាយមាសដែលជិតរូបលើកញ្ចក់ តែគ្មាននរណាសោះ ... អត់ឃើញមានមនុស្សទេ ។ មិនអស់ចិត្ត យីហ៊ុបងាកមកមើលឯកញ្ចក់វិញ នាងក៏ឃើញមុខខ្មោចយាយមាសក្នុងភាពដូចមនុស្សធម្មតា ឆ្លុះជិតនៅក្នុងកញ្ចក់ដដែល ។ រោមបះក្រញាង យីហ៊ុបងាកមកមើលក្រោយខ្នងម្ដងទៀត ។ ខាងក្រោយខ្នងនាង ... មិនមាននរណាឡើយ ... អត់មានមនុស្សមែន ។ យីហ៊ុបស្រឡាំងកាំង នាងភ័យឥតឧបមា រត់ត្របាញ់ជើងមកក្រៅបន្ទប់ ទាំងស្រែកដោយញាប់ញ័រ :

-ខ្មោចលង ម៉ាក់អើយជួយផង ។

កល្យាណរត់យ៉ាងលឿនស្លោស្លន់សំដៅមករកបន្ទប់មាតា ។ យើងទុកឱ្យនាងរត់គេចពីបិសាចមាសសិនចុះ ហើយមើលបែរមកមើលសូគិាវិញ យើងក៏ឃើញអ្នកស្រីកំពុងអង្គុយបូកបញ្ជីលុយកាក់របស់សណ្ឋាគារទីបី ដែលមានរូបអ្នកស្រី ជាអ្នកទទួលខុសត្រូវ ជាមួយនរលក្ខណ៍ វេហានិងយីហ៊ុប ។ ស្រាប់តែអ្នកស្រីភ្ញាក់ដូចគេទះមួយដៃដោយមិនដឹងខ្លួន ព្រោះនៅលើសៀវភៅបញ្ជី ក៏បែរជាលេចរូបយាយមាសបើកភ្នែកធំក្រឡោត សម្លក់មកកាន់សូគិា ។ សូគិាឆ្ងល់ផង ភ័យផងខំប្រឹង សម្លឹងមើលរូបយាយមាសជាថ្មី ។ ស្រាប់តែ មាត់ខ្មោចបាជង្គ្រុង សើចទាំងលៀនអណ្តាតមកផង លាន់សំឡេងកងរំពងខ្ទរត្រចៀកសូគិា :

-ហាស់ ហាស់ ... ហាស់ ហាស់ ...

សូគិាភ័យណាស់ ញ័រជើងទទ្រើត បេះដូងលោតស្ទើរធ្លាយទ្រូង អ្នកស្រីរត់រឹងទៅក្រៅបន្ទប់ ទាំងស្រែកដង្ហោយរកមនុស្សជួយ :

-ខ្មោចលង ! ជួយផង ! ខ្មោចលង !

សូគិារត់មកក្រៅ គាត់រត់មកជួបយីហ៊ុបដែលរត់មកគាត់ ។ ដោយសារសំឡេងដ៏ខ្លាំងរបស់គាត់ ក៏បណ្តាលឱ្យលោកកិត្យា អ្នកស្រីមាណវី លោកជំនោរអ្នកស្រីតារា វេហា នាងទារិកា នាងសយ នាងមឿន ពូឆន ផ្អើលរត់មករកយីហ៊ុបនិងអ្នកស្រីសូគិា ដោយព្រមគ្នា ។ យល់អាការៈអ្នកស្រីសូគិានិងយីហ៊ុបកំពុងមានភាពភិតភ័យ ស្លោស្លន់ រញ៊ីរញ៉េរ ដោយកំពុងរត់បែបមិនមើលទិសតំបន់នោះលោកជំនោរស្រែកសួរសូគិា :

-ប្អូនសូគិា ក្មួយយីហ៊ុប តើមានរឿងអី បានជារត់ផង ស្រែកឡូឡាផង ?

-តើផ្ទះសិទ្ធាមាន ...មាន ...ខ្មោចលង ។ ខ្មោចលងខ្ញុំណាបង ។ ខ្ញុំខ្លាច ... ខ្លាចណាស់ ។

យីហ៊ុបរត់ដល់ចំពោះមុខមនុស្សទាំងអស់ នាងមានមុខភ័យ រញ៉េរញ៉ៃ បបូរមាត់នាងកម្រើកស្ទើរមិនចេញសំឡេង ទាំងភ្នែករេគ្រប់ទិសទី :

-ជួយខ្ញុំផង ខ្មោចលង...ខ្មោចលងខ្ញុំ ។ ខ្ញុំខ្លាច...ខ្លាច ។

យីហ៊ុបសសុលចូលទៅក្នុងចំណោមមនុស្សទាំងនោះ នាងឈររញ៉េរខ្លួន ភ្នែកងាកទៅឆ្វេងម្តង ម្តងងាកទៅស្តាំ នាងខ្លាចខ្មោចដេញមកតាមលងបន្ទាចទៀត ។ អាកប្បកិរិយាសួគ៌ាក៏មានសភាពមិនខុសពីកូនស្រី ។ ទាំងម្តាយទាំងបុត្រីស្ទុះសម្រុកទៅឈរនៅកណ្តាលចំណោមមនុស្សទាំងអស់ ដើម្បីជាទីរពឹងនិងការពារពួកគេ ។ មនុស្សដែលឈរនៅទីនេះ ទៅជាមឹងមាំង មិនយល់ពីអ្វីដែលគេទាំងពីរនាក់បាននិយាយ...ហើយលោកស្រីតារាដែលឈរជិតសួគ៌ា គាត់ក៏ចាប់ស្មាសួគ៌ា ដើម្បីទប់កាយសួគ៌ាឱ្យឈរស្ងៀម រួចតារាសួរប្អូនថ្លៃ :

-សួគ៌ា ! តើជាខ្មោចស្រីមែនទេ ?

-មែនហើយ ជា...ជាខ្មោចស្រី ។ ខ្ញុំខ្លាច...ជួយខ្ញុំផងបងតារា ។ "សួគ៌ា"

មុខតារាគិត អ្នកស្រីងាកមើលលោកជំនោរនិងកូនប្រុសវេហា របៀបបញ្ជាក់ថា ពួកគេទាំងបីនាក់ក៏ធ្លាប់ជួបសភាពដូចជាខ្មោចលងបន្តិច ជាការយល់សប្តិបន្តិច ។ ស្វាមីនិងកូនប្រុសរបស់តារា បង្ហាញពីទឹកមុខយល់ស្របការគិតរបស់អ្នកស្រីតារា ។ ចំណែកអ្នកស្រីមាណវីទាញយីហ៊ុបក្រសោប គាត់ពោលលួងលោម:

-អត់មានខ្មោចទេក្មួយយីហ៊ុប ។ ក្មួយកុំខ្លាចណា ។

យីហ៊ុបឱបដៃមាណវី វាចា :

-តែខ្ញុំត្រូវខ្មោចលងមែនអ៊ំស្រី ។ "នាងងាកមកម្ដាយ ទាំងស្ទុះមកជិតម្ដាយ ស្រីស្រដី" ...ម៉ាក់ ! យប់នេះ ខ្ញុំសុំគេងបន្ទប់ជាមួយម៉ាក់ដែរ ខ្ញុំខ្លាចណាស់ ។

-ខ្មោចអី ! ប្អូនសួគ៌ា និងក្មួយយីហ៊ុបស្រមៃទេដឹង . " លោកកិត្យា "

-តែខ្ញុំក៏ដូចជាធ្លាប់ខ្មោចលងដែរបងកិត្យា ។ "អ្នកស្រីតារា "

នរលក្ខណ៍និងពិសិដ្ឋដើរចូលមកដល់ក្រោយគេ ។ ពិសិដ្ឋយល់ពីសភាពច្របូកច្របល់ដែលលោកយាយមាសបង្កការរឹកវរក្នុងវិមានមាស ឬ វិមានសិទ្ធានរៈមិនស្ដីអ្វីទេ គេបានត្រឹមតែលបដកដង្ហើមធំ ក្នុងទឹកមុខស្រងូតស្រងាត់ គេលួចចោលភ្នែកមើលទៅគ្រប់មនុស្សទាំងអស់ ដែលឈរនៅទីនេះ ។ គេលួចបារម្ភ លួចអាណិតពីវាសនាអ្នកទាំងនេះ ដែលមិនដឹងជាពេលណានឹងត្រូវលោកយាយតូចមកយាយីធ្វើបាប ដោយប្រការបែបណាទេ ។ នរលក្ខណ៍ដើរទៅជិតយីហ៊ុបនិងម្ដាយយីហ៊ុប ដោយនរលក្ខណ៍ពោលវាចា :

-តើមានរឿងអីប្អូនយីហ៊ុប ?

-ខ្មោចលងខ្ញុំណ៎ាបងលក្ខណ៍ ។

-ខ្មោចលង ! "នរលក្ខណ៍ពោលទាំងមុខឆ្ងល់ "

លោកកិត្យាមិនជឿនូវបញ្ហាថា មានខ្មោចលងនោះទេ គាត់គ្រវីក្បាល បន្ទឺទៅកាន់ពួកអ្នកបម្រើ :

-ពួកឯងបំបែកគ្នាទៅដេកវិញទៅ ។

អ្នកបម្រើទាំងអស់គ្នាដើរចេញ ទាំងពួកគេមានការរិះគិតនិងដូចជាជឿបន្តិច មិនជឿបន្តិច ។ កិត្យាបែរមកសួគ៌ា រួចលោកងាកទៅតារា ដោយលោកនិយាយ :

-យើងមិនរំខានអ្នកប្អូនទាំងពីរនិយាយទេ ។ ណ្ហើយ ! ពួកយើងក៏ត្រូវទៅសម្រាកដែរ ។

សមាជិកគ្រួសារសិទ្ធាទាំងអស់ក៏ដើរទៅរកបន្ទប់ដំណេករៀងខ្លួន ។ តែអ្វីដែលមានក្នុងចិត្តពួកគេម្នាក់ៗ ប្រាកដជាមិនច្បាស់លាស់ ពីការដែលថា មានខ្មោចលងមនុស្សក្នុងវិមានសិទ្ធា ព្រោះលើកលែងតែលោកកិត្យានិងអ្នកស្រីមាណេរីតី អ្នកទាំងនោះមានលោកជំនោរ អ្នកស្រីគុណរ៉ា នាងទារិកា វេហា ឃីហ៊ុប អ្នកស្រីសួគ៌ា ព្រមទាំងនរលក្ខណ៍ផង ពួកគេដូចជាបានជួបនឹងហេតុការណ៍ចម្លែក ដែលកើតឡើងមកលើរូបពួកគេ ។ តែសម័យនេះទៅហើយ ពិតជាមានខ្មោចឬអី ? នាយក្លាមវិញគេយាត្រាបណ្ដើរ រិះគិតរកវិធីដោះស្រាយវិវាទរវាងលោកយាយតូច និងកូនចៅរបស់គ្រួសារលោកឧកញ៉ាបណ្ដើរ ។ ថ្វីបើនាយត្រូវការទាមទារយុត្តិធម៌ តែគេមិនត្រូវការចង់ឱ្យលោកយាយសម្លាប់មនុស្សក្នុងវិមាននេះម្ដងម្នាក់ ជាបន្តបន្ទាប់ រហូតទាល់តែសាបសូន្យគ្រួសារសិទ្ធាដែរ ។

.................................................................................................................

.................................................................................................................

ពេលថ្ងៃ នាមុខផ្ទះម៉ានុត យើងឃើញម៉ានុត និងម៉ានីនដើរទៅរករថយន្ត ទាំងម៉ានុតនិយាយទៅកាន់ម៉ានីន :

-បងមានដំណឹងល្អសម្រាប់អូនទីន ។

-តើជាដំណឹងអីបងនុត ?

-បងដឹងពីទីកន្លែងនៅរបស់បងសិដ្ឋណា ។

-បងប្រាប់ខ្ញុំភ្លាមមក ខ្ញុំទឹកបងសិដ្ឋណាស់ណា ។

-អូនចាំមួយភ្លែតណា ទើបបងប្រាប់ពីទីកន្លែងរស់នៅរបស់បងសិដ្ឋ ។ ព្រោះបងត្រូវមានកិច្ចការបងទូរសព្ទទាក់ទងទៅដារ៉ុធសិន ។

និយាយចប់ ម៉ានុតលើទូរសព្ទផ្ទាប់ត្រចៀក និយាយទៅកាន់ចុងខ្សែម្ខាងភ្លាម :

-អាឡូដារ៉ុធ ! គ្នាមានកិច្ចការត្រូវទាក់ទងជាមួយឯង ។

បុរសបាននិយាយរៀបរាប់ពីគោលបំណងនរលក្ខណ៍ .ដែលនាងត្រូវការដារ៉ុធ ដើម្បីទទួលគម្រោងសាងសង់ផ្ទះសំណាក់ទាំងដប់នាងនៅទីក្រុងកែប ។ វិស្វករដារ៉ុធបានទទួលការណាត់ជួបជាមួយចៅសំណព្វរបស់សពលោកតា ទាំងរីករាយ ។ ទីបំផុត ដារ៉ុធបានផ្ដល់ការណាត់ជួបកញ្ញាសិទ្ធា នរលក្ខណ៍នារសៀលនេះនៅគេហដ្ឋានរបស់នាង ។ ក្រោយពីនិយាយទូរសព្ទជាមួយដារ៉ុធរួចរាល់ ទើបម៉ានុតបែរមករ៉ាយរ៉ាប់ពីទីកន្លែងរស់នៅ និងដំណើររឿងក្លែងកាយរបស់បងជីដូនមួយប្រាប់មកប្អូនស្រី ។ ម៉ានីនត្រេកអរណាស់ នាងសន្យាមិនទម្លាយអាថ៌កំបាំងរបស់ពិសិដ្ឋ ឱ្យនរណាបានដឹងឡើយ ហើយនាងនឹងទៅរកពិសិដ្ឋនាពេលឆាប់នេះ ដើម្បីបំបាត់ការនឹករឮកចំពោះបុរសដែលបេះដូងនាងត្រូវការ ។

ក្នុងបន្ទប់ធ្វើការរបស់នរលក្ខណ៍ក្នុងវិមានសិទ្ធា វិស្វករដារ៉ុធអង្គុយចុះលើកៅអីទល់មុខម្ចាស់វិមានសិទ្ធា ទាំងភក្ត្របុរសញញឹម សម្លឹងទៅមុខធីតា ។ ក្រមុំរូបស្រស់ញញឹមពព្រាយ ភ្ជាប់ស្នាមញញឹមជាប់បបូរមាត់ ស្រដី :

-សូមអញ្ជើញអង្គុយលោកដារ៉ុធ តើលោកសុខសប្បាយទេ ?

-បាទ សុខទុក្ខជាធម្មតា ។ ចុះអ្នកនាងនរលក្ខណ៍អញ្ជើញមកពីជប៉ុនពីអង្កាល់ ?

-ចាស ខ្ញុំមកដល់ស្រុកយើង ចំនួនពីរបីខែហើយលោក ។

-អត់ទោស ផ្ទះរបស់លក្ខណ៍មានឈ្មោះវិមានសិទ្ធា ឬ វិមានមាស ?

-អ្នកណាប្រាប់លោកថា ផ្ទះខ្ញុំឈ្មោះ វិមានមាស ?

-គឺប្រុសអ្នកស្រោចផ្កាម្នាក់ ជាអ្នកប្រាប់ខ្ញុំ ។

-អូ ! គឺគេទេតើ ។ គេម្នាក់នោះស្រឡាញ់ឈ្មោះវិមានមាសណាស់ តែផ្ទះខ្ញុំមានឈ្មោះថា វិមានសិទ្ធាណាំលោកដារ៉ុធ ។

-អូ ! អីចឹងទេ ។

បន្ទាប់មកនរលក្ខណ៍ក៏ដកប្លង់សាងសង់ផ្ទះសំណាក់មកឱ្យដារ៉ុធ ហើយដារ៉ុធក៏ពិនិត្យប្លង់សាងសង់នេះ ជាមួយនាង ។ អ្នកទាំងពីរនិយាយគ្នា ពីគម្រោងក្នុងការសាងសង់ ។ នៅខាងក្រៅបន្ទប់ធ្វើការរបស់នរលក្ខណ៍ ដែលមានទ្វារចំហបន្តិច សូតិកាំពុងពួនលបមើលមកដារ៉ុធ និងនរលក្ខណ៍ ។ អ្នកស្រីសូតិមូម៉ៅដែលកញ្ច្រូបស្អាតបានក្លាយជាម្ចាស់គម្រោងសាងសង់ដ៏ធំ ដែលជាសម្បត្តិរបស់គ្រួសារសិទ្ធា ដែលមានអ្នកស្រីជាសមាជិកមួយរូបដែរ តែមិនមានសិទ្ធិនឹងរួមចំណែកទទួលដឹងឮអ្វីបន្តិច អំពីការសាងសង់ខាងលើនេះ ។ បន្តិចក្រោយមក សូតិាដើរចេញពីទីពួន ដោយដក់ជាប់នូវផែនការខ្មៅមួយ ដើម្បីធ្វើបាបកូនស្រីលោកកិត្យា ។ អ្នកស្រីសូតិាទើបតែចាកចេញពីទីពួនលបបានបន្តិច ស្រាប់តែលេចមុខលោកជំនោរនិងលោកស្រីតារាដើរលប១ មកពួនស្តាប់ការជជែករវាងដារ៉ុធនិងនរលក្ខណ៍ ពីផែនការសាងសង់ផ្ទះសំណាក់ទាំងដប់ដែរ ។ ទឹកមុខស្វាមីនិងភរិយាទាំងពីរនាក់នេះមានភាពច្រណែនឬស្យាដិតដាមយ៉ាងខ្លាំង ។ គំនិតពួកគេ មិនខុសពីសូតិាទេ

គេមានត្រៀមកលល្បិចនឹងធ្វើបាបនរលក្ខណ៍ តាមវិធីព្រៃផ្សៃមួយ នាពេលមិនយូរប៉ុន្មានខាងមុខនេះ ។

# វគ្គ ទី ១០

អង្គុយលើកៅអីក្នុងបន្ទប់ការិយាល័យនៃសណ្ឋាគារទីបី សួគិតាពោលដោយវាចាម៉ឺងម៉ាត់ទៅកាន់បុត្រី :

-គឺថ្ងៃនេះ យើងនឹងប្រើល្បិចកំចាត់នាងលក្ខណ៍ណ៎ាកូន ។

-ចាស ម៉ាក់ តែប៉ុណ្ណោះនាងលក្ខណ៍មុខជាក្លាយជាមនុស្សញៀនថ្នាំឆ្កួតនៅពេលឆាប់ៗនេះ ជាមិនខាន។

ឯក្នុងការិយាល័យនៃសណ្ឋាគារទីពីររបស់គ្រួសារសិទ្ធាម្តង គឺមានលោកជំនោរ លោកស្រីតារាភានិងកូនប្រុសវេហាអង្គុយពិចារណា ក្នុងការរៀបផែនការធ្វើបាប ទរលក្ខណ៍ ។ លោកជំនោរស្តីទាំងមុខជោកជាំដោយកំហឹង :

-ឯងត្រូវចាប់រំលោភនាងលក្ខណ៍ ដើម្បីឱ្យនាងលក្ខណ៍បានរៀបការជាមួយឯង ហើយបន្ទាប់មកទៀត ឯងត្រូវរកវិធីធ្វើយ៉ាងណាឱ្យទ្រព្យសម្បត្តិទាំងអស់របស់គ្រួសារនាងលក្ខណ៍ព្រមទាំងវិមានសិទ្ធា ធ្លាក់មកក្នុងកណ្តាប់ដៃឯង ។ បន្ទាប់ពីចាត់ការខាងគ្រួសារនាងលក្ខណ៍ហើយ សឹមយើងបែរមកកំចាត់គ្រួសារប្អូនសួគិតាវិញម្តង ។

-ខ្ញុំយល់ហើយប៉ាម៉ាក់ តើឱ្យខ្ញុំ ...

ពេលដែលវេហាទើបតែនិយាយបានត្រឹមនេះ ទារិកាដើរមកដល់ខាងក្រៅបន្ទប់ នាងឮសម្លេងវេហាលាន់តិចៗមកប៉ះសោតាស្រី :

-តើឱ្យខ្ញុំចាត់ការនាងលក្ខណ៍អង្កាល់ លោកប៉ា ម៉ាក់ ?

-យប់នេះតែម្តងទៅកូន ។

ស្តាប់ដឹងពីកលល្បិចសាមាន្យរបស់បិតាមាតានិងបងប្រុសហើយ ស្រស់ស្រី មានភក្រ្តស្លូតចៃស នាងមិនយល់ពីទឹកចិត្តអ្នកទាំងបី ហេតុអីបែរជាកើតមានគំនិតខ្មៅកខ្វក់បែបនេះ ? នាងពិបាកក្នុងចិត្តមែនទែន មិនដឹងតើស្រីត្រូវនៅស្ងៀម ដោយបណ្តោយឱ្យមាតាបិតានិងបងប្រុសប្រព្រឹត្តនូវទង្វើថោកទាបជាតិសាមាន្យនេះ ឬ ក៏នាងត្រូវរារាំង ? ខួរក្បាលកល្យាណធ្វើការមិនឈប់ឈរ នាងប្រាកដជាពិបាកក្នុងការសម្រេចចិត្ត ។

ពេលវេលាដែលគួរខ្លាចសម្រាប់នរលក្ខណ៍មកដល់ហើយ ព្រោះពេលនេះវិញ្ញាណទី៦របស់ពិសិដ្ឋកំពុងតែប្រាប់គេ ដោយក្នុងអារម្មណ៍ពិសិដ្ឋលេចចេញនូវរូបភាពឃើញហ៊ុបដាក់ថ្នាំញៀនក្នុងកែវទឹកក្រូច បន្ទាប់មកលេចចេញរូបរេហាដាក់ថ្នាំងុយគេងក្នុងកែវ ។ ពិសិដ្ឋមានការភិតភ័យ គេព្រួយបារម្ភជូនស្រីជាទីប្រាថ្នា អ្វីដែលជាគំនុំកប់ក្នុងចិត្ត ស្រាប់តែមិនដឹងរត់ទៅណា ហើយជំនួសមកដោយការជ្រួលច្រាលក្នុងចិត្តបុរស រហូតបាត់ការគ្រប់គ្រងអារម្មណ៍ ដែលគេភ្លាត់មាត់ស្រែកតែឯង :

-អ្នកនាងលក្ខណ៍ ! ខ្ញុំត្រូវជួយនាង ។

តែភ្លាមនោះ រូបភាពខ្មោចយាយមាសដែលធ្លាប់ស្រែកយំដោយក្តីឈឺចាប់ក្នុងការទាមទារយុត្តិធម៌ ក៏ផុសមកក្នុងចិន្តាគេដែរ ។ ពិតជាពិបាកកំណត់ចិត្ត តើគេត្រូវធ្វើបែបណា ? បើតាមសម្បជញ្ញៈជាមនុស្សឈរលើភាពត្រឹមត្រូវ គេគួរជួយនរលក្ខណ៍ឱ្យផុតពីការព្យាបាទរបស់មនុស្សចិត្តអាក្រក់ទាំងនោះ ទេ ! មិនត្រូវជួយទេ ព្រោះនាងជាចៅរបស់សត្រូវលោកយាយ ហើយបើគេមិនជួយនរលក្ខណ៍ទេនាងនឹងត្រូវទទួលការរងគ្រោះ ដែលជាប្រការសមស្របនូវបំណងធ្វើបាបសមាជិក

គ្រួសារសិទ្ធា ដែលធ្លាប់ធ្វើអំពើអយុត្តិធម៌មកលើលោកយាយតូចរបស់គេ ។ ពិសិដ្ឋមិនអាចសម្រេចចិត្តថា ត្រូវធ្វើយ៉ាងម៉េចឡើយ ។ កំពុងស្ថិតក្នុងចន្លោះពីរនៃការសម្រេច ផ្កាឈូកជាច្រើនក៏ផុសមកជាមួយរូបកាយព្រះនាងទេវតាលេចចេញមក ។ ព្រះឧស្សទេវតាលាន់ជាប្រយោគ :

-ពិសិដ្ឋ ! ការសម្រេចចិត្តរបស់អ្នកនៅថ្ងៃនេះ ជាការសម្រេចនូវវាសនារបស់មនុស្សម្នាក់ ។

មានព្រះសុវណ្ណនីយតែប៉ុន្មានពាក្យនេះ ទេវតាក៏រលាយបាត់រូបទៅ ដោយពិសិដ្ឋមិនទាំងមានឱកាសបានទូលសួរនាំអ្វី ទៅកាន់ព្រះនាងផង ។ អត្ថន័យព្រះសុវណ្ណនីយទេវតា បានជម្រុញឱ្យមានការពិចារណាជាថ្មី ដល់នរៈ ។

ឯក្នុងបន្ទប់ការិយាល័យរបស់នរលក្ខណ៍ មានវត្តមានកញ្ញាយីហ៊ុបអង្គុយទល់មុខបងស្រីជីដូនមួយ ។ កូនស្រីរបស់អ្នកស្រីសូតាញញឹមដោយមុខស្លូត ស្រដីទៅកាន់នរលក្ខណ៍ :

-បងលក្ខណ៍ ខ្ញុំមកសុំទោសបង ដែលពីថ្ងៃមុន ខ្ញុំមានអាកប្បកិរិយាមិនគាប្បីទៅលើបងណាស់ ។

-ទេ ! យីហ៊ុបដូចជាមិនដែលមានធ្វើអី ដូចដែលអូននិយាយឯណា ។

-បើបងនរលក្ខណ៍មានអារម្មណ៍បែបនេះ ខ្ញុំត្រេកអរណាស់ ហើយថ្ងៃនេះដើម្បីបញ្ជាក់ពីចិត្តត្រេកអររបស់ខ្ញុំ ខ្ញុំសុំខ្លួនទៅយកទឹកក្រូចមួយកែវមកជូនបង ។

-អូនយីហ៊ុបមិនចាំបាច់ធ្វើបែបនេះទេ ។

-តែខ្ញុំរីករាយនឹងធ្វើណាបងនរលក្ខណ៍ ។

-បើអ៊ីចឹង តាមចិត្តអូនចុះ ហើយបងអរគុណអូនចំពោះទឹកក្រូចមួយកែវនោះ ទុកជាមុន ។

-ចាស មិនអីទេបង ។

និយាយរួច យីហ៊ុបដើរចេញទៅ។ មួយសន្ទុះនាងក៏ត្រឡប់មកវិញជាមួយដៃកាន់កែវទឹកក្រូច។ កញ្ញាពីសពុលញញឹម បេះដំបានទាំងរីករាយពេញបេះដូង ។ នាងគិតថា នាពេលបន្តិចខាងមុខ នាងនរលក្ខណ៍នឹងក្លាយជាមនុស្សញៀនថ្នាំដែលស្ថិតនៅក្រោមការបញ្ជារបស់នាងនិងម្ដាយនាង ។

ចំណែកពិសិដ្ឋវិញ គេដើរចុះដើរឡើងនៅក្បែររថយន្តនរលក្ខណ៍ ដោយអ្នកប្រុសមាននាទីជាអ្នកចាំបើករថយន្តជូនធីតា ក្នុងការនាងត្រូវធ្វើដំណើរទៅកាន់ទីកន្លែងផ្សេងៗ។ គេមិនទាន់ធ្វើការសម្រេចបាន តើនឹងជួយនរលក្ខណ៍ឬយ៉ាងណា? ចរន្តគំនិតពីរតែងតែលេចមកប្រឆាំងក្នុងខួរក្បាលគេ ។ ភ្លាមនោះ សម្លេងរោទិ៍លាន់ឮទូរសព្ទមួយ ដែលជាទូរសព្ទរបស់នរលក្ខណ៍បានភ្លេចចោល នៅក្នុងរថយន្ត ។ ព្រះភក្ត្រទេវតាស្រីផុតលើអេក្រង់ទូរសព្ទមួយភ្លែត រួចក៏បាត់ភ្លាមទៅវិញ។ ពិសិដ្ឋងាកមកមើលទូរស័ព្ទដែលមានសំឡេងរោទិ៍។ ពិសិដ្ឋហាក់ដូចជាមានអ្វីមកដាស់សតិដើម្បីបញ្ជាឱ្យគេត្រូវតែជួយចៅហ្វាយក្រមុំ ឱ្យផុតពីការព្យាបាទរបស់យីហ៊ុប។ មាណពនឹកឃើញពីលេសដើម្បីជួយកល្យាណឱ្យគេចផុតពីកលល្បិចយីហ៊ុបហើយ។ នរៈស្រវាទូរសព្ទដែលកំពុងរោទិ៍ រត់សំដៅទៅរកបន្ទប់ធ្វើការរបស់នរលក្ខណ៍យ៉ាងត្របាញ់ជើង ។បុរសស្ទុះចូលរឹងទៅក្នុងការិយាល័យនរលក្ខណ៍ ដោយមិនគោះទ្វារ ។ ពេលគេមកដល់ផ្នែកខាងក្នុងនៃបន្ទប់ ភ្នែកគេចោលទៅចំយីហ៊ុបដែលកំពុងកាន់កែវទឹកក្រូចមានដាក់ថ្នាំញៀន ដើរកាន់តែកៀកទៅរកនរលក្ខណ៍ ។ យុវជនរត់

យ៉ាងលឿន ទៅបុកយីហ៊ុប ។ ដោយមិនបានប្រុងប្រយ័ត្ន យីហ៊ុបដួលព្រួស របូត ធ្លាក់កែវទឹកក្រូចពីដៃ កំពុបខ្ចាយទៅលើផ្លូវ ។ ឯពិសិដ្ឋហុចទូរសព្ទកំពុងរោទិ៍ ទៅ នរលក្ខណ៍ ទាំងគេនិយាយយ៉ាងរអាក់រអួល ព្រោះហត់ដោយការរត់មករក :

-អ្នកនាងមានទូរសព្ទ ។

នរលក្ខណ៍យកទូរសព្ទ ទាំងចោលនេត្រាមើលទៅយីហ៊ុប ស្រីឃើញជាក់ជា ប្អូនជីដូនមួយកំពុងងើបពីទីដួល ។ នាងជួយភ័យជំនួសកំលោះអ្នកបើកបរ ដែល រត់សស្លើតសស្លន់ចូលមកនាង របូតបណ្ដាលឱ្យបុកយីហ៊ុប ។ ជាមួយការគិត នរលក្ខណ៍យកទូរសព្ទមកស្ដាប់ តែសំឡេងទូរសព្ទបានដាច់ទៅហើយ ។

សម្រាប់ពិសិដ្ឋ ក្រោយពីជូនទូរសព្ទទៅកាន់ម្ចាស់ស្រីរួច អ្នកប្រុសក្លែង កាយបែរមកមើលយីហ៊ុប ទាំងគេឱនក្បាលគោរពរបៀបសុំទោសដល់នាង ពី អាកប្បកិរិយាច្រងេងច្រងាងដែលគេរត់ទៅបុកនាង របូតទាល់តែនាងដួល ។ តាម ពិត ការដែលនាយក្លាម ឬ ពិសិដ្ឋរត់មកបុកយីហ៊ុប គឺជាចេតនារបស់អ្នក ដើម្បី រារាំងកុំឱ្យយីហ៊ុបអាចសម្រេចកលឧបាយ ក្នុងការធ្វើឱ្យនរលក្ខណ៍ទទួលកែវទឹក ក្រូច យកទៅបរិភោគ ។ យុវបុរសបាមាត់និយាយ :

-អ្នកនាង ខ្ញុំសុំ ...

ប៉ុន្តែពេលនោះ ដៃយីហ៊ុបយារយ៉ាងលឿនមកទះកំភ្លៀងពិសិដ្ឋ ទាំងនាង ស្រែកគំហកមកផង :

-អ្នកឯងសស្លើតសស្លក់មកពីទីណា បានជាមកបុកយើង ។

កំហឹងពិសិដ្ឋប្រាលពេញដើមទ្រូង គេនឹកខឹងចំពោះនាងក្រមុំសម្ដីអាក្រក់ ចិត្តសាមាន្យ គេសឹងតែបកអាក្រាតនូវអំពើគម្រក់របស់នាងនិងបម្រុងទះតបទៅ

នាងវិញ តែភ្លាមនោះ គេក៏ទប់ចិត្តបាន ដោយគេសម្រួលទឹកមុខ ហើយគេធ្វើជាឱនក្បាលបន្តិច ដូចជាការគោរពជាមួយការកោតខ្លាចចំពោះអំណាចចៅពៅរបស់សព្វលោកឧកញ៉ា ទាំងភ្ជាប់ប្រយោគ :

-អ្នកនាង ខ្ញុំបាទសុំទោស ព្រោះមិញនេះទូរស័ព្ទអ្នកនាងលក្ខណ៍បានភ្លេចចោលនៅក្នុងឡាន ហើយមានគេទូរស័ព្ទមករកអ្នកនាងលក្ខណ៍ ទើបខ្ញុំបាទប្រញាប់រត់យកវាមកជូនអ្នកនាងលក្ខណ៍ពេក បានជាខ្ញុំបាទរត់មិនបានមើល ហើយក៏បុកអ្នកនាងតែម្តង ។

-ទោះជាប្រញាប់យ៉ាងណាក៏មិនត្រូវភ្លើបែបនេះទេ ។ "យីហ៊ុប"

រួចយីហ៊ុបងាកមកនរលក្ខណ៍ ស្រីស្រដី :

-បងលក្ខណ៍ !អ្នកបើកឡានរបស់បងភ្លីភ្លើណាស់ ។

នរលក្ខណ៍មិនទាន់ទាំងបានឆ្លើយថាយ៉ាងម៉េចផង យីហ៊ុបកញ្ឆក់កាបូបដៃរបស់នាង ស្រីដើរចេញរឹងពីបន្ទប់បងស្រីជីដូនមួយ ។ ការពិតទៅ យីហ៊ុបមិនសូវជាខឹងនឹងទង្វើរបស់ពិសិដ្ឋដែលមកបុកនាងប៉ុន្មានទេ តែការដែលផែនការរបស់នាងត្រូវបានបំផ្លាញការរត់បុករបស់នរៈនេះ ដែលបង្កនូវការខឹងសម្បារដល់ធីតា នាងសឹងតែស្ទុះមកស៊ីសាច់នាយ ។ នរលក្ខណ៍យល់ពីចិត្តឆេវឆាវរបស់ប្អូនស្រី ហើយនាងក៏គិតថាជាការមិនសមរម្យដែរ ដែលពិសិដ្ឋរត់មកបុកយីហ៊ុបដែលធ្វើឱ្យស្រីយីហ៊ុបមានកំហឹង តែការដែលយីហ៊ុបទះកំភ្លៀងយុវជន ក៏ជាប្រការមិនគាប្បីដែលនាងគួរនឹងប្រព្រឹត្ត ។គិតយ៉ាងនេះ និមលគ្រវីក្បាលតិចៗ ដោយបែរមកមើលពិសិដ្ឋ មិនស្តីអ្វីមួយម៉ាត់ ។ ពិសិដ្ឋមុខជូរ គេមើលតបទៅនាង មុខកំលោះរបៀបអេះអុញ ។ ចៅហ្វាយស្រីរបស់នាយក្តាមស្រដី ទាំងមុខហួសចិត្ត :

-អ្នកទៅវិញចុះ បើគ្មានកិច្ចការអីទៀតទេ។

ពិសិដ្ឋមិននឹកស្មានថា នាងមិនមានការស្តីបន្ទោសមកកាន់នាយ ដូចជាយីហ៊ុបអ៊ីចឹងទេ នេះបង្ហាញថា នរលក្ខណ៍ជាមនុស្សចិត្តទូលាយ មានការពិចារណាល្អិតល្អន់ មុននឹងសំដែងចេញមកនូវអាកប្បកិរិយា ឬ ក៏សំនួនវាចាអ្វីក្តី ។ យល់ពីសន្តានចិត្តប្រពៃលោយឡាំដោយក្តីបារម្ភ នូវការប៉ះពាល់ទម្លាប់សំណាក់វេបា ដែលនឹងកើតមានលើនរលក្ខណ៍ នាយប៉ះនេះ ពិសិដ្ឋបាត់ម្ចាស់ការគំនិត គេច្រឡំមាត់ពោលទាំងមុខស្លូតថែស ទៅកាន់ចៅហ្វាយក្រមុំ :

-អ្នកនាង សុំប្រយ័ត្នខ្លួន ...

ភ្លាមនោះ ពិសិដ្ឋឈប់និយាយទៅវិញ ព្រោះគេគ្មានពស្តុតាងអ្វីត្រូវបញ្ជាក់ ឬ លេសអីដើម្បីមកពន្យល់ពីការបារម្ភរបស់គេចំពោះស្រី ពាក់ព័ន្ធទង្វើរបស់វេបាទៅលើនរលក្ខណ៍ ។ គេក៏នៅស្ងៀមឈឹង។ នរលក្ខណ៍មិនយល់ពីអ្វីដែលលាក់ក្នុងចិន្តានាយក្តាម តែនាងគិតថា គេប្រហែលជាខ្លាសដែលរត់ស្ទោស្លន់ខុសទំនងមកបុកយីហ៊ុប ឬ ខ្លាសដែលត្រូវយីហ៊ុបទះកំភ្លៀង ហើយក៏គិតអ្វីមិនច្បាស់លាស់ទើបនិយាយនូវពាក្យមិនមិនដឹងជាចង់ពោលពីអ្វីឱ្យប្រាកដមកកាន់នាង ។ គិតរួចនរលក្ខណ៍សើច នាងវាចា :

-អ្នកទេដឹងដែលត្រូវប្រយត្ន័ខ្លួន ល្ងើយ ! អ្នកទៅវិញចុះ ហើយអ្នកហៅអ្នកបោសសំអាត មកជូតទឹកក្រូចដែលកំពប់នេះផង ។

-បាទ ។

ពិសិដ្ឋដើរចេញទៅ ។ នរលក្ខណ៍ចុចទូរសព្ទ ដើម្បីមើលលេខអ្នកដែលទូរសព្ទមកនាង តែនាងមិនឃើញមានលេខកត់ត្រាក្នុងទូរសព្ទសោះ ។ នាងមានការងឿងឆ្ងល់ លាន់មាត់តែឯង :

-ហេតុអីមិនឃើញលេខអ្នកទូរសព្ទមកមុននេះ ។

វេលាយប់មកដល់ វេហានិងនរលក្ខណ៍ដើរចូលភោជនីយដ្ឋានមួយ ដែលយើងឮនូវប្រយោគលាន់ពីមាត់វេហា :

-បងសប្បាយចិត្តណាស់ ដែលលក្ខណ៍មិនប្រកាន់ខឹងចំពោះអាកប្បកិរិយាច្រងេងច្រងាងរបស់បងកន្លងមក ហើយជាកិត្តិយសបំផុត ដែលលក្ខណ៍ព្រមមកញ៉ាំបាយជាមួយបង នៅទីនេះ ។

-បងវេហា ! យើងជាបងប្អូននឹងគ្នា បើមានការលើសលោះអី យើងមិនគួរប្រកាន់គ្នាទេបង ? ហើយបងអញ្ជើញខ្ញុំមកញ៉ាំអាហារម្តង បើខ្ញុំមិនមកវាមិនសមជាបងប្អូននឹងគ្នាដែរ ។

ទាំងពីរនាក់ដើរទៅរកតុមួយ ដើម្បីអង្គុយ ។ វេហាជាអ្នកកម្ម៉ង់មុខម្ហូប ។ នរលក្ខណ៍បណ្តោយតាមបងជីដូនមួយ ព្រោះនាងគិតថា កំលោះមានបំណងចង់សុំទោសនាង ។ ឯក្រៅហាងអាហារ ពិសិដ្ឋអង្គុយក្នុងរថយន្ត បន្តិចមក គេលើកទូរសព្ទដៃរបស់គេ មកនិយាយទៅកាន់ខ្សែម្ខាងទៀត :

-អាឡូសេរី ឯងមកដល់ទីណាហើយ អ្នកនាងនរលក្ខណ៍មកដល់ហាងអាហារហើយ ។

-យើងមកដល់ក្នុងហាងហើយតើ ហើយយើងបានឃើញពួកគេទាំងពីរនាក់ដែរ ។

-យើងផុតបារម្ភហើយអីចឹង ។

ពិតមែន សេរីអង្គុយនៅតុមួយ សម្លឹងមើលទៅសកម្មភាពនរលក្ខណ៍ និងវេហា ព្រោះអ្វីៗជាផែនការរបស់វេហាបង្ក្រាបាទ មកលើនរលក្ខណ៍ត្រូវបាន ពិសិដ្ឋរ៉ាយរ៉ាប់ប្រាប់កំលោះនរតបាលទាំងអស់ ។ សេរីមានការងឿងឆ្ងល់ តើហេតុ អ្វីពិសិដ្ឋអាចដឹងជាមុននូវផែនការរបស់វេហាទៅលើនរលក្ខណ៍ តែពិសិដ្ឋសុំសិទ្ធិមិន ប្រាប់សេរី ពីចំណុចនេះ ។

គួរឱ្យភ្ញាក់ផ្អើលបំផុត គឺនៅក្នុងហាងអាហារនេះ យើងក៏ឃើញមាន ទារិកាអង្គុយនៅតុផ្សេងពីសេរី និងផ្សេងពីតុវេហា ព្រមទាំងតុនរលក្ខណ៍ដែរ ។ តែ ទារិកាមិនបានដឹងពីវត្តមានសេរីនៅទីនេះ។ នាងផ្ដោតនេត្រាតែទៅលើសកម្មភាព បងប្រុស និងនរលក្ខណ៍ តែប៉ុណ្ណោះ ។ កំលោះវេហាវិញ គេចាប់ម្ហូបដាក់ចាន នរលក្ខណ៍ គេញញឹមភ្ជាប់វាចា :

-ញ៉ាំទៅនរលក្ខណ៍ អាហារទីនេះឆ្ងាញ់ណាស់ណា បងតែងតែមកញ៉ាំ ។

-អរគុណបងវេហា ។

-បងសុំទៅបន្ទប់ទឹកមួយភ្លែត ។

-ចាស ។

បន្ទាប់មក វេហាដើរទៅរកបន្ទប់ទឹក ។ សេរីតាមមើលដំណើរចាកចេញ ពីតុរបស់វេហា ក៏ដូចគ្នាទារិកាតាមមើលវេហាដែរ ។ មួយសន្ទុះវាហាវិលមកកាន់តុ វិញ ដោយគេបន្តការបរិភោគអាហារជាបន្ត។ មិនបានប៉ុន្មាននាទីផង មានអ្នកបម្រើ ប្រុសម្នាក់ដើរកាន់កែវទឹកក្រូច យកមកដាក់ឱ្យនរលក្ខណ៍។ សេរីក្រឡេកឃើញ

នរលក្ខណ៍លើកកែវទឹកក្រូចនោះមកក្រេប ចំណែកទារិកាក៏បានឃើញនូវសកម្មភាពបងប្រុសនិងនរលក្ខណ៍ដែរ ។

មួយសន្ទុះកន្លងផុត នរលក្ខណ៍ក្រាបក្បាលលើតុ ដោយអាការៈត្រូវរងឥទ្ធិពលថ្នាំសណ្តំ ។ វេហាមុខញញឹមពព្រាយ គេដកលុយឱ្យអ្នកគិតលុយ ។ នៅពេលអ្នកបម្រើកាន់បញ្ជីគិតប្រាក់ ដើរទៅរកកន្លែងគិតប្រាក់ យល់ថា ដល់ពេលវេលាហើយ សេរីងើបដើរទៅរកវេហា ស្របពេលទារិកាងើបដើរទៅវេហាដែរ ។ គ្រាដែលវេហាលូកដៃប្រុងលើកគ្រាហ៍នរលក្ខណ៍ ទារិកាដើរមកដល់ល្មម នាងស្រែកតិចៗល្មមឮដល់បងប្រុស នូវប្រយោគ :

-ឈប់សិនបងវេហា ។

សេរីដើរមកដល់ គេនិយាយរបៀបដូចជាមិនចំពោះនរណាម្នាក់ :

-យី! អ្នកនាងនរលក្ខណ៍កើតអី ?

វេហាមុខភ្ញាក់ ខំសម្រួលទឹកមុខ ឆ្លើយ :

-យើងមិនដឹងទេ មិនដឹងហេតុអីនរលក្ខណ៍ទៅជាអីចឹង ។

-ប្រហែលនរលក្ខណ៍អស់កម្លាំងពេក ខ្យល់ចាប់ទេដឹង ។ " ទារិកា"

រួចទារិកាងាកសេរី នាងនិយាយទៅកាន់គេ :

-សេរីជួយខ្ញុំផង យើងជួយគ្នា ដើម្បីនាំនរលក្ខណ៍ទៅផ្ទះ ។

-បាទ ។ " សេរី"

ទារិកានិងសេរីគ្រាហ៍នរលក្ខណ៍ នាំដើរចេញពីតុ។ កាលបើផែនការត្រូវរលាយ វេហាខឹងណាស់ គេតាមសម្លឹងប្អូនស្រីនិងសេរីដែលកំពុងនាំយកចំណីឆ្ងាញ់របស់គេ ចាកចេញទៅ ។

# វគ្គ ទី ១១

ម៉ោង៥រសៀល ក្នុងហាងលក់គំនូរទារិកា យើងឃើញសេរីអង្គុយជិតទារិកា ។ ទារិកាមុខស្លូត នាងប្រើកែវភ្នែកសម្លឹងសេរី ដោយភាពរាំរែក សោតឯបុរសវិញ គេផ្ដោតទេត្រាមកចំភក្ត្រនាង ក្នុងន័យយោគយល់ រំពេចនោះបបូរមាត់ចីពាកម្រើកជាប្រយោគ :

-សេរី ! ខ្ញុំសុំអរគុណ ដែលមិននិយាយពីអ្វីជាទង្វើមិនល្អរបស់បងវេហាប្រាប់នរលក្ខណ៍ ។

សេរីមើលមុខទារិកា មុខគេបាក់ភាវរែកអ្វីពីស្រី រួចគេសួរនាង :

-ហេតុអីទារិកាគិតថា លោកវេហាធ្វើមិនល្អ ?

-មនុស្សស្រីម្នាក់ញ៉ាំអាហារតែពីរនាក់មនុស្សប្រុសតតូ ហើយមនុស្សស្រីបែរជាសន្លប់ តើវាមានអ្វីកើតឡើង ? មិនចាំបាច់ខ្ញុំបញ្ជាក់ទៀតទេ មែនទេ ?

-តែមានរឿងមួយ ដែលខ្ញុំមិនយល់ តើហេតុអីទារិកាទៅទាន់ហេតុការណ៍នោះ ?

ទារិកាញញឹមស្លូត និយាយទាំងមុខជិតដោយភាពរិះគិត :

-ខ្ញុំសុំមិនជម្រាប តើបានទេសេរី ?

-បាទ បានតើទារិកា ។

-ចុះសេរីវិញ តើហេតុអីបានជាអញ្ជើញទៅទាន់ហេតុការណ៍នោះដែរ ?

សេរីញញឹម និយាយ :

-ខ្ញុំមានសិទ្ធិមិននិយាយជម្រាបទារិកាដែរណ៎ា ។

ច្រើនថ្ងៃកន្លងមក នរលក្ខណ៍បាននាំដារ៉ុធមកពិនិត្យដដែលត្រូវសាងសង់ផ្ទះសំសំណាក់ទាំងដប់ ។អ្នកមកចូលរួមក្នុងដំណើរមកពិនិត្យដី មាននរលក្ខណ៍ វិស្វករដារ៉ុធ ម៉ានុត ម៉ានីន យីហ៊ុបនិងនាយក្លាម ព្រោះដំណើរមកពិនិត្យដី ជាដំណើរកម្សាន្តផងដែរ ទើបមានទាំងយីហ៊ុប ម៉ានុត ម៉ានីនមកជាមួយនរលក្ខណ៍ និងវិស្វករដារ៉ុធ ។ ដ្បិតដារ៉ុធជាមិត្តភក្តិរបស់ម៉ានុត ហើយម៉ានុតមានចេតនាតាមយកចិត្តនរលក្ខណ៍ ដើម្បីចងបេះដូងនាងមកភ្ជាប់បេះដូងគេ។ ឯម៉ានីនមានបំណងចង់ជួបមុខនាយក្លាម ឬ ពិសិដ្ឋ ទើបនាងមកតាមបងប្រុស ។ ចំណែកយីហ៊ុបមានគំនិតវាយសំណាញ់ស្នេហ៍ទាក់ម៉ានុត ឬ ដារ៉ុធ តាមតែនាងអាចធ្វើទៅបាន ព្រោះកំលោះទាំងពីរ ជាបុរសរូបសង្ហាកំពុងថ្លុកបេះដូងនារីចិត្តងាយបែបយីហ៊ុប ។ កំពុងតែដើរ ម៉ានុតនិយាយទៅកាន់នរលក្ខណ៍ :

-អ្នកនាង ! ខ្ញុំឃើញទីនេះនិងស្តាប់ផែនការរបស់អ្នកនាង ខ្ញុំយល់ថាគម្រោងការសាងសង់របស់អ្នកនាងគួរឱ្យចាប់អារម្មណ៍មែនទែន ?

-ជាពិសេស ស្នាដៃបងដារ៉ុធសាងសង់ កាន់តែគួរឱ្យទុកចិត្តថា គម្រោងអ្នកនាងលក្ខណ៍ មុខជាទទួលជោគជ័យមិនខាន ។" ម៉ានីន"

-ហើយខាងធនាគារលោក មុខជាមិនញញើតក្នុងការខ្ចីទុនរបស់ខ្ញុំទេមែនទេលោកម៉ានុត អ្នកនាងម៉ានីន ?

-ខាងធនាគារខ្ញុំ មិនមានបញ្ហាតាំងតែពីខ្ញុំបានឃើញសំណើរគម្រោងដំបូងរបស់អ្នកនាងម្ល៉េះ ព្រោះខ្ញុំបានផ្ញើវាទៅជូនបងពិសិដ្ឋជាបងជីដូនមួយខ្ញុំ ដែលជាភាគហ៊ុនធំ បានពិនិត្យនិងសម្រេចហើយតើ ។" ម៉ានុត"

-ការដែលពួកខ្ញុំមកពេលនេះ គឺមកកម្សាន្តតើ មិនមែនមកសិក្សាគម្រោងរបស់អ្នកនាងឯណា ។" ម៉ានីទ"

-អរគុណលោកនិងអ្នកនាងហើយអ៊ីចឹង ។" នរលក្ខណ៍"

ពេលនោះ ស្រាប់តែកញ្ញាយីហ៊ុបរត់មកពីចំងាយ នាងស្រែកឮៗមកកាន់នរលក្ខណ៍ :

-បងលក្ខណ៍ ! នៅដើរលេងដល់ណាទៀត ខ្ញុំឃ្លានបាយណាស់ណា៎ ។

ម៉ានុតជាមនុស្សត្រង់ គេមិនសូវចូលចិត្តចរិតឥតមារយាទរបស់យីហ៊ុបទេ ។លុះមកឮនាងស្រែកខ្លាំងៗរបៀបដូចជាមនុស្សមិនមានពូជអម្បូរ ម៉ានុតហួសចិត្ត គេសម្លឹងទៅយីហ៊ុបក្នុងទឹកមុខមិនពេញចិត្តមារយាទយីហ៊ុប រួចគេក៏ងាកមុខមកមើលជើងមេឃ ធ្វើមិនដឹង ។ នរលក្ខណ៍ពោលវាចាទៅកាន់យីហ៊ុប ដោយប្រយោគមួយៗ ក្នុងសម្លេងធម្មតា :

-បើប្អូនឃ្លាន ប្អូនញ៉ាំមុនបងចុះ ព្រោះពួកយើងត្រូវដើរមើលដីបន្តទៀត ។

ការពិតដូចយើងបានដឹងរួចមកហើយថា យីហ៊ុបរួមដំណើរជាមួយនរលក្ខណ៍មកកាន់ទីនេះ គឺក្នុងបំណងដើម្បីបង្កើនការជិតស្និទ្ធជាមួយកំលោះដាវ៉ុធដែលជាវិស្វកររូបសង្ហានិងកំលោះម៉ានុតម្ចាស់ធនាគាររូបស្អាត ។ ដ្បិតយីហ៊ុបហាក់ដូចជាលង់ស្នេហ៍ លើសម្រស់សង្ហារបស់នរៈទាំងពីរ ។ នាងមានគំនិតថា បើក្នុងចំណោមបុរសទាំងពីរ ឱ្យតែមាននរណាម្នាក់ដែលនាងទាក់ទាញបេះដូងបាន នោះគឺនាងសុខចិត្តប្រគល់បេះដូងជូនគេ ទាំងសោមនស្សរីករាយ ។ យីហ៊ុបជានារីបែបស្រីបរទេស នាងចូលចិត្តលេងជាមួយល្បែងស្នេហា ដោយមិនខ្វល់ពី

ប្រពៃណីអ្វីទាំងអស់ ។ លុះនរលក្ខណ៍មិនព្រមទៅរួមក្នុងការបរិភោគ យីហ៊ុប ញញឹមស្រស់ ស្រែងាកមកដារ៉ុធ នាងបន្លឺ :

-ចុះលោកវិស្វករមិនឃ្លានទេអ្ហេះ បើលោកឃ្លានបាយ លោកមិនចាច់ទើស ទាល់ទេ លោកអាចអញ្ជើញទៅពិសាបាយជាមួយខ្ញុំបានណា៎ ។

-បាទ! អ្នកនាងអញ្ជើញទៅពិសាបាយមុនចុះ ខ្ញុំធ្វើការមិនទាន់រួចរាល់ទេ

ទទួលបានការបដិសេធពីដារ៉ុធ យីហ៊ុបបែរមកម៉ានុត ទាំងនាងចោល សម្រស់ញញឹមរបៀបទាក់ទាញកំលោះនេះម្តង តែនាងត្រូវស្រៀវក្នុងចិត្ត ព្រោះ ភ្នែកម៉ានុតមើលមកនាង ជាភ្នែកហួសចិត្តនិងស្អប់ខ្ពើម ។ យីហ៊ុបព្យាយាមប្រឹង ញញឹមដាក់ម៉ានុត ស្រីស្រដី :

-លោកប្រធានធនាគារអាចអញ្ជើញទៅកំដរខ្ញុំបានទេ ខ្ញុំអផ្សុកណាស់ ដែលត្រូវញុំាបាយតែឯងយ៉ាងនោះ ។

-បាទ ខ្ញុំមិនមែនជាមនុស្សរត់ចោលការងារកណ្តាលទីទេអ្នកនាង សុំ អញ្ជើញពិសាតែឯងឱ្យឆ្ងាញ់ និងឱ្យឆ្អែតផងចុះ ។

ត្រូវមួយផ្លៃនៃសម្តីមុតដូចកាំបិតរបស់ម៉ានុត យីហ៊ុបស្លុកមុខបន្តិច នាង ចាប់ផ្តើមបញ្ចេញកំហឹងមកពីក្នុងទ្រូង ដោយនាងនិយាយទាំងមុខមាំ :

-គ្មាននរណាទៅជាមួយខ្ញុំក៏បាន ពួកលោកមិនមានសុជីវធម៌ចំពោះនារី អីសោះ ។

រួចយីហ៊ុបដើរចេញទៅទាំងរមាំងរមោក ។ នរលក្ខណ៍ដឹងថា ប្អូនជីដូនមួយ ធ្វើបែបនេះ គឺមិនសមរម្យសោះ តែក្នុងនាមនាងជាបងស្រីរបស់យីហ៊ុបនិងក្នុងនាម នាងជាអ្នកអញ្ជើញម៉ានុត ម៉ានីននិងដារ៉ុធមកកាន់ទីនេះ នាងចាំបាច់ត្រូវដើរតួជា

មនុស្សជ្រើសរើសយកផ្លូវកណ្ដាល ដើម្បីសម្រួលបញ្ហាដែលឃីហ៊ុបបង្កមកនេះ ។ គិតរួច នរលក្ខណ៍និយាយទៅកាន់ម៉ានុតនិងដារ៉ុធ ទាំងមុខស្ងួតក្រៀម :

-ខ្ញុំសុំទោសជំនួសគេផងលោក គេតែប៉ុណ្ណឹង ។

ម៉ានុតញញឹម និយាយ :

-ជាបងប្អូននឹងអ្នកនាង តែខុសគ្នាដូចមេឃនិងដី ។ ˝ម៉ានុតនិយាយតាមនិស្ស័យជាមនុស្សត្រង់ ឃើញយ៉ាងណា និយាយយ៉ាងហ្នឹង˝

-ប្រហែលនាងជាមនុស្សត្រង់ នឹកឃើញយ៉ាងម៉េច ក៏និយាយចេញមកណាម៉ានុត ។˝ ដារ៉ុធ˝

ដើម្បីបំភ្លេចបរិយាកាសឱ្យវិលមកសភាពធម្មតាវិញ នរលក្ខណ៍ប្រើប្រយោគក្នុងន័យផ្ដោតទៅលើការងារ មកកាន់អ្នកទាំងបីនាក់ :

-សុំអញ្ជើញទៅខាងមុខទៀត ព្រោះទីនោះមានស្ទឹងមួយ ខ្ញុំមានគម្រោងចង់កែច្នៃទីនោះណាលោកដារ៉ុធ ។

នរលក្ខណ៍នាំមុខអ្នកទាំងអស់គ្នាដើរទៅរកស្ទឹង ជាគោលដៅដែលនាងមានផែនការកែច្នៃ សម្រាប់ជាទីកម្សាន្តដល់ភ្ញៀវ ដែលនឹងមកសម្រាកនៅផ្ទះសំណាក់ទាំងដប់ នាពេលអនាគត ។

ក្រោយពីបញ្ចប់ការសិក្សាវិភាគពីដីដែលត្រូវសាងសង់ គេទាំងបួននាក់បានមកកាន់ផ្ទះចំាដី ដើម្បីបរិភោគអាហារ ។ ម៉ានុត ម៉ានីន ដារ៉ុធ នរលក្ខណ៍អង្គុយញ៉ាំបាយនៅលើកន្ទេលក្រហមដែលក្រាលពីលើរនាបផ្ទាល់របស់ផ្ទះចាំដី ជាផ្ទះឈើស្អាតតូចច្រឡឹង សាងសង់ពីឈើមានតម្លៃ របៀបជាម៉ូតបែបផ្ទះបុរាណ។ មីងសឿនជាស្រីបម្រើមាននាទីចាំបម្រើដូសបាយ ដាក់ម្ហូប សម្រាប់មនុស្សទាំង

អស់គ្នា ។ភ្នែកម៉ានីនចោលទៅចំនាយក្ដាមឈរក្រោមដើមឈើ ជាមួយដៃនរៈកាន់ចានបាយមួយ កំពុងតែឯងឯកា យ៉ាងកម្សត់ ។ នាងមានអារម្មណ៍អាណិតពិសិដ្ឋ ដែលស្ថិតនៅក្នុងស្រោមក្លែងកាយជាអ្នកបើកបររថយន្ត ទើបអ្នកប្រុសមិនអាចមានលទ្ធភាពមកចូលរួមបរិភោគជាមួយពួកនាង ។ ម៉ានីនដាក់ស្លាបព្រាចុះលើចាន នាងស្រដីទៅម៉ានុត :

-បងនុត ! ខ្ញុំសុំទៅសួរសុខទុកក្ដាមបន្តិច ព្រោះមិនទាន់បាននិយាយអីជាមួយគេទេ ។

នរលក្ខណ៍មានការសង្ស័យចំពោះទំនាក់ទំនងក្ដាមនិងបងប្អូនម៉ានុត តាំងតែយប់ដែលម៉ានុតត្រូវទៅញ៉ាំអាហារជាមួយនាងនាភោជនីយដ្ឋាន ហើយកាលយប់នោះ នាងបានឃើញក្ដាមឱបរឹតម៉ានុត យ៉ាងស្និទស្នាល ។ លុះមកឮម៉ានីនត្រូវការទៅសួរសុខទុក្ខក្ដាមយ៉ាងនេះ ស្រស់ស្រីកាន់តែមិនអស់ចិត្តពីទំនាក់ទំនងរវាងក្ដាមនិងបងប្អូនម៉ានុត ។នរលក្ខណ៍បានឮម៉ានុតឆ្លើយតបទៅប្អូនស្រី :

-អូនទីនទៅចុះ ។

ម៉ានីនងើបដើរទៅរកពិសិដ្ឋ ដែលអង្គុយញ៉ាំបាយនៅក្រោមដើមឈើមួយឯឆ្ងាយបន្តិច ។ នរលក្ខណ៍រវេទព្រាតាមមើលម៉ានីន ជាមួយទឹកមុខរិះគិត។ ម៉ានុតដឹងថា នរលក្ខណ៍ចាប់អារម្មណ៍ពីទំនាក់ទំនងបងប្អូនគេ ជាមួយពិសិដ្ឋ ទើបកំលោះស្រដីមកកាន់នរលក្ខណ៍ :

-ម៉ានីនប្អូនស្រីខ្ញុំ នាងក៏ស្គាល់ក្ដាមដែរ ព្រោះក្ដាមធ្លាប់ជួយជីវិតនាងឱ្យផុតពីពស់ចឹកម្ដង ទើបនាងតែងតែភាក់ទាក់នឹងក្ដាមយ៉ាងហ្នឹងណាំអ្នកនាង ។

-អូ ! បែបនេះទេអ្ហេះលោក ។

បើយើងបែរមកស្ដាប់ការសន្ទនារវាងក្លាមនិងម៉ានីនវិញ យើងនឹងឮស្រស់ស្រីសួរក្លាម នូវប្រយោគ :

-បងមិនទាន់និយាយប្រាប់ខ្ញុំពីសុខទុក្ខទេណ៎ា ។

-បងមិនមានកើតអីឯណាអូនមីន ។

-មើលចុះ បងគួរឱ្យអាណិតណាស់ដែលមកអង្គុយញ៉ាំបាយនៅទីនេះតែឯង

-បងអរគុណដែលអូនមីនអាណិតបង តែបងមិនមានអីទេ ដើម្បីការងារបងត្រូវចាំបាច់ធ្វើអីដែលខុសពីជីវិតពិតរបស់បង ។

-បងហ្ន ! បងមកបម្រើគេធ្វើអី ?

-បងមិនអាចនិយាយបានទេណ៎ា បងសុំទោសអូនមីន ។

ម៉ានីនសម្លក់ពិសិដ្ឋ :

-បងមិនទុកចិត្តខ្ញុំមែនទេ ?

-ទេ មិនមែនបែបនោះទេ តែបងពិតជាមិនអាចនិយាយបានមែន ។

ម៉ានីនមុខងរង៉េក់ នាងមើលមុខពិសិដ្ឋ។ ពិសិដ្ឋនិយាយ :

-អូនមីន បងមានបញ្ហាផ្ទាល់ខ្លួនណ៎ា ។

-បងមាននឹកខ្ញុំទេ ខ្ញុំនឹកបងណាស់ ។ "ម៉ានីនទាញខ្សែកពីក្នុងអាវ មកបង្ហាញពិសិដ្ឋ នាងនិយាយបន្ត "...ខ្សែកបង ខ្ញុំពាក់ជាប់កណ៎ា ព្រោះពេលនឹកបងខ្ញុំអាចមើលវានេះ ជំនួសមុខបង ។

-បងអរគុណ ចំពោះទឹកចិត្តអូន ។

-តែពេលនេះ អូនទៅវិញចុះ បើនៅជជែកជាមួយបងយូរពេក នាំតែពួកគេមានការសង្ស័យមកលើរូបបងទេ ។

-ចាស ខ្ញុំទៅវិញក៏បាន ។

ដូចកូនក្មេងស្តាប់បង្គាប់ម្តាយ ម៉ានីនដើរទៅវិញភ្លាម ទោះជាចិត្តនាងចង់ចាកចេញពីបុរសកំពូលបេះដូងត្រូវការក្តី ។ ពិសិដ្ឋដើរមករកមាត់ទឹក ក្បែរគុម្ពោតព្រៃមួយ គេអង្គុយប្របមាត់ស្ទឹង ចោលភ្នែកសម្លឹងទឹកហូរ ជាមួយការ[illegible] ខួរក្បាលពិចារណាពីទំនាក់ទំនងរវាងលោកយាយមាសនិងគ្រួសារសិទ្ធា គេកំពុង[illegible] រកវិធីស្រាយចំណងដែលចងគ្រួសារទាំងពីរ ឱ្យរលា ដោយផ្តល់ដល់គ្នានូវភាពយុ[illegible] ធម៌ ទាំងសងខាង ។ គឺលោកយាយមាសគួរតែទទួលបាននូវកេរ្តិ៍ឈ្មោះល្អឡើងវិញ ជាមួយនឹងការទទួលបានវិមានមាស ។សម្រាប់សមាជិកគ្រួសារសិទ្ធាក៏មិនត្រូវទទួលនូវការព្យាបាទពីខ្មោចយាយមាស ដោយអំពើលេងធ្វើបាប ឬ សម្លាប់នោះដែរទេ ។ ជំហាននាំកាយបន្តដំណើរទៅមុខ រហូតមកដល់ទីមួយ ស្រាប់តែនេត្រារបស់កំលោះប្រទះឃើញតាមប្រឡោះស្លឹកឈើ នូវនរលក្ខណ៍កំពុងហែលទឹកក្នុងស្ទឹងតែឯង។ កាលបើឃើញស្រស់ស្រីហែលទឹកលេងបែបនេះ យុវមាណពមិនអាចបន្តនៅទីនេះព្រោះជាប្រការមិនគាប្បី ដែលគេជាបុរសមកឈរក្បែរទឹកន្លែង ដែលស្រីក្រមុំកំពុងងូតទឹកនោះឡើយ ។ គេបែរខ្នងប្រុងដើរចេញ តែសំឡេងនរលក្ខណ៍ស្រែកជាខ្លាំងបានព្ញមកដល់ត្រចៀកគេ :

-អូយ ជួយខ្ញុំផង ។ អូយឈឺណាស់ ។

ពិសិដ្ឋងាករកប្រភពដែលមានសូរសំឡេងរបស់ធីតា គេឃើញនរលក្ខណ៍ដូចជារកកលលង់ទឹក ។អ្នកប្រុសឆ្ងល់ផង បារម្ភផង គេប្រញាប់ប្រញាល់ដើរទៅជិតមាត់ទឹក ស្របពេលដែលនាងរកកលលិចទៅក្នុងទឹកល្អម ។ ចិត្តអន្ទះសាររបស់មាណព បណ្តាលឱ្យអណ្តាតរលាស់ជាសម្រែក :

-អ្នកនាងកើតអីហ្នឹង ?

-ក្លាមជួយខ្ញុំផង ខ្ញុំរមួលក្រពើ អូយ ! ឈឺណាស់ ។

ពិសិដ្ឋហក់ប្លូងទៅក្នុងទឹក ។គេហែលយ៉ាងលឿនទៅរកកល្យាណ ។ តួចតន់កាន់តែរកកលលិចទៅក្នុងទឹក ។បុរសហែលមួយភ្លែត គេមកក្បៀកកាយនាងក្លាម ។ បុរសស្រវាក្រសោបប្រាណទួនល្អង ហែលយោងស្រីតម្រង់មករកគោក ។ជើងរបស់នាងនៅតែរមួលក្រពើ នាងមិនអាចមានកម្លាំងនឹងហែលទឹកដោយខ្លួនឯងស្រីមានការភិតភ័យ ណាជើងឈឺចុកចាប់សឹងស្ទះដង្ហើម ណាភ័យនឹងត្រូវលង់ទឹកស្ទើរបាត់ព្រលឹង លុះមានជំនួយពីក្លាម នាងក៏ស្រវាតោងកកំលោះ ដើម្បីឱ្យផុតពីការលិចលង់ ។ កំលោះក្រសោបកាយស្រឡូនរបស់ស្រីកំពូលដួងចិត្ត ពេញរង្វង់ហត្ថា តែចិត្តគេមិនបានត្រេកត្រអាលនឹងសម្រស់ស្រីទេ ព្រោះគេបារម្ភដល់គ្រោះថ្នាក់ដែលនឹងអាចមកប្រឡេះជីវិតស្រី ទើបនរៈប្រឹងប្រែងហែលសណ្តោងធីតា មករកច្រាំង ។

នៅក្បែរដើមឈើមួយដើមជាចុងជីវិញ បុរសស្ត្រីមួយគូកំពុងអង្គុយសារសង្កា គឺជាដារ៉ុធនិងម៉ានីន ។ វិស្វករកំលោះសម្លឹងមុខកល្យាណ ក្នុងទឹកមុខរាវរែកសាងប្រយោគមកកាន់នារីជាគូសន្ទនា :

-អ្នកនាងម៉ានីន ខ្ញុំ...ខ្ញុំអាចអង្គុយទីនេះបានទេ ?

-ហេតុអីមិនបាន ទីនេះខ្ញុំមានទិញផ្តាច់មុខឯណាលោកដារ៉ុធ ?

-អ្នកនាងនីន តើបេះដូងខ្ញុំមានឱកាសទទួលសន្សើមដួងចិត្តបានដែរទេ ?

ម៉ានីនឱនមុខ នាងមិនហ៊ានមើលមុខគេ បេះដូងនាងបានឆ្លាក់ឈ្មោះពិសិដ្ឋរួចទៅហើយ គ្មានសល់ចន្លោះត្រង់ណា ដែលអាចមកទទួលបុរសផ្សេងបាន

ស្រស់ស្រីពិតជាពិបាកមែនទែន ក្នុងការបដិសេធជាមួយសំណើរបស់ដារ៉ុធ ។ ប៉ុន្តែ ប្រសិនជានាងមិនប្រាប់ការពិតពីសេចក្ដីត្រូវការរបស់បេះដូងនាង ប្រាប់ដល់អ្នក ប្រុសទេ វាមិនមែនជាបញ្ហាដែលអាចនឹងបញ្ចប់នូវភាពស្រពេចស្រពិលដល់ដារ៉ុធ បានឡើយ ។ ពិតយ៉ាងនេះ នារីនោមយង់សម្រេចវាចា :

-ស្នេហា ! មិនអាចទរណាបញ្ជាបានទេ វាមកដល់ដោយមិនដឹងខ្លួន ហើយបើវាមិនមក ក៏មិនដឹងតើព្រោះហេតុអីដែរលោកដារ៉ុធ ?

-អ្នកនាងនីន ខ្ញុំរង់ចាំចម្លើយពីអ្នកនាងអស់រយៈពេលបីឆ្នាំមកហើយ ពេលវេលានេះ វាហាក់ដូចជាគ្រប់គ្រាន់សម្រាប់អ្នកនាងអាចស្គាល់ខ្ញុំបានដែរ ។

ម៉ានីនងើបពីទីអង្គុយ នេត្រាស្រីសម្លឹងទៅដើងមេឃដែលនៅពីមុខ ដ៏ឆ្ងាយសន្ធឹម និមលបោះជំហានដើរមួយទៅមុខ ដោយស្រដី :

-លោកដារ៉ុធមានគ្រប់យ៉ាង ដែលជាសម្បត្តិរបស់កូនប្រុស ទាំងរូប ទាំងចំណេះ ទាំងទ្រព្យ តែខ្ញុំមិនដឹងថា ហេតុអីពេលនេះបេះដូងខ្ញុំទទួលរូបលោក ជាបងប្រុសម្នាក់ទៅវិញ ។

ដារ៉ុធយាត្រាតាមនាង រង្វង់មុខដ៏ស្ញប់ស្ញែងរបស់បុរស បានប្រាកដក្រោម ក្រសែភ្នែករបស់ទូននាង ។បុរសព្យាយាមកាត់ចិត្តខកស្នេហ៍ ប្រឹងបន្លឺវាចា :

-តែខ្ញុំមិនចង់បានត្រឹមតែជាបងប្រុសរបស់អ្នកនាងនីនទេ ។

-តែខ្ញុំប្រហែលជាអាចជូនលោកបានតែប៉ុណ្ណឹង ព្រោះប្រសិនមិនមាន និស្ស័យ ក៏ប្រហែលជាមិនមានចំណងមកចងភ្ជាប់ជីវិតយើងបានដែរទេដឹងលោក ។

-អ្នកនាងនីន តែវិញខ្ញុំ ខ្ញុំមិនអាចប្រាប់បេះដូងខ្ញុំ ឱ្យឈប់ត្រូវការអ្នក នាងបានឡើយ ។

-ខ្ញុំមិនហ៊ានហាមលោកទេ តែខ្ញុំក៏មិនមានចម្លើយដែលប្រសើរជាងនេះសម្រាប់លោកដែរ ។ ខ្ញុំលាសិនហើយ ។

ចប់វាចា ធីតាបោះជំហានយាត្រាទៅមុខ ។ បុរសខកស្នេហ៍បានត្រឹមតែតាមសម្លឹងដំណើរចាកចេញរបស់ស្រីបណ្តូលហឫទ័យ ។ ស្គរដង្ហើមធំលាន់មកស្រាលជាមួយស្នាមជូរចត់ជិតលើផ្ទៃភក្ត្រាបុរសខកចិត្ត ។

យើងវិលមកតាមដាននាយក្លាមនិងនរលក្ខណ៍វិញ អូ ! ពិសិដ្ឋត្រាហ៍ទូនល្អង ដើរចេញពីស្ទឹងមកលើគោក ។ មកដល់លើច្រាំង ពិសិដ្ឋជួយនាងក្នុងការដាក់ឱ្យធីតាអង្គុយ ដើម្បីសម្រួលឥរិយាបទ ព្រោះនាងនៅឈឺជើងដោយសារការរមួលក្រពើ ស្ទើរតែផុតដង្ហើមម្តង១ ។មុខនរលក្ខណ៍បង្ហាញច្បាស់នូវការឈឺចាប់ដែលនាងមិនអាចទ្រាំបាន ទើបនាងស្រែកតិច១ ដោយលូកដៃមករឹតជើង :

-អូយ ! ខ្ញុំឈឺជើងណាស់ ។

ដៃពិសិដ្ឋលូកទៅជួយរឹតជើងនារី ត្រង់កន្លែងរមួលក្រពើ ទាំងស្រដី :

-អ្នកនាងទ្រាំណា៎ ខ្ញុំបាទជួយរឹតជូន ហើយបន្តិចទៀតនឹងអន់ឈឺហើយ ។

មួយខណៈកន្លងទៅ ស្រីទទួលអារម្មណ៍ថា ជើងវិលមកសភាពធូរស្រាលពីការឈឺចាប់ ។ កាលបើជើងសភាពវិលមកធម្មតា នាងសង្កេតឃើញពីភាពស្និទ្ធស្នាលដែលបង្កដោយដៃបុរសរឹតជើងឱ្យនាង ធីតាស្រាប់តែកើតការអៀនខ្មាសធ្វើឱ្យនាងមិនអាចបណ្តោយឱ្យហាមាត់ ស្ទើរតែមិនចេញសម្លេង :

-បានហើយក្លាម ខ្ញុំអន់ឈឺហើយ ។

វាចាស្រស់ស្រីលាន់មកប៉ះសោតាពិសិដ្ឋ នរៈងាកមកមើលនាង គេឃើញនាងអៀនក្រហមមុខ ចាំងសម្រស់ស្រស់ចិញ្ចាច ... ពិសិដ្ឋភាំង ផ្តោតនេត្រាឥត

ព្រិចលើរង្វង់ភក្ត្រាស្រី ក្ដីរំភើបកើតក្នុងឧរាប្រុសថ្លៃ ... ខ្សែចក្ខុនារីលបចោលមកលើផ្ទៃមុខអ្នកប្រុស ... បេះដូងទួនល្អងលោតភឹបៗ ចំហាយក្ដៅភាយពីមុខនាង ... រួចខ្សែភ្នែកគេទាំងពីរប្រទាក់គ្នា ដោយមន្ដស្នេហ៍ ។ នរលក្ខណ៍និងពិសិដ្ឋលង់ក្នុងអន្លង់នៃក្ដីស្នេហ៍យ៉ាងជ្រាលជ្រៅ អស់មួយវឹប ដោយមិនដឹងខ្លួន ។ អនុភាពស្នេហ៍សម្ងាត់បក់បោកក្នុងចិន្ដាស្រស់នារីនិងប្រុសថ្លៃ ។ មួយខណៈ អារម្មណ៍ទួននាងក៏វិលមកសភាពដើម ស្រីមានការអៀនអន់ នាងលបគេចមុខមកទិសផ្សេងទាំងប្រឹងងើបឈរ ដើម្បីឈានជើងទៅរកផ្ទះចាំចំការ ។ ពិសិដ្ឋរលត់បាត់ទូវការលង់ក្នុងអំណាចមន្តស្នេហ៍ដែរ គេសម្រួលទឹកមុខ រួចគេងើបឈរ ឆ្លៀតសួរស្រី :

-អ្នកនាងអាចដើរបានដោយខ្លួនឯងទេ ។

-ចាសមិនអីទេ ខ្ញុំអាច ...

មិនទាន់ចប់ប្រយោគផង នរលក្ខណ៍ឈានជើងដើរ តែខ្លួនប្រាណទាំងមូលមិនបានស្ដាប់បង្គាប់ស្រី ធីតាទ្រេតកាយរកកលដួល ហើយជើងក៏ឈឺជាខ្លាំងនាងភ្ញាត់មាត់ស្រែក :

-អូយ! ម៉េចឈឺម្ល៉េះ ?

ពិសិដ្ឋស្ទុះទៅទប់នាង មិនឱ្យដួល គេនិយាយ :

-រមួលក្រពើមិនងាយបាត់ឈឺភ្លាមទេអ្នកនាង ។

នរលក្ខណ៍ខាំមាត់ មិនចេញស្ដី នាងខ្មាសទរៈ នាងរំជួលក្នុងចិត្ត នាងមិនហ៊ានងាកមើលមុខគេ នាងព្យាយាមទប់ជំហរ ឈានជើងទៅមុខ តែមិនអាចទេនាងមិនអាចដើរបាន ការឈឺចាប់បង្ខំឱ្យនាងដាក់បង្អោយចុះ ។ ពិសិដ្ឋស្រដី :

-អនុញ្ញាតឱ្យខ្ញុំព្រាហ៍ណាំអ្នកនាង ។

មិនបាច់ទទួលចម្លើយពីធីតា កំលោះលូកដៃមកត្រកងទប់កាយទន់នាង ... កាយកៀកកិតគ្នា នរលក្ខណ៍មានអារម្មណ៍ច្រាស់ច្រាល ញ័រដៃញ័រជើង ទ្រូងលោតក្តុកក្តាក់ ។ នាងខ្មាសសឹងតែជ្រែកដីទៅឱ្យផុតពីមុខអ្នកប្រុស ... នាងដើរទៅមុខតិចៗ តាមការជួយគ្រាហ៍របស់បុរស ។ កាលបើការដើរក្នុងលក្ខណៈយឺតយ៉ាងនេះ វាហាក់ដូចជាសែនតានតឹងក្នុងឧរាស្រី ហេតុអីវវាងនាងនឹងអ្នកបើកបរថយន្តម្នាក់នេះ រមែងមានភាពស្និទស្នាលនឹងគ្នា ដែលនាងមិនអាចគេចវេះបាន ?ខ្មាសអៀន ខ្លាច កើតពេញទ្រូងស្រី។ ពិសិដ្ឋវិញ គេញញឹម គេលួចំតយតន់ភក្រ្តាស្រីដែលនៅកៀកបង្កើយមុខគេ ... និមលមិនហ៊ានកម្រើកខ្លួន ឬ ដៃជើង ហើយក៏មិនហ៊ានងាកមកមុខមើលគេដែរ តែស្រីហាក់ដឹងថា មានភ្នែកមួយគូកំពុងមើលមកនាង នាងចង់គេចពីភ្នែកនេះ ... តែមិនអាចគេចរួច ...

យីហ៊ុបងើបពីគេង នាងដើរចេញពីបន្ទប់មួយនៃផ្ទះចាំដី ពេលយីហ៊ុបមកដល់មុខផ្ទះ ស្រីក្មេងប្រកួកស្រែកហៅអ្នកបម្រើ :

-អើ ! នាងសឿនមកណេះ ។

សំឡេងប្រកួកហៅស្រីបម្រើ លាន់ពីមាត់របស់ចៅស្រីពៅរបស់លោកឧកញ៉ា លាន់មករំខានភាពស្ងប់ស្ងាត់របស់ម៉ានុតដែលអង្គុយអានកាសែត នៅលើគ្រែ នាមុខផ្ទះនេះ ។ ម៉ានុតងាកមករកទីដែលលាន់ស្នូរ ស្រាប់សំឡេងដូចរន្ទះរបស់យីហ៊ុបស្រែកមកម្តងទៀត :

-អើ មីខឿនមកណេះវ៉ី ។

-ស្រីស្អីគ្មានមារយាទសោះ ។" ម៉ានុតលបទឹកក្នុងចិត្ត "

យីហ៊ុបនាំកាយដើរចេញមកជិតម៉ានុត ។យល់រូបកំលោះសង្ហា នាងញញឹមដាក់ម៉ានុត ស្រីស្រដី :

-លោកម៉ានុតទេអ្ហែះ ពួកគេទៅណាអស់ហើយ ទើបលោកនៅទីនេះតែឯង ?

-បាទ គេទៅដើរកម្សាន្តបន្តិច មុននឹងទៅភ្នំពេញនាពេលល្ងាចនេះ ។ ខ្ញុំសុំលាអ្នកនាង ទៅតាមពួកគេដែរហើយ ។" ម៉ានុតនិយាយទាំងមុខស្មើ"

និយាយចប់ ម៉ានុតដើបដើរចេញរ៉ុយ ។ យីហ៊ុបរាំដៃរបៀបឃាត់បុរសនាងនិយាយ :

-លោកម៉ានុត ! លោកកុំ...

មិនខ្ចីស្តាប់ការឃាត់យ៉ាងរបស់ស្រីឆ្នាស់ ម៉ានុតដើរទៅមុខធ្វើវាហី ។ មុខយីហ៊ុបក្រញូវ ឈរសម្លក់ទៅម៉ានុតដែលកំពុងដើរទៅមុខ ធ្វើឫកបែបមិនដឹង ។ ឯមុខផ្ទះ ពិសិដ្ឋគ្រាហ៍នរលក្ខណ៍ដើរមកជិតដល់ផ្ទះល្ហម ។ ម៉ានុតងាកទៅឃើញអាការៈរបស់គេទាំងពីរ ទរៈស្រែកសួរទាំងរត់ទៅរកគេទាំងពីរ :

-អ្នកនាងលក្ខណ៍កើតអី ?

សំឡេងម៉ានុតទាញភ្នែកយីហ៊ុប ឱ្យងាកមើលទៅពិសិដ្ឋនិងនរលក្ខណ៍ នាងឃើញម៉ានុតស្ទុះទៅរកនរលក្ខណ៍និងពិសិដ្ឋ ។ យីហ៊ុបធ្លាប់តែជាស្រីមានកល ដូចនេះ នាងគិតថា ការដែលនរលក្ខណ៍មានភាពទុរ្គនទុរា ហើយត្រូវជួយគ្រាហ៍និងម៉ានុតរត់ទៅជួយដែរនេះ យីហ៊ុបយល់ថា ប្រាកដជានរលក្ខណ៍ធ្វើពុត ដើម្បីឱ្យប្រុសៗចាប់អារម្មណ៍និងយកចិត្តទុកដាក់ ជាមិនខាន។ យីហ៊ុបមួម៉ៅ, ខឹងច្រណែន ជាមួយនរលក្ខណ៍ ដែលមានមនុស្សប្រុសរូបសង្ហាដូចម៉ានុតបារម្ភពី

នរលក្ខណ៍ ។ យីហ៊ុបគ្រហឹមក្នុងដើមក សម្លក់ស្ទើរស៊ុះមកស៊ីសាច់បងស្រីជីដូនមួយ ដែលកំពុងត្រូវម៉ានុតនិងនាយក្លាមជួយគ្រាហ៍ដើរមករកផ្ទះ ។ យីហ៊ុបបោះជំហានទៅរកពួកគេ ទាំងមិនសប្បាយចិត្ត ។ ពិសិដ្ឋមិនបានសង្កេតទឹកមុខកញ្ចោមានល្បិច នាយរវល់តែបារម្ភពីអាការៈនរលក្ខណ៍ បុរសគិតថា មានយីហ៊ុបមកជាជំនួយ ទើបស្រដីទៅកាន់យីហ៊ុប :

-អ្នកនាងជួយគ្រាហ៍អ្នកនាងនរលក្ខណ៍ផង អ្នកនាងនរលក្ខណ៍រមួលក្រពើ

-មាយា ! ផោកទាប !

និយាយចប់ យីហ៊ុបដើរចេញរឹងទៅមុខ ដោយមុខពេបចំអកឱ្យបងស្រីជីដូនមួយ ។ ប្រយោគត្រេះតេះដៀលរបស់យីហ៊ុប ដូចគេយកកាំបិតមកពុះបំបែកដើមទ្រូង ... មុខនរលក្ខណ៍ស្លេកស្លូចក្រដាស នាងមិនដែលទទួលការប្រមាថ ពីនរណាបែបនេះទេ ស្រីខ្មាសចំពោះទង្វើនិងសម្តីយីហ៊ុប ដែលមិនគាប្បីមកនិយាយនិងសំដែងនូវឫកពា ដូចមិនស្គាល់នូវភាពថ្លៃថ្នូរ ។ ក្លាម ឬ ពិសិដ្ឋមិនចូលចិត្តចរិតយីហ៊ុបស្រាប់ គេមិនស្រដីមួយម៉ាត់ គ្រាន់តែប្រើក្រសែភ្នែកមិនពេញចិត្ត ព្រោះគេស្ថិតក្នុងឋានៈជាអ្នកបម្រើ។ មានតែកំលោះមាត់ឥតមេត្តាម៉ានុត ពេលឃើញអំពើរបស់យីហ៊ុប នរៈហួសចិត្ត គេស្រដីដោយត្រង់ៗប្រាប់នរលក្ខណ៍ :

-ប្អូនជីដូនមួយអ្នកនាងមាននិស្ស័យមិនល្អទេ អ្នកនាងកុំរវល់ស្តាប់សម្តីគេអី ។

វាចាម៉ានុតដូចជាលំពែងមកបុកទ្រូងស្រីនរលក្ខណ៍ ថ្វីបើវាជាពាក្យសម្តីដែលនរៈនិយាយមិនល្អពីយីហ៊ុប ដែលវាជាពាក្យមានន័យប្រមាថប្អូនជីដូនមួយ ហើយជាការលើកទឹកទឹកចិត្តដល់នាងក៏ពិតមែន តែវាជាប្រការមួយ ដែលចូលក្នុង

គន្លង ម៉ានុតក្តិចសាច់យីហ៊ុប ក៏ឈឺដល់សាច់នរលក្ខណ៍ដែរ ។ កល្យាណសែនខ្មាស ចំពោះម៉ានុត តែនាងមិនដឹងរើសយកពាក្យអ្វីមកតបទៅកាន់កំលោះម៉ានុតសោះ ។ ពិសិដ្ឋប្រហែលដាយល់ចិត្តស្រី គេនិយាយឮៗ ដើម្បីបំភ្លេបរិយាកាសតានតឹង :

- មីងសឿនអើយមកជួយផង អ្នកនាងលក្ខណ៍មិនស្រួលណា ។

មីងសឿនរត់ចេញពីក្នុងផ្ទះ ហើយពេលដែលគាត់មកដល់ក្រៅផ្ទះ គាត់ភ្ញាក់ ព្រោះឃើញចៅហ្វាយក្រមុំត្រូវគ្រាហ៍ដោយបុរសពីរនាក់ គាត់ស្ទុះមកជិតនាង ទាំងនិយាយ :

-អ្នកនាងលក្ខណ៍កើតអី ?

-មីងជួយនាំអ្នកនាងទៅក្នុងសិនទៅ មីងកុំអាលសួរអី ។"ក្លាម"

-ចាស ។" សឿនលូកដៃមកគ្រាហ៍នរលក្ខណ៍"

# ទគ្គទី ១២

ក្នុងបន្ទប់មួយនាសណ្ឋាគារទីបីរបស់គ្រួសារសិទ្ធា វេហាកំពុងដេកជាមួយនាងផល្លី ដែលនាងជាបុគ្គលិករៀបចំបន្ទប់ម្នាក់របស់សណ្ឋាគារទីបី ។ ជាព្រាននារី វេហាតែងតែផ្លាស់ប្ដូរម៉ាកស្រីកំដរបេះដូង បំពេញតណ្ហាមិនចេះឆ្អែតឆ្អន់របស់គេ ។ កាលពីលើកមុន វេហាប្រលោមលួងលោមនាងនី មកបម្រើចំណង់តណ្ហា ពេលនេះជានាងផល្លី ហើយពេលបន្តទៅមុខទៀត ប្រាកដជាស្រីផ្សេងជាក់ជាមិនខាន។

ជាមួយការស្នេហ៍កពាក់រូចរាល់ នាងផល្លីងាកមកញញឹម យកចិត្តផៅកែកំលោះ ។ វេហាញញឹមតបទៅម្ចាស់ចិត្តក្រៅទ្រូង វាចា :

-អូនគួរឱ្យស្រលាញ់ណាស់ ស្អែកមករកយើងទៀតណា៎ ។

ផល្លីញញឹមដាក់វេហា និយាយទាំងម្រិកម៉្រក់ :

-ចាស លោកប្រុស ។

ឯក្រៅបន្ទប់ នាងនីឈរសម្លក់សម្លឹងមកបន្ទប់ ក្នុងទឹកមុខដោកជាំដោយការក្រេវក្រោធ ។ បន្ទប់នេះ ... បុរសនេះ... គឺធ្លាប់ជារបស់នាង តែពេលនេះ វាបែរជារបស់ស្រីផ្សេង ... រឿងអីនាងមិនក្ដៅចិត្ត ។ នាងនីជានារីចិត្តស្មុយមួយរូប បើមិនដូច្នោះ នាងមិនមែនយកប្រាណមកប្ដូរយកប្រាក់ពីកំលោះម្ចាស់សណ្ឋាគារទេ ។ ឥឡូវបុរសជាឃ្លាំងប្រាក់របស់នាង បានក្លាយជាឃ្លាំងប្រាក់របស់អ្នកដទៃ ។សែនក្ដៅ នាងនីឈរចាំជជីកសួរវេហា ព្រោះអ្នកប្រុសមិនអាចងាយនឹងលេងសើចជាមួយនាងបានទេ ។ ទ្វារបន្ទប់បើក នាងផល្លីដើរចេញមក ញាក់មុខចំអកដាក់នាងនី ។ រវាងនាងនីនិងនាងផល្លី គឺជាប្រភេទនារីត្រូវការប្រាក់ ។ តែសម្រាប់នាងនី ថ្វីបើ

នាងយកក្រណាតមកប្តូរប្រាក់ ទោះនាងនៅមានការពិចារណា ដោយនាងផ្តល់តម្លៃដល់នារីដូចគ្នា នាងខឹងនឹងទង្វើនាងផល្លី តែនាងនៅតែយល់ថា នាងផល្លីមិនមែនជាមុខសញ្ញាសម្រាប់នាងត្រូវដោះស្រាយទេ ម្ចាស់បញ្ហាគឺជាវេហា ។ នេះជាការគិតរបស់នាងនី ទើបនាងបណ្តោយឱ្យនាងផល្លីដើរក្លួសទៅមុខ ធ្វើព្រងើយ តែយ៉ាងណាចិត្តនាងនីក៏រោលរាលដោយការខឹងនិងការឈឺចាប់មួយចំណែកមិនតិចទេ ដែលនាងផល្លីមកដណ្តើមឃ្លាំងប្រាក់របស់នាង ។ នាងមិនចាំបាច់ប្តឹងដំណើរនាងផល្លី ជាមួយការរិះគិត រិះរកវិធីជួយខ្លួននាង ។ តែត្រឹមពេលនេះ នាងមិនអាចចូលទៅរករឿងសួរនាំដល់វេហាបានជាដាច់ខាត ហើយខ្លួនកំពុងជាប់ ទាស់ទាញដោយកំហុស ខ្លួននឹងត្រូវដាច់ខ្សែជាមិនខាន ...ត្រូវតែរង់ចាំពេលវេលាល្អ ...

រាត្រីមកដល់ ផ្ទះសិទ្ធាទាំងមូលត្រូវបានបំភ្លឺដោយពន្លឺអគ្គិសនី ភ្លឺព្រោង ។ ក្រៅនេះមិនដឹងជាសមាជិកវិមានសិទ្ធាកំពុងធ្វើអ្វី ? កុំ ! ស៊ីយ៉ុបស្លៀកពាក់ស្អាត រៀបចេញទៅដើរលេង នាងយាត្រាមកកាន់បន្ទប់មាតា ។ បន្ទាប់ពីគោះទ្វារនិងបានការអនុញ្ញាតពីម្តាយ ស្រីយ៉ុបនាំកាយដើរទៅរកស្វាគា ទាំងបន្លឺវាចា :

-ម៉ាក់ ! ខ្ញុំសុំទៅដើរលេងហើយ ។

-កូនទៅដើរលេងទៀតហើយអ្ហែះ ? ហ៊ឹះ ! ពិតតែដើរលេង ចុះអារឿងក៏ចាត់នាងនរលក្ខណ៍ តើកូនគិតយ៉ាងម៉េច?

-ខ្ញុំទាក់ទងអ្នកលក់ស៊ុំញៀវមិនទាន់បានទេម៉ាក់ ។ ខ្ញុំទៅហើយម៉ាក់ ។

ស្វាគាងក់ក្បាលជាសញ្ញាយល់ព្រមតាមពាក្យរបស់កូនស្រី ។ រីឯនាងចេញទៅទាំងដៃគ្រវីក្របូប មាត់ច្រៀងហ៊ឹមៗ រង់ការស្រមៃនៃរាត្រីស្រៀង ។

តែកាលឯស្រុកត្រីតារា លោកជំនោរនិងវេហា ពួកគេមិនបានបណ្ដោយឱកាសឱ្យកន្លងទៅ ដោយគេមិនបានរិះរកកលល្បិចធ្វើបាបនរលក្ខណ៍ដែរ ។ ពេលនេះគេទាំងពីរនាក់កំពុងរៀបផែនការថ្មីក្នុងការធ្វើបាបនរលក្ខណ៍ ដោយតាភិនិយាយទៅកាន់វេហា :

-កូនត្រូវចាត់ការនាងលក្ខណ៍ទៀតហ៎ា ។

-តើឱ្យកូនចាត់ការនាងលក្ខណ៍អង្គាល់ម៉ាក់ប៉ា ?

-យប់នេះតែម្ដងទៅកូន ព្រោះនេះជាកូនសោរបន្ទប់នាងលក្ខណ៍ ។" លោកជំនោរហុចសោឱ្យវេហា"

-តែប៉ុណ្ណេះនាងឆ្កួតឯង រត់មិនរួចពីដៃកូនទេប៉ា ។

ហើយទុកឱ្យពួកគេទាំងពីរនាក់រៀបផែនការតម្រក់ ធ្វើបាបនរលក្ខណ៍ទៅទីនេះសិនចុះ ហើយបែរមកតាមសង្កេតពីកំលោះម្ចាស់ធនាគារវិញម្ដង ដែអ្នកប្រុសកំពុងកាន់រូបថតស្រី ភ្នែករបស់នរៈកំពុងតែផ្ដោតឥតព្រិចទៅលើរូបថត ភក្ត្រគេញញឹមស្រស់ ដោយការលង់ក្នុងអំណោចស្នេហ៍សម្ងាត់ តាមរយៈរូបថតស្រស់ស្រី ។ តាចាន់ដេកជិតកំលោះ គាត់ធ្វើជាបិទភ្នែក តែគាត់តែងតែសង្កេតឃើញពីអាកប្បកិរិយាប្លែករបស់នរៈ ម្យ៉ាងបើមើលទៅសាច់ឈាមរបស់ក្លាម មិនសមជាមនុស្សក្រីក្រលំបាក ទើបតាចាន់ក្លែងជាបិទភ្នែក តែគាត់លបបើកព្រឹមៗ លួចមើលមកពិសិដ្ឋ ។ គាត់ដឹងថា រូបថតដែលកំលោះកំពុងកាន់ជារូបចៅស្រីសំណព្វរបស់លោកឧកញ៉ា ។ តាចាន់កាត់យល់ថា ក្លាមកំពុងលង់ស្រឡាញ់ចៅហ្វាយស្រី ។ នេះមិនមែនជារឿងធម្មតាសម្រាប់មនុស្សដែលមានវណ្ណៈដូចក្លាមទេ ប្រាកដជានៅពីក្រោយខ្នងរបស់ក្លាម នឹងមានបង្កប់នូវអ្វីដែលគាត់មិនដឹង តែអ្វីនោះ ពិតជា

ទាក់ទងដល់គ្រួសារចៅហ្វាយរបស់គាត់មិនខាន ។

ពិសិដ្ឋកំពុងលង់ក្នុងការគនគយ់រូបថត តែគ្រាដែលគ្រួសារទារិកាកំពុងរៀបផែនការអាក្រក់បំផ្លាញឲ្យបាទនរលក្ខណ៍ អារម្មណ៍ទីប្រាំមួយរបស់ពិសិដ្ឋកំពុងតែបង្ហាញប្រាប់គេ នូវរូបភាពវេហាទទួលសោពីលោកជំទាវ ។ កាលបើឃើញរូបភាពបែបនេះ ពិសិដ្ឋស្ទះដើមអង្គុយ និយាយតិចៗតែឯង :

-អ្នកនាងនរលក្ខណ៍ត្រូវជួបគ្រោះថ្នាក់ !

សំឡេងពិសិដ្ឋកន្ត្រាក់អារម្មណ៍តាចាន់ ឱ្យមានការងឿងឆ្ងល់ គាត់លបបើកភ្នែកមើលពិសិដ្ឋ ។ គាត់ឃើញពិសិដ្ឋឈរក្នុងអាការៈឈឹងប៉ង និយាយតែឯងតិចៗនូវពាក្យចម្លែក :

-ពេកហោយតូចមាស ! លោកហោយតូចកុំសម្លាប់មនុស្ស ។

កម្តៅអានពេញទ្រូងតាចាន់ គាត់នឹកក្នុងចិត្ត :

-អាក្រមជានរណា ហេតុអ្វីគេហៅឈ្មោះលោកជំទាវមាស ជាលោកកាកក្តួក ។

យើងទុកឱ្យពិសិដ្ឋនិងតាចាន់នៅទីនេះសិនចុះ យើងមកមើលនរលក្ខណ៍វិញ ពេលនេះនាងកំពុងមើលបញ្ជីការងារនៅឡើយ ។ ពេលវេលាចេះតែរសាត់ទៅមុខ នរលក្ខណ៍នៅតែពិនិត្យការងារ យូរៗទាងស្វាប ឬ ពត់ខ្លួនពត់ដៃជើង ដែលធុញទ្រាយដោយការអង្គុយជាច្រើនម៉ោងកន្លងមក ។ យប់យន់កាន់តែជ្រៅ ភាពងងុយបានមកសណ្ឋិតលើរូបនាង ត្រីបិទបញ្ជី នាងដើរមកគ្រែគេង ។ កល្យាណប្រុសកាយលើពូក នាងចោលភ្នែកទៅចំខោអាវដែលនាងស្លៀកពាក់នៅថ្ងៃលង់ទឹក ដែលដាក់លើពូក សម្រាប់ទុកឱ្យនាងស្លៀកពាក់នាពេលត្រូវគេង អារម្មណ៍ធីតា

ស្រមៃ នាពេលពិសិដ្ឋរីតដើងឱ្យនាង ពិសិដ្ឋត្រាហ៍នាង ពិសិដ្ឋឱបនាងក្រោយប់មួយនោះ ពិសិដ្ឋជូលេសង្កត់លើរាងកាយនាងយ៉ាងស្អិតស្អាល ។ មិនយល់ចិត្តខ្លួនឯង ហេតុអីឱ្យតែពេលទំនេរ អារម្មណ៍ស្រីតែងតែហោះហើរទៅប្រឡែងជាមួយស្រមោលរូបភាពទាំងនេះ ? នាងនឹកគេ នាងចេះតែគិតដល់គេ នាងកំពុងស្រឡាញ់គេឬ ? នាងមិនច្បាស់ក្នុងចិត្តទេ ។

សំឡេងទូរស័ព្ទរបស់នរលក្ខណ៍លាន់ ស្រីលើកវាមកស្តាប់ៈ

-អាឡូជម្រាបសួរ តើជាអ្នកណា ? នាងទីអេះ ? នាងជានរណា ? មិនអីទេ បន្តិចទៀតខ្ញុំនឹងទៅជួបនាង ។

នាងទីបានរៀបរាប់ពីរឿងរ៉ាវរវាងនាងនិងវេហា រវាងវេហានិងនាងផល្លីជម្រាបប្រាប់នរលក្ខណ៍ ដើម្បីទាមទារឱ្យស្រីជួយរកយុត្តិធម៌ ។ ក្នុងនាមជាចៅហ្វាយស្រីត្រូវតែជួយដោះស្រាយដល់បុគ្គលិក ទោះជាវេហាជាសាច់ឈាមក៏ដោយ ។ នរលក្ខណ៍បានមកហៅក្តាម ដើម្បីបើករថយន្តជូនស្រីទៅកាន់សណ្ឋាគារទីបី ទាំងយប់អាធ្រាត្រ ។

នរលក្ខណ៍ដើរពីមុខ ពិសិដ្ឋដើរពីក្រោយនាង តម្រង់ទៅរកទីកន្លែងដែលនាងទីណាត់ជួប ។ ពិសិដ្ឋដើរផង គេឆ្លៀតវាចាទៅកាន់នរលក្ខណ៍ផង :

-អ្នកនាងនរលក្ខណ៍ យប់នេះ ខ្ញុំសុំអង្វរអ្នកនាងណ៎ា សុំអ្នកនាងកុំវិលទៅសម្រាន្តនៅវិមានមាសអីណ៎ា ។

-អ្នកមានមូលហេតុអីមកហាមខ្ញុំ ?

ពិសិដ្ឋឧស្សុត និយាយ :

-សុំអ្នកនាងកុំសួរពីមូលហេតុ តើបានទេ ? សុំគិតថា ខ្ញុំបារម្ភពីអ្នកនាង ។

មុខនរលក្ខណ៍ស្លត់ នាងមើលមុខគេ ជាមួយសំណួរជាច្រើនកើតក្នុងចិត្ត ។ ពិសិដ្ឋមើលមកនាង តែវិញ្ញុកបុរសជិតដោយការអង្វរ ក្នុងន័យឱ្យស្រីយល់ព្រមតាមសំណើរបស់គេ ។ ទាំងគេបន្តវាចា :

-ខ្ញុំអង្វរអ្នកនាងហើយ កុំអញ្ជើញទៅវិមានមាសក្នុងយប់នេះអី ។

កាន់តែងងឹតក្នុងចម្ងល់ ហើយនាងមិនដឹងត្រូវសួរពីចំណុចទៅចំណុចណា ដើម្បីរាវរកការពិតពីនាយក្លាម ដែលធ្វើអ្វីប្លែកមកលើរូបនាង ។ ទីបំផុតនរលក្ខណ៍មិនបានបើបវាចាមួយម៉ាត់ ។ ស្រីយកបញ្ហានាងទីមកគិតក្នុងចិត្តសិន រឿងទាក់ទងជាមួយក្លាម ចាំដោះស្រាយនៅពេលក្រោយចុះ ។ និមលពោះជំហានទៅរកកន្លែងនាងទីបានហោត់ ។ ពិសិដ្ឋដើរតាមនាងទាំងលែងស្តី គេមិនដឹងថា តើចៅហ្វាយស្រីនឹងព្រមតាមសម្តីគេដែរទេ ? គេមិនហ៊ានទិយាយបន្ថែមទេ ព្រោះមើលទៅឫកពារបស់នាង ពាក់ដូចជាមានធុរៈត្រូវធ្វើការនាពេលបន្តិចទៀតនេះ ។ អ្នកទាំងពីរដើរជិតដល់បន្ទប់មួយ ជាលេខបន្ទប់ដែលវេហាដេកជាមួយនាងទីនិងវេហាធ្លាប់ដេកជាមួយនាងផល្លី នរលក្ខណ៍ឈប់ដើរ នាងងាកមកមើលក្លាម នាងវាចា :

-ខ្ញុំធ្វើតាមសម្តីអ្នក យប់នេះ ខ្ញុំដេកក្នុងសណ្ឋាគារ ហើយអ្នកវិលទៅវិមានសិន្ទាចុះ ។

-ខ្ញុំបាទសុំមិនវិលទៅវិមានមាសទេ ។

-សុំអ្នកកុំហៅឈ្មោះផ្ទះខ្ញុំថា វិមានមាសទៀតអី ព្រោះយ៉ាងណា ខ្ញុំមិនដូរឈ្មោះផ្ទះខ្ញុំទេ ។

-ខ្ញុំមិនឈប់ហៅទេ ព្រោះ...

មុខពិសិដ្ឋទឹកឃើញអ្វីមួយ មុខគេប្រែជាស្លូត និយាយ :

-អុះ!អ្នកនាងអញ្ជើញចូលចុះ ខ្ញុំបាទទៅដេកក្នុងឡាន ដើម្បីចាំអ្នកនាង ។

និយាយចប់ ពិសិដ្ឋបកក្រោយដើរលឿនរឹង ព្រោះមិនចង់ឆ្លើយជាមួយសំណួរ ដែលស្រីអាចនឹងសួរពីអ្វីដែលអ្នកអះអាងមិនព្រមឈប់ក្នុងការហៅវិមានមាស ។ អាកប្បកិរិយាពិសិដ្ឋកាន់តែបង្កភាពងឺងើក្នុងចិត្តនរលក្ខណ៍ ស្រីតាមមើលគេ ជាមួយចម្ងល់ ទាំងនាងនឹកក្នុងចិត្ត ៖

-គេចម្លែកណាស់ មានអារម្មណ៍ប្រែប្រួលយ៉ាងម៉េចមិនដឹងទេ ។

រួចនាងងាកមកបើកទ្វារបន្ទប់ ស្រីដើរចូលទៅក្នុង ភ្នែកនាងឃើញនាងនីអង្គុយយំលើពូក ។ វត្តមាននរលក្ខណ៍ បណ្ដាលឱ្យនាងនីងាកមករកចៅហ្វាយស្រី ដោយនាងនីរត់មកឱបជើងនរលក្ខណ៍ នាងនីស្រែកយំខ្លាំងៗ ៖

-អ្នកនាងនរលក្ខណ៍ អ្នកនាងជាស្រីដូចខ្ញុំដែរ ខ្ញុំមានក្ដីសង្ឃឹមតែលើអ្នកនាងទេ ហ៊ឹក ហ៊ឹក ។

នរលក្ខណ៍មុខឆ្ងល់ នាងមើលនាងនី លក្ខណ៍និយាយ ៖

-នាងងើបសិនមក កុំធ្វើបែបនេះ នាងមានបញ្ហាអីដែលពិបាក នាងនិយាយមកចុះ បើខ្ញុំអាចជួយនាងបាន ខ្ញុំនឹងជួយនាងណា៎ ។

នាងនីងើបពីឱបជើងនរលក្ខណ៍ នាងនីយំផង និយាយផង ៖

-អ្នកនាង ខ្ញុំត្រូវ ... ត្រូវអ្នកប្រុសវេហា ... រំលោភ ហ៊ឹក ហ៊ឹក ទាំងពីថ្ងៃដែលអ្នកនាងអញ្ជើញមកធ្វើការដំបូងម្ល៉េះ ហ៊ឹក ហ៊ឹក ។

-ចុះហេតុអីនាងទើបតែមកប្រាប់ខ្ញុំនៅពេលនេះ ?

-ព្រោះតែខ្ញុំល្ងង់ ... ខ្ញុំជឿពាក្យបោកប្រាស់របស់លោកប្រុស ... គាត់លួងលោមខ្ញុំ គាត់ថា ... គាត់នឹងរៀបការជាមួយខ្ញុំ ហ៊ឹក ហ៊ឹក ។

-ហើយពេលនេះ ហេតុអីនាងយំទៅវិញ ?

-ចាស គឺខ្ញុំមានទុក្ខធំណាស់ ហ៊ឹក ហ៊ឹក ព្រោះខ្ញុំមានផ្ទៃពោះជាមួយលោកប្រុស ។

-ពេលនេះនាងត្រូវការឱ្យខ្ញុំជួយនាងយ៉ាងណា ?

-ចាស ខ្ញុំស្រឡាញ់លោកប្រុសវេហា ហ៊ឹក ហ៊ឹក ខ្ញុំអាណិតកូនក្នុងផ្ទៃហ៊ឹក ហ៊ឹក ខ្ញុំត្រូវការប្ដីនិងកូន ខ្ញុំចង់រៀបការជាមួយលោកប្រុសវេហា ។

-ពាក្យទាំងនេះ នាងគួរតែនិយាយជាមួយបងវេហា មិនមែនមកនិយាយជាមួយខ្ញុំទេ ។

-តែបងវេហាបានក្បត់ចិត្តខ្ញុំ ហើយបដិសេធមិនទទួលស្គាល់កូនក្នុងពោះខ្ញុំទេ អ្នកនាង ។

យើងទុកឱ្យនាងនីយំរៀបរាប់ពីទុក្ខសោកដោយការបោកប្រាសរបស់វេហាមួយភ្លែតសិន យើងបែរមកមើលឯវិមានសិទ្ធាវិញ គឺវេហាកំពុងចាក់សោបន្ទប់នរលក្ខណ៍ គេដើរចូលទៅក្នុងបន្ទប់ស្រី ក្នុងបំណងដើម្បីសម្រេចផែនការចាប់រំលោភនរលក្ខណ៍ ក្នុងយប់នេះ ។ ទ្វារបន្ទប់របើក ជាមួយសភាពងងឹតចាក់ភ្នែកមិនយល់បណ្ដាលឱ្យវេហាត្រូវដើររបៀបរាវិតម្រង់ទៅរកគ្រែស្រស់ស្រី ។ ក្នុងចិត្តកំលោះពាល គេគិតថា យប់នេះបុត្រីរបស់លោកកិត្យាគេចមិនផុតពីកណ្ដាប់ដៃរបស់គេឡើយ ។ ប៉ុន្តែបងប្រុសទារិកាទទួលអារម្មណ៍ថា ដូចជាមានខ្យល់ត្រជាក់ៗបក់មកប៉ះខ្នងគេ ។ បុរសងាកក្រោយដោយស្វ័យប្រវត្តិ ភ្នែករបស់គេត្រូវបើកធំៗជាមួយនឹងការភ្ញាក់ផ្អើលនឹងវត្តមានរបស់ស្រីក្រមុំរូបស្អាតមួយរូបឈរញញឹម ក្នុងទីងងឹត សម្លឹងមកគេ ដែលវេហាឃើញនាងដោយព្រាលៗ ... ភ្ញាក់ដូចគេកន្ត្រាក់

ទាញមកក្រោយ ព្រោះតែជាខ្មោចយាយមាស ។ ខ្យល់ត្រជាក់ដូចជាភាយចេញពីខ្លួនខ្មោចយាយមាស មកប៉ះមុខវេហា បុរសព្រាននារីបន្លឺសួរ ៖

-នាងជាអ្នកណា ?

ខ្មោចស្រីរលាយសូន្យសុងជាមួយភាពអន្ធការ វេហាលាន់មាត់ទាំងយកដៃញីភ្នែក ៖

-ចេះស្រវាំងភ្នែកឃើញជាមនុស្សស្រីទៅកើត ខ្ញុំនេះ ។

ស្នូរទឹកធ្លាក់ចេញពីរូប៊ីណេលាន់ពីក្នុងបន្ទប់ទឹក វេហាញញឹមក្រញូចមាត់ដើរយ៉ាងគឃ្លើនតម្រង់ត្រែពូករបស់ស្រស់ស្រី ព្រាននារីរូបស្រស់ចោលភ្នែកទៅកន្លែងដែលមានស្នូរទឹកធ្លាក់ ដោយគេនឹកគិតថា នរលក្ខណ៍កំពុងងូតទឹកនៅទីនោះ។ កំលោះក្បាលខូចប្រាសកាយដេកចាំចំណីឆ្ងាញ់ទាំងចិត្តសង្ឃឹមញញឹមទុក ។ មួយនាទី ពីរនាទី រហូតដល់ដប់នាទីកន្លងផុតទៅ ស្នូរទឹកហូរក៏លែងលាន់ឮសូរ តែទ្វារបន្ទប់ទឹក មិនឃើញរបើកសោះ វេហាសម្លឹងទៅបន្ទប់ទឹក រង់ចាំស្រមោលស្រីស្រស់បោះជំហានមករកគ្រែគេង ... ចាំបាត់ ចាំបាត់ គ្មានឃើញស្រមោលនរលក្ខណ៍ចាកចេញពីបន្ទប់ទឹក វេហាហាក់ដូចជាមានមន្ទិល សង្ស័យ បារម្ភក្រែងនរលក្ខណ៍ដឹងខ្លួន នាងពួនគេចសម្ងំលាក់កាយនៅទីនោះ ។ គិតរួច វេហាងើបដើរសំដៅបន្ទប់ទឹក ។ ដៃកំលោះរុញទ្វារបន្ទប់ទឹក ស្រាប់តែគេឮស្នូរទឹកហូរពីផ្កាឈូកលាន់មកឈូរៗជាថ្មី ។ ជាការចម្លែក ទ្វារបន្ទប់ទឹកស្រាប់តែរបើកឃ្វាំង ភ្នែករបស់វេហាមើលឃើញទឹកផ្កាឈូកបើកចោល ហូរស្រក់មកលើឥដ្ឋ ហើយមិនមានស្រមោលមនុស្សនៅទីនេះទេ ។ កំលោះមឹងម៉ាំង គេរវើភ្នែកសព្វទិសទី ក៏មិនមានឃើញមនុស្ស ។ ខ្យល់ត្រជាក់បក់មកប៉ះខ្នងគេទៀតហើយ ខ្មោចយាយមាស

ផុសភ្លែតដូចនិមិត្ត នៅពីក្រោយវេហា ។ វេហាទទួលអារម្មណ៍ដូចជាមានមនុស្ស មកពួនលីបលទៅពីក្រោយខ្នងគេ នរៈងាកវឹបមកក្រោយ ប៉ុន្តែគ្មាននរណាម្នាក់សោះ ។ វេហានិយាយតិច១ :

-អូនលក្ខណ៍ចេះលលេងនឹងបងផង ? អូនកុំពួនអី ចេញមក ។

ខ្មោចយាយមាសផុសនៅខាងក្រោយខ្នងវេហាម្តងវិញ ខ្មោចបញ្ចេញសិល្ប៍ធ្វើឱ្យទឹកលែងចេញពីផ្កាឈូក ។ វេហាដូចជាមានការសង្ស័យមិនដឹងអ្នកណាដើរមកបិទទឹកនៅពីក្រោយខ្នងគេ គេក៏ងាកមកត្រង់ទឹកផ្កាឈូក ទាំងនៅលើអង្គ ទាំងនៅត្រង់ក្បាលរ៉ូប៊ីណេផ្កាឈូក គ្មានទឹកសូម្បីមួយតំណក់ ថែមទាំងឥដ្ឋមានសភាពស្ងួតចេស វេហាដូចជាព្រឺសម្បុរខ្លាក១ ក្បាលដូចព្រឺដែរ គេប្រញាប់ប្រញាល់ដើរមករកគ្រែគេងវិញ ។ ផ្ទៃបន្ទប់មានពន្លឺភ្លើងអគ្គិសនីជះរស្មីចិញ្ចាច ធ្វើឱ្យភ្នែកវេហាក្រឡេកទៅឃើញនរលក្ខណ៍គេងនៅលើគ្រែពូក សើចញញឹមមករកគេ ។ សម្រស់នារីតូចតន់ស្រួបអារម្មណ៍វេហាឱ្យលង់ទៅក្នុងក្តីស្នេហ៍ រហូតភ្លេចគិតថា មុននេះផ្ទៃបន្ទប់ទាំងមូលងងឹតសូន្យសុង ។ បុរសពាលដើរទៅរកនាង គេទម្លាក់ខ្លួនអង្គុយប្រេបកាយស្រី ។ ខ្មោចយាយមាសក្នុងស្រោមរូបកាយនរលក្ខណ៍ងើបអង្គុយ លូកដៃមកស្រវាអោបកកំលោះ ។ មិនបង្អង់យូរ ឃើញចំណីឆ្ងាញ់មកបញ្ចុកដល់មាត់ហើយ វេហាញញឹម ស្ទុះភ្លែតក្រសោបអោបកាយស្រី ។ ផ្ទៃមុខនរលក្ខណ៍ស្រាប់តែក្លាយជាផ្ទៃមុខយាយមាស ក្នុងសភាពដូចជាមនុស្សពិត១ ។ វេហាស្រឡាំងកាំងសម្លឹងមុខយាយមាស បន្លឺសួរ :

-នាងជានរណា ?

មុខយាយមាសក្លាយជាមុខនរលក្ខណ៍ រួចក្លាយជាមុខយាយមាសវិញ តែបែបនេះជាច្រើនដង វេហាដូចជាយល់ថា ខ្លួនស្រវាំងភ្នែក គេយកដៃញីភ្នែក ហើយប្រឹងសម្លឹងស្រីស្រស់ដែលអង្គុយកៀកកាយគេ ។ វាទៅតែឋិតក្នុងសភាពជាដដែល ម្តងជាមុខយាយមាស ម្តងជាមុខនរលក្ខណ៍ ចុងក្រោយគឺជាមុខយាយមាស ។ខ្មោចយាយមាសលើកដៃបញ្ចេញសិល្ប៍រុញរាងកាយវេហា ឱ្យវិលខ្វាល់ដូចកន្ទេះឡង់ ។ វេហាស្រែកទាំងភ័យខ្លាច :

-កុំធ្វើបាបយើង កុំធ្វើបាបយើង នាងជានរណា ?

-ហាស់ ហាស់ ។

បិសាចសើចខ្ទរខ្ទាំពេញបន្ទប់ រួចក៏បញ្ឈប់សកម្មភាពសើច បញ្ចេញវេទមន្តស្រូបព្រលឹងវេហា ឱ្យដើរមកតាមខ្លួនចេញមកក្រៅបន្ទប់ ។ មនុស្សក្នុងផ្ទះសិទ្ធាទាំងអស់គេងលង់លក់អស់ទៅហើយ ម្យ៉ាងបិសាចក៏បំបាំងកាយ មិនឱ្យនរណាមើលឃើញ ក្រៅពីវេហាម្នាក់ ទើបវេហាត្រូវដើរតត្រុកដោយអំណាចស្រូបព្រលឹងរបស់បិសាច សំដៅទៅសួនឧទ្យានមុខផ្ទះ ។ លុះមកដល់សួនច្បារ ខ្មោចស្រីបញ្ចេញសិល្ប៍រុញវេហាឱ្យរត់ទៅបុកបង្គោលភ្លើង ក្បែរគុម្ពផ្កាចេកទេសជាច្រើនដង ។ ឈាមហូរហាម ពីត្រង់មុខរបួសនៅក្បាល វេហាឈឺជាខ្លាំង តែគេមិនអាចទប់កាយមិនឱ្យរត់ទៅបុកសរសរបង្គោលភ្លើងបានឡើយ ... វេហារត់បុកសរសរបង្គោលភ្លើង រត់មិនឈប់ រត់បុកជាច្រើនលើក រហូតដល់ដាច់ខ្យល់ស្លាប់ ដួលដេកនៅលើស្មៅក្បែរគុម្ពផ្កាចេកទេស ។

ពិសិដ្ឋទទួលអារម្មណ៍ដឹងភ្លាមថា យាយមាសបានសម្លាប់វេហា បុរសភ្ញាក់ក្រញ្ញាង គេស្រែកទាំងរន្ធត់ចិត្ត :

-លោកយាយកុំសម្លាប់គេ !

ស្រែកបានត្រឹមតែប៉ុណ្ណោះ កំលោះម្ចាស់ធនាគាររំចង់ទម្លាក់ខ្លួនអង្គុយលើពូករថយន្ត ទាំងមុខអស់សង្ឃឹម គេដឹងថា វេហាបានស្លាប់មុននេះបន្តិចទៅហើយ គេមិនមានវិធីណាអាចសង្គ្រោះព្រានទារីកំលោះនោះបានឡើយ ។ ស្រាប់តែវិញ្ញាណទីប្រាំមួយរបស់គេ បង្កើតរំញោចជាថ្មី ឱ្យគេតក់ស្លុតម្តងទៀត ជាមួយប្រយោគតិចៗ :

-ហ៊ឺ ! យប់នេះ លោកយាយតូចនឹងសម្លាប់អ្នកនាងឃីហ៊ុបទៀត ហេតុអីលោកយាយសម្លាប់មនុស្សមិនឈប់ឈរសោះ ។

ចរន្តគំនិតពិសិដ្ឋរត់រសីបពាសពេញខួរក្បាលគេ ពិសិដ្ឋមិនចង់ឱ្យលោកយាយតូចសម្លាប់មនុស្សជាបន្តបន្ទាប់យ៉ាងនេះទេ តែគេមិនដឹងរកវិធីណា ដើម្បីទប់ទល់ជាមួយខ្មោចយាយមាស ក៏ដូចជារកវិធីជួយសង្គ្រោះមនុស្សជាសមាជិកគ្រួសារសិទ្ធាឱ្យរួចផុតពីសេចក្តីស្លាប់ ... គិតចុះគិតឡើង ប្រហែលមានតែនាងនរលក្ខណ៍ទេដែលអាចជួយជាគំនិតដល់រូបគេ ។ បុរសរូបសង្ហាក៏ស្ទុះងើបរត់ដើម្បីទៅរកទូរលូងដើម្បីពិគ្រោះយោបល់ ។ រត់បានប្រហែលជាប្អូនប្រាំជំហាន ពិសិដ្ឋស្រាប់តែឈប់ង៉ក់ ធ្លាយវាចាតែឯកឯង :

-តើយើងនិយាយថាម៉េច ដើម្បីឱ្យនាងជឿយើងហ្ន៎ ?គ្មានផ្លូវដែលនាងជឿយើងឡើយ ។

គេដើរយឺតៗត្រឡប់មករករថយន្តរបស់នរលក្ខណ ដែលមុននេះ គេទើបតែចាកចេញពីយាន មុខគេបង្ហាញនូវភាពអស់សង្ឃឹមរលីងក្នុងចិត្ត ដើម្បីរកផ្លូវ

ជួយមនុស្សទាំងអស់ក្នុងវិមានសិទ្ធា ឱ្យរួចផុតគ្រោះថ្នាក់ពីកណ្ដាប់ដៃយាយមាស ។ មកដល់រថយន្ត បុរសក្លែងកាយចូលអង្គុយក្នុងយាន ទាំងល្ងើងល្ងើយក្នុងចិត្ត ។

យីហ៊ុបឯណោះវិញ នាងទើបតែចេញពីឱស្ថតែក ស្រីដើរតម្រង់ទៅរករថយន្តរបស់ស្រី ក្នុងគំនិតបម្រុងវិលត្រឡប់ទៅកាន់វិមានសិទ្ធាវិញ ។ កញ្ញាឆ្នាស់ផ្ដើមបញ្ឆេះយានក្នុងល្បឿនលឿនស្ទើរ តាមទម្លាប់ចិត្តព្រហើនរបស់ក្មេងឈាមរាវ ។ ខ្មោចយាយមាសផុសភ្លែតអង្គុយច្រងុកៗ នៅបាំងខាងក្រោយខ្នងយីហ៊ុប ។ សិល្ប៍បិសាចធ្វើឱ្យអំពូលភ្លើងនៅក្នុងរថយន្តបញ្ចេញពន្លឺភ្លឺដូចថ្ងៃ រួចភ្លាមនោះពន្លឺក៏រលត់ភ្លឹប ។ យីហ៊ុបឆ្ងល់ណាស់ នាងលាន់មាត់ :

-យ៉ាងម៉េចវាហ្នឹង បានជាម្ដងឆេះ ម្ដងភ្លឺ ។

មិនទាន់ទាំងចប់ប្រយោគកញ្ញាឆ្នាស់ស្រួលបួលផង សភាពក្នុងឡាន ក៏ភ្លឺចែសម្ដងទៀត ជាមួយដៃយាយមាសលូកមកកេះស្មាយីហ៊ុប ។ យីហ៊ុបភ្ញាក់ព្រើតងាកក្រោយភ្លែត នាងឃើញខ្មោចយាយមាសក្នុងសភាពជាមនុស្សធម្មតា សើចស្នាញដាក់នាង យីហ៊ុបលាន់មាត់ :

-នាងឯងមកពីណា មកនៅក្នុងឡានយើងតាំងអង្កាល់ ?

មុខយាយមាសក្លាយជាមុខបិសាច ភ្នែកលៀនឡើងក្រហមដូចឈាម សក់វែងរតេរតាយ ហាមាត់បំពងសំណើចញ័ររង្គើររថយន្តទាំងមូល ។ យីហ៊ុបតក់ស្លុតនាងស្រែកទាំងរន្ធត់ :

-ខ្មោច! ជួយផង !

ខ្មោចស្រីលោតផ្លោតមកអង្គុយកៀកយីហ៊ុប លូកដៃមកទាញចង្កូតយានឱ្យរេទៅបុកសរសរដងគោម ។ យីហ៊ុបមិនអាចទប់ចង្កូតយានមិនឱ្យទៅបុកសសរ

ដងគោមបានឡើយ កម្លាំងមនុស្សធ្វើម៉េចអាចឈ្នះសិល្បៈរបស់ខ្មោច។ យីហ៊ុប ភ័យណាស់ នាងទាញចង្កូតផង នាងស្រែកផង :

-កុំធ្វើបាបយើង លែង អូយ យើងខ្លាច ខ្លាចណាស់ ។

ស្រាប់ចង្កូតរថយន្តរបស់យីហ៊ុបរេយ៉ាងលឿនស្លេវ ទៅរកសសរដងគោម លាន់ឮសូរម៉ាំង ... យីហ៊ុបក៏ស្លាប់ភ្លាមក្នុងថ្លុកឈាមស្រោចជោកប្រាណ ។ បិសាច សើចរំពងមេឃ បោះស្ទេវចេញពីយានយន្ត ទៅកណ្តាលលំហអាកាស បន្សល់ សំណើចយ៉ាងគ្រលួច កណ្តាលយប់ស្ងាត់ ។

ចំណែកនរលក្ខណ៍វិញ នាងកំពុងតែអង្គុយបន្តស្តាប់ការរៀបរាប់របស់ នាងនី ដែលទាមទារឱ្យនាងជួយធ្វើយ៉ាងណា ដើម្បីឱ្យវេហាទទួលស្គាល់កូនក្នុងផ្ទៃ នរលក្ខណ៍ក៏ស្រដីជាចុងក្រោយមកកាន់បុគ្គលិករូបនេះ :

-ណ្ហើយ ! ចាំស្អែកខ្ញុំនឹងណាត់បងវេហាមកជួបនាង នៅចំពោះមុខខ្ញុំ ហើយខ្ញុំនឹងនិយាយ ឱ្យបងវេហាទទួលខុសត្រូវលើរូបនាង ។

នាងនីសំពះនរលក្ខណ៍ និយាយ :

-ដូចខ្ញុំគិតមិនខុស អ្នកនាងតែម្នាក់គត់ដែលអាចជួយខ្ញុំ ។

នរលក្ខណ៍មុខគិត និយាយ :

-នាងទៅចុះណ៎ា តែមិនត្រូវទៅផ្ទះទាំងយប់បែបនេះទេ នាងទៅក្នុង គេងបន្ទប់អ្នកធ្វើការវេនយប់ចុះ ។

នាងនីសំពះនរលក្ខណ៍ :

-ចាស អរគុណអ្នកនាង ។

នាងនីដើរចេញទៅ ទាំងចិត្តសង្ឃឹម នាងលែងបារម្ភថា កូននឹងអត់ឪពុកទៀតហើយ ។ នរលក្ខណ៍មានការអាណិតនាងនី នាងមិនគួរលេងសម្ដីផ្អែមល្ហែមរបស់បងជីដូន នរលក្ខណ៍ត្រូវតែរកវិធីព្យាយាមបង្ខំឱ្យវេហាផ្ដល់យុត្តិធម៌ដល់នាងនី ទោះជាបុរសព្រានមិនទទួលស្គាល់នាងជាភរិយា ក៏ត្រូវតែមានការទទួលខុសត្រូវ លើកូនក្នុងផ្ទៃនាងនីដែរ ។ គិតបណ្ដើរ ជំហាននាំកាយស្រីដើរទៅរកទ្វារបណ្ដើរ គ្រាដែលទ្វារបន្ទប់របើក ស្រីឃើញពិសិដ្ឋឈរចាំនៅមាត់ទ្វារបន្ទប់ នាងភ្ញាក់ស្រឡាំងកាំង បន្លឺសួរគេ :

-ហេតុអីអ្នកមកនៅទីនេះ ?

-ខ្ញុំបាទចង់ឱ្យអ្នកនាងអញ្ជើញទៅវិមានមាសវិញក្នុងយប់នេះ ព្រោះនៅទីនោះកំពុងកើតរឿងធំហើយ ។

-អ្នកកំពុងធ្វើឱ្យខ្ញុំឆ្ងល់ហើយ ។

-បាទ សុំកុំសួរពីមូលហេតុអី សុំអ្នកនាងប្រញាប់អញ្ជើញទៅវិមានមាសវិញចុះ ។

នរលក្ខណ៍ឆ្ងល់ នាងមើលមុខគេ នាងឃើញមុខពិសិដ្ឋមានភាពស្រងូតស្រងាត់ នរលក្ខណ៍និយាយ :

-តោះ! យើងទៅវិមានសិទ្ធា មិនមែនទៅវិមានមាសទេណ៎ក្លាម ។

ក្លាមងក់ក្បាល មិនមានតវ៉ាទាមទារឱ្យស្រីហៅឈ្មោះវិមានសិទ្ធា ជាវិមានមាសទៀតទេ ដោយគេមានការបារម្ភដល់សុវត្ថិភាពមនុស្សក្នុងគ្រួសារសិទ្ធា ។ យល់ថា មាណពមិនតវ៉ាក្នុងការហៅឈ្មោះផ្ទះ ជាវិមានសិទ្ធា ធីតាគិតក្នុងចិត្ត :

-ចម្លែកណាស់យប់នេះ គេមិនតវ៉ាដែលយើងហៅថា វិមានសិទ្ធាទេហ្ន៎? ហើយហេតុអីយើងត្រូវស្តាប់និងធ្វើតាមសម្តីមនុស្សម្នាក់នេះ ? បើនេះជាពេលយប់ទៀតផង យើងមិនគួរទៅណា មកណា ជាមួយគេ តែពីរនាក់ទេ ។

គិតដល់ត្រឹមនេះ ស្រីល្អងាកមកក្លាម ស្រដី :

-អ្នកមិនបាច់ទៅជាមួយយើងទេ ។

-អ្នកនាងកុំខ្លាចខ្ញុំ ខ្ញុំបាទយកកិត្តិយសកូនប្រុសមកធានា ខ្ញុំបាទមិនធ្វើអ្វីដោយមិនគាប្បីទៅលើខ្លួនអ្នកនាង ឱ្យមានមន្ទិលទេ ។

ស្រីគិតថា វាមិនគួរឱ្យទុកចិត្តចំពោះការធ្វើដំណើរតែពីរនាក់ ជាមួយមនុស្សប្រុស នាពេលយប់អាធ្រាត្រ ។ ពិសិដ្ឋយល់ច្បាស់ពីការគិតរបស់នាង គេដកកាំភ្លើងខ្លីមួយដើម ហុចមកធីតា ទាំងវាចា:

-នេះជាកាំភ្លើងដែលតាចាន់ឱ្យខ្ញុំបាទទុកការពារផ្ទះ ។ ខ្ញុំបាទជូនអ្នកនាងដើម្បីការពារខ្លួន ។

និយាយចប់ នរៈបោះជំហានយ៉ាងលឿន ដើម្បីទៅរករថយន្ត ។ ចៅស្រីសំណព្វរបស់សពលោកឧកញ៉ា មានការចម្លែកក្នុងចិត្តចំពោះភាពផ្លាស់ប្តូរឫកពារបស់អ្នកបើកបររថយន្ត តែមទិមលព្យាយាមដើរតាមក្លាម ទាំងអារម្មណ៍រិះគិត ។

យប់នេះ នាយក្លាមបើកឡានក្នុងល្បឿនលឿនជាងធម្មតា ។ នរលក្ខណ៍មិនបានហាមឃាត់ ឬ សួរនាំអ្វីទៅកាន់អ្នកបើកបរទេ នាងគ្រាន់តែចម្លែកក្នុងចិត្តពីទង្វើរបស់ក្លាម ។ រថយន្តបានមកដល់ទីមួយ ភ្នែកពិសិដ្ឋក្រឡេកទៅឃើញ

រថយន្តយីហ៊ុបដែលបុកសរសរដងគោម មាណេពដឹងថា យីហ៊ុបមិនបានមានជីវិតទៀត គេបន្លឺទាំងញាប់ញ័រក្នុងចិត្ត :

-អ្នកនាង! នុ៎ះ ដូចជាឡានអ្នកនាងយីហ៊ុប ។

-ឡានអូនយីហ៊ុបមែន ។ យី! យ៉ាងម៉េចហ្នឹង ? ឈប់សិនក្លាម ។

ក្រោយពីពិសិដ្ឋបានបញ្ឈប់រថយន្ត ទាំងនរលក្ខណ៍និងកំលោះម្នីម្នារត់ទៅរករថយន្តរបស់យីហ៊ុប ។ នរលក្ខណ៍ក្រឡេកឃើញប្អូនស្រីជីដូនមួយបែកក្បាលហូរឈាម ផ្កាប់មុខនឹងចង្កូតរថយន្ត ។ រន្ធត់ចិត្តពន់ប្រមាណ ស្រស់ស្រីស្រែកទាំងស្លុតឱរ៉ា :

-ប្អូនយីហ៊ុប !

ពិសិដ្ឋដឹងឥតច្រឡំ យីហ៊ុបគ្មានជីវិតរស់នៅលើផែនដីនេះតទៅទៀតទេ ។ គេស្រងូតស្រងាត់ក្នុងចិត្ត គេព្រួយបារម្ភពីវាសនាអ្នកដែលមិនទាន់ស្លាប់ តើនឹងជួបគ្រោះអាក្រក់នៅពេលណា ?

# វគ្គ ទី ១២

ដប់ថ្ងៃកន្លងមក ។

រាត្រីនេះ លើមេឃងងឹតសូន្យសុង គ្មានទាំងដួងចន្ទ គ្មានទាំងដួងតារា សូម្បីតែតាមបន្ទប់នានា នៅក្នុងវិមានមាសទាំងមូល ក៏គ្មានពន្លឺអ្វីបន្តិចដែរ...ថ្មើរនេះម៉ោងមួយយប់ទៅហើយ ពិសិដ្ឋឈរក្នុងសួនច្បារមុខវិមានមាសតែម្នាក់ឯង ។ កំលោះងើយមើលមេឃ និយាយតិចៗ :

-លោកយាយមាសចេញមក ចៅមានការចង់និយាយជាមួយលោកយាយ

ក្បែរគុម្ពផ្កាចេកទេសដ៏ស៊ុបទ្រុបមួយ ស្រមោលមនុស្សម្នាក់លិបលេ ពួនលបមើលមកពិសិដ្ឋ ត្រចៀកជននោះផ្ទៀងស្ដាប់នូវពាក្យពេចន៍ដែលពិសិដ្ឋនិយាយតែឯង មានន័យ :

-លោកយាយតូច ចៅមិនសប្បាយចិត្តទេ ដែលលោកយាយសម្លាប់មនុស្សក្នុងវិមានមាសនេះ ជាបន្តបន្ទាប់ អ្នកនាងឃីហ៊ុបក្ដី លោកវេហាក្ដី ពួកគេមិនគួរត្រូវលោកយាយសម្លាប់ទេ ។ ចៅសូមឱ្យលោកយាយឈប់សម្លាប់មនុស្សក្នុងផ្ទះនេះទៀតទៅ ហើយស្អែកនេះ ចៅនឹងប្រកាសដោយចំហ ដើម្បីទាមទារយកវិមានមាស ពីគ្រួសារនេះវិញហើយ ។

និយាយដល់ត្រឹមនេះ ពិសិដ្ឋយកដៃតោងមែកផ្កាឃីតថូ ក្នុងអាកប្បកិរិយាល្ហើយអស់សង្ឃឹម រួចតេនិយាយឮៗជាងមុន :

-ហេតុអីលោកយាយតូចមិនចេញមកជួបចៅ ?

ទោះជាពិសិដ្ឋដង្ហោយស្រែកហៅឱ្យខ្មោចលោកយាយតូចរបស់គេ ឱ្យចេញមកជួបនរៈ តែគ្មានស្រមោលបិសាចបង្ហាញកាយនៅពីមុខពិសិដ្ឋទាល់តែសោះ ។ ភាពមនុស្សធម៌កំពុងតែបង្ខំឱ្យពិសិដ្ឋរិះរកវិធីជួយមនុស្សក្នុងគ្រួសារសិទ្ធា ឱ្យផុតពីសេចក្តីស្លាប់ ។ គេសង្ឃឹមថា លោកយាយតូចមកចេញមុខមក ដើម្បីគេអាចជជែកតវ៉ាជាមួយខ្មោច ដើម្បីដោះស្រាយគំនុំនឹងការសងសឹងរបស់ខ្មោចស្រីទៅលើគ្រួសារសិទ្ធា ។ ប៉ុន្តែគ្មានព្រលឹងខ្មោចស្រីចេញមកជួបពិសិដ្ឋទេ ។ អស់សង្ឃឹមពន់ពេក នរៈទម្លាក់បង្គុយចុះនៅគល់ដើមផ្កាយីតថូ ក្បាលរបស់គេឱនមកផ្ទប់លើជង្គង់ ដែលបញ្ឈរទាំងពីរ ជាមួយហត្ថាទាំងទ្វេលើកជ្រោងសក់ទៅក្រោយ ដោយក្តីឈឺចាប់ ។ ស្រមោលជនដែលពួនក្បែរគុម្ពផ្កាចេកទេស យាត្រាសន្សឹមៗមករកពិសិដ្ឋ ឥឡូវយើងបានឃើញមុខជននេះហើយ គាត់គឺជាតាចាន់ ។ ដោយលង់ជាមួយក្តីឈឺចាប់ និងការអស់សង្ឃឹម ពិសិដ្ឋមិនបានដឹងថា តាចាន់កំពុងខិតមកជិតខ្លួនគេទេ។ សំឡេងអ្នកបម្រើចំណាស់បានលាន់មកប៉ះត្រចៀកម្ចាស់ធនាគាររំចង់ :

-ក្មួយ !

ភ្ញាក់ព្រើត ពិសិដ្ឋងាកមកតាចាន់ នាយស្រដី :

-លោកតាតាមដានខ្ញុំអ្ហេះ ?

-ក្មួយ ! ឯងមានការពាក់ព័ន្ធជាមួយលោកជំទាវមាស មែនទេ ?

-បានជាលោកតាដឹងទៅហើយ ខ្ញុំមិនលាក់ទៀតដែរ-ព្រោះយ៉ាងណា ស្អែកនេះ ខ្ញុំនឹងជម្រាបមនុស្សក្នុងផ្ទះនេះ ដោយចំហថា ខ្ញុំមកទាមទារយុត្តិធម៌ជូនលោកយាយតូចរបស់ខ្ញុំ ។

-ឯងមករកយុត្តិធម៌ជូនលោកជំទាវមាស ? ប្រហែលឯងយល់ច្រឡំអីម្យ៉ាង ក្នុងរឿងវិមានសិទ្ធាជាមួយជំទាវមាសទេដឹង ?

-នេះជាវិមានមាសណាំលោកតា មិនមែនវិមានសិទ្ធាទេ ។

-មកតាមតា តានឹងនិយាយអ្វីទាំងអស់ ដែលទាក់ទងនឹងការដូរឈ្មោះផ្ទះនេះ ប្រាប់ដល់ឯង ។

ចប់ប្រយោគ តាចាន់ក៏ដើរតម្រង់ទៅកាន់វិមានសិទ្ធា ទាំងគាត់និយាយបណ្តើរផង :

-កាលពីដំបូងផ្ទះនេះ មានឈ្មោះវិមានសិទ្ធា ក្រោយមកលោកឧកញ៉ាបានប្រកាសប្រគល់វិមានសិទ្ធាដល់លោកជំទាវមាស ជាភរិយាទីបី ដែលលោកម្ចាស់ស្រឡាញ់ជាងគេនិងផ្លាស់ឈ្មោះវិមានសិទ្ធា ទៅជាវិមានមាសវិញ ។

ពិសិដ្ឋដើរតាមតាចាន់ ទាំងគេពោលវាចា :

-គឺដោយសារតែហេតុផលនេះ ដែលផ្ទះនេះត្រូវតែមានឈ្មោះវិមានមាសដូចពេលមុន មិនត្រូវមានឈ្មោះជាវិមានសិទ្ធាទេលោកតា ។

-ក្តាមចាំស្តាប់បន្តសិនចុះ ចៅដឹងទេ បន្ទាប់ពីលោកឧកញ៉ាប្រគល់ផ្ទះនេះដល់លោកជំទាវមាសបានមួយខែ ស្រាប់តែថ្ងៃមួយ ជំទាវមាសបានក្បត់ចិត្តលោកឧកញ៉ា ដោយគាត់ស្រឡាញ់នាយផល ជាអ្នកគ្រប់គ្រងអ្នកបម្រើ ។ ជំទាវមាសនិងនាយផល បានស្រឡាញ់គ្នាដោយលួចលាក់ ហើយរឿងផិតក្បត់ក៏ត្រូវបានលោកឧកញ៉ាចាប់បាន នាពេលអ្នកទាំងពីរកំពុងជួបគ្នា នៅក្នុងបន្ទប់ដំណេករបស់លោកជំទាវមាសតែម្តង ។

តាចាន់អាក់សម្តីបន្តិច គាត់ដកដង្ហើមធំ ហាក់ដូចជាអតីតកាលរបស់ជំទាវមាសបានមកចាក់ដោតចិត្តគាត់ ។ ពិសិដ្ឋមិនបានហើបរាំចាមួយម៉ាត់ គេតាមសម្លឹងតាចាន់ ជាមួយទឹកមុខពិចារណា ។តាចាន់បន្ទរការតានតឹង ទើបគាត់បន្តសម្តី:

-គឺតាំងពីថ្ងៃនោះមក លោកឧកញ៉ាលះលែងជាមួយលោកជំទាវមាស ដោយលោកមិនប្តឹងផ្តល់អ្វីទេ លោកបានឱ្យលោកជំទាវមាសចាកចេញទៅជាមួយនាយផល ដោយមិនបំបាក់បំបែកពួកគាត់ ។ លោកឧកញ៉ាគ្រាន់តែកំដកហូតយកវិមានមាសនិងដូរឈ្មោះផ្ទះនោះ មកជាវិមានសិទ្ធាវិញ តែលោកឧកញ៉ាមិនបានដកយកទ្រព្យមួយចំនួន ដែលជាសម្បត្តិរបស់លោក បានប្រគល់ជូនលោកជំទាវមាសពីពេលមុននោះទេ ។ ការបាត់បង់ភរិយាសំណព្វចិត្ត ដោយជំទាវមាសផិតក្បត់ នាំដល់ការឈឺចាប់ក្នុងទ្រូងលោកជាខ្លាំង ព្រោះថាជំទាវមាសជាភរិយា ដែលលោកឧកញ៉ាស្រឡាញ់ជាងគេ ។ ព្រោះតែការឈឺចាប់និងការអាម៉ាស់ បានបង្ខំឱ្យលោកឧកញ៉ាបានបោះបង់ផ្ទះនេះចោលជាច្រើនឆ្នាំ ដោយលោកនាំលោកជំទាវពីរនាក់ទៀតនិងកូនៗ ទៅរស់នៅតាមខេត្ត លើកលែងតែគ្រួសារលោកជំនោរដែលរស់នៅប្រទេសថៃតាំងតែពីមុននោះម្ល៉េះ ហើយកាលណោះលោកឧកញ៉ាមិនទាន់មានចៅ សូម្បីម្នាក់នៅឡើយទេ ។ លុះដល់ជំនាន់ប៉ុលពត មានតែតាម្នាក់គត់បានទៅរស់ជាមួយគ្រួសារគាត់ ឯអ្នកបម្រើទាំងអស់ក្នុងផ្ទះនេះ ជាអ្នកបម្រើទើបតែមកនៅក្នុងពេលថ្មីៗនេះទេ ។ នៅក្នុងជំនាន់អង្គការខោអាវខ្មៅនោះ ក៏ដូចគ្រួសារខ្មែរទាំងអស់ដែរ គ្រួសារលោកឧកញ៉ា ត្រូវបាត់បង់លោកជំទាវទាំងពីរ និងបងប្រុសបង្កើតរបស់អ្នកនាងទរលក្ខណ៍ ដោយពួកគាត់ទាំងបីនាក់ បានទទួល

មរណភាព ។ ក្រោយពីពេលចេញពីរបបខែរក្រហមអាវខ្មៅ លោកឧកញ៉ាបានទិញវិមានសិទ្ធាពីប្រជាជនជំនាន់១៩៧៩បានរស់ក្នុងវិមាននេះ ដែលគេលក់ផ្ទះនេះយ៉ាងថោកជូនមកគាត់ ។ ទោះជាគាត់ទិញផ្ទះសិទ្ធាមកជាកម្មសិទ្ធិមែន តែគាត់ទិញទុកចោលតែប៉ុណ្ណោះ ។

-ចុះក្រោយមក តើមានរឿងរ៉ាវយ៉ាងម៉េចទៀតលោកតា ?

-លុះក្រោយមក លោកជំទាវមានកូន គឺអ្នកប្រុសវេហានិងអ្នកនាងទារិកា ទើបគ្រួសារលោកជំទាវនាំកូនមករស់ជុំជាមួយលោក ឧកញ៉ា ហើយទើបតែប៉ុន្មានខែនេះទេ ដែលគ្រួសារលោកឧកញ៉ាមករស់ក្នុងវិមាន សិទ្ធានេះវិញ ។

តាចាន់ឈប់និយាយ ងាកមើលមុខពិសិដ្ឋ គាត់ឃើញពិសិដ្ឋមានអាការៈឈឺចាប់ ចំពោះទង្វើមិនគាប្បីរបស់លោកយាយតូច តែគំនិតមួយបានប្រាប់គេថាជួនកាលអាចមិនពិតដូចតាចាន់និយាយក៏មិនដឹង ព្រោះតាចាន់ជាមនុស្សបម្រើជំនិតរបស់លោកឧកញ៉ា ។ ដូចនេះ តាចាន់អាចនឹងនិយាយអ្វី ក្នុងហេតុផលការពារនិងលំអៀងទៅលើលោកឧកញ៉ា ដែលមិនមែនជាកំហុសលោកយាយតូច ។ ប៉ុន្តែពិសិដ្ឋមិនទាន់សន្មតថា តើគួរជឿ ឬ មិនជឿនូវសម្ដីតាចាន់ ទើបបុរសស្រដី :

-បើពិតដូចតានិយាយមែន គឺលោកឧកញ៉ាជាមនុស្សគួរឱ្យគោរពណាស់ ។

-តាមិនបាននិយាយអ្វីដែលមិនពិតទេ ប្រុសចិត្តដូចលោកឧកញ៉ា គួរឱ្យគោរពណាស់ ។ ពេលតានឹកដល់ថ្ងៃដែលតានិងលោកឧកញ៉ាទៅទាន់ហេតុការណ៍នោះ តាស្រៀវសាច់ដោយការបារម្ភជួសលោកជំទាវមាសនិងនាយផលមែនទែន ព្រោះបើប្រុសខ្លះ ដែលទៅឃើញការផិតក្បត់របស់ប្រពន្ធនៅនឹងភ្នែកបែបនេះ

ប្រហែលជាគេមិនទុកជីវិតឱ្យមនុស្សក្បត់ខ្លួនបានរស់ទេ តែលោកឧកញ៉ាមិនដូច្នេះទេ ។

-អ៊ីចឹងខ្ញុំកំពុងច្រឡំធ្ងន់ណាស់ ហើយលោកយាយតូចវិញទេដែលជាអ្នកខុស ឬលោកតាចាន់?

-ក្មួយគិតណា៎ បើលោកឧកញ៉ាជាមនុស្សមិនមានចិត្តល្អ ហេតុអីឯងមកសុំការងារធ្វើ លោកទទួលឯងភ្លាម ។

-មែនហើយ កាលណោះគឺពិតដូចសម្ដីតាមែន។

-ណ្ហើយ យើងទៅដេកវិញ ។

និយាយតែប៉ុណ្ណេះ តាចាន់ក៏ដើរទៅបន្ទប់ដេក ។ ពិសិដ្ឋមិនបានដើរទៅតាមគាត់ គេងើយមុខមើលទៅមេឃដែលងងឹតឈឹង ។ គេនិយាយតែក្នុងចិត្ត :

-តើខ្ញុំគួរជឿតាចាន់ទេហ្ន ?

ពិសិដ្ឋកំពុងរារែកក្នុងការគិត ស្រាប់តែកញ្ចុំស្រទាប់ផ្កាឈូកផុសមកអមដោយទេវតាស្រីផុសមកជាមួយ ។ ពិសិដ្ឋងាកមកសួរទេវតា :

-ព្រះនាងទេវតា តើអ្វីដែលតាចាន់និយាយ ជាការពិតទេ ?

-បើអ្នកចង់ឃើញការពិត អ្នកមកតាមយើងមក ។

ទេវតាយាងនាំមុខពិសិដ្ឋ សំដៅទៅបន្ទប់ដាក់អីវ៉ាន់ចាស់ៗ របស់វិមានមាស។ មកដល់មុខបន្ទប់មួយ ដែលមានសោចាក់ពីក្រៅ ។ ទេវតាបញ្ចេញបារមីធ្វើឱ្យសោបន្ទប់នោះរបើក ដោយទេវតាមានព្រះសុវណ្ណនីយ :

-អ្នកចូលទៅចុះ ។

ដោយជាពេលយប់ ផ្ទៃបន្ទប់ទាំងមូលងងឹតសូន្យសុង។ ព្រះនាងទេវតាលើកព្រះហស្តបញ្ចេញជាពន្លឺភ្លឺចិញ្ចាច ញ៉ាំងឱ្យផ្ទៃបន្ទប់មានភាពភ្លឺដូចពេលថ្ងៃ។ ក្នុងបន្ទប់មានសុទ្ធតែរបស់របរចាស់ៗ ជាគំនរសៀវភៅ ជាឡាំងចាស់ៗ ។ ទទួលបញ្ជាពីទេវតា ពិសិដ្ឋដើរចូលទៅខាងក្នុងបន្ទប់ ។ ទេវតាលើកព្រះហស្តចង្អុលទៅចំសៀវភៅចាស់មួយ ដាក់លើតុកញ្ចាស់ ទាំងមានសុវណ្ណនីយ :

-អ្នកបើកសៀវភៅនោះ ហើយអ្នកអានវាទៅ ។

ចប់ព្រះសុវណ្ណនីយ ទេវតារលាយបាត់ តែពន្លឺនៅមានភាពភ្លឺចែងចាំងពេញផ្ទៃបន្ទប់។ ពិសិដ្ឋបើកសៀវភៅចាស់ គេអានអក្សរដែលមានក្នុងសៀវភៅដែលមានសេចក្តី :

-មាស ! បងស្រឡាញ់អូនជាងភរិយាទាំងពីររបស់បងទៅទៀត ។ ពេញ្ចោះអូន ពេញ្ចោះផ្ទះ គឺបងជាអ្នកដាក់។ បងស្រលាញ់នាង បងតែងគិតជានិច្ច បើយើងមានកូនជាមួយគ្នា កូននោះប្រហែលជាស្អាតដូចជាអូនមិនខាន ។ ប៉ុន្តែ ... អ្វីៗវាអាចប្រែប្រួលមែន អូនមាសបានក្បត់បង ... បងឈឺចាប់ស្ទើរឆ្កួត ។ ឧកញ៉ាដូចបង បែរជាមានប្រពន្ធក្បត់ទៅស្រឡាញ់អ្នកកាន់បញ្ជីក្នុងគ្រួសារបង តែបងមិនខឹងអូនទេ បងគិតថា ប្រហែលជាមកពីបងមានកំហុសដែរ គឺបងជាប្រុសមានភរិយាដល់ទៅបីនាក់ បងក៏មិនមែនជាប្តីល្អណាស់ណាទេ មែនទេ? ដូច្នេះបងមិនគួរយកទោសអូនធ្ងន់ធ្ងរពេកដែរ។ តែយ៉ាងណាទង្វើអូនក្បត់បង គឺអូនខុសមែន ... អូនធ្វើឱ្យបងចុកចាប់ ... បងអាម៉ាស់ ... បងមិនអាចមិនផ្តន្ទាទោសអូនបានឡើយ ។ អំពើខុសរបស់អូន វាសមតែមានការទទួលទោសអ្វីម្យ៉ាង ។ បងត្រូវតែ

ដាក់ទណ្ឌកម្មដល់មនុស្សខុស គឺបងដកហូតវិមានមាសនិងដូរឈ្មោះផ្ទះនេះ មកជាវិមានសិទ្ធា ។ បងធ្វើបែបនេះ គឺវាសមរម្យហើយណាំអូនមាស ។

ពិសិដ្ឋអានចប់ មុខគេស្រងូតស្រងាត់ គេជឿលើកំណត់ហេតុរបស់លោកឧកញ៉ា ព្រោះអាថ៌កំបាំងនេះ ត្រូវបើកកាយដោយទេវតាជាជំនួយដល់រូបគេ។ ពេលមុននេះ តាចាន់បាននិយាយប្រាប់គេនូវរឿងរ៉ាវលោកយាយតូច ដែលធ្វើមិនល្អទៅលើលោកឧកញ៉ា ទើបមានការប្រែប្រួលឈ្មោះវិមានមាស ទៅវិមានសិទ្ធា កាលណោះគេមិនទាន់ជឿមួយរយភាគរយនូវសម្ដីតាចាន់។ ឥឡូវគេមិនអាចមិនជឿបានទេ ។ ពិសិដ្ឋដាក់សៀវភៅចុះ រួចដើរចេញពីបន្ទប់ទាំងល្ងឹងល្ងើយក្នុងចិត្តតេហេងហាង គេលែងចង់ពិចារណាពីអ្វីទៀតហើយ ។

# វគ្គ ទី ១៣

ការដឹងនូវរឿងរ៉ាវពិត ពីកំហុសលោកយាយតូចមាស ដែលបានប្រព្រឹត្ត អំពើក្បត់ចិត្តលោកឧកញ៉ា បង្ហាញនូវការរិះគិតជាថ្មីមកប៉ះពាល់ដល់អារម្មណ៍ពិសិដ្ឋ ជាពិសេសមរណភាពជាបន្តបន្ទាប់របស់មនុស្សជាសាច់ឈាមគ្រួសារសិទ្ធា ដោយសារខ្មោចលោកយាយតូចមាស បានកំពុងដុតរោលដួងចិត្តគេ ឱ្យមានការវេទនា អាណិតអាសូរនិងជាប្រការមិនយុត្តិធម៌ សម្រាប់អ្នកស្លាប់ទាំងប៉ុន្មាននាក់នេះ ។ នរៈគិតទៀតថា ខ្មោចលោកយាយតូចបានធ្វើនូវអ្វីមិនគាប្បី ព្រោះអ្នកមានកំហុសជាលោកយាយតូចយ៉ាងពិត ។មាណពមិនអាចគាំទ្រនូវទង្វើរបស់ព្រលឹងខ្មោចលោកយាយតូច ដែលយកគំនុំមកធ្វើជាការសងសឹកយ៉ាងកំណាចសាហាវ ។ គេត្រូវតែត្រឡប់ទៅពិភាក្សាជាមួយលោកជំទាវវ៉ដួលនិងអ្នកម្តាយរបស់គេ ដើម្បីស្វែងរកវិធីទប់ស្កាត់ដល់ព្រលឹងលោកយាយមាស ក្នុងការរាំងមិនឱ្យខ្មោចលោកយាយតូចបន្តសម្លាប់មនុស្ស ដែលជាបាបកម្មដល់ខ្មោចលោកយាយមាសផង ។ គេគិតឃើញថា វាជាការចំបាច់ត្រូវតែវិលទៅផ្ទះមួយខណៈ ឬ គេអាចទៅផ្ទះរបស់គេ ជារៀងរហូតក៏មិនដឹង ។ យ៉ាងនេះហើយ ទើបវេលានេះ ពិសិដ្ឋ ឬ នាយក្លាមក៏ចូលមកសុំការអនុញ្ញាតពីលោកកិត្យានិងលោកស្រីមាលាវី ដើម្បីវិលទៅផ្ទះ ។ នរៈផ្គុំម្រាមដៃសំពះ ទាំងស្រងឺទៅកាន់លោក កិត្យានិងលោកស្រីមាលាវីជាមាតាបិតារបស់ស្រីនវលក្ខណ៍ :

-លោកប្រុស លោកស្រី ខ្ញុំបាទទទួលដំណឹងថា ម្តាយខ្ញុំបាទឈឺ ទើបខ្ញុំបាទមកសុំច្បាប់ពីលោកទាំងពីរ ដើម្បីទៅស្រុក មើលម្តាយ ។

ឯក្បែរទ្វារបន្ទប់ទទួលភ្ញៀវ នរលក្ខណ៍ដើរមកដល់ល្មម ស្រីស្ដាប់ឮនូវប្រយោគខាងលើរបស់ពិសិដ្ឋ ដែលទើបតែនិយាយក្នុងន័យសុំច្បាប់ ពីលោកឪពុកនិងអ្នកម្ដាយរបស់ធីតា ដើម្បីគេវិលទៅផ្ទះ ។ បេះដូងស្រីស្រាប់តែដូចជាប្រហោងធ្លុង នាងមានអារម្មណ៍ហេងហាង មិនចង់ឱ្យគេទៅណា ឆ្ងាយពីក្រសែភ្នែកនិមល ។ ស្រីល្អនៅឈរលបស្ដាប់នូវការសន្ទនារវាងនាយ ក្ដាមនិងម្ដាយឪពុករបស់នាង ដើម្បីបានដឹងនូវលទ្ធផលនៃការសម្រេចចិត្ត របស់អ្នកបើកបររថយន្ត ។ នាងឮបិតាសួរនាយក្ដាម :

-តើឯងទៅស្រុកប៉ុន្មានថ្ងៃដែរ ?

-បាទ បើម្ដាយខ្ញុំបាទមិនធ្ងន់ធ្ងរ ខ្ញុំបាទនឹងវិលមកវិញនៅពេលឆាប់ តែបើគាត់មិនស្រួលខ្លាំង ខ្ញុំបាទសុំច្បាប់មិនកំណត់ទេ។ លោកអាចកាត់ប្រាក់ខែខ្ញុំបាទតាមនោះចុះទាន ។

-ខ្ញុំមិនមែនសួរឯង ដើម្បីសំដៅចង់កាត់ប្រាក់ខែឯងទេ ខ្ញុំសួរនេះ គឺដើម្បីរកមនុស្សមកជំនួសឯង ក្នុងការជូនកូនលក្ខណ៍ទៅលោមកណោតើ ។

អ្នកស្រីមាណវីដកលុយហុចឱ្យពិសិដ្ឋ ទាំងគាត់និយាយ :

-នេះជាប្រាក់ខែឯងនិងលុយមួយចំនួនដែលខ្ញុំជួយដល់ឯង ដើម្បីយកទៅមើលជំងឺម្ដាយឯងណា៎។

ពិសិដ្ឋទទួលលុយ គេសំពះអ្នកស្រីមាណវីនិងលោកកិត្យា :

-លោកទាំងពីរមានសន្ដានចិត្តល្អណាស់ នេះខ្ញុំបាទមិនទាន់ដល់ពេល ត្រូវបើកលុយផង ។ ខ្ញុំបាទសុំអរគុណហើយទាន ។

-អើ !ឯងប្រញាប់ទៅចុះ ។ " កិត្យា"

-កាលណាម្ដាយឯងបានជា ឯងក៏មកកាលនោះចុះណា៎។ "មាណវី"

-បាទ អរគុណលោកប្រុស លោកស្រី ។

ឯក្រៅបន្ទប់ មុខនរលក្ខណ៍ស្ងួតចែស នាងបារម្ភខ្លាចនាយក្ដាម លែងវិលមកវិញ បើសម្ដីគេពោលទៅកាន់ម្ដាយឪពុកស្រី មិនអាចកំណត់ថា តើមាណពអាចមកវិញ ឬ មិនមកនោះទេ ? វាស្ថិតនៅលើស្ថានភាពជំងឺម្ដាយរបស់បុរស ។ នរលក្ខណ៍មិនអាចដឹងពីលទ្ធផលចុងក្រោយទេ តែការដែលអវត្តមានរូបនាយក្ដាមពីទីផ្ទះរបស់ស្រី នរលក្ខណ៍ទទួលភាពស្រងូតស្រងាត់ សោកស្ដាយយ៉ាងម៉េចមិនដឹង នាងប្រហែលជាមានចិត្តលបលួចប្រតិព័ទ្ធគេទេដឹង ? នាងមិនអាចមានចម្លើយពីសំណួរនេះឡើយ ។ កំពុងតែឈរភាំង ពិសិដ្ឋដើរចេញពីក្នុងបន្ទប់មក គេឃើញនរលក្ខណ៍មានទឹកមុខចង់យំ ជាមុខពោរពេញដោយការឈឺចាប់អស់សង្ឃឹម គេហាក់កាត់យល់ពីអារម្មណ៍ស្រី ព្រោះនាងឈរនៅជិតមាត់ទ្វារបន្ទប់នេះ នាងប្រាកដជាបានស្ដាប់ឮនូវការនិយាយគ្នា រវាងនាយនិងមាតបិតានាងជាមិនខាន ។ បេះដូងពិសិដ្ឋដូចជាជ្រុះបាត់របស់ពិសេសក្នុងជីវិត គេល្ហល្ហេវក្នុងចិត្តហើយប្រហែលជាចិត្តស្រីថ្លៃ ដូចចិត្តគេដែរទេដឹង ? ទើបនាងឈរភាំងភ្លេចខ្លួនយ៉ាងនេះ ។ អ្នកប្រុសសម្លឹងនិមល ជាមួយមុខញញឹមស្ងួត រួចគេលើកដៃសំពះនាងក្នុងនាទីគេជាអ្នកបើកបររថយន្ត :

-អ្នកនាងនរលក្ខណ៍ ខ្ញុំបាទជម្រាបលា ។

ប្រយោគលារបស់បុរស បណ្ដាលឱ្យទឹកភ្នែកស្រីល្អរកកលហូរចុះ មកនាងព្យាយាមទប់ទឹកនេត្រាមិនឱ្យស្រក់ នាងងាកមុខទៅម្ខាង ដើម្បីគេចពីក្រសែភ្នែកដ៏មុតរបស់កំលោះ ។ ស្រីហុចលុយឱ្យពិសិដ្ឋ នូននាងស្រដី :

-អ្នកយកលុយទៅប្រើការចុះ ។

នេត្រាពិសិដ្ឋវាវរកចម្លើយពីនេត្រាស្រី គេចង់គយគន់ភក្ត្រនារីជាទីស្រឡាញ់ ដើម្បីស្រូបយកមកទុកក្នុងបេះដូង គេមិនចង់ឃ្លាតពីស្រី គេរន្ធត់ចំពោះទឹកចិត្តនាង ដែលគេដឹងថា នាងកំពុងតតាំងជាមួយការរកកលហូរទឹកភ្នែកដោយក្តីអាល័យគេ ជាមួយចិត្តអៀនខ្មាស ដែលនាងមិនគួរនឹងបង្ហាញទូវបំណងរបស់បេះដូងនាង ចំពោះរូបគេ ។ ចិត្តអាណិត ចិត្តស្នេហ៍ ជម្រុញឱ្យពិសិដ្ឋលូកដៃទៅចាប់ដៃនាងដែលកាន់លុយហុចមករកគេ ។ស្រីមិនបានដកហត្ថាពីដៃគេទេ តែនរៈដឹងថា ដៃនាងញ័រនៅក្នុងដៃគេ ... ពិសិដ្ឋរំភើប គេសឹងតែសារភាពការពិតប្រាប់នាងថា គេជានរណា គេស្រឡាញ់នាងកម្រិតណា គឺមានតែនាងម្នាក់ជាម្ចាស់គ្រងបេះដូងគេ... តែមិនអាចទេ កាលបើគេកំពុងនៅក្នុងសភាពជានាយក្លាមនាកាលៈទេសៈដែលលោកយាយតូចរបស់គេកំពុងតែព្យាបាទគ្រួសារនេះ ... ស្នេហាពិតត្រូវចេះទប់ចិត្ត ត្រូវរង់ចាំកាលៈទេសៈមកដល់ នោះគេប្រាកដជាបើកកកាយដួងចិត្ត ... ពិសិដ្ឋយល់ចិត្តស្រី គេក្លង់នេត្រាចំភក្ត្រានាង ជាមួយស្នាមញញឹមស្ងួតជិតលើបបូរមាត់គេ ជាមួយវាចា :

-អ្នកនាងនរលក្ខណ៍ ខ្ញុំបាទនឹងមកវិញទេ ។

នេះជាភាសាស្នេហ៍លាក់មុខ តែជាប្រយោគមានន័យផ្តល់ការលើកទឹកចិត្តដល់ស្រី ដើម្បីមិនឱ្យនាងអស់សង្ឃឹមពេក ។ បានឮសម្តីបុរស នរលក្ខណ៍ធូរស្រាលក្នុងអារម្មណ៍ តែភាពជាស្រីក្រមុំក្នុងត្រកូលថ្លៃថ្នូរ នាងមិនអាចបង្ហាញបេះដូងចំពោះកំលោះឡើយ ។ ដើម្បីជាការលាក់លៀមទូវក្តីស្នេហ៍សម្ងាត់ ស្រី

សម្រួលទឹកមុខ មកកាន់សភាពធម្មតា រួចនាងបែរមកមើលមុខគេ ស្រដីក្នុងន័យបញ្ចៀសបញ្ហា ៖

-អ្នកណាសួរអ្នក ខ្ញុំបារម្ភពីជំងឺម្ដាយអ្នកតើ ។

ពិសិដ្ឋយល់ឥតច្រំឡំ ពីអាការៈអៀនអន់របស់ធីតា គេធ្វើជាមិនយល់ទាំងស្រុង តែគេឡើតញញឹមស្រស់ ជាការលលេងផង ជាការប្រាប់ដល់នាងផងថា គេស្មានចិត្តនាងមិនខុសទេ នាងក៏ដូចគេ គឺមានបេះដូងអប់ដោយក្ដីស្នេហ៍លើបល ទើបគេនិយាយ ៖

-បាទ ខ្ញុំបាទដឹងតើ អ្នកនាងបារម្ភពីជំងឺម្ដាយខ្ញុំបាទ ខ្ញុំបាទអរគុណ ។

មិនមែនស្រីមិនដឹងថា ក្លាមមិនដឹងចិត្តនាងទេ តែភាពជាស្រីក្រមុំក្នុងផ្ទត់ប្រពៃណី ចាំបាច់ឱ្យនាងបែរមុខចេញពីមើលមុខគេ ហើយវាចា ៖

-អ្នកទៅចុះ ។

-ខ្ញុំបាទជម្រាបលា ហើយខ្ញុំបាទនឹងវិលវិញណាំអ្នកនាង ។

ពិសិដ្ឋឡើតបញ្ជាក់ពីការដែលគេត្រូវវិលមកកាន់ទីនេះជាថ្មី ដល់បណ្ដូលចិត្ត ។ កល្យាណទទួលអារម្មណ៍ថា ត្រេកអរ ធូរស្រាលក្នុងចិត្ត តែភាពជាស្រីក្រមុំអមដោយកិត្តិយស នាងចាំបាច់មិនហ៊ានងាកមកមើលមុខបុរស ស្រីនៅតែមើលទៅទិសដែលនាងមើលនាពេលមុន ។ ពិសិដ្ឋវិញ កំលោះមើលនាងមួយភ្លែត រួចគេញញឹមយ៉ាងស្រស់ បោះជំហានចាកចេញទៅ ។ ពិសិដ្ឋដើរបានពីរបីជំហាន គេមិនអស់ចិត្ត ក៏ងាកមកមើលនាង ស្របពេលនរលក្ខណ៍ងាកមុខមកមើលខ្នងគេ ។ យល់ថានារីលបមើលគេ បុរសក្បាលខិលក៏ញញឹមស្រស់ដាក់នាង កល្យាណខ្មាសស្ទើរនឹងជ្រែកដី ទៅឱ្យបាត់ពីមុខនរៈ ... នាងខ្មាសដែលលបមើលគេ ហើយត្រូវគេ

ចាប់បាន ។ ស្រីប្រញាប់បែរខ្លួនដើរទៅវិញ ។ ពិសិដ្ឋញញឹមយ៉ាងផ្អែមល្ហែម គេទទួលស្គាល់ថា នរលក្ខណ៍ជានារីមិនប្រកាន់វណ្ណៈ នាងមានបេះដូងអប់ដោយស្នេហ៍បរិសុទ្ធ ។ស្រីម្នាក់នេះមានលំអគ្រប់យ៉ាង ចិត្តល្អ សម្តីរាក់ទាក់មិនច្រឡោះបោះបោក មានមេត្តាធម៌ចំពោះអ្នកក្រោមបង្គាប់ ព្រមដោយរូបសម្បត្តិស្រស់ត្រចះត្រចង់ ។

ពិសិដ្ឋនិងម្តាយមកដល់ផ្ទះលោកយាយវំដួល ដែលនៅក្នុងខេត្តបាត់ដំបង ។ ជាផ្ទះឈើបូរាណ សង់ពីឈើមានតម្លៃ ប្រកបដោយសួនឧទ្យានពោរពេញ ដោយបុប្ផាដេរដាសគ្រប់ពណ៌ចម្រុះក្លិនយ៉ាងប្រណិត ទាក់ចិត្តជិតអារម្មណ៍ ។ នុំះហ្ន៎ ! ពិសិដ្ឋមុខស្លូតអង្គុយបត់ជើង ទាបជើងលោកយាយវំដួល ។ មុខលោកយាយជំទាវមានភាពស្រពាប់ស្រពោនកំពុងបណ្តែតអារម្មណ៍ស្រមៃទៅរកអតីតកាលរបស់លោកយាយមាសជាប្អូនស្រី ។ ព្រោះមុននេះ ពិសិដ្ឋបានរ៉ាយរ៉ាប់នូវអំពើខុសឆ្គងរបស់លោកយាយមាស ជម្រាបជូនគាត់និងម្តាយជាហូរហែ ។ ក្បែរលោកយាយវំដួល គឺលោកស្រីវិចង់ប្រកបដោយរង្វង់ភក្ត្រស្លូតចែស អង្គុយនៅលើកៅអីមួយ ។ ទាំងម្តាយ ទាំងជីដូនរបស់ពិសិដ្ឋ សុទ្ធតែមានការស្មានមិនដល់ថា លោកយាយមាសបានធ្វើនូវរឿងអាក្រក់បែបនេះ ហើយថែមទាំងជាព្រលឹងខ្មោចដ៏សាហាវទៀតផង ។ ជាមួយមុខក្រៀមក្រំ ពិសិដ្ឋស្រដីទៅកាន់ម្តាយនិងលោកយាយ :

-លោកយាយ ! ម៉ាក់ ! រឿងរ៉ាវ គឺបែបនេះទៅវិញទេ ។

-បើបែបនេះ នោះជាទឹកចិត្តប្រពៃរបស់លោកឧត្តញ៉ាចំពោះប្អូនមាសណាស់ ។ កន្លងមក យាយខឹងខុសទៅលើរូបលោកឧកញ៉ាសិទ្ធាហើយ ។

-ម៉ាក់! នរណាខុស នរណាត្រូវ បញ្ហាគួរតែអាចបញ្ចប់ហើយ តែពេលនេះអ្នកមីងមាសមិន ...

ចាប់បាន ។ ស្រីប្រញាប់បែរខ្លួនដើរទៅវិញ ។ ពិសិដ្ឋញញឹមយ៉ាងផ្អែមល្ហែម គេទទួលស្គាល់ថា នរលក្ខណ៍ជានារីមិនប្រកាន់វណ្ណៈ នាងមានបេះដូងអប់ដោយស្នេហ៍បរិសុទ្ធ ។ស្រីម្នាក់នេះមានលំអគ្រប់យ៉ាង ចិត្តល្អ សម្ដីរាក់ទាក់មិនទ្រគោះបោះបោក មានមេត្តាធម៌ចំពោះអ្នកក្រោមបង្គាប់ ព្រមដោយរូបសម្បត្តិស្រស់ត្រចះត្រចង់ ។

ពិសិដ្ឋនិងម្ដាយមកដល់ផ្ទះលោកយាយវង្ហួល ដែលនៅក្នុងខេត្តបាត់ដំបង ។ ជាផ្ទះឈើបុរាណ សង់ពីឈើមានតម្លៃ ប្រកបដោយសួនឧទ្យានពោរពេញ ដោយបុប្ផាដេរដាសគ្រប់ពណ៌ចម្រុះក្លិនយ៉ាងប្រណិត ទាក់ចិត្តជិតអារម្មណ៍ ។ ទុំះហ្នំ ! ពិសិដ្ឋមុខស្លុតអង្គុយបត់ជើង ទាបជើងលោកយាយវង្ហួល ។ មុខលោកយាយជំទាវមានភាពស្រពាប់ស្រពោនកំពុងបណ្ដែតអារម្មណ៍ស្រមៃទៅរកអតីតកាលរបស់លោកយាយមាសជាប្អូនស្រី ។ ព្រោះមុននេះ ពិសិដ្ឋបានរ៉ាយរ៉ាប់នូវអំពើខុសឆ្គងរបស់លោកយាយមាស ជម្រាបជូនគាត់និងម្ដាយជាហូរហែ ។ ក្បែរលោកយាយវង្ហួល គឺលោកស្រីវិចង់ប្រកបដោយរង្វង់ភក្ត្រស្លូតថែស អង្គុយនៅលើកៅអីមួយ ។ ទាំងម្ដាយ ទាំងជីដូនរបស់ពិសិដ្ឋ សុទ្ធតែមានការស្មានមិនដល់ថា លោកយាយមាសបានធ្វើនូវរឿងអាក្រក់បែបនេះ ហើយថែមទាំងជាព្រហើនខ្មោចដ៏សាហាវទៀតផង ។ ជាមួយមុខក្រៀមក្រំ ពិសិដ្ឋស្រដីទៅកាន់ម្ដាយនិងលោកយាយ :

-លោកយាយ ! ម៉ាក់ ! រឿងរ៉ាវ គឺបែបនេះទៅវិញទេ ។

-បើបែបនេះ នោះជាទឹកចិត្តប្រពៃរបស់លោកឧកញ៉ាចំពោះប្អូនមាសណាស់ ។ កន្លងមក យាយខឹងខុសទៅលើរូបលោកឧកញ៉ាសិទ្ធាហើយ ។

-ម៉ាក់! នរណាខុស នរណាត្រូវ បញ្ហាគួរតែអាចបញ្ចប់ហើយ តែពេលនេះ អ្នកមីងមាសមិន ...

លោកតាត្រូវប៉ុលពតបង្ខំឱ្យសឹកមកជាគ្រហស្ថមួយរយៈ ។ ចេញពីរបបប៉ុលពត លោកតាគង់មិនបានបួសវិញទេ លោកធ្វើជាគ្រូទស្សន៍ទាយ គ្រូបង្ក្រាបខ្មោចបិសាច ឬ ដោះអំពើធ្មប់ជាដើម និងផ្សំថ្នាំឱសថបុរាណសម្រាប់ព្យាបាលអ្នកស្រុកអ្នកភូមិ លោកមិនដែលយកតម្លៃព្យាបាល ឬ ទស្សន៍ទាយជាប្រាក់ ពីនរណាម្នាក់ឡើយ។ លោកជួយសង្គ្រោះមនុស្សដោយភាពមេត្តា ហើយអ្នកស្រុកអ្នកភូមិ មានទាំងក្រុមគ្រួសារលោកយាយរំដួល តែងតែធ្វើបាយសម្លមកជូនលោកតាគង់ ព្រោះលោកមិនទទួលប្រាក់។ ប្រសិនជាមិនមាននរណាយកបាយសម្លមកជូន លោកតាក៏បេះផ្លែឈើដើម្បីយកមកបរិភោគ ។

ក្រោយពីសម្រេចចិត្តថា មកសុំជំនួយពីលោកតាគង់នោះ គ្រួសារពិសិដ្ឋដែលមានលោកយាយរំដួល អ្នកស្រីរំចង់និងពិសិដ្ឋបានមកជួបលោកតាគង់ នៅក្នុងព្រៃដែលជាទីកន្លែងសំណាក់ធម៌របស់គាត់ ។ ក្រោយពីបានស្តាប់ការរៀបរាប់នូវរឿងរ៉ាវខ្មោចលោកយាយមាសនិងគ្រួសារសិទ្ធា ចប់សព្វគ្រប់ លោកតាក៏និយាយទៅកាន់អ្នកទាំងបី :

-អ្នកទាំងអស់គ្នាបារម្ភពីអាយុជីវិតរបស់មនុស្សទាំងនោះ ជាការត្រឹមត្រូវហើយ តែអ្នកត្រូវតែដឹងថា ផលកម្មរបស់ម្នាក់ៗ មិនដូចគ្នាទេ ហើយគ្មាននរណាអាចជួយរំដោះកម្មឱ្យនរណាបានទេ អ្នកណាសាងមកយ៉ាងណា នឹងជួបយ៉ាងនោះ។

-តើលោកតាអាចជួយអ្វីដល់ពួកខ្ញុំករុណាបានដែរទេ្ទ ? " រំដួល "

-ដើម្បីចិត្តមេត្តាធម៌របស់ពួកអ្នក ខ្ញុំអាចជួយតាមដែលអាចជួយបាន ។ " និយាយដល់ត្រឹមនេះ លោកតាគង់ងាកមកពិសិដ្ឋ " ... ចៅយកពូថៅនេះទៅវាអាចជួយចៅបាន ក្នុងពេលចាំបាច់ ។

ក្រោយពីទទួលបានពូថៅសិល្បិ៍ពីលោកតាគង់ គ្រួសារពិសិដ្ឋក៏ធ្វើដំណើរមកកាន់ផ្ទះលោកយាយរំដួល ដែលស្ថិតនៅក្នុងក្រុងបាត់ដំបងវិញ ។ ពេលដែលពិសិដ្ឋកំពុងបើកបររថយន្ត គេមានអារម្មណ៍ដឹងថា នាយប់នេះ ខ្មោចលោកយាយមាសនឹងបញ្ចេញសកម្មភាពសម្លាប់មនុស្សនៅក្នុងផ្ទះសិទ្ធាជាមិនខាន ។ ពិសិដ្ឋងាកមកម្ដាយដែលអង្គុយនៅខាងស្ដាំដៃ គេស្រដី :

-លោកយាយ!ម៉ាក់! មិនស្រួលទេ យប់នេះ លោកយាយតូចនឹងសម្លាប់មនុស្សក្នុងវិមានសិទ្ធាទៀតហើយ ។

ពិសិដ្ឋហៅឈ្មោះវិមានសិទ្ធាដោយពេញមាត់ គេលែងត្រូវការទាមទារហៅឈ្មោះផ្ទះរបស់នរលក្ខណ៍ថា វិមានមាស ទៀតហើយ។ បានឮប្រយោគរបស់ចៅប្រុស ក្នុងន័យប្អូនស្រីនឹងបង្កការសម្លាប់មនុស្ស ដែលជាអំពើបាបកម្មលោកជំទាវរំដួលក៏ពោលមកកាន់ចៅទាំងចិត្តអន្ទះអន្ទែងដោយក្ដីបារម្ភ :

-អ៊ីចឹងចៅប្រញាប់បើកឡានទៅវិមានសិទ្ធាវិញទៅចៅសិដ្ឋ យើងមិនបាច់ទៅផ្ទះយើងទេ ព្រោះពេលនេះល្ងាចហើយ ហើយការជួយសង្គ្រោះជីវិតមនុស្ស ជាការសំខាន់ ។

-បត់ឡានទៅភ្នំពេញទៅកូន ក្រែងមិនទាន់ហេតុការណ៍ ។

-បាទ ម៉ាក់ ។

ពិសិដ្ឋបត់ឡានសំដៅទៅរកផ្លូវដែលត្រូវធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញ។ មនុស្សទាំងបីនាក់មានការព្រួយបារម្ភ ខ្លាចក្រែងមិនអាចទៅទាន់ហេតុការណ៍ដែលខ្មោចលោកយាយមាសនឹងបង្កព្យាបាទសម្លាប់មនុស្សនៅផ្ទះសិទ្ធា បើពេលនេះគឺម៉ោងបីរសៀលទៅហើយ ។ ពិសិដ្ឋបញ្ជារថយន្ត ក្នុងល្បឿនកៅសិបគីឡូម៉ែត្រ

ក្នុងមួយម៉ោង ព្រោះពេលនេះរថយន្តរបស់ពួកគេកំពុងស្ថិតនៅក្នុងទឹកដីខេត្តបាត់ដំបង ដែលមានចម្ងាយរាប់រយគីឡូម៉ែត្រពីភ្នំពេញ ។

ពេលយប់មកដល់ អ្នកស្រីសូគិាសម្រាន្តលើពូក រង្វង់ភក្ត្ររបស់គាត់ជោកជាំទៅដោយទឹកនេត្រាហូររហាម ដៃទាំងទ្វេរបស់គាត់អោបរូបថតយីហ៊ុបផ្ទប់នឹងទ្រូង ។ កូនស្រីទោលបណ្តូលចិត្តតែមួយ បានទៅចោលគាត់ហើយ នាងទៅដោយគ្មានពេលវិលវិញ។ អ្នកស្រីកើតទុក្ខរីងរៃ សោកស្តាយបុត្រីសំណព្វចិត្ត ។ កំពុងតែស្លុងក្នុងទម្ងន់ទុក្ខសោករុករានក្នុងដួងចិត្ត សំឡេងយីហ៊ុបលាន់លឺ្វយៗមកប៉ះត្រចៀកអ្នកស្រីសូគិា :

-ម៉ាក់ ! ខ្ញុំមកហើយ ។

សូគិាភ័យស្លោស្លន់ស្លុះងើបពីគ្រែ ទាំងត្រឡើតតើត របូតជ្រុះរូបថតយីហ៊ុប ទៅនឹងឥដ្ឋ បណ្តាលបែកកញ្ចក់ខ្ទាយ ។អ្នកស្រីស្រែកទាំងរន្ធត់ :

-កុំមកលេងម៉ាក់យីហ៊ុប ។ ម៉ាក់ខ្លាចណាស់ ។

ដៃវែងពីរចេញពីរូបថតយីហ៊ុប លូកមករកច្របាច់កសូគិា អ្នកស្រីភ័យណាស់ ស្ទុះរត់ត្របាញ់ជើងទៅរកទ្វារចេញ ។ ខ្មោចយាយមាសផុសភ្លែតនៅពីមុខសូគិា បញ្ចេញសំណើចយ៉ាងគ្រលួច ដូចស្រូបឆក់យកព្រលឹង សូគិាឱ្យរន្ធត់ឥតឧបមា ។ សូគិាភ័យផងខ្លាចផង ស្រែកលាន់សំឡេងជាខ្លាំង :

-នាងជានរណា? ហេតុអីចូលបន្ទប់យើងបាន ?

-កុំយកផ្ទះយើង ហាស់ ហាស់ ។

ដៃទាំងពីររបស់ខ្មោចយាយមាសលូតវែង មកចាប់ច្របាច់កសូគិា ទាំងលើកខ្លួនសូគិា ឱ្យហើបផុតពីឥដ្ឋ ។ សូគិាភ័យផង ខ្លាចផង ប្រឹងរើបម្រះមិនរួចផង គាត់ស្រែកឡុល១ដោយសារបំពង់កត្រូវបិសាចច្របាច់ :

-លែង១ ....អ៊ឹះ ...លែង អួយ ។

ខ្មោចយាយមាសរឹតកសូគិាកាន់តែខ្លាំងឡើង១ ម្ដាយយីហ៊ុបត្រដរខ្យល់បម្រះមិនរួចពីដៃបិសាច អ្នកស្រីបានត្រឹមតែបើកភ្នែកធំ១ ដោយការភ័យខ្លាចសម្លឹងមើលទៅខ្មោចស្រី បម្រះខ្ញើក១ តែមិនរបូតពីដៃបិសាច។ ខ្មោចយាយមាសគំឡើងភ្នែកធំ១សម្លឹងទៅសូគិា រួចដៃបិសាចរឹតបន្តឹងកសូគិា ទាល់តែអ្នកស្រីដាច់ខ្យល់ស្លាប់ ទើបបិសាចគ្រវែងខ្លួនសូគិា បោះចោលទៅលើឥដ្ឋ ។ ខ្មោចយាយមាសសម្លាប់មនុស្សរួចហើយ ក៏ប្រែកាយមកជារូបយាយមាស ដែលមានសភាពដូចជាមនុស្ស ដើរចេញពីបន្ទប់អ្នកស្រីសូគិា សំដៅទៅរកបន្ទប់លោកជំនោរ ។

នៅតាមផ្លូវជាតិលេខប្រាំ ពិសិដ្ឋកំពុងតែបញ្ជាយានមកដល់ទីក្រុងកំពង់ឆ្នាំងហើយ គេមានអារម្មណ៍ដឹងថា លោកយាយមាសបានសម្លាប់លោកស្រីសូគិារួចជាស្រេច ។ ពិសិដ្ឋមានមុខវង្វេង គេងាកមកម្ដាយទិងជីដូន ទាំងគេវាចា :

-លោកយាយតូចសម្លាប់មនុស្សហើយលោកយាយធំ ។

-ពុទ្ធោ! ប្អូនមាស ប្អូនសាងកម្មពៀរទៀតហើយ ។

-ម៉ាក់! លោកយាយធំ! លោកយាយតូចកំពុងរកសម្លាប់មនុស្សទៀតហើយ ។

-បើកឡានឱ្យលឿនទៅកូន ក្រែងយើងអាចជួយអ្វីដល់ពួកគេបាន ។

-បាទ ម៉ាក់ ។

ក្នុងបន្ទប់លោកជំនោរឯវិមានសិទ្ធាវិញ លោកជំនោរកំពុងអង្គុយវាយកំព្យូទ័រតែម្នាក់ឯង ។ខ្មោចយាយមាសដើរមកដល់ពីក្រោយខ្នងលោកជំនោរ បិសាចបញ្ចេញខ្យល់ត្រជាក់បក់បោកទៅលើខ្លួនឪពុកទារិកា ធ្វើឱ្យលោកងាកមករកនាងបិសាច ។ ដោយទទួលធាតុត្រជាក់ចម្លែកខុសពីធម្មតាមកប៉ះខ្នង ស្វាមីអ្នកស្រីតារាក៏ងាកក្រឡេត ហើយគាត់ភ្ញាក់ព្រើត ព្រោះឃើញមនុស្សស្រីម្នាក់ឈរពីក្រោយយ៉ាងកៀកខ្លួន លោកក៏ភ្ញាត់មាត់សួរ :

-នាងជានរណា យើងដូចជាធ្លាប់ស្គាល់នាង នាងមកធ្វើអីក្នុងបន្ទប់យើង ?

-យើងមកយកផ្ទះយើង ។

ឥឡូវនេះ លោកជំនោរចំណាំមុខខ្មោចយាយមាសបានហើយ គាត់ដឹងថាជំទាវមាសបានស្លាប់ជាយូរឆ្នាំមកហើយ បើជំទាវមកពេលនេះ គឺជាព្រលឹងខ្មោច ... ជាមួយខ្មោច តើនរណាមិនខ្លាច ? គាត់ខ្លាចជាខ្លាំង ជើងដៃរបស់គាត់រញ៉េរញ៉ៃធ្មេញក៏រណ្ដំគ្នា គាត់ស្រែកដោយស្រឡាំងកាំង :

-អ្នកមីងមាសតើ តែអ្នកមីងជាខ្មោច ! ខ្មោចលង ជួយខ្ញុំផង ។

ជំនោរស្ទុះងើបពីតុកំព្យូទ័រ ដើម្បីរត់គេចពីការយាយីរបស់បិសាច។ ប៉ុន្តែខ្មោចកំណាចមិនបានទុកឱកាសឱ្យគាត់រត់គេចបានឡើយ បិសាចបានបញ្ចេញសិល្ប៍រុញជើងលោកជំនោរឱ្យទាក់នឹងខ្សែភ្លើង ដែលតចេញពីកំព្យូទ័រដោតនៅជញ្ជាំងបណ្ដាលឱ្យលោកដួលពីលើខ្សែភ្លើង រួចអណ្ដាតភ្លើងក្រហមឆ្អៅចេញពីខ្សែភ្លើង មកដុតរោលលើខ្លួនលោកជំនោរ ធ្វើឱ្យលោកស្រែកយ៉ាងខ្លាំងដោយការក្ដៅរោលរាល :

-អូយ! ក្ដៅណាស់ អូយ! ជួយផង ។

លោកជំនោរប្រកាច់ដោយកំដៅភ្លើងដុត លោកខំប្រឹងងើបពីការជាប់ស្អិតពីលើខ្សែភ្លើង ក្នុងបំណងរត់គេចពីអណ្ដាតភ្លើង។ ប៉ុន្តែខ្លួនរបស់គាត់មិនអាចកម្រើកបានឡើយ ហាក់ដូចជាគេយកដែកគោលមកបោះជាប់នៅមួយកន្លែងជាមួយខ្សែភ្លើងនោះ ។ ភ្លើងត្របាក់ឆេះខ្លួនលោកជំនោរម្ដងបន្តិចៗ មិនខុសអ៊ីពីការដែលគេអាំងគាត់ទាំងរស់ ធ្វើឱ្យគាត់ក្ដៅឈឺផ្សា រលេះរលួយសាច់ ។ ចំណែកខ្មោចកំណាចឈរសើចយ៉ាងគ្រលួច រង្គើផ្ទៃបន្ទប់ទាំងមូល ។ ទីបំផុតឪពុកទារិកាប្រកាច់ស្លាប់យ៉ាងវេទនា ។ ដឹងថា លោកជំនោរស្លាប់ដោយដៃខ្លួនហើយ បិសាចស្រីសើចខ្លាំងៗរំពងផ្ទៃបន្ទប់ :

-ហាស់ ហាស់... ហាស់ ហាស់ ។

អ្នកស្រីតារាកាន់ចានផ្លែឈើ ក្នុងបំណងដើរមករកស្វាមី ក្នុងបន្ទប់ធ្វើការលោកជំនោរ ។ លុះឃើញប្ដីដួលស្លាប់នៅក្បែរតុកំព្យូទ័រ អ្នកស្រីតក់ស្លុតជ្រុះចានផ្លែឈើពីដៃ ស្រែកទាំងរន្ធត់ :

-បងជំនោរយ៉ាងម៉េចហ្នឹង ?

អ្នកស្រីតារាងាកទៅឃើញខ្មោចយាយមាសឈរសើច អង្រួនខ្លួន ញ័រទទ្រើត រញ្ជួយអស់ផ្ទៃបន្ទប់ អ្នកស្រីសួរទាំងងឿងឆ្ងល់និងចម្លែកក្នុងចិត្ត :

-នាងជាអ្នកណា ?

-កុំយកផ្ទះយើង ហាស់ ហាស់ កុំយកផ្ទះយើង ។

ផ្ទៃមុខរបស់ខ្មោចយាយមាសក្លាយទៅជាមុខបិសាច មានភ្នែកលៀនក្រហម អណ្ដាតវែងចេញពីបបូរមាត់ប្រឡាក់ឈាម ធ្លាក់មកដល់ដី សក់រពេរពាយបក់បោកពាសពេញមុខខ្មោច ជាមួយការបំពងសំណើចថ្ងូរថ្ងូរ មិនដាច់សូរ :

-ហាស់ ហាស់ កុំយកផ្ទះយើង ហាស់ហាស់ ។

-ខ្មោច ! ខ្មោចលង !

ជាមួយសម្រែក អ្នកស្រីតារាស្ទុះរត់យ៉ាងលឿនក្នុងបំណងគេចចេញពីខ្មោចស្រី ខ្មោចយាយមាសហោះតាមពីក្រោយអ្នកស្រីបញ្ចេញសំណើចដូចគេថ្ងូរដូចគេទួញសោក ហាក់ដូចជាសង្វើញដេញអ្នកស្រី ឱ្យគាត់រត់កាន់តែលឿនជាងមុន។ មកដល់ជណ្តើរសម្រាប់ចុះទៅជាន់ទីមួយនៃវិមានសិទ្ធា ដៃរបស់បិសាចលូកទៅចាប់ទាញសក់អ្នកស្រីតារាពីក្រោយ មកបួងក្នុងដៃ ។ អ្នកស្រីភ័យខ្លាច តក់ស្លុតស្ទុះយ៉ាងប្រញាប់ដើម្បីរត់ទៅមុខ ឱ្យផុតពីដៃខ្មោច បណ្តាលឱ្យជើងតារាជាន់ខុសកាំជណ្តើរ ហើយខ្លួនគាត់ក៏ដួលរមៀលតាមកាំជណ្តើរទៅផ្នែកខាងក្រោម ។ ខ្មោចយាយមាសឈរសម្លឹងមើលទៅ សភាពអ្នកស្រីតារាកំពុងដួលបោកក្បាលទង្គិចទៅកាំជណ្តើរ ទាំងខ្មោចស្រីបង្អួរសំណើចគួរឱ្យព្រឺក្បាល។ តារាត្រូវបោកក្បាល បែកឈាមរហាម ហើយសន្លប់បាត់មាត់នៅនឹងកាំជណ្តើរ ។ បិសាចស្រីក៏រលាយរូប បាត់ស្ងូន្យឈឹង ។

ឯមុខវិមានសិទ្ធា រថយន្តរបស់ពិសិដ្ឋបត់ក្បាលចូលមកឈប់នៅ ក្បែរមាត់ទ្វារផ្ទះ ។ លោកស្រីរំចង់ លោកយាយរំដួលនិងពិសិដ្ឋរត់ត្របាញ់ជើងទៅក្នុងផ្ទះ ។

ពេលនេះដែរ ក្នុងបន្ទប់នរលក្ខណ៍ ធីតាកំពុងអង្គុយមុខស្ងួត ទឹកដល់ក្តាមសំណព្វចិត្ត នាងមិនយល់សោះ មិនដឹងហេតុអីស្រីទឹកប្រុសម្នាក់នេះយ៉ាងចម្លែកគេជាអ្នកបើកបររថយន្តរបស់នាងទេតើ ។គេមិនមានឋានៈដែលអាចសមរម្យ មកធ្វើជាគូអនាគតរបស់ស្រីទេ ប៉ុន្តែភាពក្លាហាន ទឹកចិត្តប្តូរផ្តាច់ដែលគេបានលះបង់សូម្បីតែជីវិត ដើម្បីជួយសង្គ្រោះនាង វាតែងតែលងជាប់ក្នុងអារម្មណ៍នាង

គ្មានពេលរលុប ... ស្រីដឹងច្បាស់ហើយ នាងពិតជាស្រឡាញ់ក្លាម នាងមិនអាចបដិសេធសេចក្ដីត្រូវការរបស់បេះដូងស្រី ... កំពុងបណ្ដែតអារម្មណ៍ទៅរកម្ចាស់ដួងចិត្ត ស្រាប់តែព្រលឹងខ្មោចយាយមាសហោះចូលខ្លួននរលក្ខណ៍ ។ ឥទ្ធិពលបិសាចបានសណ្ដំចិត្តនាង ឱ្យលុះក្នុងអនុភាពបញ្ជារបស់ខ្មោច។ នរលក្ខណ៍ក្នុងព្រលឹងខ្មោចងើបដើរចេញទៅក្រៅបន្ទប់ ដើរមកមកផ្នែកកណ្ដាលនៃវិមាន ។ នៅទីនេះ មានអ្នកបម្រើស្រីប្រុស មានពូធន តាចាន់ នាងមន នាងភាព លោកកិត្យាឈរជិតលោកស្រីមាណេរី កំពុងចោមរោមមើលទៅទារិកាយំឱបតារា ។ ស្រស់ស្រីយំដង្ហោយហៅមាតា :

-ម៉ាក់អើយ ម៉ាក់កុំកើតអីណា៎ ហ៊ឹក ហ៊ឹក កូនខ្លាចណាស់ម៉ាក់ ហេតុអីម៉ាក់ដួលអីចឹង ?

លោកកិត្យាងាកមកសួរបម្រើទាំងអស់ ដែលឈរជិតគាត់ :

-ហេតុអីប្អូនតារាដួលនៅទីនេះ មានអ្នកណាដឹងទេ ?

មិនទាន់មានអ្នកបម្រើឆ្លើយមកកាន់លោកកិត្យាផង នាងសយរត់មកដល់ នាងនិយាយទាំងមុខភិតភ័យប្រាប់កិត្យា :

-លោកប្រុស ! លោកជំទាវទទួលមរណភាពហើយ ។

-សយថាម៉េច ប្អូនជំទាវស្លាប់ហើយ ។

ទារិកាភ្ញាក់ នាងងាកមកមើលសយ និយាយទាំងទឹកភ្នែករហាម :

-ប៉ាខ្ញុំខូចអ្នកមីងសយ ? ពុទ្ធោ ! ប៉ា ហ៊ឹក ហ៊ឹក ប៉ាអើយកុំទៅណាចោលខ្ញុំ ហ៊ឹក ហ៊ឹក ប៉ាកុំទៅណាចោលខ្ញុំ ហ៊ឹក ហ៊ឹក ។

មិនរង់ចាំចម្លើយពីស្រីបម្រើ ទារិកាស្ទុះរត់ទាំងយំគគ្រូក សំដៅទៅរកបន្ទប់ឪពុក ។ មនុស្សទាំងអស់គ្នាស្រឡាំងកាំងនឹងការស្លាប់ដោយគ្មានហេតុផលរបស់លោកជំនោរ ។ មិនទាន់មាននរណាហើបមាត់និយាយអ្វីផង នាងមឿនជាស្រីបម្រើក៏រត់មកដល់ និយាយទាំងមុខភ័យ :

-លោកស្រីសូត្រាខូចហើយលោកស្រី ។

លោកកិត្យានិងអ្នកស្រីមាលាវីភ្ញាក់ព្រើត គាត់ស្រែកព្រមគ្នា ដោយអាការៈហួសចិត្តនិងតក់ស្លុត :

-សូត្រាខូចហើយ !

ពិសិដ្ឋ រំចង់ យាយរំដួលរត់ចូលមកដល់ ។ នរៈក្រឡេកទៅមើលនាងភាពនិងនាងមន្ទដែលកំពុងលើកតាភាពីទីដួលសន្លប់ ។ ពិសិដ្ឋនិយាយទាំងមុខអស់សង្ឃឹម ដោយមិនចំពោះនរណា :

-ពួកខ្ញុំមកយឺតពេល !

ទារិការត់បកត្រឡប់មករកលោកកិត្យា ទាំងនាងស្រែកយំខ្លាំងៗ :

-ជួយខ្ញុំផង នរលក្ខណ៍ចម្លែកណាស់ មិនដឹងយ៉ាងម៉េចទេ ?

ទាំងអស់គ្នាងាកមើលទៅក្រោយខ្នងទារិកា ពួកគេឃើញនរលក្ខណ៍ដើរមក ក្នុងសភាពនាងបើកភ្នែកធំៗ និយាយចេញជាសំឡេងខ្មោច :

-កុំយកផ្ទះយើង យើងមិនឱ្យផ្ទះយើងទៅពួកឯងទេ ។

ពិសិដ្ឋដឹងភ្លាមថា យាយមាសកំពុងស្ថិតនៅក្នុងខ្លួននរលក្ខណ៍ គេស្រែកទៅកាន់នាង :

-លោកយាយតូច! កុំធ្វើបាបអ្នកនាងលក្ខណ៍ ។

យាយរំដួលស្រែកទៅកាន់នរលក្ខណ៍ :

-ប្អូនមាស! កុំធ្វើបាបពួកគេ ។

ព្រលឹងយាយមាសបញ្ជាជើងនរលក្ខណ៍ឱ្យស្ទុះទៅរកទារិកា ជាមួយដៃទាំងពីរលូកមករកច្បាមកទារិកា ដោយភ្នែកនរលក្ខណ៍បើកធំៗ មាត់នាងសើចមិនឈប់ ជាសំណើចស្អប់ទៅ អ្នកដែលបានឮត្រូវព្រឺក្បាលសំពោង ។ ទារិកាភ័យជាខ្លាំង ព្រោះដៃនរលក្ខណ៍ចាប់កនាងជាប់ហើយ នាងស្រែកភ្លាត់សំឡេង :

-ជួយខ្ញុំផង! ជួយខ្ញុំផង !

ដៃនរលក្ខណ៍រឹតច្របាច់កទារិកា ស្រីរងគ្រោះបម្រះផងស្រែកផង :

- លែងខ្ញុំទៅលក្ខណ៍ ។

-លោកយាយតូច! កុំធ្វើបាបអ្នកនាងទារិកា ។ "ពិសិដ្ឋ"

-កូនលក្ខណ៍កុំធ្វើបែបនេះ លែងទារិកាមកកូន ។ "លោកកិត្យា"

ពិសិដ្ឋងាកមកលោកកិត្យា និយាយប្រាប់លោក :

-លោកប្រុស!មានព្រលឹងលោកយាយតូចសណ្ឋិតក្នុងរូបអ្នកនាងនរលក្ខណ៍

-ក្ដាម! ព្រលឹងស្អី ? យើងស្ដាប់ឯងមិនយល់ទេ ។ កិត្យា

-គឺជាព្រលឹងខ្មោចអ្នកមឹងមាសដែលកំពុងនៅក្នុងរូបនាង ។ វិចង់

-ព្រលឹងអ្នកមឹងមាសនៅក្នុងខ្លួនកូនស្រីខ្ញុំ ។ កិត្យា

នរលក្ខណ៍អូសទារិកាគេចចេញពីហ្វូងមនុស្សទាំងអស់ ទាំងដៃនៅតែច្បាមករបស់ទារិកាមិនលែង ជាមួយសំណើចលាន់ក្រលូចស្ទើរបែកក្រដាសត្រចៀកមនុស្សក្នុងផ្ទះ ។ ទារិកាភ័យណាស់ នាងប្រឹងរើបម្រះផង ក្រាញ់ននៀលមិនទៅតាមការអូសទាញរបស់ខ្មោចយាយមាសផង ។ មនុស្សជាអ្នកបម្រើហាក់ដូចជាស្រឡាំងកាំង ដោយម្នាក់ៗមិនដឹងត្រូវធ្វើអ្វី បើពួកគេគិតថា ប្រហែលជានរលក្ខណ៍និងទារិកាកំពុងឈ្លោះគ្នា ។ មានតែពិសិដ្ឋដែលស្ទុះរត់ទៅរកនារីទាំងពីរ ។ ទារិកាត្រូវនរលក្ខណ៍អូសទីណាត់ទីណែង ទាំងកម្រោល នាំយកទៅមុខ ។ ទារិកាស្រែកទាំងរន្ធត់ :

-ជួយខ្ញុំផង! ជួយខ្ញុំផង! ខ្ញុំខ្លាចណាស់! លក្ខណ៍អើយលែងខ្ញុំទៅ ។

អ្នកស្រីមាណវីដែលបានដឹងពីពិសិដ្ឋថា ព្រលឹងយាយមាសកំពុងតែស្ថិតនៅក្នុងរូបកូនស្រី គាត់បារម្ភដល់សុវត្ថិភាពរបស់ទារិកាផង ភ័យពីកូនស្រីផង គាត់ស្រែក :

-ក្ដាម!ជួយកូនលក្ខណ៍និងក្មួយទារិកាផង ។ប៉ាវ៉ាទៅជួយក្ដាមផង ។

ពិសិដ្ឋស្ទុះទៅចាប់ទាញដៃនរលក្ខណ៍ប្រឡេះចេញពីកទារិកា ប៉ុន្តែកម្លាំងមនុស្សធ្វើម្ដេចអាចឈ្នះកម្លាំងបិសាច ពិសិដ្ឋមិនអាចបេះដៃរបស់នរលក្ខណ៍ ឱ្យ

ចេញពីករបស់ទារិកាបានទាល់តែសោះ លោកកិត្យាក៏ស្ទុះមកជួយទាញដៃនរលក្ខណ៍ចេញពីកទារិកាដែរ ។ ប៉ុន្តែមិនអាចសមដូចបំណងរបស់លោកឡើយ ។ យាយរំដួលភ័យណាស់ គាត់ស្រែកទៅកាន់ខ្មោចប្អូនស្រី :

-លែងនាងទៅប្អូនមាស ។ កុំធ្វើបាបគេ ។

សម្រែកយាយរំដួលគ្មានអនុភាពបង្អាក់ ទង្វើសាហាវរបស់បិសាចកំណាចបានទេ។ មើលចុះ ! អំណាចសិល្បរបស់ខ្មោចយាយមាស រុញលោកកិត្យានិងពិសិដ្ឋឱ្យខ្ទាតត្រឡប់មកក្រោយ ។ បិសាចក្នុងរូបកាយនរលក្ខណ៍ក៏បន្តលើកត្រវែងទារិកា បោកផ្ទប់ទៅជញ្ជាំង ។ ទារិកាសន្លប់បាត់មាត់ឈឹង ។ មនុស្សទាំងអស់នៅក្នុងផ្ទះភ័យស្លោស្លន់ ព្រោះមិនដឹងបង្ក្រាបបិសាចដោយវិធីណា ។ ពិសិដ្ឋឈរឡេឡាគិតមិនលេច ក្នុងការជួយរំដោះនរលក្ខណ៍ឱ្យផុតពីព្រលឹងខ្មោច ស្រាប់តែសំឡេងអ្នកស្រីមាណវីស្រែកៈ

-ជួយផង! ជួយផង! នរលក្ខណ៍លែងម៉ាក់ ។

-ហាស់ហាស់ យើងសម្លាប់ទាំងអស់គ្នា ហាស់ហាស់ ។

ពិសិដ្ឋកាន់តែភិតភ័យ គេបារម្ភដល់សុវត្ថិភាពអ្នកស្រីមាណវី ដែលកំពុងត្រូវបិសាចច្បាមកម្តង។ គេគិតថា មានតែកូនពូថៅសិល្បរបស់លោកតាគង់ទេដឹងដែលអាចបង្ក្រាបខ្មោចយាយមាសបាន ប៉ុន្តែបើគេយកពូថៅសិល្បទៅកាប់ព្រលឹងខ្មោចយាយមាស គឺដូចជាគេកាប់ទៅលើរូបកាយនរលក្ខណ៍។ គេពិតជារាវែក មិនដឹងធ្វើយ៉ាងណា ព្រោះបើគេកាប់នរលក្ខណ៍ នាងអាចនឹងត្រូវរបួស ឬ ក៏នាង

ស្លាប់ក៏មិនដឹង។ តែបើមិនកាប់នរលក្ខណ៍ ដើម្បីបង្ក្រាបព្រលឹងបិសាចទេ គឺមិនមានវិធីអាចជួយសង្គ្រោះមនុស្សក្នុងវិមានសិទ្ធាបានដែរ ពិសិដ្ឋកំពុងតែរារែក... ទេវតាស្រីផុសទៅពីមុខពិសិដ្ឋ ។ គ្មាននរណាម្នាក់អាចមើលឃើញទេវតា ក្រៅពីពិសិដ្ឋ ។ ព្រះនាងទេវតាមានព្រះសុរិយ៍ល្អិតយទៅកាន់អ្នកកំលោះ :

-ដល់ពេលអ្នកត្រូវប្រើរបស់ពិសេសហើយ ទើបកម្ចាត់ព្រលឹងដែលពោរពេញដោយគំនុំនេះបាន ។

-បើខ្ញុំប្រើរបស់ពិសេសនោះកម្ចាត់ព្រលឹងលោកយាយតូច នោះអ្នកនាងនរលក្ខណ៍អាចនឹងរបួស ឬ ស្លាប់ ហើយលោកយាយតូចមុខជា ...

-ពេលវេលាមិនអនុញ្ញាតឱ្យអ្នករារែកទេ ប្រញាប់សម្រេចចិត្តទៅ មុនពេលមានមនុស្សស្លាប់ទៀត ។

ចប់ព្រះសុរិយ៍ល្អិតយ ព្រះកាយទេវតាក៏រលាយបាត់សូន្យ ពិសិដ្ឋដែលមិនទាន់សម្រេចចិត្តបាន ក៏ស្រែកទៅកាន់ទេវតា :

-ព្រះនាងទេវតា ខ្ញុំមិនយល់...

-កូនសិដ្ឋ! មកជួយអ្នកស្រីនេះផង ។"វ៉ិចង់"

ម្ដាយពិសិដ្ឋស្រែកយ៉ាងតក់ស្លុត ព្រោះខ្មោចកំពុងតែច្របាច់កអ្នកស្រីមាណវីយ៉ាងខ្លាំង ទាល់តែអ្នកស្រីបើកភ្នែកក្រឡង់ ធ្លាក់អណ្ដាតចេញពីមាត់ ។ ពិសិដ្ឋងាកទៅឃើញសភាពរបស់អ្នកស្រីមាណវី ហើយសភាពលោកកិត្យាកំពុងជួយទាញដៃនរលក្ខណ៍ចេញពីកភរិយា ឯតាចាន់ និងពូឆន ជាអ្នកបម្រើប្រុស

កំពុងជួយប្រឡេះដៃនរលក្ខណ៍ពីកម្តាយនាងដែរ ។ ទោះជាមនុស្សប្រុសដល់ទៅបីនាក់ តែមិនអាចបង្ក្រាបកម្លាំងខ្មោចយាយមាសបាន មុខអ្នកស្រីមាលាវីកាន់តែស្លេកស្លាំង បបូរមាត់គាត់ញ័រទទ្រើត ...

ពិសិដ្ឋរត់រឹងចេញទៅក្រៅផ្ទះ ក្នុងបំណងទៅយកកូនពូថៅសិល្ប៍ពីក្នុងរថយន្ត ។ គ្រាន់តែយកបានកូនពូថៅសិល្ប៍ នរៈក៏រត់បកសំដៅមកក្នុងគេហដ្ឋានវិញ ។ ដៃកាន់ពូថៅសិល្ប៍យ៉ាងជាប់ ភ្នែកពិសិដ្ឋសម្លឹងទៅសកម្មភាពបិសាចកំពុងតែច្របាច់កអ្នកស្រីមាលាវី ជាមួយសភាពប្រទាញប្រទង់ រវាងមនុស្សប្រុសបីនាក់និងខ្មោចស្រី ... ពិសិដ្ឋនៅតែរារែក...គេមិនដាច់ចិត្ត លើកពូថៅសម្លាប់នរលក្ខណ៍ដែលមានព្រលឹងលោកយាយតូចនៅពីក្នុងខ្លួននាងនោះទេ ...ប្រសិនជានាងត្រូវបាត់បង់ជីវិត ដោយសារតែពូថៅនេះ គេនឹងសោកស្តាយស្រីជាទីស្រឡាញ់ គេនឹងឈឺចាប់អស់មួយជីវិត ហើយគេមិនដាច់ចិត្តធ្វើឱ្យព្រលឹងខ្មោចលោកយាយតូចមានការឈឺចាប់ដោយអំណាចពូថៅសិល្ប៍ ... តែគេក៏មិនដាច់ចិត្តឱ្យអ្នកស្រីមាលាវីទទួលមរណភាពដោយសារតែទង្វើរបស់ខ្មោចលោកយាយតូចដែរ ។ សំឡេងទេវតាស្រីលាន់ឡើងក្នុងត្រចៀកពិសិដ្ឋ :

-ប្រញាប់សម្រេចចិត្តទៅ មុនពេលមានមនុស្សស្លាប់ទៀត ។

ព្រះសុវណ្ណនីយរបស់ទេវតាស្រី ជាអំណាចពិសេសផ្តល់កម្លាំងទិព្វ ជម្រុញឱ្យដៃកំលោះលើកពូថៅសិល្ប៍គប់តម្រង់ទៅដៃនរលក្ខណ៍ ដែលកំពុងច្បាមកអ្នកស្រីមាលាវី ។ មុខពូថៅហោះមកប៉ះសាច់នរលក្ខណ៍ បង្កើតចេញជាដុំភ្លើងហោះចេញពីរាងកាយនរលក្ខណ៍ ។ រួចដុំភ្លើងលេចចេញជាស្រមោលយាយមាស ដែលស្រែកថ្ងូរ

ណាន់គ្រលូចដោយការឈឺចាប់ ហើយក៏រលាយបាត់សូន្យសុង ។ ពិសិដ្ឋដឹងថា លោកយាយមាសត្រូវវិនាសព្រលឹង ហើយគឺគេជាអ្នកធ្វើបាបព្រលឹងលោកយាយមាស តែស្រែកទាំងរន្ធត់ :

-លោកយាយតូច ឱ្យចៅសុំទោស ។

សម្រែកនរលក្ខណ៍ឈឺដោយសារមុខពូថៅកាប់ដៃស្រី បានលាន់ :

-អូយ! ឈឺណាស់ ។

ពិសិដ្ឋងាកមកមើលនរលក្ខណ៍ដោយស្វ័យប្រវត្តិ តែឃើញដៃនាងរលាចេញពីកអ្នកស្រីមាណវី ទាំងខ្លួននាងរលំរកកលដួល ។ ពិសិដ្ឋស្ទុះភ្លែតទៅទ្រកាយស្រីមិនឱ្យដួលបោកទៅលើឥដ្ឋ ។ ឯអ្នកស្រីមាណវីដែលទ្រុឌទ្រោមកម្លាំង ដោយការប្រទាញប្រទង់ជាមួយខ្មោចយាយមាសនាពេលមុននេះ លុះពេលរបូតពីការឃឺយាររបស់បិសាច អ្នកស្រីល្ងើយណាស់ គ្មានកម្លាំងកំហែង គាត់ក៏ដួលព្រួស ។ លោកកិត្យាស្ទុះមកជួយទប់រាងកាយភរិយាមិនឱ្យដួលចុះ ។

# វគ្គ ទី ១៤

ទារិកាយំឱបម្ដាយដែលសម្រាន្តស្ដូកស្ដឹងលើគ្រែ ប្រកបដោយកម្រាលសស្អុស ។ អ្នកស្រីតារាបើកភ្នែកភ្លឹះៗមើលទៅលើពិដាន ក្នុងអាការៈដូចជាមិនដឹងមិនឮអ្វីដែលនៅជុំវិញខ្លួនគាត់ ដៃទាំងពីររបស់អ្នកស្រីមានព្យួរសេរ៉ូម ក្បាលអ្នកស្រីរុំដោយបង់ស អ្នកស្រីធ្លាក់ក្នុងអាការៈជាមនុស្សមានសភាពបែបវិកលចរិត ។ ស្រីទារិកាសោកសង្រេងឥតឧបមា បងប្រុសក៏ស្លាប់ បិតាក៏លាចាកលោក មាតាក៏មានសតិមិននឹងនរ ។ កល្យាណយំផង ស្រដីផង ទាំងដៃនៅតែក្រសោបកាយមាតា :

-ម៉ាក់អើយ ហេតុអីម៉ាក់លែងនិយាយអីយ៉ាងនេះ ហ៊ឹក ហ៊ឹក ។

កំលោះសេរីឈរជិតនារីដែលគេលួចប៉ងប្រាថ្នា ភក្ត្រាអ្នកប្រុសស្រពាប់ស្រពោន បន្លឺទៅកាន់នូនល្អង :

-ទារិកាទប់ចិត្តណា៎ មិនយូរទេអ្នកមីងអាចនឹងជាបាន ។

-គ្រាន់តែអាចជាទេ មែនទេសេរី ? តែអ្វីឱ្យប្រាកដ គឺម៉ាក់មិនដឹងជា ឬមិនជាឡើយ ហ៊ឹកហ៊ឹក ។

-ក្មួយស្រី ! មីងសោកស្ដាយ ដោយសារតែព្រលឹងចងគំនុំរបស់អ្នកមីងមាស ទើបធ្វើឱ្យគ្រួសារនាងត្រូវមកជួបហេតុអាក្រក់យ៉ាងនេះ ។" អ្នកស្រីវិចង់"

-ខ្ញុំយល់អ្នកមីង គឺលោកយាយមាសមានគំនុំនិងបានសងសឹកមកលើគ្រួសារខ្ញុំ តែចំណែកលោកពិសិដ្ឋវិញ គាត់បានព្យាយាមជួយពួកយើងជានិច្ច ហ៊ឹកហ៊ឹក តែយ៉ាងណាមនុស្សនិងខ្មោច ធ្វើម៉េចអាចនឹងនិយាយគ្នាបាន ហ៊ឹកហ៊ឹក ។

-យាយស្តាយ ! ស្តាយដែលគ្រួសារខាងយាយទម្រាំរកវិធីមកជួយគ្រួសារចៅបាន ទីបំផុត គ្រួសារចៅបានបាត់បង់មនុស្សជាច្រើនយ៉ាងនេះ ។" លោកយាយរំដួល"

-ប្រហែលជាពួកខ្ញុំមានជំពាក់កម្មអ្វីជាមួយលោកយាយមាសទេដឹង ហ៊ឹក ហ៊ឹក ទើបមានរឿងបែបនេះណ៎ាលោកយាយ ។" ទារិកា"

បើយើងបែរមកមើលបន្ទប់មួយផ្សេង ដែលស្ថិតក្នុងមន្ទីរពេទ្យតែមួយ ដែលអ្នកស្រីតារាកំពុងសម្រាកដើម្បីព្យាបាលជំងឺ គឺក្នុងបន្ទប់មួយនេះ យើងឃើញនរលក្ខណ៍គេងសន្លប់ដោយមានដៃព្យួរសេរ៉ូម នៅលើគ្រែរបស់មន្ទីរពេទ្យ ។ ទាំងពិសិដ្ឋ ទាំងអ្នកស្រីមាណវីនិងលោកកិត្យា ម្នាក់ៗពោរពេញទៅដោយអារម្មណ៍ធ្ងន់ពាប គេព្រួយបារម្ភពីស្ថានភាពរបួសនរលក្ខណ៍ ក៏ដូចជាសុខភាពផ្លូវចិត្តរបស់នាង ។ គ្មាននរណានិយាយរកនរណាទេ ព្រោះម្នាក់ៗសុទ្ធតែខ្វាយខ្វល់ពីសុខភាពស្រស់ស្រី ដូចគ្នា ។ ស្នូរគោះទ្វារបន្ទប់បានលាន់ឮឡើង លោកកិត្យាដែលនៅជិតទ្វារជាងគេ ក៏បានដើរមកបើកទ្វារ ។ លោកយាយរំដួល អ្នកស្រីរំចង់និងសេរីបានប្រាកដកាយនៅចំទ្វារដែលរបើក ។ លោកយាយរំដួលសួរមកកាន់លោកកិត្យាៈ

-ចៅលក្ខណ៍ដឹងខ្លួនឬនៅក្មួយកិត្យា ?

-បាទអ្នកមីង កូនលក្ខណ៍មិនទាន់ដឹងខ្លួនទេ ។

កិត្យាសួរមកកាន់សេរី :

-ប្អូនតារាដឹងស្មារតីហើយមែនទេក្មួយសេរី ?

-បាទ អ្នកមីងតារាដឹងស្មារតីមុននេះបន្តិចលោកពូ តែគាត់ហាក់ដូចជាគ្មានវិញ្ញាណអ្វីទេ ។

លោកកិត្យាងាកមកមើលមាណវី លោកនិយាយ :

-ម៉ាក់វា អូននៅមើលកូនលក្ខណ៍ណ៎ា បងទៅមើលប្អូនតារាសិន ហើយបើកូនលក្ខណ៍ដឹងខ្លួនពេលណា អូនទៅតាមបងភ្លាម ។

-ចាសបង ហើយបងឆាប់មកវិញ។ ខ្ញុំនឹងទៅមើលប្អូនតារាម្តង ។

លោកកិត្យាងក់ក្បាលទទួលពាក្យភរិយា រួចលោកបោះជំហានចាកចេញទៅកាន់បន្ទប់អ្នកស្រីតារា ជាមួយកំលោះសេរី ។ លោកយាយរំដួលនិងអ្នកស្រីរំចង់ដើរចូលមករកមាណវី ទាំងយាយរំដួលបន្លឺ :

-ចៅស្រីមិនទាន់ដឹងខ្លួនទៀតហ្ន៎ ។

-ចាសអ្នកមីង គេមិនទាន់ដឹងខ្លួនទេ ។ អ្នកមីង ! លោកស្រី ! សូមអញ្ជើញអង្គុយ ។

អ្នកស្រីរំចង់និងម្តាយរបស់អ្នកស្រីអង្គុយចុះលើកៅអីមួយម្នាក់ ក្បែរអ្នកស្រីមាណវី ។ ម្តាយពិសិដ្ឋងាកមកមើលកូនប្រុស គាត់យល់អាការៈកំលោះកំពុងលង់ក្នុងអន្លង់ជ្រៅនៃទុក្ខសោក ភ្នែកពិសិដ្ឋផ្តោតជាប់ទៅលើមុខរបស់នរលក្ខណ៍ដែលនាងបិទភ្នែកគេងស្ពូកស្ពឹង ។ សម្រាប់ពិសិដ្ឋ ក្នុងបន្ទប់ទាំងមូលហាក់បីដូចជាគ្មានមនុស្សម្នាក់ នៅទីនេះគឺមានតែនរលក្ខណ៍បណ្តូលចិត្តរបស់គេតែម្នាក់គត់ មុខកំលោះជូរចត់ គេឈឺចាប់ដែលខ្លួនគេជាមូលហេតុបង្ករបួសដល់និមល រហូតធ្វើឱ្យនាងត្រូវដេកសន្លប់មិនដឹងខ្លួនយ៉ាងនេះ ... បើសិនជាអាច គេនឹងឈឺជំនួសស្រីពិសិដ្ឋនឹងព្រមភ្លាម .. តែមិនអាចទេ គឺនាងដែលកំពុងដេកសន្លប់នៅចំពោះមុខគេ។ យល់អាការៈសោកសៅរបស់បុត្រ អ្នកម្តាយរបស់នរៈបន្លឺតិចៗមកកាន់កូនប្រុស :

-កូនសិដ្ឋទៅញ៉ាំបាយសិនណ៎ាកូន ។

នេត្រាពិសិដ្ឋផ្តោតឥតព្រេចលើទម្រង់ភក្ត្រាស្រស់ស្រី បបូរមាត់គេកម្រើក ស្ទើរមិនឮសម្លេង :

-ខ្ញុំមិនឃ្លានទេម៉ាក់ ខ្ញុំចង់នៅមើលនាង ដើម្បីពេលនាងដឹងខ្លួនមក ខ្ញុំនឹងបាននិយាយសុំទោសនាង ដែលខ្ញុំធ្វើឱ្យនាងមានរបួសនាំឱ្យហូរឈាមច្រើនយ៉ាងនេះ ទើបនាងសន្លប់ឃ្លីរអ៊ីចឹង ។

-ក្មួយពិសិដ្ឋមិនគួរធ្វើបាបខ្លួនទេ ហើយក្មួយកុំគិតបែបនេះអី អ្វីដែលវាកើតលើរូបកូនលក្ខណ៍ នោះមិនមែនជាកំហុសរបស់ក្មួយទេ វាជាការជួយរបស់ក្មួយចំពោះគ្រួសារមីងវិញតើ ។

-តែយ៉ាងណា អ្នកនាងនរលក្ខណ៍ឈឺខ្លួនដោយសារខ្ញុំដែរអ្នកមីង ។

ស្រដីចប់ ពិសិដ្ឋអង្គុយធ្មឹង ប្រើភ្នែកសម្លឹងផ្ទៃមុខនរលក្ខណ៍ដូចគ្រាមុន ។ គេមិនឃ្លាន គេមិនស្រេក គេមិនអស់កម្លាំង គេត្រូវការឱ្យស្រស់ស្រីឆាប់ដឹងខ្លួន ទើបគេបាត់បារម្ភ ។

រាត្រីមកដល់ ក្នុងបន្ទប់ដែលនរលក្ខណ៍គេងសម្រាកព្យាបាល នៅសល់តែអ្នកស្រីមាណាវីនិងពិសិដ្ឋដែលអង្គុយកំដរនរលក្ខណ៍ ព្រោះលោកកិត្យា លោកយាយរំដួលនិងលោកស្រីរំចង់ ត្រូវវិលទៅចាត់ចែងពិធីបុណ្យសពរបស់លោកជំនោរនិងអ្នកស្រីសូតា ។ អ្នកស្រីមាណាវីក៏ជាដូចពិសិដ្ឋ សុទ្ធសឹងតែមានទឹកមុខព្រួយបារម្ភពីអាការៈរបស់នរលក្ខណ៍ ព្រោះនាងមិនទាន់បានដឹងខ្លួននៅឡើយ ។ ព្រះនាងទេវតាផុសពីក្រោយខ្នងពិសិដ្ឋ ព្រះនាងលើកព្រះហស្តបញ្ចេញរស្មីជះមកលើអ្នកស្រីមាណាវី អ្នកស្រីស្រាប់តែស្ងាប ហើយទន់ត្របកភ្នែក ក្រាបក្បាលសម្រាន្តលក់លើគ្រែបាត់ទៅ ។ ព្រះនាងទេវតាទ្រង់ព្រះសម្រួលតិចៗ ចោលព្រះនេត្រាសម្លឹងមើល

មកពិសិដ្ឋដែលអង្គុយភាំង គន់មើលតែមុខនរលក្ខណ៍ ។ ពិសិដ្ឋហាក់មិនបានដឹងថា ព្រះនាងទេវតាផុសនៅក្បែរគេទេ ព្រោះព្រះនាងមិនមានព្រះបំណងឱ្យពិសិដ្ឋបាន ដឹងថា ព្រះនាងនឹងចេញមករកគេ នាពេលនេះ ។ ភ្លាមនោះ ព្រះកាយព្រះនាង ទេវតាក៏រលាយបាត់ទៅ បន្សល់ទុកពិសិដ្ឋតែឯងឯកា អង្គុយសម្លឹងភក្ត្រាស្រស់ស្រី។ កំពោះលាន់វាចាតិចៗតែឯង :

-អ្នកនាងលក្ខណ៍ ខ្ញុំស្រឡាញ់អ្នកនាង។ ខ្ញុំបារម្ភពីអ្នកនាងណាស់ អ្នកនាង ឆាប់ដឹងខ្លួនមក ។

នេត្រានរលក្ខណ៍បើកសន្សឹមៗ ពិសិដ្ឋក្រឡេកឃើញ គេញញឹមស្រដី :

-អ្នកនាងនរលក្ខណ៍ដឹងខ្លួនហើយ ខ្ញុំត្រេកអរណាស់ ។

-ខ្ញុំកើតអី ខ្ញុំនៅទីណា ?

-អ្នកនាងចាំស្ដាប់ណ៎ា ខ្ញុំនឹងជម្រាបជូន ។

ពិសិដ្ឋរៀបរាប់នូវរឿងរ៉ាវទាំងឡាយ តាំងពីទំនាក់ទំនងរវាងលោកឧកញ៉ា សិទ្ធានិងលោកយាយមាស ពីទំនាក់ទំនងលោកយាយមាសជាមួយគ្រួសាររបស់គេ ព្រមទាំងគំនុំសងសឹកដែលកប់ក្នុងព្រលឹងខ្មោចយាយមាស រហូតដល់ខ្មោចយាយ មាសបានសម្លាប់មនុស្សនៅក្នុងផ្ទះសិទ្ធា ជាបន្តបន្ទាប់ ។ ចុងក្រោយបំផុត គេក៏ មិនភ្លេចរៀបរាប់អំពីរឿងរ៉ាវ ដែលកើតឡើងដោយអំណាចសិល្ប៍យាយមាស ដែល ស្ថិតក្នុងរូបកាយនរលក្ខណ៍ ដើម្បីប្រាប់ទៅស្រស់ស្រីបណ្ដូលចិត្ត ដោយគ្មានលាក់ លៀមនូវអ្វីបន្តិចឡើយ ។ ពីតាតូចតន់ស្ដាប់ការបរិយាយរបស់អ្នកប្រុស នាងដក ដង្ហើមធំជាមួយការរិះគិត ។ កំលោះម្ចាស់ធនាគាររំចង់បន្លឺទាំងភក្ត្រស្រងូតស្រងាត់ :

-រឿងរ៉ាវបែបហ្នឹងណាអ្នកនាង ហើយពេលនេះ ម៉ាក់ខ្ញុំ លោកយាយធំ លោកប៉ាអ្នកនាង កំពុងតែចាត់ចែងបុណ្យសពលោកពូធំនៅរនិងអ្នកមីងសូគា ទើបនៅទីនេះមានតែខ្ញុំ និងម៉ាក់នាងមកកំដរនាង ហើយម៉ាក់នាងប្រហែលជាអស់កម្លាំង ដោយសារលោកយាយតូចធ្វើបាបគាត់ ទើបគាត់សម្រាន្តលក់មុននេះបន្តិចហ្នឹងណា ។

-សេចក្ដីស្រឡាញ់ ! ការចង់បាន ! វាមានអនុភាពគួរខ្លាចមែន សូម្បីតែលោកយាយមាសបានរលត់ជីវិតពីលើលោកនេះទៅហើយ តែចិត្តគាត់ដែលដក់ជាប់ដោយការស្រឡាញ់វិមានសិទ្ធា រហូតក្លាយជាគំនុំព្យាបាទអ្នកដទៃដល់ម្លឹង ។ ពីថ្ងៃនេះ ទោះជាអ្នកណាចង់ហៅវិមានសិទ្ធាក៏បាន ឬ ហៅវិមានមាសក៏បាន គឺតាមចិត្តគេចុះ ។

-អ្នកនាងចិត្តល្អដូចលោកឧកញ៉ាអ៊ីចឹង ហើយពេលនេះខ្ញុំសុំទោស ដែលធ្វើឱ្យអ្នកនាងមកឈឺខ្លួន យ៉ាងនេះ ។

-លោកមិនគួរពោលពាក្យសុំទោសមកកាន់ខ្ញុំទេ ព្រោះលោកមានគុណលើគ្រួសារខ្ញុំ លោកបានជួយជីវិតពួកយើងទាំងបួននាក់ គឺខ្ញុំ ទារិកា ម៉ាក់ខ្ញុំនិងលោកប៉ាខ្ញុំ ដូច្នេះមានតែខ្ញុំត្រូវអរគុណដល់លោកវិញផង ។

ពិសិដ្ឋលួចមើលមុខនាង ជាមួយអាការៈស្ងាបស្ងង់ចិត្តស្រី គេស្រដីទាំងមុខញញឹម :

-ហើយដែលខ្ញុំនេះបានក្លែងខ្លួនជានាយក្លាមមកបោកប្រាស់អ្នកនាងនោះ តើអ្នកនាងខឹងនឹងខ្ញុំដែរទេ ?

ពាក្យ "នាយក្តាម "វាហាក់ដូចជាមកគាស់កកាយស្រមោលអនុស្សាវរីយ៍ដ៏ស្និទ្ធស្នាល ដែលអ្នកបើកបររថយន្តឈ្មោះក្តាមនេះ បានប៉ះពាល់កៀកកិតយ៉ាងស្និទ្ធស្នាលជាមួយនួនល្អង។ មែនហើយ ! នាយក្តាមធ្លាប់ឱបស្រីយ៉ាងណែន ធ្លាប់បានបីត្រកងកាយនាងយ៉ាងស្និទ្ធ ធ្លាប់បានយកដៃទាំងពីររបស់គេមករឹតច្របាច់កំភួនជើងនិមលគ្រានាងរមួលក្រពើនិងជាពិសេសគឺគេជាអ្នកបានជួយជីវិតនាង ឱ្យផុតពីគ្រោះថ្នាក់ដល់ទៅពីរលើក ម្តងគឺគេបានជួយនាងឱ្យផុតពីឡានបុកនាយប់មួយ ម្តងទៀតគឺគេជួយនាងឱ្យផុតពីលង់ទឹក ...រំលឹកដល់ភាពស្និទ្ធស្នាលទាំងនេះស្រីខ្មាស នាងមិនហ៊ានមើលមុខអ្នកថ្លៃ រួចក៏ល្បាណបន្ទីដោយប្រយោគស្រាលៗ :

-ខ្ញុំមិនដឹងទេ ។

និយាយតែប៉ុន្មានពាក្យនេះ ស្រស់ស្រីបែរមុខទៅម្ខាង ក្លែងជាសម្លឹងបិទភ្នែកគេង ធ្វើជាហី។ ពិសិដ្ឋលបគន់ភក្ត្រានាង ពីចំហៀង ជាមួយមុខបុរសជិតដាមដោយស្នាមញញឹមពព្រាយ ។

ក្នុងបន្ទប់ព្យាបាលរបស់អ្នកស្រីតារាវិញ ទារិកានិងនាងសយ នៅកំដរអ្នកស្រីតារា ។ ទារិកាលុះដោយអំណាចទុក្ខសោក នាងស្រពាប់ស្រពោនក្នុងចិត្តហូរទឹកនេត្រាមិនឈប់ឈរ។ នាងសយជាស្រីបម្រើស្រដីទៅកាន់ចៅហ្វាយក្រមុំទាំងមុខក្រៀមក្រំ :

-អ្នកនាងមិនពិសាបាយតាំងតែពីព្រឹកម្ល៉េះ នាងខ្ញុំទៅយកបាយថ្មីមកដូរជូនអ្នកនាងណា៎ ។

ទារិកាមិនបានឆ្លើយតបមកកាន់ស្រីបម្រើ នេត្រានាងនៅតែផ្តោតជាប់ទៅលើផ្ទៃមុខរបស់អ្នកម្តាយ ។នាងសយលែងស្តីអ្វីបន្តទៀតដែរ នាងដើរលបៗទៅលួច

បង្អើបទ្វារបន្ទប់ ហើយចេញទៅក្រៅបាត់ ព្រោះនាងមិនចង់រំខានអារម្មណ៍ទារិកា ។ ទារិកាសម្លឹងម្ដាយ នាងនិយាយទាំងរអាក់រអួល :

-ម៉ាក់អើយ!ម៉ាក់រស់ដូចគ្មានវិញ្ញាណជាមនុស្ស ...កូនអាណិតម៉ាក់ ហ៊ឹក។

ទ្វារបន្ទប់លាន់ស្នូរ កល្យាណហាក់មិនចាប់អារម្មណ៍ពីស្នូរនោះឡើយ នាងនៅតែអង្គុយច្រងុក សម្លឹងតែមុខម្ដាយ ។ កំលោះសេរីបើកទ្វារ ដើរចូលមករកស្រស់ស្រី គេក្រឡេកឃើញភក្ត្រានួនល្អង ជោកជាំដោយជលនេត្រ គេរន្ធត់ចិត្តពន់ប្រមាណ ។ បុរសដើរសសៀរមករកស្រី គេស្រដីតិចៗ :

-ទារិកា ! សុំនាងយំទៅ យំតាមដែលនាងចង់យំ ដើម្បីឱ្យបានធូរទ្រូង ។

ទារិកាងាកយឺតៗមកសេរី ទាំងទឹកភ្នែករហាម :

-សេរីមើលម៉ាក់ខ្ញុំចុះ ម៉ាក់រស់ដូចមិនមែនរស់ ម៉ាក់វេទនាយ៉ាងណា ?

-ទារិកា!នាងកុំទាន់អស់សង្ឃឹមពេក អ្វីៗវាអាចនឹងប្រែមកជាល្អវិញណា៎។

-ខ្ញុំមិនមានសង្ឃឹមទេសេរី ហ៊ឹកហ៊ឹក ងាកទៅលោកប៉ា ហ៊ឹក ហ៊ឹក លោកទៅចោលខ្ញុំហើយ ខ្ញុំលែងជួបលោកប៉ាទៀតហើយ ដូចដែលខ្ញុំលែងបានជួបបងវេហា ជារហូតមកដែរ ... តែប៉ុន្មានថ្ងៃនោះ ជីវិតរបស់ខ្ញុំប្រែប្រួលយ៉ាងនេះ ហ៊ឹក ហ៊ឹក ហេតុអី ?ហេតុអី ?

សេរីទាញនាងមកឱប គេស្រដីទាំងមុខស្លុតក្នុងចិត្ត ដោយក្ដីអាសូរស្រី :

-ទប់ស្មារតីណា៎ទារិកា...ទប់ស្មារតីឱ្យបាន នាងមិនមែនអស់អ្វីទាំងអស់ទេ ...នាងនៅមានខ្ញុំ ... នាងមានខ្ញុំ ... ខ្ញុំនឹងជាអ្នកថែរក្សានាង ។

ទារិកាយំង៉ក់ៗក្នុងទ្រូងសេរី មិនស្ដីអ្វីជាបន្តទេ ... កំលោះនគរបាលសោកសៅ តែលែងមានពាក្យអ្វីមកលួងលោមស្រីដែរ ... វាដូចដែលនាងនិយាយមិនខុស

ជីវិតនាងវាដូចត់ពេក តែមួយរយៈពេលដ៏ខ្លីសោះ លោកិយនេះស្រាប់តែក្លាយជាកំណាចសាហាវ ធ្វើបាបនាងអ៊ីម្ល៉េះ ។តែសម្រាប់គេ គេនឹងផ្ដល់នូវការកក់ក្ដៅដល់ស្រី ... គេនឹងថែរក្សានាង ... គេនឹងធ្វើឱ្យនាងលែងហេងហាង ... តែពេលនេះ គេទុកឱ្យនាងយំសិនចុះ ...យំឱ្យអស់ចិត្ត ដើម្បីបន្ធូរនូវក្ដីឈឺចាប់ ពីក្នុងទ្រូងស្រី ។

................................................................................................

................................................................................................

ប្របមាត់ស្ទឹងអនុស្សាវរីយ៍ ព្រះអាទិត្យរះភ្លឺចិញ្ចែចបាចសាចរស្មីចាំងព្រិច១មកលើរលក រំលេចជាពណ៌ប្រាក់ភ្លឺផ្លេកកម្រើកតិច១តាមចលនាដែលវាតាបក់ប៉ះ...វាយោបក់រំភើយមកបបោសអង្អែលអារម្មណ៍បុរសស្ត្រីមួយគូ កំពុងអង្គុយសារសងធ្លា នាមាត់ស្ទឹង ។ អ្នកទាំងពីរ គឺជាពិសិដ្ឋនិងនរលក្ខណ៍ គេអង្គុយជិតគ្នា នេត្រាតយគន់ទៅចលនាទឹករលកនៅក្នុងស្ទឹងដែលចាំងជះព្រិច១ ដោយរស្មីព្រះទិនករ ។ ប្រយោគស្រាល១ភ្ជាប់ស្នាមញញឹមលើបបូរមាត់ស៊ីជម្ពូររបស់ស្រីស្រស់បន្លឺឡើង :

-ចម្លែកណាស់ លើលោកនេះមានមនុស្សដែលមានវិញ្ញាណទី៦ ដូចជាបងមែនតើ ។

-បងមិនដឹងប្រាប់អូនថាម៉េចទេ តែបងគឺយ៉ាងនោះមែន ជាញឹកញាប់បងតែងយល់សប្ដិឃើញអូន បងតែងឃើញលោកយាយតូច បងតែងឃើញទេវតា ហើយបងសុំហាមអូនណា ក្នុងរយៈពេលដែលបងទៅបួស ដើម្បីឧទិសមគ្គផលជូនលោកយាយតូចមួយរយៈខាងមុខនេះ អូនមិនត្រូវញញឹមដាក់មនុស្សប្រុសណាទេ ព្រោះបងនឹងមើលឃើញពីអ្វីដែលអូនបានធ្វើនោះ ជាមិនខាន ។

នរលក្ខណ៍សម្លក់ពិសិដ្ឋ ស្រដីទាំងក្អឹកក្អក់អមស្នាមញញឹមមានមន្តស្នេហ៍ :

-បងឯងអីក៏កាចម្លេះ អូនមិនធ្វើតាមទេ បងមើលឃើញ ក៏ឃើញទៅ ។

-មាត់អូននិយាយថាទេ តែខ្សែភ្នែកអូនប្រាប់បងថា អូនព្រមធ្វើតាមសម្ដីបងទេដឹង ?

ពិតជាដូចសម្ដីពិសិដ្ឋនិយាយមិនខុស មាត់នាងប្រកែក តែចិត្តនាងមិនហ៊ានធ្វើអ្វីដែលជាការរំលងចិត្តប្រុសថ្លៃឡើយ ។ នាងស្រឡាញ់ពិសិដ្ឋ ពិសិដ្ឋស្រឡាញ់នាង ហើយគេមិនត្រូវជំទាស់ចិត្តគ្នាឡើយ តែកាលបើត្រូវពិសិដ្ឋទាយចិត្តនាងត្រូវពាលពៅសែនខ្មាស នាងលូកដៃមកក្ដិចភ្លៅពិសិដ្ឋ ទាំងភ្នែកសម្លក់គេ យ៉ាងឃ្នាន់ខ្នាញ់ ។ សម្រស់ស្រីនាពេលសម្លក់ ឆក់ស្រូបបេះដូងបុរសឱ្យលង់ក្នុងក្ដីស្រឡាញ់យ៉ាងជ្រាលជ្រៅ គេគន់ភក្រ្តនួនល្អង គេញញឹមស្រស់ គេដឹងថា ស្រីស្រឡាញ់គេដូចតែគេស្រឡាញ់នាងដែរ លុះត្រូវនាងក្ដិចដោយឃ្នាន់ខ្នាញ់យ៉ាងនេះ គេធ្វើជាស្រែក ជាការលលេង :

-អូយ ! បងខ្លាចហើយអូនសំឡាញ់ ។

ម៉ានីននិងដារ៉ុថដើរមកដល់ពីក្រោយគេទាំងពីរ ដៃដារ៉ុថកាន់ក្រដាសប្លង់គម្រោងសាងសង់ផ្ទះសំណាក់ទាំងដប់ ។ ម៉ានីនចោលភ្នែកសម្លឹងទៅកាន់បងប្រុសជីដូនមួយ ព្រោះនាងឃើញពិសិដ្ឋកំពុងរមួលខ្លួនដោយត្រូវនរលក្ខណ៍ក្ដិចភ្លៅ ទើបស្រីម៉ានីនញញឹម និយាយចំអន់ពិសិដ្ឋ :

-បងសិដ្ឋស្រមោចខាំអ្ហេះ ទើបស្រែកខ្លាំងម្លេះ ?

ពិសិដ្ឋងាកមកមើលមើលដារ៉ុថ ទាំងទរះញាក់ភ្នែកដាក់ដារ៉ុថ :

-ដារ៉ុថប្រយ័ត្នណា៎ ក្រចកដៃគូដណ្ដឹងឯង បែបស្រួចមិនចាញ់ក្រចកអូនលក្ខណ៍ទេ ។

-តែអូនទីនរបស់ខ្ញុំ មិនធ្វើបាបខ្ញុំទេ ទាំងស្លូតណាស់ណា ។

ម៉ាទីនសម្លក់ជារុំផ បន្លឺ :

-អូនស្លូតតែត្រូវទេ បើបងបានក្បត់ចិត្តខ្ញុំនោះ ខ្ញុំក្លាយជាខ្លាញីភ្លាម មែនទេបងលក្ខណ៍ ?

នរលក្ខណ៍មិនទាន់ឆ្លើយតបមកកាន់វាចាម៉ាទីនផង ស្រាប់តែកំលោះសេរី និងក្រមុំទារិកាបណ្ដើរគ្នាត្រសងទាំងគូ មករកពួកគេទាំងបួន ទាំងដៃទារិកាកាន់ផក់សម្រាប់គូ ហើយសំឡេងសេរីស្រែកពីចម្ងាយ លាន់មកផង :

-មានអីសើចហ្នឹង ចែកខ្ញុំសើចផង ។

ពិសិដ្ឋស្រែកតបទៅកាន់សេរី មុខញញឹមស្រស់ :

-ពួកគ្នាកំពុងត្រូវខ្លាញីប្រុងត្របាក់ណាំសេរី ។

សេរីនិងទារិកាដើរមកកាន់តែជិតគេទាំងបួនទាក់ រួចសេរីសើច បន្លឺតបមកពិសិដ្ឋ :

-ខ្លាញីត្របាក់ មកពីខ្លាឈ្មោលក្បាលខិលទេដឹង ?

ប្រយោគរបស់សេរី បង្កសំណើចដល់ពួកគេទាំងអស់គ្នា ជាសំណើចនៃការយល់ចិត្តរបស់សង្សារទាំងបីគូ ... ជាសំណើចដ៏ផ្អែមល្ហែមអប់ដោយលំអងមន្តស្នេហ៍ ... សំណើចសុភមង្គលគ្មានថ្ងៃរុះរោយ ...ព្រះពាយក៏ផាយផាត់រសាត់មកត្រសៀកអប់ដោយក្លិនផ្កាព្រៃសាយភាយប្រហើរ លាយឡំដោយសំឡេងបក្សាបក្សីងនាយជាយព្រៃ ស្រែកអបអរឱ្យពរជ័យដល់គូស្នេហ៍ដែលស្មោះភក្ដី ។

**ចប់**

ថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០០៥